# កម្មដ្ឋាននិទ្ទេស

វត្តនិគ្រោធវ័ន

រៀបរៀងដោយ

ភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

ពុទ្ធសករាជ ២៥៥៧

សម្រាប់ជាធម្មទាន

# កម្មដ្ឋាននិទ្ទេស

វត្តនិគ្រោធវ័ន

រៀបរៀងដោយ

ភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

ពុទ្ធសករាជ ២៥៤៧

សម្រាប់ជាធម្មទាន

-សៀវភៅ **កម្មដ្ឋាននិទ្ទេស**

-គម្ពីរជាឧបករណ៍ក្នុងការរៀបរៀង នេះគឺ

ព្រះត្រៃបិដក និង អដ្ឋកថា សមន្តប្បាសាទិកា

វិសុទ្ធមគ្គ សមាធិនិទ្ទេស អដ្ឋកថា សារត្ថបកាសិនី

អដ្ឋកថា បរមត្ថទីបនី សារត្ថទីបនីដីកា ។

- រៀបរៀងដោយអាចារ្យ **សុវណ្ណជោតោ ឌួខ-សុវណ្ណ**

-អ្នកជួយពិនិត្យ

**ភិក្ខុ ភុច ប៉ូណា**

**ភិក្ខុ ធម្មភាមោ មិត្ត សាន**

**ភិក្ខុ វិនយធរោ តុន ប៊ុនសាយ**

-អ្នកជួយវាយអត្ថបទ

**ភិក្ខុ សុវណ្ណជោតោ ភិក្ខុ គង់-សុមិត្ត**

**សាមណេរ អ៊ុំ-ពលភា**

-ទីកន្លែងធ្វើ វត្តនិគ្រោធវ័ន "គល់ទទឹង"

-កាលបរិច្ឆេទ ពុទ្ធសករាជ ២៥៥៧

# អារម្ភកថា

សៀវភៅ **កម្មដ្ឋាននិទ្ទេស** នេះ កើតឡើង ដោយហេតុខាងក្រោមនេះ ៖

ក្នុងពុទ្ធសករាជ ២៥៥២ ខ្ញុំបានបង្រៀននូវធម៌និងវិន័យខ្លះៗ ដល់ពុទ្ធបរិស័ទ នៅក្នុងវត្តនិគ្រោធវ័ន ជាវត្តប្រតិបត្តិជាមួយព្រះសង្ឃ ឬនិងជាធម៌ប្រតិបត្តិក្នុងកម្មដ្ឋាន បានជាធម៌អប់រំចិត្ត ។

ដោយមានបំណងឱ្យពុទ្ធបរិស័ទ បានសិក្សានិងប្រព្រឹត្តបដិបត្តិក្នុងកម្មដ្ឋាខ្លះៗ ដែលជាការជម្រះចិត្តរបស់ខ្លួនឱ្យបានផូរផង់ មានធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ធ្វើខ្លួនឱ្យបានជាអ្នកមានប្រក្រតីនៅដោយធម៌ ដូចដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ចំពោះភិក្ខុ ជាអ្នកនៅដោយធម៌ថា "ភិក្ខុមិនបានញ៉ាំងថ្ងៃឱ្យកន្លងទៅ ដោយការរៀននូវធម៌ (ជាដើម) នោះ មិនលះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ ប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ភិក្ខុជាអ្នកនៅដោយធម៌យ៉ាងនេះឯង" ដែលប្រព្រឹត្តទៅដើម្បីបាននូវសេចក្តីសុខ ផុតពីកិលេសមានរាគៈជាដើម ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ៖

**"ទុន្និគ្គហស្ស លហុនោ យត្ថកាមនិបាតិនោ**
**ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។**

ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នាក្នុងអារម្មណ៍ណាមួយ

រមែងជាគុណញុាំងប្រយោជន៍ឱ្យសម្រេច (ព្រោះថា) ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្ដីសុខ" ។

**"សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**
**ចិត្តំ រក្ខេ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។**

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញបានដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នាក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្ដីសុខ" ។

ដោយមហាកុសលចេតនាណា ដែលខ្ញុំមានសេចក្ដីជ្រះថ្លាក្នុង ព្រះ-សទ្ធម្មរចនានេះ សូមព្រះសទ្ធម្មតម្កល់នៅអស់កាលយូរ សូមបុណ្យកុសលបានជាបច្ច័យនៃបញ្ញាត្រាស់ដឹងនូវសច្ចធម៌ ដល់ព្រមដោយបដិសម្ភិទាក្នុងកាលជាអនាគត ។

ម្យ៉ាងទៀត បុណ្យកុសលនេះ ចូរសម្រេចដល់ញាតិ មួយអន្លើដោយសព្វសត្វទាំងអស់ ចូរជាអ្នកបានសោយរសនៃព្រះសទ្ធម្ម របស់ព្រះមានព្រះភាគចុះ ។

សូមអនុមោទនា !!!

**ភិក្ខុ សុវណ្ណជោតោ ឡូខ-សុវណ្ណ**

# សន្លឹកប្រាប់មាតិកា

## កម្មដ្ឋាននិទ្ទេស

១-ការចម្រើនសមាធិ ... ... ... ... ... ... ... ... ... ... ... ... ... ... ០១

២-កុលបុត្ររៀនកម្មដ្ឋានត្រូវបំពេញសីលឱ្យបរិសុទ្ធជាមុន ...... ០២

៣-បលិពោធ ១០ យ៉ាង ... ... ... ... ... ... ... ... ... ... ... ... ... ... ០៧

៣.១-អាវាសបលិពោធ ... ... ... ... ... ... ... ... ... ... ... ... .... ០៨

៣.២-កុលបលិពោធ ... ... ... ... ... ... ... ... ... ... ... ... ... .... ១១

៣.៣-លាភបលិពោធ ... ... ... ... ... ... ... ... ... ... ... ... ... ១៦

៣.៤-គណបលិពោធ ... ... ... ... ... ... ... ... ... ... ... ... ... .... ១៧

៣.៥-កម្មបលិពោធ ... ... ... ... ... ... ... ... ... ... ... ... ... ..... ១៨

៣.៦-អទ្ធានបលិពោធ ... ... ... ... ... ... ... ... ... ... ... .... ១៩

៣.៧-ញាតិបលិពោធ ... ... ... ... ... ... ... ... ... ... ... ... ..... ១៩

៣.៨-អាពាធបលិពោធ ... ... ... ... ... ... ... ... ... ... ... ... ២១

៣.៩-គន្ថបលិពោធ ... ... ... ... ... ... ... ... ... ... ... ... ... ២១

៣.១០-ឥទ្ធិបលិពោធ ... ... ... ... ... ... ... ... ... ... ... .... ២៧

៤-កម្មដ្ឋាន ២ យ៉ាង ... ... ... ... ... ... ... ... ... ... ... ... ... ... ២៨

៥-កម្មដ្ឋាន ៤០ ... ... ... ... ... ... ... ... ... ... ... ... ... ... ..... ៣២

កសិណ ១០ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៣៣

អសុភ ១០ ... ... ... ... ... ... ... ... ... ... ... ... ... ... .... ៣៣

អនុស្សតិ ១០ ... ... ... ... ... ... ... ... ... ... ... ... ... ..... ៣៤

ព្រហ្មវិហារ ៤ ... ... ... ... ... ... ... ... ... ... ... ... ... ... .... ៣៦

អរូប ៤ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... .... ៣៦

សញ្ញា ១ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៣៦

ចតុធាតុវវដ្ឋាន ... ... ... ... ... ... ... ... ... ... ... ... ... .... ៣៧

៦-កម្មដ្ឋានដែលគួរដល់ចរិតរបស់កុលបុត្ត ... ... ... ... ... ... ... .. ៣៧

៧-គួររៀនកម្មដ្ឋានក្នុងសំណាក់ពុទ្ធឱរស ទាំងលោកអ្នកបានឈាន .. ៤៤

**៨-កម្មដ្ឋាន ៧ យ៉ាង**

៨.១ ពុទ្ធានុស្សតិ ... ... ... ... ... ... ... ... ... ... ... ... ... .... ៥០

៨.២ មេត្តាព្រហ្មវិហារ ... ... ... ... ... ... ... ... ... ... ... ..... ៥៥

៨.៣ មរណានុស្សតិ ... ... ... ... ... ... ... ... ... ... ... ... .... ៦០

៨.៤ អសុភកម្មដ្ឋាន ១០ ... ... ... ... ... ... ... ... ... ... ... .. ៦៦

១ ឧទ្ធុមាតកអសុភ ... ... ... ... ... ... ... ... ... ... ... .... ៦៦

២ វិនីលកអសុភ ... ... ... ... ... ... ... ... ... ... ... ... .... ៧២

៣ វិបុព្វកអសុភ ... ... ... ... ... ... ... ... ... ... ... ... .... ៧៣

៤ វិច្ឆិទ្ទកអសុភ ... ... ... ... ... ... ... ... ... ... ... ... ..... ៧៤

៥ វិក្ខាយិតកអសុភ ... ... ... ... ... ... ... ... ... ... ... ..... ៧៤

៦ វិក្ខិត្តកអសុភ ... ... ... ... ... ... ... ... ... ... ... ... ..... ៧៥

៧ ហតវិក្ខិត្តកអសុភ ... ... ... ... ... ... ... ... ... ... ... ៧៥

៨ លោហិតកអសុភ ... ... ... ... ... ... ... ... ... ... ... .... ៧៦

៩ បុឡុវកអសុភ ... ... ... ... ... ... ... ... ... ... ... ... .... ៧៦

១០ អដ្ឋិកអសុភ ... ... ... ... ... ... ... ... ... ... ... ... .... ៧៧

៨.៥ កាយគតាសតិ ... ... ... ... ... ... ... ... ... ... ... ... ... ... .... ៧៩
៨.៦ អានាបានស្សតិ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៨៧
អានាបានស្សតិក្នុងវិនយបិដក ... ... ... ... ... ... ... ... ... ៩៥
អដ្ឋកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៩៩
អធិប្បាយវិធីអប់រំសតិ ៣២ យ៉ាង ... ... ... ... ... ... ... .. ១១០
មតិខ្យល់ដកដង្ហើម តាមអដ្ឋកថាវិន័យនិងព្រះសូត្រ ... ..... ១១១
ចម្រើនអានាបានស្សតិកម្មដ្ឋាន រមែងបានបាមោជ្ជៈជាដើម .. ១១៣
ភិក្ខុកំណត់កម្មដ្ឋានហើយ កាយសង្ខារទើបស្ងប់ ... ... ... .... ១១៨
កាយសង្ខារល្អិតទៅតាមលំដាប់ ... ... ... ... ... ... ... ... .. ១២១
វិធីមនសិការអានាបានស្សតិកម្មដ្ឋាន ៨ យ៉ាង ... ... ... ..... ២២៧
អធិប្បាយវិធីរាប់ខ្យល់ដកដង្ហើមចេញចូល ... ... ... ... .... ២២៨
អធិប្បាយខាងដើមកណ្តាលនិងទីបំផុតខ្យល់ដង្ហើមចេញចូល ១៣១
សេចក្តីឧបមាដូចមនុស្សពិការយោលទោង ... ... ... ... ..... ១៣៣
សេចក្តីឧបមាដូចអ្នករក្សាទ្វារ ... ... ... ... ... ... ... ... ..... ១៣៤
ការកំណត់ខ្យល់ដកដង្ហើម ប្រៀបដូចរណារ ... ... ... ... .... ១៣៤
ឧបាយជាហេតុនាំអានាបានស្សតិកម្មដ្ឋានមក ... ... ... ... ... ១៣៩
ធម៌ ៣ យ៉ាងមានបរិបូរណ៏កម្មដ្ឋានទើបដល់អប្បនា ... ... .. ១៤៤
ចិត្តរមែងតាំងមាំជាសមាធិដោយអង្គ ២ ... ... ... ... .... ១៤៦
ឧបាយរក្សាអានាបានស្សតិកម្មដ្ឋាន ... ... ... ... ... ... ... ... ១៤៧
៨.៧ ឧបសមានុស្សតិ ... ... ... ... ... ... ... ... ... ... ... ... ..... ១៦១
៩-សេនាសនៈទោស ១៨ យ៉ាង ... ... ... ... ... ... ... ... ... ..... ១៦២

១០-វិហារដែលសមគួរ ... ... ... ... ... ... ... ... ... ... ... ... ... ១៦៤

## ១១-សិក្សាព្រះសូត្រ

១-មរណស្សតិសូត្រ ទី១ ... ... ... ... ... ... ... ... ... ... ... ១៦៦

២-ការចម្រើនមរណស្សតិសូត្រ ទី២ ... ... ... ... ... ... .... ១៧២

៣-ករណីយមេត្តសូត្រ ... ... ... ... ... ... ... ... ... ... ...... ១៧៧

៤-បឋមធម្មវិហារិកសូត្រ ... ... ... ... ... ... ... ... ..... ២២៤

៥-ទុតិយធម្មវិហារិកសូត្រ ... ... ... ... ... ... ... ... .... ២២៩

៦-ឆន្ទសូត្រ ... ... ... ... ... ... ... ... ... ... ... ... ...... ២៣១

៧-អសុភសូត្រ ... ... ... ... ... ... ... ... ... ... ... ...... ២៣៩

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

*សូមនមស្ការចំពោះព្រះមានព្រះភាគ*

*អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។*

# កម្មដ្ឋាននិទ្ទេស

## ១-ការចម្រើនសមាធិ

*នៅក្នុងគម្ពីរវិសុទ្ធិមគ្គ លោកពោលដោយការចម្រើនសមាធិយ៉ាងពិស្តារ តែក្នុងទីនេះសូមពោលដោយសង្ខេបតទៅ ៖*

*ចំណែកពាក្យឆ្លើយក្នុងបញ្ហានេះថា "សមាធិនោះគប្បីចម្រើនដូចម្តេច" ? នេះ គប្បីជ្រាបដូចតទៅនេះ សមាធិណាដែលសម្បយុត្តដោយអរិយមគ្គ ដែលខ្ញុំពោលទុកមុនហើយក្នុងទុកសមាធិមានពាក្យថា "នេះសមាធិជា ២ ដោយជាលោកិយនិងលោកុត្តរៈ" ដូច្នេះជាដើម ន័យនៃការចម្រើនអរិយមគ្គ សមាធិនោះសង្គ្រោះចូលជាមួយន័យនៃការចម្រើនបញ្ញាបានដូចគ្នា ព្រោះថា កាលបញ្ញាចម្រើនហើយ មគ្គសមាធិនោះ ក៏ជាការចម្រើនដោយពិត ព្រោះហេតុនោះ យើងនឹងមិនប្រាប្ថាយកមគ្គសមាធិនោះមកពោលជាផ្នែកមួយផ្សេងទេ ពោលមគ្គសមាធិនោះនឹងគប្បីចម្រើនយ៉ាងនេះៗ ចំណែកសមាធិដែលជាលោកិយនេះណា លោកិយសមាធិនោះ*

ដែលព្រះយោគីវចរញ៉ាំងសីលទាំងឡាយឲ្យបរិសុទ្ធ តាមន័យដែលពោលហើយ តាំងនៅក្នុងសីលដែលបរិសុទ្ធល្អហើយ បណ្ដាបលិពោធ ១០ ប្រការ បលិពោធណារបស់លោកមាន កាត់បលិពោធនោះចេញហើយចូលទៅរកអ្នកឲ្យកម្មដ្ឋាន ដែលជាកល្យាណមិត្រ កាន់យកកម្មដ្ឋាន ៤០ កម្មដ្ឋានណាមួយដែលសមគួរដល់ចរិយារបស់ខ្លួន លះវិហារដែលមិនសមគួរដល់ការចម្រើនសមាធិចេញ នៅក្នុងវិហារ ដែលសមគួរកាត់សេចក្ដីកង្វល់តូចៗ (ចេញឲ្យអស់ផង) ហើយគប្បីជាអ្នកមិនធ្វើភាវនាវិធីទាំងពួងឲ្យថយចុះ ចម្រើនសាចុះឡើងនេះ ជាសេចក្ដីសង្ខេបក្នុងការចម្រើនសមាធិនោះ ។

## ២-កុលបុត្ររៀនកម្មដ្ឋានត្រូវបំពេញសីលឱ្យបរិសុទ្ធជាមុន

ក្នុងអដ្ឋកថាព្រះវិន័យ ពោលទុកថា ៖

ចតុព្វិធំ តាវ សីលំ វិសោធេតព្វំ ។ តត្ថ តិវិធា វិសោធនា : អនាបជ្ជនំ, អាបន្នវុដ្ឋានំ, កិលេសេហិ ច អប្បតិបីឡនំ ។ ឯវំ វិសុទ្ធសីលស្ស ហិ ភាវនា សម្បជ្ជតិ ។ កុលបុត្តគួរជម្រះសីល ៤ យ៉ាង ឲ្យហ្មត់ចត់ជាមុន ។ ក្នុងសីលនោះ មានវិធីជម្រះឲ្យហ្មត់ចត់ ៣ យ៉ាងគឺ មិនត្រូវអាបត្តិ ១ ចេញចាកអាបត្តិដែលត្រូវហើយ ១ មិនសៅហ្មងដោយកិលេសទាំងឡាយ ១ ។ ពិតមែន ភាវនារមែងសម្រេច

ដល់កុលបុត្រអ្នកមានសីលបរិសុទ្ធយ៉ាងនោះ ។

ក្នុងគម្ពីរសារត្ថទីបនីដីកា ពន្យល់ថា ៖

ពាក្យថា **សីល ៤ យ៉ាង** បានដល់ សីល ៤ យ៉ាង គឺ បាតិមោក្ខសំវរសីល ជាដើម ។ ពាក្យថា **មិនត្រូវអាបត្តិ** បានដល់ មិនត្រូវអាបត្តិ ៧ កងណាមួយ ។ ពាក្យថា **ចេញចាកអាបត្តិដែលត្រូវហើយ** គឺចេញចាកអាបត្តិដែលមានការធ្វើតបបាន ដែលត្រូវហើយ ដោយការធ្វើតបតាមធម៌ មានអធិប្បាយថា ចេញចាកអាបត្តិដែលជាទេសនាគាមិនី ដោយការសម្ដែងអាបត្តិ ចេញចាកអាបត្តិដែលជាវុដ្ឋានគាមិនី ដោយការធ្វើតាមវិន័យកម្ម មានបរិវាសជាដើម ។ ពិតមែន ការចេញចាកអាបត្តិដែលត្រូវហើយ រមែងមានបានសូម្បីដោយការសម្ដែង ព្រោះហេតុនោះ សូម្បីការសម្ដែងនោះ ក៏សង្គ្រោះចូលដោយការចេញចាកអាបត្តិនោះឯង ។

ពាក្យថា **មិនលាយឡំដោយកិលេសទាំងឡាយ** គឺមិនលាយឡំដោយបាបធម៌ទាំងឡាយ មានជាដើមយ៉ាងនេះថា គឺ **កោធៈ** (សេចក្ដីក្រោធ) **ឧបនាហៈ** (ចងក្រោធទុក) **មក្ខៈ** (រមើសគុណ) **បលាសៈ** (វាយឫកស្មើ) **ឥស្សា** (ច្រណែន) **មច្ឆរិយៈ** (កំណាញ់) **មាយា** (ពុតត្បុត) **សាឋេយ្យៈ** (អួតអាង) **ថម្ភៈ** (ចចេសរឹងរូស) **សារម្ភៈ** (ប្រណាំងប្រជែង) **មានៈ** (ប្រកាន់ខ្លួន) **អតិមានៈ** (មើលងាយគេ) **មទៈ** (ស្រវឹង) **បមាទៈ** (សេចក្ដីប្រមាទ), មានអធិប្បាយថា មិនញ៉ាំងបាបធម៌ទាំងនោះ

*ឲ្យកើតឡើង ។*

*<u>ក្នុងអដ្ឋកថាវិន័យ</u> ពោលទៀតថា ៖*

យម្បិទំ ចេតិយង្គណវត្តំ ពោធិយង្គណវត្តំ ឧបជ្ឈាយវត្តំ អាចរិយវត្តំ ជន្តាឃរវត្តំ ឧបោសថាគារវត្តំ ទ្វេអសីតិ ខន្ធកវត្តានិ ចុទ្ទសវិធំ មហាវត្តន្តិ ឥមេសំ វសេន អាភិសមាចារិកសីលំ វុច្ចតិ, តម្បិ សាធុកំ បរិបូរេតព្វំ។ *កុលបុត្រគួរបំពេញសូម្បីសីលដែលលោកហៅថា អភិសមាចារិកសីល ឲ្យបរិបូរណ៍ល្អជាមុន ដោយអំណាចវត្តទាំងនេះគឺ វត្តទីលានព្រះចេតិយ វត្តទីលានដើមពោធិព្រឹក្ស ឧបជ្ឈាយវត្ត អាចរិយវត្ត វត្តក្នុងរោងភ្លើង វត្តក្នុងរោងឧបោសថ ខន្ធកវត្ត ៨២ មហាវត្ត ១៤ ។*

យោ ហិ "អហំ សីលំ រក្ខាមិ, កឹ អាភិសមាចារិកេន កម្ម"ន្តិ វទេយ្យ, តស្ស សីលំ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ អាភិសមាចារិក-វត្តេ បន បរិបូរេ សីលំ បរិបូរតិ, សីលេ បរិបូរេ សមាធិ គព្ភំ គណ្ហាតិ ។ *ពិតមែន កុលបុត្រណា គប្បីពោលថា "យើងរក្សាសីល, កម្មដោយអាភិសមាចារិកវត្ត នឹងមានប្រយោជន៍អ្វី ? " សីលរបស់កុលបុត្រនោះ ដែលនឹងបរិបូរណ៍បាននោះ មិនមែនជាឋានៈដែលនឹងមានបាន ។ តែកាល*

អាភិសមាចារិកវត្តបរិបូរណ៍ សីលក៏បរិបូរណ៍ ។ កាលសីលបរិបូរណ៍ សមាធិរមែងកាន់យកគក៌ (តាំងស៊ប់) ។

វុត្តញ្ហេតំ ភគវតា : "សោ វត, ភិក្ខវេ, ភិក្ខុ អាភិសមាចារិកំ ធម្មំ អបរិបូរេត្វា "សីលានិ បរិបូរេស្សតី"តិ នេតំ ឋានំ វិជ្ជតី"តិ វិត្ថារេតព្វំ ។

សមពិត ដូចព្រះតម្រាស់ដែលព្រះមានព្រះភាគ ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអ្នកមិនញ៉ាំងធម៌ គឺ អាភិសមាចារិកៈឲ្យបរិបូរណ៍ ឈ្មោះថា ញ៉ាំងសីលទាំងឡាយ ឲ្យបរិបូរណ៍បាន ហេតុនុ៎ះ រមែងមិនមានទេ" (បើមិនបានបំពេញអាភិសមាចារិកធម៌ហើយ នឹងបំពេញសេក្ខធម៌បាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបំពេញសេក្ខធម៌ហើយ នឹងបំពេញសីលបាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបំពេញសីលហើយ នឹងបំពេញសម្មាទិដ្ឋិបាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបំពេញសម្មាទិដ្ឋិហើយ នឹងបំពេញសម្មាសមាធិបាន ហេតុនុ៎ះរមែងមិនមានទេ) សូត្រនេះកុលបុត្រគប្បីឲ្យពិស្តារ ។

តស្មា តេន យម្បិទំ ចេតិយង្គណវត្តាទិ អាភិសមាចារិកសីលំ វុច្ចតិ, តម្បិ សាធុកំ បរិបូរេតព្វំ ។

ព្រោះហេតុដូច្នោះ កុលបុត្រនេះ គួរបំពេញសូម្បីវត្ត មានចេតិយង្គណវត្តជាដើម ដែលលោកហៅថា **អាភិសមាចារិសីល**

ឲ្យបរិបូរណ៍ដោយល្អជាមុន ។

ក្នុងគម្ពីរសារត្ថទីបនីដីកា ពន្យល់ថា ៖

ក្នុងពាក្យថា **អាភិសមាចារិកសីល** នេះ មានសេចក្ដីវិនិច្ឆ័យ ដូច្នេះ : ពាក្យថា **អភិសមាចារ** ប្រែថា ការប្រព្រឹត្តិដោយអើពើខ្ពស់បំផុត, អភិសមាចារនោះឯង ជាអាភិសមាចារិក: ។ ម្យ៉ាងទៀត សីលដែលទ្រង់បញ្ញត្តប្រារព្ធអភិសមាចារ ឈ្មោះថា អាភិ-សមាចារិក:, សីល គឺអភិសមាចារិក:នោះ ឈ្មោះថា អាភិ-សមាចារិកសីល ។ ពាក្យថា **អាភិសមាចារិកសីល** នេះ ជាឈ្មោះរបស់សីលដែលរាប់បញ្ចូលនៅក្នុងខន្ធកវត្ត ។ ក្នុងពាក្យថា យើងនឹងរក្សាសីល កម្មដោយអាភិសមាចារិកវត្ត នឹងមានប្រយោជន៍អ្វីជាដើម ។ ពាក្យថា **សីល** គប្បីកាន់យកសីលដែលរាប់បញ្ចូលនៅក្នុងឧភតោវិភង្គប៉ុណ្ណោះ ព្រោះសីលដែលរាប់បញ្ចូលនៅក្នុងខន្ធកវត្ត លោកកាន់យកដោយសព្ទថា **អាភិសមាចារិកសីល** ។ បទថា បរិបូរេ សេចក្ដីស្មើនឹង បរិបុណ្ណោ ប្រែថា បរិបូរណ៍ហើយ ឬស្មើនឹង បរិបូរិតេ ប្រែថា ឲ្យបរិបូរណ៍ហើយ ។

ក្នុងអដ្ឋកថាវិន័យ ពោលទៀតថា ៖

តតោ "អាវាសោ ច កុលំ លាភោ
គណោ កម្មញ្ច បញ្ចមំ
អទ្ធានំ ញាតិ អាពាធោ

កន្ថា ឥទ្ធីតិ តេ ទសា"តិ ។

ឯវំ វុត្តេសុ ទសសុ បលិពោធេសុ យោ បលិពោធោ អត្ថិ, សោ ឧបច្ឆិន្ទិតព្វោ ។

*ខាងមុខពីការជម្រះសីលឲ្យហ្មត់ចត់នោះ ក៏គួរកាត់បលិពោធ (សេចក្តីកង្វល់) យ៉ាងណាមួយដែលមានក្នុងបណ្តាបលិពោធ ១០ យ៉ាង ដែលអាចារ្យទាំងឡាយពោលទុកយ៉ាងនេះថា បលិពោធ (សេចក្តីកង្វល់) ១០ យ៉ាងនោះ គឺ* ***អាវាស*** *១* ***ត្រកូល*** *១* ***លាភ*** *(គឺបច្ច័យបួន) ១* ***គណៈ*** *(គឺពួក) ១* ***ការងារ*** *(គឺការកសាង) ជាគម្រប់ប្រាំ ១* ***អទ្ធានៈ*** *(គឺដើរផ្លូវឆ្ងាយ) ១* ***ញាតិ*** *១* ***អាពាធ*** *១* ***គន្ថៈ*** *(គឺការរៀនបរិយត្តិ) ១* ***ឥទ្ធិឫទ្ធិ*** *១ ។ កុលបុត្រដែលកាត់បលិពោធបានយ៉ាងនេះហើយ ទើបគួររៀនកម្មដ្ឋាន ។*

## ៣. អធិប្បាយបលិពោធ ១០ យ៉ាង

*ក្នុងគម្ពីរវិសុទ្ធិមគ្គ លោកពន្យល់ថា ៖*

*គ្រឿងកង្វល់ ១០ ប្រការនេះឯង ឈ្មោះថា បលិពោធ ក្នុងបលិពោធ ១០ នោះ អាវាសនោះឯង ហៅថា អាវាសបលិពោធ ន័យក្នុងបលិពោធក្រៅនេះ មានត្រកូលជាដើម ក៏ដូចន័យនេះ, វិនិច្ឆ័យក្នុងបលិពោធ ១០ នោះ គប្បីជ្រាបដូច្នេះ ៖*

## ៣.១ អាវាសបលិពោធ

បណ្ដាពាក្យទាំងនោះ បន្ទប់តូចសូម្បីមួយ ក៏ហៅថា **អាវាស**, បរិវេណ ១ ក៏ហៅថា **អាវាស**, សូម្បីសង្ឃារាមទាំងមូល ក៏ហៅថា អាវាស ។ អាវាសនេះនោះ មិនមែនជា បលិពោធដល់ភិក្ខុទាំងពួងទេ ។ ក៏ក្នុងសេចក្ដីនេះ ភិក្ខុណាត្រូវខ្វល់ខ្វាយក្នុងការផ្សេងៗ មានកសាងថ្មីជាដើមក្នុងអាវាសនោះក្ដី មានការសន្សំវត្ថុ (គ្រឿងបរិភោគ) ទុកច្រើនក្នុងអាវាសនោះក្ដី មានសេចក្ដីអាល័យ គឺមានចិត្តជាប់ជំពាក់ក្នុងអាវាសនោះ ដោយហេតុណាមួយក្ដី អាវាសនោះទើបជាបលិពោធដល់ភិក្ខុនោះប៉ុណ្ណោះ មិនជាបលិពោធដល់ភិក្ខុក្រៅនេះទេ ។ រឿងតទៅនេះជានិទស្សនៈ ក្នុងសេចក្ដីដែលអាវាសមិនជាបលិពោធនោះ

មាននិទានមកថា កុលបុត្ត ២ នាក់ ចេញអំពីក្រុងអនុរាធបុរៈ (ដើរទៅ) រហូតបានទៅបួសក្នុងវត្តថូបារាម ។ បព្វជិត ២ រូបនោះ មួយរូបរៀនមាតិកាបានស្ទាត់ជំនាញ ៣ មាតិកា ជាអ្នកមានវស្សាគ្រប់ ៥ បវារណាហើយ ទៅកាន់ជនបទឈ្មោះបាចីនខណ្ឌរាជី ។ មួយរូបទៀត គង់នៅក្នុងថូបារាមនោះ ។ មួយរូបដែលទៅបាចីនខណ្ឌរាជី នៅទីនោះយូរទៅបានជាព្រះថេរៈ ហើយគិតថា "ទីនេះជាទីសមគួរដល់ការស្នាក់នៅដូច្នេះ យើងនឹងប្រាប់សេចក្ដីនេះ ដល់ភិក្ខុដែលជាសម្លាញ់ផងចុះ" ហើយចេញអំពីជនបទនោះ

(ដើរតាមផ្លូវទៅ) រហូតចូលទៅកាន់ថ្ងបារាម ព្រះថេរៈអ្នករួមវស្សា ឃើញលោកកំពុងដើរចូលមកកាន់វត្ត ក៏ទៅទទួលយកបាត្រនិងចីវរ ធ្វើ(អាគន្តុកៈ)វត្ត ព្រះថេរៈអាគន្តុកៈ ចូលកាន់សេនាសនៈហើយ គិតថា "បន្តិចទៀតសម្មាញ់របស់យើងនឹងបញ្ជូនទឹកដោះថ្លា ឬទឹកអំពៅ ឬទឹកបានមកឲ្យហើយមើលទៅ ព្រោះលោកជាអ្នកនៅយូរហើយក្នុងនគរនេះ" (រង់ចាំ) រហូតដល់ពាក់កណ្តាលយប់ក៏មិនបានទទួល (នូវវត្តុដែលគិតទុក) រហូតពេលព្រឹកទើបគិតជាថ្មីថា "ពេលនេះលោកនឹងត្រូវបញ្ជូនបបរ និងម្ហូបដែលពួកឧបដ្ឋាកបញ្ជូនមកឲ្យយើងមិនខាន" សូម្បីបបរនិងម្ហូបដែលគិតទុកនោះ ក៏មិនបានឃើញ ទើបគិតតទៅទៀតថា "អើហ្ន៎ ! របស់បញ្ជូនមកមិនមាន ពួកឧបដ្ឋាកគង់នឹង (រង់ចាំ) ប្រគេនលោកពេលចូលទៅបិណ្ឌបាតមិនខាន" លុះចូលដល់ក្រុង (ដើម្បីបិណ្ឌបាត) ជាមួយព្រះថេរៈអាវាសិកនោះអំពីព្រលឹម លោកទាំងពីរដើរទៅតាមផ្លូវមួយ បានបបរមួយវែក ក៏ទៅអង្គុយហុតជាមួយគ្នាក្នុងរោងឆាន់ សូម្បីឥឡូវនេះ ភិក្ខុអាគន្តុកៈ ក៏នៅគិតទៀតថា "បបរជាប្រចាំក៏មិនមាន ក្នុងពេលឆាន់បាយថ្ងៃត្រង់នេះឯង មនុស្សទាំងឡាយគង់នឹងប្រគេនបាយយ៉ាងប្រណីតមិនខាន" សូម្បីដល់វេលាឆាន់បាយត្រង់ ក៏នៅតែមិនបាន លោកក៏ឆាន់អាហារដែលទៅ

បិណ្ឌបាតមកនោះឯង ទើបសួរឡើងថា "លោកដ៏ចម្រើន លោកចិញ្ចឹមអត្តភាពរហូតមកយ៉ាងនេះឬ" កាលព្រះថេរៈ ពោលថា "យ៉ាងនេះហើយអាវុសោ" ទើបពោលពាក្យបបួលថា "លោកម្ចាស់ដ៏ចម្រើន ជនបទបាចីនខណ្ឌរាជីជាទីសប្បាយ យើងទៅទីនោះជាមួយគ្នាចុះ" ព្រះថេរៈទទួលយល់ព្រមទៅ ក៏ចេញអំពីនគរតាមទ្វារទិសខាងត្បូង ដើរទៅតាមផ្លូវដែលទៅកាន់ភូមិស្មូនឆ្នាំងទៅតែម្តង មិនត្រឡប់មកវត្តទៀតឡើយ ភិក្ខុអាគន្តុកៈក៏និយាយប្រទាញថា "ហេតុអ្វីលោកនិមន្តផ្លូវនេះវិញ" ព្រះថេរៈឆ្លើយថា "អាវុសោលោកពោលសរសើរជនបទបាចីនខណ្ឌរាជី មិនមែនឬ ? (ទៅជនបទនោះ គឺដើរទៅតាមផ្លូវនេះឯង" ភិក្ខុអាគន្តុកៈ (ចំឡែកក្នុងចិត្តដែលលោកមិនត្រឡប់ទៅទុកដាក់របស់របរឯវត្ត) ទើបសួរថា "ក៏ក្នុងទីលំនៅដែលលោកម្ចាស់នៅយូរមកហើយ អតិរេកបរិក្ខារណាមួយមិនមានទេឬ" ព្រះថេរៈតបថា "អើអាវុសោ គ្រែតាំង ដែលយើងប្រើក៏ជារបស់សង្ឃ ខ្ញុំក៏រក្សាវាទុករៀបរយហើយ របស់អ្វីដទៃក៏មិនមាន (ទើបមិនចាំបាច់ត្រឡប់ទៅវត្តទៀតទេ) ភិក្ខុអាគន្តុកៈទូលថា "តែឈើប្រត់ និងបំពង់ប្រេង ស្បែកជើងស្ពាយបាត្ររបស់ ខ្ញុំព្រះករុណានៅទីនោះ" ព្រះថេរៈ ពោលថា "អាវុសោ លោកមកស្នាក់នៅមួយថ្ងៃ មានរបស់ទុកដាក់ដល់ទៅ

ប៉ុណ្ណោះឬ ? ភិក្ខុអាគន្តុកៈទូលថា ព្រះករុណា ក៏មានចិត្តជ្រះថ្លា ថ្វាយបង្គំព្រះថេរៈរួចពោលថា "លោកម្ចាស់ដ៏ចម្រើនសម្រាប់ភិក្ខុ ដូចលោកម្ចាស់អរញ្ញវាស (ការនៅដូចនៅក្នុងព្រៃ) រមែងទៅបាន ក្នុងទីគ្រប់កន្លែងដែលត្រូវទៅ ថូបារាមជាទីបញ្ចុះព្រះសារីរិកធាតុ ព្រះពុទ្ធជាម្ចាស់ ៤ ព្រះអង្គ បានស្តាប់ធម៌យ៉ាងសប្បាយក្នុង លោហៈប្រាសាទ បានទមស្ការព្រះចេតិយ និងបានជួបភិក្ខុជា ថេរៈធំ ប្រព្រឹត្តទៅហាក់បីដូចជាពុទ្ធកាល សូមលោកម្ចាស់ (ចូរ នៅតទៅ) ក្នុងថូបារាមនេះចុះ (កុំទៅបាចីនខណ្ឌរាជីជាមួយខ្ញុំឡើយ" ដូច្នេះហើយ ថ្ងៃស្អែកឡើងក៏កាន់បាត្រចីវរត្រឡប់ទៅតែម្នាក់ឯង ។ អាវាសរមែងមិនជាបលិពោធសម្រាប់ដូចភិក្ខុ (ជាថេរៈ នៅក្នុង ថូបារាម) នេះឯង ។

## ៣.២ កុលបលិពោធ

ត្រកូលរបស់ញាតិក្តី ត្រកូលរបស់ឧបដ្ឋាកក្តី ឈ្មោះថា ត្រកូល ។ ពិតមែន សម្រាប់ភិក្ខុរបខ្ទះអ្នកប្រឡូកប្រឡំ (ជាមួយ មនុស្សក្នុងត្រកូល ស្និទ្ធស្នាលពាក់ព័ន្ធ) ដោយន័យថា កាល គេបានដល់នូវសេចក្តីសុខក៏សុខផង ដូច្នេះជាដើម សូម្បីត្រកូល ឧបដ្ឋាក ក៏ជាបលិពោធបាន (ទឹងពោលទៅថ្វីដល់ត្រកូលញាតិ) ភិក្ខុ(ដូច)នោះ ទឹងលះបង់មនុស្សក្នុងត្រកូលទៅសូម្បីតែវិហារ

ជិតស្រុក ដើម្បីស្តាប់ធម៌ ក៏មិនបាន (ចំណែក)ភិក្ខុរូបខ្លះ សូម្បី (តែ)មាតាបិតា ក៏មិនជាបលិពោធទេ ដូចជាភិក្ខុកំលោះជាក្មួយ របស់ព្រះតិស្សត្ថេរៈ អ្នកនៅកោរណ្ឌកវិហារ ។

មានរឿងពោលមកថា ភិក្ខុកំលោះរូបនោះ បានទៅរោហណជនបទ ដើម្បីរៀនបាលី ចំណែកឧបាសិកា (ជាញោមស្រី) ត្រូវជាប្អូនរបស់ព្រះថេរៈ ក៏សួរដំណឹងរបស់លោកកូនចំពោះព្រះថេរៈរឿយៗ ថ្ងៃមួយព្រះថេរៈគិតថា ជាការវំខាន (ក៏ទៅ) នាំភិក្ខុកំលោះត្រឡប់មកវិញ ទើបធ្វើដំណើរឆ្ពោះទៅកាន់រោហណជនបទ ។ ចំណែកភិក្ខុកំលោះ ក៏គិតថា យើងនៅទីនេះយូរហើយ ឥឡូវនេះ យើងនឹងទៅសួរសុខទុក្ខឧបជ្ឈាយ៍ នឹងប្រាប់ដល់ញោមហើយ (ចាំត្រឡប់មកវិញ) ដូច្នេះ, ហើយក៏ចេញអំពីរោហណជនបទមក ភិក្ខុទាំងពីររូបមកជួបគ្នានៅត្រង់ឆ្នេរស្ទឹងមួយកន្លែង ភិក្ខុកំលោះក៏ធ្វើ (ឧបជ្ឈាយវត្ត) ដល់ព្រះថេរៈទៀបដើមឈើមួយ ព្រះថេរៈសួរថា នឹងទៅទីណា ? ក៏ប្រាប់សេចក្តីដែលគិតនោះ (ឲ្យជ្រាប) ព្រះថេរៈទើបពោលថា អ្នកធ្វើនេះល្អហើយ ឧបាសិកាក៏សួរដល់អ្នកមិនដាច់ សូម្បីយើងមកនេះក៏ដើម្បី (ឲ្យអ្នកត្រឡប់ទៅ) ហ្នឹងឯង អ្នកទៅចុះ ចំណែកយើងនឹងទៅនៅចាំវស្សា (ក្នុងវិហារណាមួយ) ក្នុងទឹកដីនេះឯង ដូច្នេះហើយ ក៏បញ្ជូនភិក្ខុកំលោះនោះទៅ

លោក(ទៅ)ដល់(កោរន្ទក)វិហារនោះ ក្នុងថ្ងៃចូលវស្សាល្មម សូម្បីសេនាសនៈដែលបានដល់លោក ក៏គឺជាទីសេនាសនៈដែលញោមប្រុសរបស់លោកកសាងទុកនោះឯង កាលថ្ងៃស្អែកឡើង (បន្ទាប់ពីថ្ងៃចូលវស្សា) ញោមប្រុសរបស់លោកមកសួរ (សេនាសនគ្គាហាបកៈ) ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សេនាសនៈរបស់ខ្ញុំព្រះករុណា បានដល់ភិក្ខុអង្គណា" បានឮថា បានដល់ ភិក្ខុកំលោះជាអាគន្តុកៈ ទើបទៅរកថ្វាយបង្គំលោក ពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សម្រាប់ភិក្ខុដែលចាំវស្សាក្នុងសេនាសនៈរបស់ខ្ញុំព្រះករុណា មានវត្ត (ដែលត្រូវបដិបត្តិ) លោកសួរថា "វត្តអ្វីខ្លះឧបាសក" ញោមប្រុសប្រាប់ថា "វត្តគឺត្រូវទទួលភត្តក្នុងផ្ទះរបស់ខ្ញុំម្ចាស់តែម្យ៉ាង របូតអស់ត្រីមាស ១ បវារណាហើយ វេលាទៅត្រូវមកប្រាប់លា ១" លោកទទួលដោយតុណ្ហីភាព ។ ចំណែកឧបាសកទៅផ្ទះវិញប្រាប់ឧបាសិកាថា ព្រះគុណម្ចាស់ជាអាគន្តុកៈ ១ រូប ចូលចាំវស្សាក្នុងអាវាសរបស់យើង យើងគប្បីទំនុកបម្រុងដោយគោរពចុះ ឧបាសិកាក៏ទទួលពាក្យថា សាធុ ! ហើយឲ្យចាត់ចែងខាទនីយភោជនីយដ៏ប្រណិតទុក ។ ឯភិក្ខុកំលោះដល់ពេលឆាន់ ក៏ទៅកាន់ផ្ទះរបស់ញាតិ មិនមានអ្នកណាចំណាំមុខលោកបានសូម្បីត្រឹមតែម្នាក់ លោកឆាន់បិណ្ឌបាតក្នុងផ្ទះនោះ ចាំ

វស្សាហួតអស់ត្រីមាសហើយពោលលាថា អាត្មានឹងទៅ កាលនោះពួកញាតិរបស់លោកក៏សូមអង្វរថា "ស្អែកនេះសឹមទៅលោកម្ចាស់" ថ្ងៃស្អែកឡើងប្រគេនចង្ហាន់លោកក្នុងផ្ទះនោះហើយ ថែមប្រេងពេញបំពង់ ប្រគេនស្ករអំពៅ ១ ដុំ និងសំពត់សាដកប្រវែង ៩ ហត្ថ (មួយផ្ទាំង) ហើយទើបអនុញ្ញាតឲ្យលោកទៅ ភិក្ខុកំលោះធ្វើអនុមោទនាហើយ ក៏បែរមុខ(ត្រឡប់ទៅកាន់) រោហណជនបទវិញ ។ ចំណែកឧបជ្ឈាយ៍របស់លោក បវារណាហើយដើរតាមផ្លូវមកក៏បានជួបលោក ក្នុងទីដែលធ្លាប់ជួបគ្នាមុននោះឯង ភិក្ខុ-កំលោះថ្វាយបង្គំព្រះថេរៈហើយ បានធ្វើឧបជ្ឈាយវត្តដល់ព្រះថេរៈទៀបគល់ឈើត្រង់កន្លែងមួយ កាល(បានធ្វើវត្ត) ហើយ ព្រះថេរៈសួរលោកថា "នែ៎អាវុសោ **ភទ្រមុខ** (អ្នកមានមុខស្រស់) អ្នកបានជួបឧបាសកនិងឧបាសិកា (ញោម) របស់អ្នកហើយឬ ? ភិក្ខុទទួលថា "បានជួបហើយលោកម្ចាស់" ហើយក៏និយាយប្រាប់ព្រឹត្តិការណ៍ទាំងពួង លាបជើងរបស់ព្រះថេរៈដោយប្រេងនោះ ធ្វើទឹកបានដោយទឹកអំពៅ (ប្រគេន) ប្រគេនសំពត់សាដកមួយផ្ទាំងនោះចំពោះព្រះថេរៈ ថ្វាយបង្គំហើយប្រាប់ថា លោកម្ចាស់ រោហ-ណជនបទ ប៉ុណ្ណោះ ជាទីសប្បាយសម្រាប់ខ្ញុំព្រះករុណា ហើយក៏(លា)ទៅ ចំណែកព្រះថេរៈ ក៏និមន្តមកកាន់គោរន្ទកវិហារ ថ្ងៃស្អែក

ឡើងទើបចូលទៅកាន់ស្រុកកោរន្ទកគ្រាម ។ ចំណែកឧបាសិកាសង្ឃឹមក្នុងចិត្តថា លោកបងរបស់ខ្ញុំ នឹងនាំលោកកូនមកក្នុងថ្ងៃនេះឯង តែងឈរចាំមើលផ្លូវរាល់ថ្ងៃ (ថ្ងៃនោះ) នាងឃើញព្រះថេរៈមកតែមួយអង្គឯង ក៏សម្គាល់ថា ប្រហែលជាកូនរបស់ខ្លួនស្លាប់បាត់ទៅហើយ ទើបព្រះថេរៈមកតែមួយអង្គឯង ក៏ដួលចុះផ្សែរកយំរៀបរាប់ទៀបព្រះបាទាព្រះថេរៈ ព្រះថេរៈលើកបានថា "ភិក្ខុកំលោះមកហើយ មិនឲ្យអ្នកណាស្គាល់ខ្លួន ព្រោះសេចក្តីប្រាថ្នាតិច (តឡូប់) ចេញទៅហើយ មែនពិតហ្ន៎ ! " ទើបលួងលោមនាង (ឲ្យស្បើយពីបរិទេវៈ) ហើយនិយាយព្រឹត្តិការណ៍ទាំងពួងឲ្យស្តាប់ ក៏ទាញយកសំពត់សាដកមួយផ្ទាំងនោះ ចេញអំពីស្បោកបាត្រសម្តែង (ឲ្យឃើញច្បាស់) ឧបាសិកាជ្រាបសេចក្តីពិតដូច្នោះ កើតសេចក្តីជ្រះថ្លា បែរមុខទៅទិសដែលលោកកូនទៅក្រាបចុះនមស្ការពោលថា "ព្រះមានព្រះភាគ គង់នឹងធ្វើភិក្ខុដូចជាបុត្ររបស់ខ្ញុំនេះឯងហ្ន៎ ឲ្យជាកាយសក្ខី (អ្នកមានខ្លួនជាបន្ទាល់) ត្រាស់រថវិនីតបដិបទា នាលកបដិបទា តុវដ្តកបដិបទា និងមហាអរិយវង្សប្រដិបទា ដែលសម្តែងសេចក្តីសន្តោសដោយបច្ច័យ ៤ និងសេចក្តីត្រេកអរដោយភាវនា គួរឲ្យសរសើរ សូម្បីឆាន់អាហារនៅក្នុងផ្ទះរបស់មាតាបង្កើតដល់ទៅ ៣ ខែ លោកក៏មិនបានបង្ហើប

ថា អាត្មាជាកូនរបស់ញោម ញោមជាមាតាបិតារបស់អាត្មា ឱ ! អច្ឆរិយមនុស្ស” សម្រាប់ភិក្ខុ (មានចិត្តមិនជាប់ជំពាក់) យ៉ាងនេះ ឯង សូម្បីតែមាតាបិតា នៅមិនជាបលិពោធទេ នឹងបាច់ពោល ទៅថ្វីដល់ត្រកូលឧបដ្ឋាកដទៃនោះ ដោយប្រការដូច្នេះ ។

## ៣.៣ លាភបលិពោធ

បច្ច័យ ៤ ឈ្មោះថា លាភ សួរថា បច្ច័យ ៤ នោះ ជាបលិពោធបានយ៉ាងណាខ្លះ ? ឆ្លើយថា ក៏ក្នុងទីដែលភិក្ខុមានបញ្ញា ទៅ មនុស្សទាំងឡាយរមែងថ្វាយបច្ច័យ មានបរិវារច្រើន (ក្នុងទីដែលទាយកនិមន្តបុណ្យ) ។ កាលលោកអនុមោទនា សម្តែងធម៌ ដល់មនុស្សទាំងនោះ រមែងមិនបានឱកាសបំពេញសមណធម៌ ។

តាំងពីអរុណរះឡើងរហូតដល់បឋមយាម នៅប្រឡូកប្រឡំ ជាមួយមនុស្សមិនដាច់ចន្លោះ រៀងរាល់ថ្ងៃតទៅ លុះពេលទៀបភ្លឺ ពួកភិក្ខុអ្នកកាន់បិណ្ឌបាតជាវត្ត ប្រភេទពាហុល្លិកៈ (ជាអ្នកប្រាថ្នាច្រើនដោយបច្ច័យ) មកនិយាយប្រាប់ថា “លោកម្ចាស់ ឧបាសកឈ្មោះនេះ ឧបាសិកាឈ្មោះនោះ អមាត្យឈ្មោះនេះ បុត្តអមាត្យឈ្មោះឯណោះ ធីតារបស់អមាត្យឯណោះ ប្រាថ្នានឹងឃើញលោកម្ចាស់”, លោក (កាត់មិនបាន) ក៏ប្រាប់ភិក្ខុទាំងនោះឲ្យជួយកាន់បាត្រនិងចីវរ ហើយជាអ្នកត្រៀមនិមន្តទៅ ត្រូវជាអ្នកខ្វល់ខ្វាយ (ក្នុងការសង្គ្រោះអ្នកដទៃ) ជានិច្ច, បច្ច័យទាំងនោះ

រមែងជាបលិពោធដល់ភិក្ខុអ្នកមានបុណ្យនោះដូច្នេះ, កាលភិក្ខុដូច្នោះ គប្បីលះពួកគណៈចេញ ត្រាច់ទៅតែម្នាក់ឯងក្នុងទីកន្លែងដែលមនុស្សមិនស្គាល់លោក យ៉ាងនេះទើបលោកអាចកាត់បលិ-ពោធនោះបាន ដោយប្រការដូច្នេះ ។

## ៣.៤ គណបលិពោធ

គណៈភិក្ខុអ្នករៀនព្រះសូត្រក្តី គណៈរបស់ភិក្ខុអ្នករៀនអភិធម្មក្តី ឈ្មោះថា **គណៈ**, ភិក្ខុណាកាលឲ្យឧទ្ទេសខ្លះ បរិបុច្ឆាខ្លះដល់គណៈនោះ រមែងមិនបានឱកាសសម្រាប់បំពេញសមណធម៌ គណៈរមែងជាបលិពោធដល់ភិក្ខុនោះ គណៈបលិពោធនោះ លោកគប្បីកាត់ចេញដោយឧបាយដូចតទៅនេះ គឺបើការងារ (រៀនសូត្រ) របស់ភិក្ខុនោះសម្រេចបានច្រើនហើយ ការងារដែលនៅសល់តិច លោកគប្បីធ្វើការងារនោះឲ្យស្រេច ហើយទើបចូលទៅព្រៃចុះ, បើការងារដែលហើយបានតិច ដែលនៅសល់ច្រើន (លោកគប្បីចូលទៅរកគណវាចក (អ្នកទូន្មាន) ដទៃឲ្យទូន្មានជំនួស កុំគប្បីទៅ (ឆ្ងាយ) ឲ្យលើសពី ១ យោជន៍ គប្បីចូលទៅរកគណវាចកដទៃ (ដែលស្ថិតនៅសំណាក់) ខាងក្នុងទីកំណត់ ១ យោជន៍ សូមអង្វរឲ្យលោកជួយសង្គ្រោះដល់ភិក្ខុក្នុងគណៈរបស់ខ្លួន ដោយសង្គហវិធីមានឲ្យឧទ្ទេសជាដើម (ជំនួសខ្លួនចុះ) ។ ប្រសិនបើរកមិនបាន ដូចពោលមកនេះទេ ក៏គប្បីប្រាប់ (ភិក្ខុទាំងនោះ) ថា "អាវុសោ

ទាំងឡាយ កិច្ចឯណានីមួយរបស់ខ្ញុំមាន ខ្ញុំ(មិនអាចបង្រៀនពួកលោកតទៅទៀតបានទេ) និមន្តលោកទាំងឡាយទៅរកកន្លែង(រៀន) តាមសប្បាយចុះ” ដូច្នេះហើយ គប្បីលះបង់គណៈនោះចោល ហើយចេញទៅចម្រើនកម្មដ្ឋានរបស់ខ្លួនចុះ ។

## ៣.៥ កម្មបលិពោធ

នវកម្ម (ការកសាងថ្មី) ឈ្មោះថា **កម្ម** (ការងារ), កាលភិក្ខុអ្នកធ្វើនវកម្មនោះ ចាំបាច់ត្រូវដឹងសម្ភារដែលអ្នកធ្វើការងារមានជាងឈើជាដើមបានទុកដាក់ហើយ និងនៅមិនទាន់បាន (ទុកដាក់) ត្រូវខ្វល់ខ្វាយ (មើល) ក្នុងការងារដែលគេធ្វើហើយ និងនៅមិនទាន់បានធ្វើ ។ អ្នកធ្វើនវកម្ម ត្រូវមានបលិពោធច្រើនយ៉ាង ដូច្នេះឯង, សូម្បីកម្មបលិពោធនោះ គប្បីកាត់ចេញដោយឧបាយដូចតទៅនេះគឺ បើការងារនៅសល់តិច គប្បីធ្វើបង្ហើយឲ្យស្រេច បើនៅសល់ច្រើន ប្រសិនបើជានវកម្មរបស់សង្ឃសោត គប្បីប្រគល់ដល់សង្ឃ ឬដល់ភិក្ខុអ្នកទទួលភារៈ (ក្នុងសង្ឃកិច្ច) ទាំងឡាយ ប្រសិនបើជានវកម្មរបស់ខ្លួន ក៏ត្រូវប្រគល់ឲ្យដល់ភិក្ខុអ្នកទទួលភារៈរបស់ខ្លួន ។ កាលបើមិនមានភិក្ខុអ្នកទទួលភារៈ ដូច្នេះ គប្បីលះបង់ (ការងារ) ឲ្យដល់សង្ឃចុះ (ហើយសឹមចេញទៅ) ។

## ៣.៦ អទ្ធានបលិពោធ

*ការដើរផ្លូវ ឈ្មោះថា* ***អទ្ធាន****, ក៏បញ្ជាបេក្ខៈរបស់ភិក្ខុណា មាននៅទីណាក្តី បច្ច័យប្រភេទណាដែលភិក្ខុណាត្រូវបាននៅទីណាក្តី កាលបើភិក្ខុនោះ នៅមិនទាន់បានជួបបញ្ជាបេក្ខៈ និងបច្ច័យនោះទេ លោកមិនអាចឈប់នៅបាន ដែលគមិកចិត្ត (ចិត្តគិតនឹងទៅ) សូម្បីនៃភិក្ខុអ្នកចូលព្រៃបំពេញសមណធម៌ហើយ ក៏ជារបស់លំបាកបន្ទោបង់បាន ព្រោះដូច្នេះគប្បីធ្វើកិច្ចនោះឲ្យស្រេចហើយ ទើបធ្វើសេចក្តីខ្វល់ខ្វាយក្នុងការបំពេញសមណធម៌ចុះ ។*

## ៣.៧ ញាតិបលិពោធ

*បុគ្គលទាំងឡាយដែលត្រូវស្គាល់ មានដូច្នេះគឺ ក្នុងវត្ត (បុគ្គលជាដើមថា) ឧបជ្ឈាយ៍ អាចារ្យ សទ្ធិវិហារិក អន្តេវាសិក ភិក្ខុជាសិស្សរួមឧបជ្ឈាយ៍ រួមអាចារ្យជាមួយគ្នា, ក្នុងផ្ទះមាន មាតាបិតា បងប្អូនប្រុស បងប្អូនស្រីជាដើម ឈ្មោះថា* ***ញាតិ*** *, កាលបុគ្គលទាំងនោះមានជម្ងឺជាដើម ទើបជាកង្វល់ដល់ភិក្ខុនេះ ។ ព្រោះដូច្នេះ កង្វល់នោះ លោកគប្បីកាត់ចេញដោយការឧបដ្ឋាក ធ្វើបុគ្គលទាំងនោះ (គឺជួយព្យាបាលជម្ងឺបុគ្គលនោះ) ឲ្យជាហើយ (សឹមចេញទៅព្រៃចុះ) ។*

*ក្នុងបុគ្គលទាំងនោះ (ដូចជា) ឧបជ្ឈាយ៍ជាអ្នកមានអាពាធ បើនៅមិនទាន់ធូស្រាលទេ (កុំប្រញាប់ទៅ) ត្រូវនៅបដិបត្តិលោក*

ហេតុអស់ជីវិតចុះ ។ បព្វជ្ជាចារ្យ ឧបសម្បទាចារ្យ សទ្ធិវិហារិក អន្តេវាសិក និងភិក្ខុដែលខ្លួន (សូត្រកម្មវាចា) ឲ្យឧបសម្បទា និងឲ្យបព្វជ្ជា និងភិក្ខុរួមព្រះឧបជ្ឈាយ៍ (មានជម្ងឺ) ក៏ត្រូវបដិបត្តិដូច (ឧបជ្ឈាយ៍) នោះចុះ ។ ចំណែកនិស្សយាចារ្យ ឧទ្ទេសាចារ្យ និស្សយន្តេវាសិក ឧទ្ទេសន្តេវាសិក និងភិក្ខុរួមអាចារ្យ ត្រូវបដិបត្តិត្រឹមតែនិស្ស័យនិងឧទ្ទេសមិនទាន់ចប់, (តែ) កាលអាចក៏គប្បីបដិបត្តិតទៅទៀតចុះ ;

សូម្បីមាតាបិតា ក៏ត្រូវបដិបត្តិដូចក្នុងឧបជ្ឈាយ៍ចុះ ពិតមែនមាតាបិតានោះ សូម្បីបើលោកជាអ្នកស្ថិតនៅក្នុងរាជសម្បត្តិ បើលោកនៅប្រាថ្នាទទួលការទំនុកបម្រុងអំពីបុត្រសោត ភិក្ខុក៏ត្រូវធ្វើពិត, ម្យ៉ាងទៀត បើថ្នាំរបស់លោកមិនមាន ក៏ត្រូវឲ្យថ្នាំជារបស់ខ្លួន កាលបើថ្នាំរបស់ខ្លួនមិនមាន ក៏គួរស្វែងរកដោយភិក្ខាចារមកឲ្យ (លោក) បាន ;

តែសម្រាប់បងប្អូនប្រុសស្រី (មានជម្ងឺ) គប្បីផ្សំថ្នាំដែលជារបស់ខ្លួនគេនោះឯងឲ្យប៉ុណ្ណោះ បើថ្នាំ (របស់បងប្អូនប្រុសស្រី) មិនមាន គប្បីឲ្យថ្នាំរបស់ខ្លួនជារបស់ខ្ចី កាល(រក)បានខាងក្រោយទើបកាន់យក(សង) កាល(រក)មិនបាន កុំគប្បីទារឡើយ ។ ទឹងធ្វើថ្នាំ ទឹងឲ្យថ្នាំដល់ស្វាមីរបស់បងប្អូនស្រី ដែលមិនមែនជាញាតិ រមែងមិនគួរ តែគប្បីឲ្យថ្នាំដល់បងប្អូនស្រី ប្រាប់ឲ្យៗដល់ស្វាមីរបស់នាង, ន័យសូម្បីក្នុងភរិយារបស់បងប្អូនប្រុស ក៏ដូច

ន័យនេះ, ប៉ុន្តែបុត្តធីតារបស់បងប្អូនប្រុសស្រី ជាញាតិរបស់ភិក្ខុ នោះដូច្នេះ គួរឲ្យថ្នាំដល់បុត្តធីតាដែលជាក្មួយៗ នោះរមែងគួរ ។

## ៣.៨ អាពាធបលិពោធ

រោគយ៉ាងណាមួយ ឈ្មោះថា **អាពាធ**, រោគនោះ កាលបើវានៅបៀតបៀន ទើបឈ្មោះថា ជាបលិពោធ, ព្រោះដូច្នេះ គប្បីកាត់កង្វល់ចេញដោយការធ្វើភេសជ្ជៈ តែបើសូម្បីកាលភិក្ខុធ្វើភេសជ្ជៈ (ព្យាបាលរោគ) ពីរបីថ្ងៃហើយអាពាធមិនជាសោត ក៏គប្បីតិះដៀលអត្តភាពថា "នាហំ តុយ្ហំ ទាសោ, ន ភដកោ, តំយេវ ហិ ពោសេន្តោ អនមតគ្គេ សំសារវដ្ដេ ទុក្ខំ បត្តោ : យើងមិនមែនជាអ្នកបម្រើរបស់អ្នក, មិនមែនជាកូនឈ្នួលរបស់អ្នក, ក៏ព្រោះតែយើងចិញ្ចឹមអ្នកនេះឯង ទើបបាន ទទួលសេចក្ដីទុក្ខក្នុងសង្សារវដ្ដ មានទីបំផុត(ខាងដើម) គេមិនអាចដឹងបាន" ដូច្នេះ ហើយចេញទៅបំពេញសមណធម៌ចុះ ។

## ៣.៩ គន្ថបលិពោធ

ការបរិហារបរិយត្តិ ឈ្មោះថា **គន្ថ** , ការបរិហារបរិយត្តិនោះ រមែងជាកង្វល់ដល់ភិក្ខុជានិច្ច ដោយកិច្ចមានការស្វាធ្យាយជាដើម ប៉ុណ្ណោះ មិនជាកង្វល់ដល់ភិក្ខុក្រៅនេះ (ដែលមិនបានខ្វល់ខ្វាយ)

ទេ រឿងទាំងនេះ (ជានិទស្សនៈ) ក្នុងសេចក្តីដែលគន្ថៈមិនជាបលិពោធ សម្រាប់ភិក្ខុអ្នកមិនខ្វល់ខ្វាយ,

បានឮមកថា ព្រះទេវត្ថេរៈដែលជាមជ្ឈិមភាណកៈ (អ្នកសូត្រមជ្ឈិមនិកាយ) ទៅកាន់សំណាក់របស់ព្រះទេវត្ថេរៈអ្នកដែនមាល័យ សូមកម្មដ្ឋាន ព្រះថេរៈសួរថា អាវុសោ លោកជាអ្នករៀនបានប៉ុន្មានក្នុងបរិយត្តិ ? ព្រះមជ្ឈិមភាណកៈតបថា លោកម្ចាស់ ខ្ញុំជំនាញមជ្ឈិមនិកាយ, ព្រះថេរៈពោលថា អាវុសោ មជ្ឈិមនិកាយនោះ បរិហារលំបាក កាលស្វាធ្យាយមូលបណ្ណាសកៈ មជ្ឈិមបណ្ណាសកៈ ក៏មក(លាយ) កាលស្វាធ្យាយមជ្ឈិមបណ្ណាសកៈ ឧបរិបណ្ណាសកៈ ក៏មក(ច្រឡូកច្រឡំ) (កាលបើរវល់មិនចេះចប់ដូច្នេះ) ពេលណាកម្មដ្ឋាននឹងកើតមានដល់លោកបាន, ព្រះមជ្ឈិមភាណកៈប្តេជ្ញាថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា បានរៀនកម្មដ្ឋានក្នុងសំណាក់ព្រះគុណម្ចាស់ហើយ នឹងមិនងាកមើល (គន្ថៈ) តទៅឡើយ ដូច្នេះហើយទទួលយកកម្មដ្ឋាន (ទៅធ្វើសេចក្តីព្យាយាម) មិនបានធ្វើការស្វាធ្យាយដល់ទៅ ១៩ ឆ្នាំ លុះដល់ឆ្នាំទី ២០ ក៏បានសម្រេចព្រះអរហត្ត ។ ថ្ងៃមួយ លោកពោលដល់ភិក្ខុទាំងឡាយ ដែលនាំគ្នាមកដើម្បីនឹងស្វាធ្យាយ (ប្រាប់)ថា អាវុសោទាំងឡាយ កាលយើងមិនងាកមើលបរិយត្តិរហូតដល់ទៅ ២០ ឆ្នាំ

តែថា យើងមានការសន្សំ បានធ្វើទុកក្នុងបរិយត្តិនោះ និមន្តលោកទាំងឡាយផ្តើម(ស្វាធ្យាយទៅ)ចុះ (កាលភិក្ខុទាំងនោះស្វាធ្យាយទៅប្រាជកថា លោកនៅចាំបរិយត្តិនោះបានល្អ) លោកមិនមានការស្ទាក់ស្ទើរ សូម្បីក្នុងព្យញ្ជនៈត្រឹមតែមួយតួ តាំងពីដើមរហូតដល់ចប់ ។

សូម្បីព្រះនាគត្ថេរៈ អ្នកនៅក្នុងភ្នំកុរុន្ទិយគិរីលះបង់បរិយត្តិដល់ទៅ ១៨ ឆ្នាំ ហើយមកសម្តែងធាតុកថាដល់ភិក្ខុទាំងឡាយ កាលភិក្ខុទាំងនោះ (ចាំបានហើយយកទៅ) ផ្ទៀងផ្ទាត់ជាមួយព្រះថេរៈគាមវាសីទាំងឡាយ ប្រាជកថា បញ្ហាសូម្បីមួយដែលមកខុសលំដាប់ ក៏មិនមាន ។

សូម្បីក្នុងមហាវិហារព្រះថេរៈ ឈ្មោះថា ចូឡាភ័យដែលជា**តិបិដក** (ទ្រទ្រង់បិដកទាំង៣) មិនបានរៀនអដ្ឋកថាឡើយ (នឹកក្នុកឡើង) ឲ្យមនុស្សវាយសុវណ្ណភេរីថា នឹងបរិវត្ត (ពណ៌នា) ឬប្រែបិដកទាំង ៣ ក្នុងវង្ស (អ្នកសិក្សា) បញ្ចនិកាយ ។ ពួកភិក្ខុផងគ្នា (បានឮថាព្រះចូឡាភ័យ មិនមានគ្រូអាចារ្យ) ទើបក្លែងធ្វើជាពោលជំទាស់ថា "បានរៀនអំពីសំណាក់អាចារ្យណាមក ព្រះចូឡាភ័យក៏ចូរពោលតែត្រង់ដែលបានរៀនអំពីអាចារ្យរបស់ខ្លួនចុះ យើងទាំងឡាយ មិនព្រមឲ្យពោលក្រៅអំពីនេះ" សូម្បីឧបជ្ឈាយ៍

ក៏បានសួរលោកដែលមកឧបដ្ឋាកខ្លួនថា អាវុសោ ! លោកឲ្យគេវាយស្គរឬ ? លោកទូលថា "ព្រះករុណា" ឧបជ្ឈាយ៍ទើបសួរទៀតថា "ព្រោះហេតុអ្វី" លោកប្រាប់ថា "ខ្ញុំព្រះករុណានឹងបរិវត្តធម៌ (ប្រែធម៌ឲ្យមនុស្សស្តាប់)" ព្រះឧបជ្ឈាយ៍សាកល្បងសួរទៀតថា "នែ៎អាវុសោអភ័យ អាចារ្យទាំងឡាយពោលបទនេះ ដូចម្តេច ? លោកឆ្លើយភ្លាមថា ពោលយ៉ាងនេះ, ឧបជ្ឈាយ៍ ធ្វើជាពោលបដិសេធដោយសំឡេងថា "ហ៊ឺ ហ៊ឺ" លោកក៏ឆ្លើយជាថ្មី ដោយបរិយាយដទៃៗ ថា "ពោលយ៉ាងនេះៗ" ដល់ទៅ ៣ ដង ព្រះថេរៈក៏បដិសេធថា ហ៊ឺហ៊ឺ ទាំងអស់ ហើយពោលថា នែ៎អាវុសោ គន្លងដែលអ្នកពោលឆ្លើយមុនដំបូងនោះឯងជាអាចរិយមគ្គ (កថាមគ្គរបស់អាចារ្យ) តែព្រោះអ្នកមិនបានរៀនពីអាចរិយមុខ (មាត់របស់អាចារ្យ) ទើបមិនអាចប្រាកដប្រជាថា អាចារ្យទាំងឡាយពោលយ៉ាងនេះ ព្រោះដូច្នេះ អ្នកចូរទៅស្តាប់ក្នុងសំណាក់នៃអាចារ្យទាំងឡាយ (ដែលគួរជាអាចារ្យ) របស់ខ្លួនចុះ ។ លោកសួរថា នឹងទៅក្នុងទីណាល្អ ព្រះឧបជ្ឈាយ៍ទើបប្រាប់ថា ព្រះថេរៈព្រះនាមធម្មរក្ខិតៈ អ្នកជំនាញក្នុងបរិយត្តិទាំងពួង គង់នៅវត្តតុលាធារបព៌ត ក្នុងរោហណជនបទត្រើយស្ទឹងម្ខាងឯណោះ អ្នកចូលទៅកាន់សំណាក់របស់លោកចុះ ។

ព្រះចូឡាភ័យទទួលពាក្យ (ព្រះឧបជ្ឈាយ៍) ថ្វាយបង្គំលាព្រះថេរៈហើយ ទៅកាន់សំណាក់ព្រះថេរៈធម្មរក្ខិតៈ ព្រមដោយបរិវារប្រមាណ ៥០០ រូប (កាលចូលទៅដល់ហើយ) ថ្វាយបង្គំហើយអង្គុយចុះ ព្រះថេរៈសួរថា មកមានកិច្ចការអ្វី ? ក៏ពិតថេរៈដីកាថា មកដើម្បីស្តាប់ធម៌ ទើបព្រះថេរៈពោលថា អាវុសោអភ័យ ភិក្ខុទាំងឡាយមកសួរខ្ញុំក្នុងទីឃនិកាយ និងមជ្ឈិមនិកាយ (ខ្លះ) ម្តងម្កាល ចំណែកសូត្រដ៏សេសខ្ញុំមិនធ្លាប់មើលរំលឹកមកប្រមាណ ៣០ ឆ្នាំហើយ តែណ្ហើយចុះ ពេលកណ្តាលយប់ លោក (មក) បរិវត្តក្នុងសំណាក់ខ្ញុំ ពេលថ្ងៃខ្ញុំនឹងពោលដល់លោក (ឲ្យលោកស្តាប់ថាតើមានខុសត្រូវយ៉ាងណា) ព្រះចូឡាភ័យយល់ព្រមធ្វើយ៉ាងនោះ ។ ពួកអ្នកស្រុកឲ្យធ្វើបារាំធំក្បែរទ្វារបរិវេណហើយមកស្តាប់ធម៌ជុំគ្នារាល់ថ្ងៃ ។ ព្រះថេរៈយកសូត្រដែលព្រះចូឡាភ័យបរិវត្តក្នុងពេលយប់មកពោល (ផ្ទៀងផ្ទាត់) ក្នុងវេលាថ្ងៃ (មិនមានខុស)រឿយៗ ទៅរហូតដល់ចប់(ព្រះសូត្រ) ហើយ(គង់នឹងសង្កេតឃើញថា ព្រះចូឡាភ័យមានបដិភាណខ្ពស់ជាងខ្លួន ទើបថ្ងៃមួយចូលទៅ)អង្គុយលើកន្ទេលជិតព្រះអភយត្ថេរៈ ពោលថា “លោកមានអាយុ ចូរប្រាប់កម្មដ្ឋានដល់ខ្ញុំព្រះករុណាផងចុះ” ព្រះចូឡាភ័យទើបពោលថា “ព្រះគុណម្ចាស់និយាយអ្វី ? ក្រែងកម្មដ្ឋាននោះ ខ្ញុំ

ក៏បានស្តាប់មកក្នុងសំណាក់របស់ព្រះគុណម្ចាស់នោះឯង មិនមែនឬ ? ខ្ញុំព្រះករុណានឹងប្រាប់កម្មដ្ឋានអ្វីទៀត ដែលព្រះគុណម្ចាស់នៅមិនទាន់ដឹងនោះ” លំដាប់នោះ ព្រះថេរៈទើបពោល (ឲ្យច្បាស់ឡើង)ថា “អាវុសោ ! ផ្លូវរបស់បុគ្គលអ្នកទៅដល់ហើយនោះ ជាផ្លូវតែមួយ (ដែលលោកពោលដូចនេះក៏ព្រោះ) ជ្រាបថា ពេលនោះព្រះអភយត្ថេរៈ ជាព្រះសោតាបន្ន ។

គ្រានោះ ព្រះបូឡាក៏យឲ្យកម្មដ្ឋានដល់ព្រះថេរៈហើយ ក៏(ត្រឡប់)មក បរិវត្តធម៌ជិតលោហៈប្រាសាទ (ក្នុងអនុរាធបុរៈ) ក្រោយមកបានឮដំណឹងថា (ព្រះថេរៈបានសម្រេចព្រះអរហត្ត) បរិនិព្វានហើយ ។ កាលបានឮដូច្នេះ ទើបប្រាប់(សិស្ស)ឲ្យយកចីវរមកឲ្យ ដណ្តប់ចីវរ (ជាបរិមណ្ឌល) ហើយពោលសរសើរព្រះថេរៈ (ក្នុងចំណោមភិក្ខុទាំងឡាយ) ថា “អាវុសោទាំងឡាយ ព្រះអរហត្តមគ្គ សមគួរដល់លោកអាចារ្យរបស់យើងហើយ លោកអាចារ្យរបស់យើងជាអ្នកស្មោះត្រង់ ជាអាជានេយ្យបុគ្គល[១] ទើបលោកព្រមអង្គុយលើកន្ទេលជិតធម្មន្តេវាសិករបស់ខ្លួន ពោលថា

---

១. មហាដីកាពោលថា លោកស្មោះត្រង់ ព្រោះមិនមានសាថេយ្យ,

ឈ្មោះថា អាជានេយ្យ ព្រោះដឹងហេតុដែលគួរដឹង មិនវង្វេង ។

"លោកចូរប្រាប់កម្មដ្ឋានដល់ខ្ញុំផងចុះ" អាវុសោទាំងឡាយ ព្រះ-អរហត្តមគ្គ សមគួរដល់ព្រះថេរៈ (អាចារ្យ) លោកហើយ ។

គន្ថៈ រមែងមិនជាបលិពោធ ដល់ភិក្ខុទាំងឡាយដែលមានគុណធម៌ ដូច្នេះឯង ។

## ៣.១០ ឥទ្ធិបលិពោធ

បទថា ឥទ្ធិ (សេចក្តីកន្លងព្រោះឫទ្ធិ) សំដៅយកឫទ្ធិជារបស់បុថុជ្ជន ដែលឫទ្ធិមានក្នុងបុថុជ្ជននោះ ជាវត្ថុដែលលំបាករក្សា ដូចក្មេងតូចដេកផ្ងារ និងដូចសន្ទូងស្រូវខ្ចីៗ បែកធ្លាយបានដោយត្រឹមតែបន្តិច ។ ក៏ឫទ្ធិនោះ រមែងជាបលិពោធដល់វិបស្សនា មិនជាបលិពោធដល់សមាធិទេ ព្រោះឫទ្ធិនោះ បុគ្គលបានសម្រេចសមាធិហើយទើបបាន ព្រោះហេតុនោះឯង ឥទ្ធិបលិពោធ ព្រះ-យោគាវចរ ប្រាថ្នាក្នុងវិបស្សនា គប្បីកាត់បលិពោធ (គឺឫទ្ធិនោះ) ចេញ, (ចំណែក) បលិពោធដ៏សេស (៩ យ៉ាង) ព្រះយោគាវចរអ្នកប្រាថ្នាសមថៈ ត្រូវកាត់ចេញ ។

ក្នុងគម្ពីរសារត្ថទីបនីដីកា លោកពោលទុកថា ឈ្មោះថាបលិពោធ ព្រោះអត្ថថា ជំទាស់នូវការចម្រើនកម្មដ្ឋាន គឺចូលទៅរារាំងមិនឲ្យប្រព្រឹត្តទៅ ។ លោកពោលទុក ព្រោះផ្ចាស់ ៖ អក្សរជា **ឍ** អក្សរ សំដៅសេចក្តីថា ជាការអន្តរាយ ។ ពាក្យថាគប្បីចូលទៅកាត់ គឺគប្បីចូលទៅរើចេញ ដោយការធ្វើឲ្យសម្រេច

ហើយទៅ ឬដោយការប្រមូលទុក អធិប្បាយថា គប្បីធ្វើមិនឲ្យជាកន្ទល់ ។

## ៤.កម្មដ្ឋាន ២ យ៉ាង

កម្មដ្ឋាន ២ យ៉ាង គឺ **សព្វត្ថកកម្មដ្ឋាន** (កម្មដ្ឋានមានប្រយោជន៍ក្នុងកុសលធម៌ទាំងពួង) ១ **បារិហារិយកម្មដ្ឋាន** (កម្មដ្ឋានគួរបរិហារទុកឲ្យល្អ) ១ ។ បណ្តាកម្មដ្ឋានទាំង ២ យ៉ាងនោះ **មេត្តា** (ដែលផ្សាយទៅ) ក្នុងជនផ្សេងៗ មានពួកភិក្ខុជាដើមក្តី **មរណស្សតិ** (ការរលឹកដល់សេចក្តីស្លាប់)ក្តី ឈ្មោះថា សព្វត្ថកកម្មដ្ឋាន ។ ព្រះអាចារ្យពួកខ្លះពោលថា **អសុភសញ្ញា** (ជាសព្វត្ថកកម្មដ្ឋាន ក៏មាន) ។ ពិតមែន មេត្តា (នោះ) ជាដំបូង ភិក្ខុអ្នកចម្រើនកម្មដ្ឋាន ត្រូវកំណត់យកពួកភិក្ខុនោះហើយ ចម្រើនទៅក្នុងពួកភិក្ខុដែលនៅក្នុងសីមា (ជាមួយគ្នា) ដោយន័យថា "សីមដ្ឋកភិក្ខុសង្ឃេ សុខិតា ភវន្តុ អព្យាបជ្ឈា សូមភិក្ខុសង្ឃទាំងឡាយដែលនៅក្នុងសីមា ចូរជាអ្នកមានសេចក្តីសុខ មិនបៀតបៀនគ្នាចុះ" អំពីនោះគប្បីចម្រើនទៅក្នុងពួកទេវតា ដែលនៅក្នុងសីមា (នោះ), បន្ទាប់ពីនោះ គប្បីចម្រើនទៅក្នុងឥស្សរជនក្នុងគោចរគ្រាម, ហើយទើបចម្រើនទៅក្នុងមនុស្ស (អ្នកស្រុក) ក្នុងគោចរគ្រាមនោះ រហូតទៅដល់ (សត្វតិរច្ឆាន) ទាំងពួង ។ ក៏ឯដោយមេត្តា (ដែលផ្សាយទៅ) ក្នុងពួកភិក្ខុ លោករមែងធ្វើឲ្យភិក្ខុទាំង

ឡាយដែលនៅរួមជាមួយគ្នាមានចិត្តទន់ភ្លន់ (ក្នុងខ្លួនលោកបាន) ។ កាលដូច្នោះ ភិក្ខុទាំងនោះ ក៏ជាសុខសំវាស (មានការនៅរួមជាសុខ) សម្រាប់លោក ។ ដោយមេត្តា (ដែលផ្សាយទៅ) ក្នុងពួកទេវតាដែលនៅក្នុងសីមានោះ លោកនឹងជាអ្នកដែលទេវតាទាំងឡាយ អ្នកមានចិត្តដែលមេត្តានោះធ្វើឲ្យទន់ភ្លន់ហើយ ចាត់ការរក្សាយ៉ាងល្អ ដោយការរក្សាដែលជាធម៌ដោយមេត្តា ។ (ដែលចម្រើនទៅ) ក្នុងឥស្សរជនក្នុងគោចរគ្រាម លោកនឹងជាអ្នកដែលឥស្សរជនទាំងឡាយ អ្នកមានចិត្តដែលមេត្តានោះធ្វើឲ្យទន់ភ្លន់ហើយ ចាត់ការរក្សាប្រុងប្រយ័ត្នយ៉ាងល្អ ដោយការរក្សាដែលប្រពៃតាមធម៌ ។ ដោយមេត្តា (ដែលចម្រើនទៅ) ក្នុងមនុស្សទាំងឡាយក្នុងគោចរគ្រាមនោះ លោករមែងជាអ្នកដែលមនុស្សទាំងនោះ អ្នកមានចិត្តដែលមេត្តានោះ ធ្វើឲ្យជ្រះថ្លាហើយ មិនមើលងាយត្រាច់ទៅ (បានតាមសប្បាយ) ។ ដោយមេត្តា (ដែលចម្រើនទៅ) ក្នុងពួកសត្វ (សត្វតិរច្ឆាន)ទាំងពួង លោកនឹងជាអ្នកមានការត្រាច់ទៅ មិនទើសទាក់ក្នុងទីទាំងពួង ។ម្យ៉ាងទៀត ដោយ **មរណស្សតិ** កាលលោកគិតថា អវស្សំ មយា មរិតព្វំ យើងនឹងត្រូវស្លាប់ពិតប្រាកដ ដូច្នេះ នឹងលះអនេសនា (ការស្វែងរកដែលមិនសមគួរ) ចេញបាន មានសេចក្តីសង្វេគ ចម្រើនខ្ពស់ឡើងជាអ្នកមានការប្រព្រឹត្តមិនធូរថយ (ក្នុងសម្មាបដិបត្តិ) ។ ម្យ៉ាងទៀត លោកមានចិត្តដែលបានសន្សំ (អប់រំ) ហើយក្នុងអសុភសញ្ញា

អារម្មណ៍ទាំងឡាយសូម្បីជាទិព្វ រមែងមិនទាក់ចិត្ត (របស់លោក) ដោយធ្វើឲ្យលំបាកបាន ។ ដោយប្រការដូចពោលមកដូចនេះ កម្មដ្ឋាន ៣ មានមេត្តាជាដើម លោកទើបហៅថា សព្វត្ថកកម្មដ្ឋាន ព្រោះហេតុជាកម្មដ្ឋានដែល (កុលបុត្រគប្បីប្រាថ្នា) ត្រូវការ គឺ គប្បីប្រាថ្នាក្នុងការនានុយោគទាំងពួង ព្រោះសេចក្ដីជាកម្មដ្ឋានមានឧបការៈច្រើនប្រការ ១ ហេតុជាទីតាំងនៃការងារ គឺការប្រកបប្រឹងប្រែងរឿយៗ នូវយោគការនាដែលបំណងប្រាថ្នាប្រការ ១ ។

ចំណែកថា កម្មដ្ឋានណាក្នុងកម្មដ្ឋានទាំង ៤០ សមគួរដល់ចរិយារបស់កុលបុត្រណា កម្មដ្ឋាននោះ លោកហៅថា បារិហារិយកម្មដ្ឋានរបស់កុលបុត្រនោះ ព្រោះជាកម្មដ្ឋានដែលកុលបុត្រនោះ គួរបរិហារជានិច្ច និងព្រោះជាបទដ្ឋាននៃការនាជាន់ខ្ពស់របស់លោកផង, លោកអ្នកឲ្យកម្មដ្ឋានទាំង ២ យ៉ាង ដូចពោលមកនេះ អ្នកនោះឈ្មោះថា (កម្មដ្ឋានទាយក) អ្នកឲ្យកម្មដ្ឋាន ព្រះយោគាវចរត្រូវចូលទៅរកអ្នកឲ្យកម្មដ្ឋាននោះ ។

ពាក្យនេះ លោកពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គ ចំណែកក្នុងអដ្ឋកថាវិន័យលោកពោលទុកថា ៖

ក៏បណ្ដាអារម្មណ៍ ៣៨ ប្រការ កម្មដ្ឋានណាដែលសមគួរដល់ចរិតរបស់កុលបុត្រណា កម្មដ្ឋាននោះ លោកហៅថា **បារិហារិយកម្មដ្ឋាន** ព្រោះជាកម្មដ្ឋានដែលកុលបុត្រនោះ គួរបរិហារទុកជានិច្ច ដោយន័យតាមដែលពោលហើយនុ៎ះឯង ។ តែក្នុង

តតិយបារាជិកនេះ អានាបានកម្មដ្ឋាននេះឯង លោកហៅថា បារិហារិយកម្មដ្ឋាន ។

ក្នុងគម្ពីរសារត្ថទីបនីដីកា លោកពោលទុកថា ៖

ភិក្ខុអ្នកប្រកបក្នុងកម្មដ្ឋាន ឈ្មោះថា **កម្មដ្ឋានិកោ** ប្រែថា អ្នកប្រកប គឺអ្នកប្រកបរឿយៗ នូវការនា ដែលភិក្ខុអ្នកប្រកបកម្មដ្ឋាននោះ ។ ពាក្យថា **កំណត់** គឺកំណត់កាត់យ៉ាងនេះថា ភិក្ខុទាំងពួងក្នុងវិហារនេះ ។ បទថា **សហវាសីនំ** ប្រែថា ភិក្ខុអ្នកនៅរួមគ្នា ។ ពាក្យថា **ធ្វើឲ្យកើតមានចិត្តមុទិតា** គឺធ្វើចិត្តឲ្យទន់កើតឡើងក្នុងខ្លួន ។ ក៏ប្រយោជន៍ដោយការធ្វើឲ្យកើតភាពជាអ្នកមានចិត្តទន់របស់អ្នកនៅរួមគ្នាជាដើមនេះ គប្បីសម្តែងដោយមេត្តា-និសង្សសូត្រ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា ជាទីស្រឡាញ់របស់មនុស្សទាំងឡាយជាដើម ។

ពាក្យថា **ជាអ្នកមានការប្រព្រឹត្តិទៅមិនធូរថយ** គឺមិនជាអ្នកមានសេចក្តីប្រព្រឹត្តិធូរថយ មានសេចក្តីព្យាយាមថោកថយក្នុងសម្មាបដិបត្តិ សេចក្តីថា ជាអ្នកប្រកបព្យាយាមក្នុងអារម្មណ៍សូម្បីជាទិព្វ អធិប្បាយថា នឹងបាច់ពោលទៅថ្វីក្នុងអារម្មណ៍ក្រៅនេះ ។ ពាក្យថា **ក្នុងគ្រប់ទីស្ថាន** គឺក្នុងកិច្ចដែលសមណៈគប្បីធ្វើគ្រប់យ៉ាង ឬក្នុងការតាមប្រកបកម្មដ្ឋានទាំងពួង ។ ពាក្យថា **គប្បីត្រូវការ** គឺគប្បីត្រូវការដោយអំណាចការសេពរបូតថ្មីកក្នុងខាងដើម ។

ការប្រកបរឿយៗ នូវការចម្រើនការប្រកប ឈ្មោះថា **យោគា-នុយោគោ** ប្រែថា ការប្រកបរឿយៗនូវសេចក្ដីព្យាយាម ។ កម្ម ដោយការប្រាថ្នា គឺវត្ថុដែលគួរធ្វើ បានដល់ ការប្រកបរឿយៗ នូវយោគៈនោះនៃកម្ម គឺការប្រកបរឿយៗនូវយោគៈនោះ ។ ពាក្យថា **ព្រោះភាពជាបទដ្ឋាន** គឺព្រោះជាហេតុនៃការសម្រេច ។

លោកអាចារ្យពោលតាមន័យដែលមកហើយ ក្នុងបាលីថា ក្នុងអារម្មណ៍ ៣៨ ដូច្នេះនេះនោះឯង ដោយវៀរអាកាសកសិណ និងអាលោកកសិណចេញ ព្រោះកសិណទាំង ៨ ដែលជាអារម្មណ៍ របស់រូបជ្ឈាន មានបឋវីកសិណជាដើម លោកបានពោលទុក ដោយសរុបក្នុងបាលី ដោយធ្វើអាលោកកសិណឲ្យចូលចុះក្នុង ឱទាតកសិណ និងធ្វើបរិច្ឆិន្នាកាសកសិណ ឲ្យចូលចុះក្នុងកសិណុ-គ្ឃាដិមាកាសកសិណ ។ ក៏កាលកាន់យកអាកាសកសិណ និង អាលោកកសិណទុកមួយផ្នែក តាមន័យអដ្ឋកថា ក៏ជាកម្មដ្ឋាន ៤០ នេះឯង ។

## ៥. កម្មដ្ឋាន ៤០

ក្នុងបាលីនោះ កម្មដ្ឋាន ៤០ ទាំងនេះគឺ កសិណ ១០ អសុភ ១០ អនុស្សតិ ១០ ព្រហ្មវិហារ ៤ អរូប ៤ សញ្ញា ១ វវដ្ឋាន ១ (ដូច្នេះ) ។

## កសិណ ១០ ទាំងនេះ គឺ

១-បឋវីកសិណ កសិណមានដីជាអារម្មណ៍,

២-អាបោកសិណ កសិណមានទឹកជាអារម្មណ៍,

៣-តេជោកសិណ កសិណមានភ្លើងជាអារម្មណ៍,

៤-វាយោកសិណ កសិណមានខ្យល់ជាអារម្មណ៍,

៥-នីលកសិណ កសិណមានពណ៌ខៀវជាអារម្មណ៍,

៦-បីតកសិណ កសិណមានពណ៌លឿងជាអារម្មណ៍,

៧-លោហិតកសិណ កសិណមានពណ៌ក្រហមជាអារម្មណ៍,

៨-ឱទាតកសិណ កសិណមានពណ៌សជាអារម្មណ៍,

៩-អាលោកកសិណ កសិណមានពន្លឺជាអារម្មណ៍,

១០-បរិច្ឆិន្នាកាសកសិណ កសិណមានអាកាសដែលកំណត់ជាអារម្មណ៍ ។

## អសុភ ១០ ទាំងនេះ គឺ

១-ឧទ្ធុមាតកអសុភ អសុភហើមពោរពងឡើង,

២-វិនីលកអសុភ អសុភហើមមានពណ៌ខៀវគួរខ្ពើម,

៣-វិបុព្វកអសុភ អសុភហើមមានខ្ទុះហូរទៅក្នុងខាងលើខាងក្រោម,

៤-វិច្ឆិទ្ទកអសុភ អសុភដែលគេកាត់ដាច់ជាកំណាត់ៗ,

៥-វិក្ខាយិតកអសុភ អសុភដែលសត្វខាំកកេរស៊ី មានស្នាមរលុះរលួយផ្សេងៗ,

៦-វិក្ខិត្តកអសុភ អសុភដែលគេកាត់ដាច់ចេញពីគ្នា ជាកំណាត់ៗ រាត់រាយទៅផ្សេងៗ,

៧-ហតវិក្ខិត្តកអសុភ អសុភដែលគេកាប់សាប់មាន ស្នាមរវាម,

៨-លោហិតកអសុភ អសុភត្រូវប្រហារមានឈាមហូរ ស្រោចស្រប់,

៩-បុឡុវកអសុភ អសុភដែលមានដង្កូវចុះហូរចេញ តាមទ្វារទាំង ៩,

១០-អដ្ឋិកអសុភ អសុភមានតែគ្រោងឆ្អឹងខ្ចាត់ខ្ចាយ ផ្សេងៗ ។

## អនុស្សតិ ១០ ទាំងនេះ គឺ

១-ពុទ្ធានុស្សតិ សេចក្តីរឭករឿយៗ មានពុទ្ធគុណ ជាអារម្មណ៍,

២-ធម្មានុស្សតិ សេចក្តីរឭករឿយៗ មានធម្មគុណ ជាអារម្មណ៍,

៣-សង្ឃានុស្សតិ សេចក្តីរឭករឿយៗ មានសង្ឃគុណ ជាអារម្មណ៍,

៤-សីលានុស្សតិ សេចក្តីរឭករឿយៗ មានសីលគុណ ជាអារម្មណ៍,

៥-ចាគានុស្សតិ សេចក្តីរឭករឿយៗ មានចាគគុណ មកជាអារម្មណ៍,

៦-ទេវតានុស្សតិ សេចក្តីរឭករឿយៗ មានសទ្ធាទិគុណ របស់ទេវតា និងសទ្ធាទិគុណរបស់ខ្លួនជាអារម្មណ៍,

៧-មរណានុស្សតិ សេចក្តីរឭករឿយៗ មានសេចក្តីស្លាប់ ជាអារម្មណ៍,

៨-កាយគតាសតិ សេចក្តីរឭករឿយៗ តាំងចុះក្នុងកាយ មានកោដ្ឋាសនិមិត្តនៃអាការ (៣២ ប្រការ) មានសក់ជាដើម ជាអារម្មណ៍,

៩-អានាបានស្សតិ សេចក្តីរឭកមានខ្យល់អស្សាស បស្សាសនិមិត្តជាអារម្មណ៍,

១០-ឧបសមានុស្សតិ សេចក្តីរឭករឿយៗ មានគុណ ព្រះនិព្វានដែលជាទីរម្ងាប់នូវទុក្ខទាំងពួងជាអារម្មណ៍ ។

## ព្រហ្មវិហារ ៤ ទាំងនេះ គឺ

១-មេត្តា ការផ្សាយមេត្តាដល់សព្វសត្វទាំងអស់,

២-ករុណា ការផ្សាយករុណាដល់សព្វសត្វទាំងអស់,

៣-មុទិតា ការផ្សាយមុទិតាដល់សព្វសត្វទាំងអស់,

៤-ឧបេក្ខា ការផ្សាយឧបេក្ខាដល់សព្វសត្វទាំងអស់ ។

## អរូប ៤ ទាំងនេះ គឺ

១-អាកាសានញ្ចាយតនៈ យកអាកាសដែលកសិណបើកហើយ មកជាអារម្មណ៍ (កសិណុគ្ឃាដិមាកាស) ។

២-វិញ្ញាណញ្ចាយតនៈ ស្រាវយកអរូបវិញ្ញាណទី ១ ដែលផ្សាយទៅ មិនមានទីបំផុតមកជាអារម្មណ៍ ។

៣-អាកិញ្ចញ្ញាយតនៈ កំណត់យកអរូបវិញ្ញាណទី ២ ដែលផ្សាយទៅ មិនមានអ្វីតិចតួចមកជាអារម្មណ៍ ។

៤-នេវសញ្ញានាសញ្ញាយតនៈ កំណត់យកសេចក្ដីល្អិតរបស់អរូបវិញ្ញាណទី ៣ ដែលមានស្មើរតែនឹងមិនមានមកជាអារម្មណ៍ ។

## សញ្ញា ១ គឺ

១-អាហារេបដិក្កូលសញ្ញា យោគាវចរពិចារណាអាហារដោយបដិកូល ឈ្មោះថា សញ្ញា ។

## ចតុធាតុវវដ្ឋាន ១ គឺ

*១-ចតុធាតុវវដ្ឋាន ដែលយោគាវចរពិចារណាកំណត់ ធាតុទាំង ៤ ក្នុងករជកាយ ឈ្មោះថា ចតុធាតុវវដ្ឋាន ដូច្នេះឯង ។*

## ៦_កម្មដ្ឋានដែលគួរដល់ចរិតរបស់កុលបុត្ត

*ក្នុងគម្ពីរសារត្ថទីបនីដីកា ភាគ២ ទំព័រ២៩២-២៩៥ ថា ៖*

*ក្នុងពាក្យថា កម្មដ្ឋានណា សមគួរដល់ចរិតរបស់កុលបុត្រ ណានេះ នីងវិនិច្ឆ័យដូចតទៅនេះ ៖*

រាគចរិតស្ស តាវ ទស អសុភា កាយគតាសតីតិ ឯកាទសកម្មដ្ឋានានិ អនុកូលានិ, *ជាដំបូងសម្រាប់បុគ្គលរាគចរិត កម្មដ្ឋានដែលសមគួរ ក៏មាន ១១ យ៉ាង គឺអសុភ ១០ កាយគតាសតិ ១ ;*

ទោសចរិតស្ស ចត្តារោ ព្រហ្មវិហារា ចត្តារិ វណ្ណកសិណានីតិអដ្ឋ, *សម្រាប់បុគ្គលទោសចរិត កម្មដ្ឋានដែលសមគួរ ក៏មាន ៨ យ៉ាង គឺព្រហ្មវិហារ ៤ វណ្ណកសិណ ៤ ;*

មោហចរិតស្ស ច វិតក្កចរិតស្ស ច ឯកំ អានាបានស្សតិកម្មដ្ឋានមេវ, *សម្រាប់បុគ្គលដែលជាមោហចរិត*

*និងវិតក្កចរិត កម្មដ្ឋានដែលសមគួរមាន ១ គឺ អានាបានស្សតិ-កម្មដ្ឋាន ;*

សទ្ធាចរិតស្ស បុរិមា ច អនុស្សតិយោ, *សម្រាប់បុគ្គលដែលជាសទ្ធាចរិត កម្មដ្ឋានដែលសមគួរគឺ អនុស្សតិ ៦ ខាងដើម ;*

ពុទ្ធិចរិតស្ស មរណស្សតិ ឧបសមានុស្សតិ ចតុធាតុវវត្ថានំ អាហារេ បដិក្កូលសញ្ញាតិ ចត្តារិ, *សម្រាប់បុគ្គលដែលជាពុទ្ធិចរិត កម្មដ្ឋានដែលសមគួរមាន ៤ យ៉ាង គឺ មរណានុស្សតិ ១ ឧបសមានុស្សតិ ១ ចតុធាតុវវត្ថាន ១ អាហារេបដិកូលសញ្ញា ១ ,*

សេសកសិណានិ ចត្តារោ ច អារុប្បា សព្វចរិតានំ អនុក្កូលានិ ។ *កសិណដ៏សេស និងអរូបទាំង ៤ សមគួរដល់បុគ្គលគ្រប់ចរិតទាំងអស់ ។*

កសិណេសុ ច យំ កិញ្ចិ បរិត្តំ វិតក្កចរិតស្ស, អប្បមាណំ មោហចរិតស្សអនុក្កូលន្តិ វេទិតព្វំ ។ *ចំណែកក្នុងបណ្តាកសិណទាំងឡាយ មណ្ឌលកសិណតូចយ៉ាងណាមួយគប្បីជ្រាបថា សមគួរដល់បុគ្គលវិតក្កចរិត, មណ្ឌលកសិណដែលមិនមានប្រមាណ គប្បីជ្រាបថា សមគួរដល់បុគ្គលដែលជាមោហ-ចរិត ។*

យថាវុត្តេនេវ នយេនាតិ "យោគានុយោគកម្មស្ស បទដ្ឋានត្តា"តិ ឥមមត្ថំ អតិទិស្សតិ ។ *ពាក្យថា តាមន័យដែលបានពោលទុកហើយនោះ លោកអាចារ្យសម្ដែងចំពោះសេចក្ដីនេះថា ព្រោះជាបទដ្ឋានរបស់កម្មដ្ឋាន គឺការប្រកបរឿយៗ នូវសេចក្ដីព្យាយាម ។*

*ក្នុងគម្ពីរសុត្តន្តបិដក ភាគ៦៦ ទំព័រ៣៩ ព្រះធម្មសេនា-បតីសារីបុត្ត ពោលអធិប្បាយថា ៖*

*ព្រះមានព្រះភាគ ទ្រង់ជ្រាបថា បុគ្គលនេះជារាគចរិត នេះជាទោសចរិត នេះជាមោហចរិត នេះជាវិតក្កចរិត នេះជាសទ្ធាចរិត នេះជាញាណចរិត ។*

រាគចរិតស្ស ភគវា បុគ្គលស្ស អសុភកថំ កថេតិ; *ព្រះមានព្រះភាគ ទ្រង់សម្ដែងអសុភកថា ចំពោះបុគ្គលជារាគចរិត;*

ទោសចរិតស្ស ភគវា បុគ្គលស្ស មេត្តាភាវនំ អាចិក្ខតិ ; *ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់មេត្តាភាវនា ចំពោះបុគ្គលជាទោសចរិត ។*

មោហចរិតំ ភគវា បុគ្គលំ ឧទ្ទេសេ បរិបុច្ឆាយ កាលេន ធម្មស្សវនេ កាលេន ធម្មសាកច្ឆាយ គរុសំវាសេ និវេសេតិ ; *ព្រះមានព្រះភាគ ទ្រង់ញុំាងបុគ្គលជាមោហចរិត ឲ្យតាំងនៅក្នុងឧទ្ទេស (ការរៀនបាលី) ក្នុងបរិបុច្ឆា (ការរៀន*

*អដ្ឋកថា) ក្នុងការស្ដាប់ធម៌តាមកាល ក្នុងការសាកសួរធម៌តាមកាល ក្នុងការនៅរួមជាមួយនឹងគ្រូ ។*

វិតក្កចរិតស្ស ភគវា បុគ្គលស្ស អានាបានស្សតឹ អាចិក្ខតិ *ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់អានាបានស្សតិ ចំពោះបុគ្គលជាវិតក្កចរិត ។*

សទ្ធាចរិតស្ស ភគវា បុគ្គលស្ស បសាទនីយំ និមិត្តំ អាចិក្ខតិ ពុទ្ធសុពោធឹ ធម្មសុធម្មតំ សង្ឃសុប្បដិបត្តឹ សីលានិ ច អត្តនោ ; *ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់និមិត្តគួរជ្រះថ្លា គឺការត្រាស់ដឹងប្រពៃនៃព្រះពុទ្ធ ការទ្រទ្រង់ល្អនៃធម៌ ការប្រតិបត្តិប្រពៃនៃព្រះសង្ឃ និងសីលទាំងឡាយសម្រាប់ខ្លួន ចំពោះបុគ្គលជាសទ្ធាចរិត ។*

ញាណចរិតស្ស ភគវា បុគ្គលស្ស វិបស្សនានិមិត្តំ អាចិក្ខតិ អនិច្ចាការំ ទុក្ខាការំ អនត្តាការំ ។

*ព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់នូវវិបស្សនានិមិត្ត គឺអាការមិនទៀង អាការជាទុក្ខ អាការមិនមែនខ្លួន ចំពោះបុគ្គលជាញាណចរិត ។*

# អដ្ឋកថា

បទថា រាគចរិតោ ជារាគចរិតជាដើម នេះដូច្នេះ ឈ្មោះថា **ជារាគចរិត** ព្រោះមានការប្រព្រឹត្តិ ក្នុងអារម្មណ៍ដោយសេចក្ដីតម្រេក ។ ឈ្មោះថា **ជាទោសចរិត** ព្រោះមានការប្រព្រឹត្តិក្នុងអារម្មណ៍ដោយសេចក្ដីប្រទូសរ៉ាយ ។ ឈ្មោះថា **ជាមោហចរិត** ព្រោះមានការប្រព្រឹត្តិដោយសេចក្ដីវង្វេង ។ ឈ្មោះថា **ជាវិតក្កចរិត** ព្រោះមានការប្រព្រឹត្តិក្នុងអារម្មណ៍ដោយការវិតក្កៈ ដោយសេចក្ដីត្រិះរិះ ។ ឈ្មោះថា **ជាសទ្ធាចិត្ត** ព្រោះមានការប្រព្រឹត្តក្នុងអារម្មណ៍ដោយសេចក្ដីជឿ ។ ឈ្មោះថា **ជាញាណចរិត** ព្រោះមានការប្រព្រឹត្តិជាសេចក្ដីដឹង ប្រព្រឹត្តដោយការដឹង ប្រព្រឹត្តដោយសេចក្ដីដឹង ឬប្រព្រឹត្តដើម្បីសេចក្ដីដឹង ។ បទថា រាគចរិតស្ស ដល់បុគ្គលដែលជារាគចរិត គឺរាគៈក្រាស់ ច្រើនដោយរាគៈ ។ សូម្បីបទដទៃក៏មានន័យនេះដូចគ្នា ។

បទថា អសុភកម្មំ កាថេតិ ត្រាស់អសុភកថា គឺទ្រង់ប្រាប់កថាបដិសំយុត្តដោយអសុភៈ ១០ យ៉ាង មានឧទ្ធុមាតកៈ (អសុភហើមពោរពងឡើង) ជាដើម ។ ដូចដែលព្រះមានព្រះភាគ ត្រាស់ទុកថា គួរចម្រើនអសុភៈ ដើម្បីលះរាគៈ ដូច្នេះ ។ បទថា មេត្តាភាវនំ អាចិក្ខតិ គឺត្រាស់ប្រាប់មេត្តាភាវនា គឺត្រាស់

មេត្តាភាវនាដែលជាសេចក្ដីស្រឡាញ់ក្នុងចិត្ត ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា គប្បីចម្រើនមេត្តា ដើម្បីលះព្យាបាទ ដូច្នេះ ។

បទថា ឧទ្ទេសេ ក្នុងការរៀន គឺក្នុងការរៀន ស្វាធ្យាយ ។ បទថា បរិបុច្ឆាយ ក្នុងការសាកសួរ គឺក្នុងអដ្ឋកថា ។

បទថា កាលេន ធម្មស្សវនេ ក្នុងការស្ដាប់ធម៌តាមកាល គឺក្នុងការស្ដាប់បរិយត្តិធម៌ឲ្យក្រៃលែងក្នុងវេលារៀន ។

បទថា ធម្មសាកច្ឆាយ ក្នុងការសន្ទនាធម៌ គឺក្នុងការសន្ទនាជាមួយនឹងអ្នកដទៃ ។

បទថា គរុសំវាសេ ក្នុងការនៅរួមនឹងគ្រូ គឺក្នុងការចូលជិតគ្រូ ។ បទថា និវេសេតិ ឲ្យនៅ គឺឲ្យតាំងនៅក្នុងសំណាក់របស់អាចារ្យ ។ បទថា អានាបានស្សតឹ អាចិក្ខតិ ប្រាប់អានាបានស្សតិ គឺប្រាប់កម្មដ្ឋានសម្បយុត្តដោយអានាបានស្សតិ (កំណត់ខ្យល់ដកដង្ហើមចូលចេញ) ដូចដែលព្រះមានព្រះភាគ ត្រាស់ទុកថា គប្បីចម្រើនអានាបានស្សតិ ដើម្បីកម្ចាត់វិតក្កៈ ។

បទថា ចាសាទនីយំ និមិត្តំ អាចិក្ខតិ ត្រាស់ប្រាប់ព្រះសូត្រដែលជានិមិត្តល្អ គឺត្រាស់ប្រាប់ព្រះសូត្រដែលឲ្យកើតសេចក្ដីជ្រះថ្លា មានចូឡវេទល្លសូត្រ និងមហាវេទល្លសូត្រជាដើម ។ បទថា ពុទ្ធសុពោធឹ ការត្រាស់ដឹងល្អនៃព្រះពុទ្ធ គឺការត្រាស់ដឹងភាវៈជាពុទ្ធរបស់ព្រះមានព្រះភាគ ។ បទថា ធម្មសុធម្មំ

ការទ្រទ្រង់ល្អនៃធម៌ គឺសេចក្ដីដែលលោកុត្តរធម៌ ៩ យ៉ាង ដែលព្រះមានព្រះភាគ ត្រាស់ទុកល្អហើយ ។ បទថា សុប្បដិបន្នោ ការបដិបត្តិល្អរបស់ព្រះសង្ឃ គឺការបដិបត្តិល្អ មានការបដិបត្តិប្រពៃរបស់ព្រះអរិយសង្ឃ ៨ ពួក ។

បទថា សីលានិ ច អត្តនោ សីលរបស់ខ្លួន គឺទ្រង់ប្រាប់សីលដែលជារបស់ខ្លួន ។ បទថា វិបស្សនានិមិត្តំ ធម៌ដែលជានិមិត្តនៃវិបស្សនា គឺទ្រង់ប្រាប់ធម៌ដែលបដិសំយុត្តដោយវិបស្សនាមានការកើតនិងសេចក្ដីរលត់ជាដើម ។

បទថា អនិច្ចាការំ មានអាការមិនទៀង គឺមានអាការមានហើយត្រឡប់ជាមិនមាន ។ បទថា ទុក្ខាការំ មានអាការជាទុក្ខ គឺមានអាការបៀតបៀន គឺការកើត និងសេចក្ដីរលត់ ។ បទថា អនត្តាការំ មានអាការមិនប្រព្រឹត្តទៅក្នុងអំណាច ។

(ចាកសទ្ធម្មបជ្ជោតិកា អដ្ឋកថា. ៦៦ / ៣៨៦)

# ៧-គួររៀនកម្មដ្ឋានក្នុងសំណាក់ពុទ្ធឱរស ឬអ្នកបានឈាន

មួយទៀត កុលបុត្រអ្នកមានសីលបរិសុទ្ធ និងកាត់បលិ-ពោធបានហើយយ៉ាងនោះ កាលនឹងរៀនកម្មដ្ឋាននេះ គួររៀនក្នុងសំណាក់ពុទ្ធបុត្រ អ្នកឲ្យចតុត្ថជ្ឈានកើតឡើងដោយកម្មដ្ឋាននេះឯង ហើយចម្រើនវិបស្សនា បានសម្រេចភាពជាព្រះអរហន្ត ។ កាលមិនបានព្រះខីណាស្រពនោះ គួររៀនក្នុងសំណាក់ព្រះអនាគាមី កាលមិនបានសួម្បីព្រះអនាគាមីនោះ ក៏គួររៀនក្នុងសំណាក់ព្រះសកទាគាមី ។ កាលមិនបានសូម្បីព្រះសកទាគាមីនោះ ក៏គួររៀនក្នុងសំណាក់ព្រះសោតាបន្ន, កាលមិនបានសូម្បីព្រះសោតាបន្ននោះ ក៏គួររៀនក្នុងសំណាក់របស់លោកអ្នកបានចតុត្ថជ្ឈាន ដែលមានអានាបានៈជាអារម្មណ៍, កាលមិនបានលោកអ្នកបានចតុត្ថជ្ឈានសូម្បីនោះ ក៏គួររៀនក្នុងសំណាក់របស់ព្រះវិនិច្ឆយាចារ្យ អ្នកមិនវង្វេងទាំងក្នុងបាលីនិងអដ្ឋកថា ។ មែនពិត ព្រះអរិយបុគ្គលទាំងឡាយ មានព្រះអរហន្តជាដើម រមែងប្រាប់ចំពោះមគ្គដែលខ្លួនបានសម្រេចហើយប៉ុណ្ណោះ ។ ចំណែកព្រះវិនិច្ឆយាចារ្យនេះ ជាអ្នកមិនវង្វេង កំណត់អារម្មណ៍ជាទីសប្បាយ និងមិនសប្បាយ ក្នុងអារម្មណ៍ទាំងពួងហើយទើបប្រាប់ឲ្យ ដូចជាអ្នកនាំទៅកាន់ផ្លូវដ៏រីធំក្នុងព្រៃស្បាតដូច្នោះ ។ (ចាកអដ្ឋកថា សមន្តប្បាសាទិកា)

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា</u> ៖

កុលបុត្រអ្នកប្រាថ្នានឹងរៀនកម្មដ្ឋានណា គប្បីរៀនកម្មដ្ឋានក្នុងសំណាក់ព្រះខីណាស្រព អ្នកញុំាងឈានពួក ៤ ឬបានឈានពួក ៥ ឲ្យកើតឡើង ដោយអំណាចកម្មដ្ឋាននោះនុ៎ះឯងហើយ ចម្រើនវិបស្សនា មានឈានជាបទដ្ឋាន សម្រេចការអស់ទៅនៃអាសវៈ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា គប្បីរៀនយកអំពីសំណាក់ពុទ្ធបុត្ត អ្នកញុំាងចតុត្ថជ្ឈានឲ្យកើតឡើងហើយ ដោយកម្មដ្ឋាននេះឯង ហើយចម្រើនវិបស្សនា បានសម្រេចអរហត្តផល ។ ពាក្យថា **ព្រះអរិយបុគ្គលទាំងឡាយ មានព្រះ-អរហន្តជាដើម** លោកអាចារ្យផ្ដើមទុកដើម្បីនឹងសម្ដែងថា លោកជាពហុស្សូតនេះឯង អាចល្អជាងព្រះខីណាស្រពខ្លះ ក្នុងការឲ្យកម្មដ្ឋាននេះ ។ ពាក្យថា **ដូចអ្នកនាំទៅកាន់ផ្លូវដ៏វិធំ** សេចក្ដីថា ប្រៀបដូចសម្ដែងវិធីនៃកម្មដ្ឋាន និងធ្វើឲ្យដូចជាផ្លូវដ៏វិធំ ។ ពាក្យថា **កំណត់អារម្មណ៍ជាទីសប្បាយ និងមិនសប្បាយ** សេចក្ដីថា លោកអាចារ្យរមែងប្រាប់កម្មដ្ឋានដល់កុលបុត្រណា ក៏កំណត់សេចក្ដីសមគួរដែលជាឧបការៈ និងមិនជាឧបការៈដល់កុលបុត្រនោះដោយប្រការទាំងពួង ។

ឥឡូវនេះ លោកអាចារ្យសម្ដែងបំព្រួមសេចក្ដីនេះថា កុលបុត្រចូលទៅកាន់សំណាក់អាចារ្យអ្នកឲ្យកម្មដ្ឋាន មិនគប្បីពាក់ស្បែក-ជើង ដោយជើងដែលលាង និងលាបប្រេង បាំងឆត្រ ប្រើអ្នក

កាន់គ្រឿងប្រើប្រាស់ និងភេសជ្ជៈ មានធុងប្រេង និងទឹកឃ្មុំ ទឹកអំពៅជាដើម មានអន្តេវាសិកហែហមជុំវិញដើរទៅ ។ តែគប្បីបំពេញគមិកវត្តហើយ ហើយកាន់បាត្រ និងចីវររបស់ខ្លួន ដោយខ្លួនឯង ចូលទៅកាន់វត្តណាៗ ក្នុងចន្លោះផ្លូវក្នុងទីគ្រប់កន្លែង ក៏បំពេញវត្តនោះៗ តាមសមគួរ គឺអាគន្តុកវត្តក្នុងវេលាចូលទៅកាន់វត្ត គមិកវត្តក្នុងវេលាចេញអំពីវត្ត គប្បីជាអ្នកមានបរិក្ខារស្រាលព្រម មានការប្រព្រឹត្តិដុសខាត់យ៉ាងក្រៃលែង ទើបពោលថា ជាអ្នកមានការប្រព្រឹត្តស្រាល ដល់ព្រមដោយវិន័យនិងអាចារៈ ។ ក៏កាលទៅយ៉ាងនេះហើយ កាលចូលទៅកាន់វត្តនោះ គប្បីឲ្យធ្វើឈើស្ទន់ឲ្យជាកប្បិយៈ ក្នុងចន្លោះនោះ គឺយកទៅហើយ ទើបចូលទៅ តែមិនគប្បីឈប់សម្រាកបន្តិច ហើយដើរទៅកាន់បរិវេណដទៃ ដោយគិតថា យើងនឹងធ្វើការលាងជើង លាបជើងជាដើម ទៅកាន់សំណាក់អាចារ្យ ។

ព្រោះហេតុអ្វី ?

ព្រោះបើក្នុងទីនោះ គប្បីមានភិក្ខុទាំងឡាយជាវិសភាគរបស់អាចារ្យនោះ ភិក្ខុទាំងនោះសួរដល់ហេតុដែលមកនៅហើយ ពោលទោសរបស់អាចារ្យ ហើយពោលថា វិនាសហើយលោក បើលោកមកនៅសំណាក់អាចារ្យនោះ នឹងគប្បីញ៉ាំងវិប្បដិសារៈ ឲ្យកើតឡើង ដែលជាហេតុឲ្យលោកគប្បីវិលត្រឡប់ចេញទៅអំពីទីនោះ

វិញបាន ព្រោះហេតុនោះ គប្បីសួររកទីនៅរបស់លោកអាចារ្យ ហើយត្រូវចូលទៅក្នុងទីនោះឯង ។

ពាក្យថា **អាចារ្យដែលមានប្រការដូចពោលហើយ** បានដល់អាចារ្យជាកល្យាណមិត្ត តាំងនៅក្នុងសេចក្តីចម្រើន ស្វែងរកតែប្រយោជន៍ (តាំងនៅ) ដោយចំណែកមួយ ប្រកបដោយគុណ មានសទ្ធាជាដើម មានប្រការដូចដែលបានពោលទុកហើយ ដោយន័យមានជាដើមយ៉ាងនេះថា ៖

បិយោ គរុ ភាវនីយោ វត្តា ច វចនក្ខមោ
គម្ភីរញ្ច កថំ កត្តា នោ ចដ្ឋានេ និយោជយេ

ភិក្ខុជាអ្នក (ធ្វើខ្លួន) ឲ្យជាទីស្រឡាញ់ ១ គួរគោរព ១ គួរសរសើរ ១ ឧស្សាហ៍ប្រៀនប្រដៅ ១ អត់ធន់ចំពោះពាក្យសំដី ១ ជាអ្នកនិយាយពាក្យជ្រាលជ្រៅ ១ ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរ ១ ។

ក្នុងពាក្យថា **អ្នកមានចិត្តដែលខ្លួនឲ្យត្រេកអរហើយ ដោយវត្តបដិបត្តិនេះ** មានវិនិច្ឆ័យដូច្នេះ បើអាចារ្យជាភិក្ខុខ្ចីជាង កុំគប្បីត្រេកអរសោមីចិកម្ម មានការទទួលបាត្រនិងចីវរជាដើម, បើអាចារ្យជាភិក្ខុចាស់ជាង គប្បីទៅថ្វាយបង្គំអាចារ្យ ។ កាលលោកប្រាប់ថា ចូរដាក់បាត្រនិងចីវរចុះអាវុសោ ទើបដាក់ចុះ កាលលោកប្រាប់ថា ចូរផឹកទឹកចុះ បើប្រាថ្នាគប្បីផឹក កាលលោកពោលថា ចូរលាងជើងចុះ មិនគួរលាងជើងភ្លាមទេ ព្រោះបើទឹកដែលលោកនាំ (ជង)

មក ក៏គប្បីជាការមិនសមគួរ, តែបើលោកពោលថា លាងជើងចុះអាវុសោ ខ្ញុំមិនបាននាំមកទេ (អ្នកដទៃនាំមក) ក៏គួរអង្គុយលាងជើងបាន ក្នុងឱកាសទីកំបាំង ដែលអាចារ្យមិនឃើញ ឬក្នុងទីចំណែកម្ខាងសូម្បីនៃវិហារកណ្តាលវាល ។ បើអាចារ្យនាំកែវប្រេងមកឲ្យ គប្បីក្រោកឡើង ប្រើដៃទាំងពីរទទួលដោយគោរព, ព្រោះបើមិនទទួលកែវប្រេងនោះទេ អាចារ្យក៏នឹងគប្បីគិតបការដទៃបានថា ភិក្ខុរូបនេះធ្វើការប្រើប្រាស់រួមគ្នាមិនល្អចាប់ដើមតាំងពីនេះឯង, តែកាលបានទទួលហើយក៏មិនគួរលាបជើងមុនទេ ព្រោះបើប្រេងនោះ ជាទឹកប្រេងសម្រាប់រីតខ្លួនរបស់អាចារ្យសោត ក៏នឹងគប្បីជាការមិនសមគួរ, ព្រោះដូច្នោះគប្បីលាបក្បាលមុនហើយទើបលាបអវយវៈដទៃ មានកជាដើម កាលលោកប្រាប់ថា អាវុសោប្រេងនោះនេះជាប្រេងសម្រាប់ប្រើបានគ្រប់យ៉ាង លាបជើងក៏បានដូច្នេះ ចាំលាបជើង រួចស្រេចហើយគប្បីប្រាប់ថា "ខ្ញុំនឹងរក្សាប្រេងនេះ លោកម្ចាស់" កាលអាចារ្យទទួលយកទៅគប្បីប្រគេនលោកចុះ ។

មិនគួរនិយាយថា លោកម្ចាស់មេត្តាប្រាប់កម្មដ្ឋានដល់ខ្ញុំចុះតាំងពីថ្ងៃនេះទៅ ។ រាប់ចាប់តាំងពីថ្ងៃទី ២ ទៅ បើអាចារ្យមានឧបដ្ឋាកជាប្រចាំ ក៏គប្បីសូមនឹងឧបដ្ឋាកនោះហើយធ្វើវត្តខ្លះ ។ បើសូមហើយលោកមិនព្រមឲ្យ កាលបានឱកាសទើបចាំធ្វើវត្ត កាលនឹងធ្វើក៏គួរបង្អោនប្រគេនឈើស្ទន់ទាំង ៣ ខ្នាត គឺខ្នាតតូច កណ្តាល

និងធំ ។ ទឹកលុបមុខ ទឹកស្រង់ ក៏គួរចាត់ចែងប្រគេនទាំងពីរយ៉ាង គឺទឹកក្តៅនិងទឹកត្រជាក់ ។ តាំងពីពេលនោះតទៅ លោកអាចារ្យប្រើយ៉ាងណារហូត ៣ ថ្ងៃ ក៏ត្រូវចូលទៅតម្កល់ប្រគេនយ៉ាងនោះឯង រហូតអស់កាលជានិច្ច ។ កាលលោកមិនធ្វើការចំពោះយ៉ាងណា ប្រើប្រាស់តាមតែបាន ក៏គប្បីបង្អោនប្រគេនតាមដែលរកបានចុះ ។ នឹងពោលឲ្យច្រើនទៅធ្វើអ្វី វត្តដ៏ប្រពៃដែលព្រះមានព្រះភាគទ្រង់បញ្ញត្តទុកក្នុងវត្តក្ខន្ធកៈនោះណា មានជាដើមថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអន្តេវាសិក ត្រូវប្រព្រឹត្តដោយប្រពៃក្នុងអាចារ្យ ។ ឯការប្រព្រឹត្តិដោយប្រពៃក្នុងអាចារ្យនោះ ដូច្នេះ គឺអន្តេវាសិកត្រូវក្រោកអំពីព្រឹក ហើយដោះស្បែកជើង ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ហើយប្រគេនឈើស្ទន់ ប្រគេនទឹកសម្រាប់លាងមុខក្រាលអាសនៈទុក បើបបរមាន អន្តេវាសិកត្រូវលាងភាជន៍ ហើយបង្អោនបបរទៅប្រគេន កាលបើអាចារ្យហុតបបររួចហើយ អន្តេ-វាសិកត្រូវប្រគេនទឹក ត្រូវធ្វើវត្តទាំងនោះចុះ ។ គប្បីឃើញថា កុលបុត្រ អ្នកបដិបត្តិដោយន័យតាមដែលពោលមកនេះ រមែងញុំាងចិត្តរបស់លោកអាចារ្យឲ្យត្រេកអរដោយវត្តបដិបត្តិ ។

(ចាកគម្ពីរសារត្ថទីបនីដីកា)

## ៨.កម្មដ្ឋាន ៧ យ៉ាង

*កម្មដ្ឋានទាំងអស់មាន ៤០ ដូចបានពោលមកហើយ តែក្នុងទីនេះ សូមលើកយកកម្មដ្ឋាន ៧ មកសម្ដែងអធិប្បាយតទៅ :*

### ៨.១ ពុទ្ធានុស្សតិ

សទ្ធាចរិតស្ស បុរិមា ឆ អនុស្សតិយោ : *សម្រាប់បុគ្គលដែលជាសទ្ធាចរិត កម្មដ្ឋានដែលសមគួរគឺ អនុស្សតិ ៦ ខាងដើម (ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ) ;*

*កាលបើព្រះយោគាវចរកុលបុត្រ អ្នកប្រកបដោយសេចក្ដីជ្រះថ្លា មានប្រាថ្នាដើម្បីចម្រើននូវពុទ្ធានុស្សតិ ជាលំដាប់ដំបូង គប្បីចូលទៅកាន់ទីដែលស្ងាត់កំបាំង សម្ងំនៅក្នុងសេនាសនៈសមគួរហើយ រលឹកដល់ព្រះគុណរបស់ព្រះមានព្រះភាគ យ៉ាងនេះថា* ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

*តទៅនេះជាន័យក្នុងការរលឹកក្នុងពុទ្ធគុណទាំងនោះ ។ (គឺ) រលឹក (ប្រកប* ***ឥតិបិ*** *ទុកគ្រប់បទ) ថា*

សោ ភគវា ឥតិបិ អរហំ *(សូម្បីព្រោះហេតុយ៉ាងនេះ*

*ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្ត),*

សោ ភគវា ឥតិបិ សម្មាសម្ពុទ្ធោ *(សូម្បីព្រោះហេតុយ៉ាងនេះ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គត្រាស់ដឹងនូវញេយ្យ-ធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ)* ។បេ។

សោ ភគវា ឥតិបិ ភគវា *(សូម្បីព្រោះហេតុយ៉ាងនេះ ព្រះមានព្រះភាគអង្គនោះ ជាព្រះភគវា)* ។

*(ពាក្យថា **ឥតិបិ** នោះ) មានអធិប្បាយថា "ព្រោះហេតុនេះៗ" ។*

*បណ្ឌិតរមែងរលឹកថា ក្នុងបទទាំងនោះ ព្រះមានព្រះភាគអង្គនោះ បានព្រះនាមថា **អរហំ** ព្រោះហេតុ (៥ ន័យ) នេះមុន គឺ **អារកត្តា** ព្រោះភាពជាអារកៈ (អ្នកឆ្ងាយ) ១ **អរីនំ អរានញ្ច ហតត្តា** ព្រោះភាពដែលទ្រង់កំចាត់អរិ (សត្រូវ) ទាំងឡាយចេញបាន ១ និងព្រោះទ្រង់ទំលាយអរៈ (កាំ)ទាំងឡាយចេញបាន ១ **បច្ចយាទីនំ អរហត្តា** ព្រោះភាពជាអរហៈ (អ្នកគួរទទួល) ទក្ខិណាវត្ថុទាំងឡាយមានបច្ច័យជាដើម ១ **បាបករណេ រហាភាវា** ព្រោះភាពមិនមានរហៈ (ទីកំបាំង) ក្នុងការធ្វើបាប ១ ។ល។*

អារកត្តា ហតត្តា ច កិលេសារីន សោ មុនិ
ហតសំសារចក្ការោ បច្ចយាទីន ចារហោ
ន រហោ ករោតិ បាបានិ អរហំ តេន វុច្ចតីតិ ។

ព្រះមានព្រះភាគអង្គនោះ ព្រះនាមថា **អរហំ** ព្រោះភាពដែលទ្រង់ឆ្ងាយចាកកិលេស ១ ព្រោះភាពដែលទ្រង់កំចាត់ អរិ គឺកិលេសទាំងឡាយចេញ ១ ព្រះអង្គជាអ្នកទំលាយនូវកាំនៃសង្សារចក្ក ១ ជាអ្នកគួរដល់ទក្ខិណាវត្ថុទាំងឡាយមានបច្ច័យ ជាដើម ១ ទ្រង់មិនធ្វើបាបទាំងឡាយក្នុងទីកំបាំង ១ ព្រោះហេតុនោះ ទើបព្រះនាមថា **អរហំ** ដោយប្រការទាំងពួង ដូចពណ៌នាមកដូច្នេះឯង ។

## ពុទ្ធានុស្សតិ

កាលបើព្រះយោគាវចរនោះ រលឹកដល់ព្រះពុទ្ធគុណថា "ព្រោះហេតុនេះៗ" ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្ត ។ល។ ព្រោះហេតុនេះៗ ព្រះមានព្រះភាគអង្គនោះ ជាព្រះភគវា ដូច្នេះនេះ ក្នុងសម័យនោះ ចិត្តរបស់លោក រមែងមិនជាចិត្តដែលរាគៈចាំស្ទាក់ មិនជាចិត្តដែលទោសៈចាំស្ទាក់ មិនជាចិត្តដែលមោហៈចាំស្ទាក់ឡើយនោះឯង ។ ក្នុងសម័យនោះ ចិត្តរបស់លោករមែងជាចិត្តប្រព្រឹត្តទៅត្រង់ ប្រារព្ធ (គុណ) ព្រះតថាគតជាម្ចាស់ កាលលោកគ្របសង្កត់នីវរណៈបាន ដោយមិនមានបរិយុដ្ឋានកិលេស មានរាគៈជាដើមយ៉ាងនោះ ឈ្មោះថា មានចិត្តប្រព្រឹត្តទៅត្រង់ ព្រោះភាពដែលមានចិត្តប្រាថ្នាចំពោះព្រះកម្មដ្ឋាន ដូច្នេះ វិតក្កៈនិងវិចារៈ ដែលបង្អោនទៅក្នុងពុទ្ធគុណ រមែងប្រព្រឹត្តទៅ ។ កាលទឹកកាលត្រិះរិះ ព្រះពុទ្ធគុណ

រឿយៗទៅ បីតិរមែងកើតឡើង ។ សេចក្ដីខ្វល់ខ្វាយចិត្តរបស់លោក ដែលមានចិត្តប្រកបដោយបីតិរមែងស្ងប់ ដោយបស្សទ្ធិដែលមានចិត្ត ជាបទដ្ឋាន ។ សុខទាំងផ្លូវកាយ ទាំងផ្លូវចិត្ត រមែងកើតដល់លោក ដែលមានសេចក្ដីខ្វល់ខ្វាយស្ងប់ហើយ, ចិត្តរបស់លោកមានសុខ ជាចិត្តមានពុទ្ធគុណជាអារម្មណ៍ រមែងជាសមាធិ អង្គឈានរមែង កើតឡើងដោយលំដាប់ក្នុងមួយខណៈ ដូចពោលមកដូច្នេះ ។ តែ ព្រោះសេចក្ដីដែលពុទ្ធគុណទាំងឡាយ ជាអាម្មណ៍ដែលជ្រាលជ្រៅ ឬព្រោះភាពដែលចិត្តបង្អោនទៅ ក្នុងការរលឹកដល់ពុទ្ធគុណមាន ប្រការផ្សេងៗ ឈាននេះទើបជាឈានដែលមិនដល់អប្បនា ដល់ ត្រឹមឧបចារៈប៉ុណ្ណោះ (ទិង) ឈាននេះនោះ ក៏ដល់នូវការរាប់ថា ពុទ្ធានុស្សតិនោះឯង ព្រោះជាឈានដែលកើតឡើង ដោយអំណាច ការរលឹកដល់ពុទ្ធគុណ ។

## អានិសង្សការចម្រើនពុទ្ធគុណ

ក៏ឯភិក្ខុដែលប្រកបរឿយៗ នូវពុទ្ធានុស្សតិនេះ រមែងជាអ្នកមាន សេចក្ដីគោរព មានសេចក្ដីកោតក្រែងក្នុងព្រះសាស្ដា បានសេចក្ដី បរិបូរណ៍នៃសទ្ធា សេចក្ដីបរិបូរណ៍នៃសតិ សេចក្ដីបរិបូរណ៍នៃបញ្ញា និងបានសេចក្ដីបរិបូរណ៍នៃបុណ្យ ជាអ្នកច្រើនដោយបីតិ និង បាមោជ្ជៈ អត់ធន់ចំពោះសេចក្ដីខ្លាច និងសេចក្ដីតក់ស្លុតចិត្ត អាច ដោះទុក្ខ, មានការដឹង (ដូច) ថាបាននៅជាមួយព្រះសាស្ដា ។

ម្យ៉ាងទៀត សូម្បីសរីរៈរបស់លោកដែលពុទ្ធគុណានុស្សតិប៉ះផ្ទប់ រមែងល្អគួរដល់ការបូជាដូចផ្ទះព្រះចេតិយ ។ ចិត្ត (របស់លោក) រមែងបង្អោនទៅក្នុងពុទ្ធភូមិ ។ ម្យ៉ាងទៀត ក្នុងកាលមានការជួបជួនជាមួយនឹងវត្ថុដែលនឹងគប្បីប្រព្រឹត្តកន្លង ហិរិឱត្តប្បៈរមែងប្រាកដដល់លោក ហាក់បីដូចជាលោកឃើញព្រះសាស្តានៅចំពោះមុខ ។ ម្យ៉ាងទៀត កាលនៅមិនទាន់សម្រេចគុណដ៏ក្រៃលែងឡើងទៅ លោករមែងមានសុគតិ ជាទីប្រព្រឹត្តទៅក្នុងខាងមុខ ។

តស្មា ហវេ អប្បមាទំ កយិរាថ សុមេធសោ
ឯវំ មហានុភាវាយ ពុទ្ធានុស្សតិយា សទាតិ ។

ព្រោះហេតុនោះឯង អ្នកមានបញ្ញាល្អ គប្បីធ្វើសេចក្ដីមិនប្រមាទ ក្នុងពុទ្ធានុស្សតិ ដែលមានអានុភាពច្រើនយ៉ាងនេះគ្រប់កាលហោង ។

នេះជាសេចក្ដីសង្ខេប ក្នុងពុទ្ធានុស្សតិ ចំណែកសេចក្ដីពិស្តារ អ្នកសិក្សាគប្បីមើលក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ក្នុងធម្មានុស្សតិជាដើមក៏ដូចគ្នា ខ្ញុំមិនបានពោលទុកក្នុងទីនេះទេ ។

## ៨.២ មេត្តាព្រហ្មវិហារ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវមេត្តាព្រហ្មវិហារ គប្បីចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ អង្គុយនៅឲ្យស្រួល ពិចារណានូវទោសក្នុងសេចក្តីប្រទុស្ត (ទោស) និងអានិសង្សក្នុងសេចក្តីអំណត់ ( ខន្តី ) ជាមុន ។

ទោសក្នុងសេចក្តីប្រទុស្តដូចម្តេចខ្លះ ? អានិសង្សក្នុងសេចក្តីអំណត់ ដូចម្តេចខ្លះ ? ហេតុអ្វីទើបត្រូវពិចារណាជាមុន ?

ទោសក្នុងសេចក្តីប្រទុស្តនោះលោកពោលទុកថា "បើបុគ្គលណាដែលទោសគ្របសង្កត់ហើយ បុគ្គលនោះអាចហ៊ានសម្លាប់សត្វជាដើមបាន" ឯអានិសង្សក្នុងសេចក្តីអំណត់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដូច្នេះជាដើមថា "ខន្តី គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម" បានជាត្រូវពិចារណាជាមុន ព្រោះថាកម្មដ្ឋាននេះព្រះយោគីត្រូវចម្រើនដើម្បីនឹងលះបង់នូវទោសៈ ហើយនឹងបាននូវខន្តីប៉ុណ្ណោះ បើមិនបានពិចារណាឲ្យឃើញជាមុនហើយ ក៏មិនអាចដើម្បីនឹងលះបង់នូវទោសដែលមិនឃើញ ហើយបាននូវអានិសង្សដែលមិនដឹងនោះឡើយ ។

កាលដែលព្រះយោគីប្រារព្ធនឹងចម្រើនមុនដំបូង កុំអាលចម្រើនក្នុងបុគ្គលដែលជាទោស ៤ ពួកគឺ បុគ្គលដែលមិនជាទីស្រឡាញ់ ១

សម្លាញ់ដែលជាទីស្រឡាញ់ក្រៃពេក ១ បុគ្គលដែលជាកណ្តាល ១ បុគ្គលដែលមានពៀរដល់គ្នា ១ មិនតែប៉ុណ្ណោះសោត សូម្បីបុគ្គលដែលមិនមែនជាខេត្ត ២ ពួកគឺ បុគ្គលដែលមានភេទខុសគ្នា ១ បុគ្គលដែលធ្វើមរណកាលកន្លងហើយ ១ ក៏មិនគប្បីចម្រើនមេត្តា-ព្រហ្មវិហារទៅរកជាដំបូងឡើយ ។

បុគ្គលទាំងនោះ មានទោសដល់មេត្តាព្រហ្មវិហារដូចម្តេច ទើបលោកហាមមិនឲ្យចម្រើនជាដំបូង ?

បុគ្គលទាំងនោះមានទោសដូច្នេះគឺ បុគ្គលដែលមិនជាទីស្រឡាញ់លំបាកនឹងទាញមកតម្កល់ទុកឲ្យជាទីស្រឡាញ់, សម្លាញ់ដែលជាទីស្រឡាញ់ក្រៃពេក លំបាកនឹងទាញមកតម្កល់ទុកឲ្យជាកណ្តាល បុគ្គលដែលជាកណ្តាល លំបាកនឹងទាញមកតម្កល់ទុកឲ្យជាទីគោរព និងជាទីស្រឡាញ់ បុគ្គលដែលមានពៀរដល់គ្នា បើចម្រើនមេត្តាព្រហ្មវិហារទៅរកនឹងកើតសេចក្តីក្រោធ បុគ្គលដែលមានភេទខុសគ្នានឹងកើតសេចក្តីតម្រេក បុគ្គលដែលធ្វើមរណកាលកន្លងទៅហើយនឹងមិនដល់នូវអប្បនានិងឧបចារៈ ហេតុនោះ ទើបលោកហាមមិនឲ្យចម្រើនមេត្តាទៅរកជាដំបូង ។

បើដូច្នោះត្រូវឲ្យចម្រើនចំពោះបុគ្គលដូចម្តេចជាមុន ?

ត្រូវឲ្យបម្រើនចំពោះខ្លួនព្រះយោគីជាមុន គឺត្រូវបម្រើនឲ្យរឿយៗថា "**អហំ សុខិតោ ហោមិ និទ្ទុក្ខោ** សូមឲ្យអញបានដល់នូវសេចក្ដីសុខ កុំមានទុក្ខឡើយ" ឬនឹងបម្រើនថា "**អវេរោ អព្យាបជ្ជោ អនីឃោ សុខី អត្តានំ បរិហរាមិ** សូមឲ្យអញជាបុគ្គលគ្មានពៀរ គ្មានទុក្ខ គ្មានទោស ឲ្យមានតែសេចក្ដីសុខ សូមរក្សាខ្លួនឲ្យបានយ៉ាងនេះជាដរាបទៅ" ដូច្នេះក៏បាន ។

បើព្រះយោគី ចម្រើននូវមេត្តាព្រហ្មវិហារចំពោះខ្លួនយ៉ាងនេះជារឿយៗហើយ អប្បនាចិត្តនៅមិនទាន់កើតឡើង ក៏គប្បីតម្កល់ទុកនូវខ្លួនឲ្យជាបន្ទាល់ ហើយទាញយកសត្វទាំងឡាយដទៃមកប្រៀបថា "អញប្រាថ្នានូវសេចក្ដីសុខ ខ្ពើមរអើមទុក្ខ ប្រាថ្នាចង់រស់ មិនចង់ស្លាប់យ៉ាងណា សត្វទាំងឡាយដទៃ ក៏ប្រាថ្នានូវសេចក្ដីសុខ ខ្ពើមរអើមទុក្ខ ប្រាថ្នាចង់រស់ មិនចង់ស្លាប់យ៉ាងនេះដែរ" រួចហើយត្រូវចម្រើនមេត្តាចំពោះបុគ្គលដែលគួរគោរព មានអាចារ្យ និងឧបជ្ឈាយ៍ជាដើមឲ្យរឿយៗថា "**ឯស សប្បុរិសោ សុខិតោ ហោតុ និទ្ទុក្ខោ** សូមឲ្យលោកជាសប្បុរសនុ៎ះ បានដល់នូវសេចក្ដីសុខ កុំបីមានទុក្ខឡើយ" ។

ដោយអំណាចដែលព្រះយោគី ចម្រើននូវមេត្តាព្រហ្មវិហារ ចំពោះបុគ្គលមានសភាពយ៉ាងនេះ អប្បនាចិត្តក៏នឹងកើតឡើងដោយពិត តែបើនៅមិនទាន់ដល់នូវសេចក្ដីត្រេកអរដោយព្យាយាមប៉ុណ្ណោះ គប្បីចម្រើនចំពោះបុគ្គលជាទីស្រឡាញ់ បុគ្គលដែលជាកណ្ដាល បុគ្គលដែលមានពៀរដល់គ្នាតទៅទៀត ចម្រើនក្នុងកោដ្ឋាសនីមួយៗ ធ្វើចិត្តឲ្យគួរដល់កម្ម ទាញយកបុគ្គលដែលជាទីស្រលាញ់មកដាក់ត្រង់កន្លែងបុគ្គលដែលជាកណ្ដាលៗ មកដាក់ត្រង់កន្លែងបុគ្គលដែលមានពៀរដល់គ្នាតទៅទៀត ចម្រើនក្នុងកោដ្ឋាសនីមួយៗ ធ្វើចិត្តឲ្យគួរដល់កម្ម ទាញយកបុគ្គលដែលជាទីស្រលាញ់ មកដាក់ត្រង់កន្លែងបុគ្គលដែលជាកណ្ដាលៗ មកដាក់ត្រង់កន្លែងបុគ្គលដែលមានពៀរដល់គ្នា បន្ទោបង់នូវបដិឃក្នុងបុគ្គលដែលមានពៀរដល់គ្នា លំដាប់មកទៀត គប្បីចម្រើនឲ្យរឿយៗ ញុំាងចិត្តឲ្យប្រព្រឹត្តទៅស្មើ ជាសីមសម្ភេទ[១] ក្នុងជនទាំង ៤ ពួកគឺ ខ្លួនព្រះយោគី ១ បុគ្គលដែលជាទីស្រលាញ់ ១ បុគ្គលដែលជាកណ្ដាល ១ បុគ្គលដែលមានពៀរ

---

១- **សីមា** (ដែន) ក្នុងទីនេះមាន ៤ គឺ បុគ្គលដែលជាទីស្រឡាញ់ដែន ១ បុគ្គលដែលជាកណ្ដាលដែន ១ បុគ្គលដែលមានពៀរដែន ១ ខ្លួនព្រះយោគីដែន ១ ត្រង់ដែលផ្សាយមេត្តាចិត្តទៅស្មើក្នុងដែនទាំង ៤ ហៅថា "សីមសម្ភេទ" ។

ដល់គ្នា ១ មិនឲ្យមានធ្ងន់មានស្រាលជាងគ្នា សីមសម្ភេទនេះហើយ ដែលលោកហៅថានិមិត្តក្នុងកម្មដ្ឋាននេះ ព្រោះថា ក្នុងព្រហ្មវិហារ ទាំង ៤ មិនមានឧគ្គហនិមិត្ត និងបដិភាគនិមិត្តដូចក្នុងកសិណទាំង ១០ ជាដើមឡើយ មានតែសមថនិមិត្ត ដែលប្រព្រឹត្តទៅដោយ អំណាចនៃសីមសម្ភេទប៉ុណ្ណោះ ។

បើព្រះយោគីសេពនូវនិមិត្តនោះដោយច្រើន ចម្រើនឲ្យរឿយៗ ឡើងទៅ ក៏នឹងបានដល់នូវអប្បនាឈានដោយងាយមិនមានលំបាក ឡើយ តែក្នុងកម្មដ្ឋាននេះ ឲ្យសម្រេចបានតែត្រឹមតតិយជ្ឈានក្នុង ចតុក្កន័យ ឬចតុត្ថជ្ឈានក្នុងបញ្ចកន័យប៉ុណ្ណោះ តែបើព្រះយោគី ផ្សាយមេត្តាព្រហ្មវិហារ ដោយអំណាចនៃឈាននីមួយៗ ចំពោះសត្វ ដែលនៅក្នុងទិស ១ ទិស ២ ដរាបដល់គ្រប់ទិសទាំង ១០ ជាអនោ- ធិសោផរណា[១] ដោយអាការ ៥[២] ជាឱធិសោផរណា[៣] ដោយ អាការ ៧[៤] ជាទិសាផរណាដោយអាការ ១០[៥] ក៏នឹងបាននូវ

---

(១) ផ្សាយមេត្តាព្រហ្មវិហារមិនមានចំពោះសត្វថា "សត្វទាំងអស់ ប្រាណទាំងអស់ ភូតទាំងអស់ បុគ្គលទាំងអស់ ដែលរាប់ថាមានអត្តភាពទាំងអស់ ចូរកុំឱ្យមានពៀរ កុំឱ្យមានទុក្ខ កុំឱ្យមានទោស ចូរឱ្យបានសេចក្តីសុខ ចូររក្សាខ្លួនឱ្យបានយ៉ាងនេះ ដរាបទៅ" ។ (២) អាការ ៥ នោះ គឺ សត្វទាំងអស់ ១ ប្រាណទាំងអស់ ១ ភូតទាំងអស់ ១ បុគ្គលទាំងអស់ ដែលរាប់ថាមានអត្តភាពទាំងអស់ ១ ។ (៣) ផ្សាយ មេត្តាព្រហ្មវិហារចំពោះសត្វ ដោយក្រុមៗ ថា "ស្ត្រីទាំងអស់ បុរសទាំងអស់ អរិយៈ -

*អានិសង្ស ១១ យ៉ាង មានដេកទៅជាសុខជាដើម មានទៅកើតទៅក្នុងស្ថានព្រហ្មលោក ជាទីបំផុត ។*

## ៨.៣ មរណានុស្សតិ

*កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវមរណានុស្សតិកម្មដ្ឋាន គប្បីចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗហើយ ធ្វើទុកក្នុងចិត្តដោយឧបាយថា "***មរណំ ភវិស្សតិ ជីវិតិន្ទ្រិយំ ឧបច្ឆិជ្ជិស្សតិ*** *: សេចក្តីស្លាប់គង់តែនឹងមាន ជីវិតិន្ទ្រីយ៍មុខជានឹងដាច់បង់ទៅ" ឬថា "***មរណំ មរណំ*** *: ស្លាប់ៗ" ដូច្នេះក៏បាន ។ បើធ្វើទុកក្នុងចិត្តដោយឧបាយយ៉ាងនេះហើយ នីវរណធម៌ទាំង ៥ មិនទាន់ទ្រោមទៅ ស្មារតីមិនទាន់តាំងនៅ កម្មដ្ឋានក៏មិនទាន់ដល់នូវឧបចារៈ ត្រូវឲ្យរឭកដល់សេចក្តីស្លាប់ដោយអាការ ៨ យ៉ាងតទៅទៀត ។*

*អាការទាំង ៨ យ៉ាងនោះដូចម្តេច ?*

---

ទាំងអស់ អនរិយៈទាំងអស់ ទេវតាទាំងអស់ មនុស្សទាំងអស់ វិនបាតិកទាំងអស់ ចូរកុំឱ្យមានពៀរ ។ល។ ចូររក្សាខ្លួនឱ្យបានយ៉ាងនេះដរាបទៅ " ។ (៤) អាការ ៧ នោះ គឺ "ស្ត្រីទាំងអស់ ១ ។ល។ វិនបាតិកទាំងអស់ ១ ។ (៥) ផ្សាយមេត្តាព្រហ្មវិហារទៅរកសត្វក្នុងទិសទាំង ១០ សត្វក្នុងទិសនីមួយៗ ចាត់ថា អាការមួយៗ រួមត្រូវជាអាការ ១០ ។

*អាការទាំង ៨ យ៉ាងនោះដូច្នេះ គឺ :*

**១.វធកបច្ចុប្បដ្ឋានតោ** *ត្រូវរឭកថា "សេចក្តីស្លាប់តាំងឡើងប្រាកដ ដូចជាសត្រូវងារដាវផ្គងដាក់លើក" ។*

**២.សម្បត្តិវិបត្តិតោ** *ត្រូវរឭកថា "ធម្មតាសម្បត្តិក្នុងលោកសុទ្ធតែកន្លងនូវវិបត្តិទៅពុំបាន" ។*

**៣.ឧបសំហរណតោ** *ត្រូវរឭកដល់សេចក្តីស្លាប់របស់ខ្លួនប្រៀបដោយសេចក្តីស្លាប់របស់អ្នកដទៃ ។*

**៤.កាយពហុសាធារណតោ** *ត្រូវរឭកថា "កាយនេះទូទៅដល់អន្តរាយច្រើនប្រការ មានត្រកូលនៃសត្វជន្លូវ ៨០ ជាដើម" ។*

**៥.អាយុទុព្វលតោ** *ត្រូវរឭកថា "អាយុនេះមានកម្លាំងថយពន់ពេក ព្រោះថា ជីវិតរបស់សត្វទាំងឡាយជាប់នៅដោយខ្យល់អស្សាសៈ បស្សាសៈ ជាដើម" ។*

**៦.អនិមិត្តតោ** *ត្រូវរឭកថា "សេចក្តីស្លាប់មិនមានកំណត់ព្រោះថា ជីវិតជាដើមរបស់សត្វទាំងឡាយរកកំណត់មិនបាន" ។*

**ជីវិតំ ព្យាធិ កាលោ ច ទេហនិក្ខេបនំ គតិ**
**បញ្ចេតេ ជីវលោកស្មឹ អនិមិត្តា ន នាយរេ ។**

*ធម៌ ៥ យ៉ាងនេះគឺ ជីវិត ១ ព្យាធិ ១ កាល ១ ទេហនិក្ខេបនៈ (ស្ថានទីដាក់ចុះរាងកាយ) ១ គតិ ១ របស់សត្វទាំងឡាយ*

ក្នុងជីវលោក មិនមាននិមិត្ត ដឹងមិនបាន ។

ក្នុងធម៌ ៥ យ៉ាងនោះ ជីវិតឈ្មោះថាមិនមាននិមិត្ត ព្រោះមិនមានកំណត់ថា នឹងគប្បីរស់នៅត្រឹមប៉ុណ្ណេះ មិនរស់នៅតពីនេះទៅ (ដូច្នេះជាដើម) ព្រោះថាសត្វទាំងឡាយ រមែងស្លាប់តាំងពីក្នុងកាលនៅជាកលលៈក៏មាន ក្នុងកាលដែលនៅជាអព្វុទៈ ជាបេសិ ជាឃនៈ នៅក្នុងគភ៌បាន ១ ខែ បាន ២ ខែ បាន ៣ ខែ បាន ៤ ខែ បាន ៥ ខែ បាន ១០ ខែក៏មាន ក្នុងសម័យដែលចេញចាកផ្ទៃក៏មាន អំពីនោះក៏ស្លាប់ខាងក្នុង ១០០ ឆ្នាំក៏មាន ខាងក្រៅ (លើសពី) ១០០ ឆ្នាំក៏មានដូចគ្នា ។

សូម្បីព្យាធិ ឈ្មោះថាមិនមាននិមិត្ត ព្រោះមិនមានកំណត់ថាសត្វទាំងឡាយនឹងស្លាប់ដោយព្យាធិនេះប៉ុណ្ណោះ មិនស្លាប់ដោយព្យាធិដទៃ ព្រោះថាសត្វទាំងឡាយស្លាប់ដោយរោគភ្នែកក៏មាន ដោយរោគក្រៅនេះមានរោគត្រចៀកជាដើមយ៉ាងណាមួយក៏មាន ។

សូម្បីកាល ក៏ឈ្មោះថាមិនមាននិមិត្ត ព្រោះមិនមានកំណត់យ៉ាងនេះថា នឹងត្រូវស្លាប់ក្នុងកាលនេះប៉ុណ្ណោះ មិនស្លាប់ក្នុងកាលដទៃ ព្រោះថាសត្វទាំងឡាយរមែងស្លាប់ក្នុងពេលព្រឹកក៏មាន ក្នុងពេលដទៃមានពេលថ្ងៃត្រង់ជាដើម ពេលណាមួយក៏មាន ។

*សុប្បទេហនិក្ខេបនៈ* ក៏ឈ្មោះថាមិនមាននិមិត្ត ព្រោះមិនមានកំណត់យ៉ាងនេះថា កាលសត្វទាំងឡាយស្លាប់ រាងកាយនឹងត្រូវដាក់នៅទីនេះប៉ុណ្ណោះ មិនមិនដាក់នៅទីដទៃ ព្រោះថារាងកាយរបស់បុគ្គលទាំងឡាយអ្នកកើតក្នុងស្រុក (ទៅស្លាប់) ដាក់នៅក្រៅស្រុកក៏មាន រាងកាយរបស់បុគ្គលទាំងឡាយអ្នកកើតក្រៅស្រុក (មកស្លាប់) ដាក់នៅក្នុងស្រុកក៏មាន ដោយន័យជាមួយគ្នានោះ បណ្ឌិតគប្បី (ពណ៌នា) ឲ្យទូលំទូលាយទៅច្រើនប្រការ ជាដើមថា "រាងកាយរបស់បុគ្គលទាំងឡាយអ្នកកើតលើគោក (ទៅស្លាប់) ដាក់នៅក្នុងទឹក ឬថារាងកាយរបស់បុគ្គលទាំងឡាយអ្នកកើតក្នុងទឹក (មកស្លាប់) ដាក់នៅលើគោក" ... ។

*សុប្បគតិ* ក៏ឈ្មោះថាមិនមាននិមិត្ត ព្រោះមិនមានកំណត់យ៉ាងនេះថា សត្វអ្នកចុតិអំពីគតិនេះ នឹងត្រូវ (ទៅ) កើតក្នុងគតិនេះ ព្រោះថាសត្វទាំងឡាយអ្នកចុតិអំពីទេវលោក (មក) កើតក្នុងពួកមនុស្សក៏មាន អ្នកចុតិអំពីមនុស្សលោក (ទៅ) កើតក្នុងលោកដទៃមានទេវលោកជាដើមទីណាមួយក៏មាន ព្រោះយ៉ាងនេះ (សត្វ) លោកទើបវិលវល់ទៅក្នុងគតិ ៥ ដូចគោដែលគេទឹមទុកក្នុងយន្ត (គឺបើកវិលជុំវិញ) ដើរវិលនៅដូច្នោះ ។

**៧-អទ្ធានបរិច្ឆេទតោ** ត្រូវរឭកថា "ជីវិតរបស់មនុស្សក្នុងកាលឥឡូវនេះ កំណត់យ៉ាងយូរបំផុតត្រឹមមួយរយឆ្នាំ បើលើសក៏បន្តិចបន្តួច" ។ (កំណត់នេះតាមជំនាន់អាយុខយមួយរយឆ្នាំ) ។

**៨-ខណបរិត្តតោ** ត្រូវរឭកថា "ជីវិតរបស់សត្វទាំងឡាយ បើពោលតាមបរមត្ថ តូចពេកណាស់ ប្រព្រឹត្តទៅបានតែត្រឹម ១ ខណចិត្តប៉ុណ្ណោះឯង" ។

បណ្ដាអាការទាំង ៨ យ៉ាងនេះត្រង់អាការទី ៣ ដែលថា ត្រូវរឭកដល់សេចក្ដីស្លាប់របស់ខ្លួន ប្រៀបដោយសេចក្ដីស្លាប់របស់អ្នកដទៃនោះ ត្រូវប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គល ៧ ពួកគឺ :

**១-យសមហត្តតោ** ប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គលដែលមានយសបរិវារច្រើន មានស្ដេចមហាសម្មតិរាជ និងស្ដេចមន្ធាតុ ជាដើម ។

**២-បុញ្ញមហត្តតោ** ប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គលដែលមានបុណ្យច្រើន មានជោតិយសេដ្ឋី និងជដិលសេដ្ឋីជាដើម ។

**៣-ថាមមហត្តតោ** ប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គលដែលមានកម្លាំងច្រើន មានស្ដេចវាសុទេព និងពលទេពជាដើម ។

**៤-ឥទ្ធិមហត្តតោ** ប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គលដែលមានឫទ្ធិច្រើន ដូចព្រះមោគ្គល្លានត្ថេរ ។

**៥.បញ្ញាមហន្តតោ** ប្រៀបដោយសេចក្តីស្លាប់របស់បុគ្គលដែលមានប្រាជ្ញាច្រើន ដូចព្រះសារីបុត្តត្ថេរ ។

**៦.បច្ចេកពុទ្ធតោ** ប្រៀបដោយបរិនិព្វានរបស់ព្រះបច្ចេកពុទ្ធ ។

**៧.សម្មាសម្ពុទ្ធតោ** ប្រៀបដោយបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធ ។

ត្រូវប្រៀបដូចម្តេចសេចក្តីស្លាប់របស់បុគ្គលទាំង ៧ ពួកនេះ ?

ត្រូវប្រៀបធៀបថា "អម្បាលដូចជាបុគ្គលដែលថ្កើងថ្កានដល់ម្លោះ គង់កន្ទងមិនផុតពីសេចក្តីស្លាប់ ចំណង់បើអាត្មាអញ ជាបុគ្គលថោកថយដល់ម្ល៉េះ ដូចម្តេចនឹងកន្ទងឲ្យផុតអំពីសេចក្តីស្លាប់ទៅបាន" ។

កាលបើព្រះយោគី រឭកដល់សេចក្តីស្លាប់ដោយអាការទាំង ៨ យ៉ាង អាការណាមួយហើយ ដោយអំណាចដែលធ្វើទុកក្នុងចិត្តរឿយៗ ចិត្តក៏សេពនូវការនាច្រើន ស្មារតីក៏តម្កល់នៅ មានសេចក្តីស្លាប់ជាអារម្មណ៍ នីវរណធម៌ ក៏ទ្រោមទៅ អង្គឈានសោតក៏កើតប្រាកដឡើង តែក្នុងមរណានុស្សតិកម្មដ្ឋាននេះ មានអំណាចឲ្យសម្រេចបានតែត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាចឲ្យសម្រេចដល់អប្បនាឈានបានឡើយ ។

## ៨.៤ អសុភកម្មដ្ឋាន ១០

### ១ ឧទ្ធុមាតកអសុភ

កាលបើព្រះយោគាវចរ មានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុងឧទ្ធុមាតកអសុភ គប្បីចូលទៅកាន់សំណាក់កល្យាណមិត្ត ដូចន័យដែលពោលមកក្នុងខាងដើម រៀនយកនូវវិធីដើរទៅកាន់អសុភ-និមិត្ត វិធីកំណត់នូវនិមិត្តជិតខាង វិធីកាន់យកនូវនិមិត្ត វិធីពិចារណាតាមផ្លូវដែលដើរទៅដើរមក រហូតដល់អប្បនាវិធីជាទីបំផុត ចេញទៅនៅក្នុងទីសេនាសនៈដ៏សមគួរដល់សមាធិភាវនា ហើយសឹមស្វែងរកអសុភនិមិត្តនឹងចម្រើន ។

**ត្រង់ដែលថារៀនយកនូវវិធីដើរទៅកាន់អសុភនិមិត្តនោះដូចម្ដេច ?**

ត្រូវរៀនឲ្យដឹងថា : មុនដែលនឹងដើរទៅកាន់កន្លែងដែលរូបអសុភតម្កល់នៅ ត្រូវប្រាប់ដល់លោកដែលជាសង្ឃត្ថេរជាមុន សឹមដើរចេញទៅ មិនត្រូវទៅ ២ ឬ ៣ រូប ត្រូវធ្វើទុកក្នុងចិត្តនូវមូល-កម្មដ្ឋានជានិច្ច ត្រូវកាន់ឈើប្រត់ដើរទៅ ដើម្បីការពារនូវអន្តរាយមានឆ្កែជាដើម ត្រូវដើរប្រុងស្មារតីសង្រួមឥន្ទ្រិយ៍ទាំង ៦ ត្រូវកំណត់ឲ្យដឹងទិស ដឹងទ្វារ ដឹងផ្លូវដែលខ្លួនចេញដើរទៅ ត្រូវឲ្យដឹងខាង-ឆ្វេង ខាងស្ដាំ នៅទីណាមានវត្ថុអ្វី មិនត្រូវដើរចូលទៅកាន់អសុភអំពីខាងក្រោមខ្យល់ ។

**ត្រង់ដែលថារៀនយកនូវវិធីកំណត់និមិត្តជិតខាងនោះដូចម្ដេច ?**

*ត្រូវរៀនឲ្យដឹងថា : ពេលដែលចូលទៅដល់រូបអសុភហើយ មិនត្រូវសម្លឹងមើលរូបអសុភជាដំបូងឡើយ ត្រូវកំណត់រកទិសដែលសម្លឹងមើលទៅឃើញអសុភប្រាកដ ត្រូវឈរនៅក្នុងទីជាចន្លោះ មិនជាខាងក្រោមខ្យល់ ខាងលើខ្យល់ មិនឆ្ងាយពេកជិតពេក មិនបែរខាងក្បាលពេក បែរខាងចុងជើងពេក ត្រូវកំណត់ទីជុំវិញឲ្យដឹងថាខាងណាមានវត្ថុអ្វី ថ្ម ឬដំបូកជាដើម ធំ ឬ តូច ខ្ពស់ ឬ ទាប ជាមុន ត្រូវធ្វើទុកក្នុងចិត្តនូវវត្ថុជិតខាងផ្អែបជាមួយនឹងតួអសុភ ថា "នេះថ្ម នេះអសុភ" ជាដើម ។*

**ត្រង់ដែលថា រៀនយកនូវវិធីកាន់យកនូវនិមិត្តនោះដូចម្ដេច ?**

**ត្រូវរៀនឱ្យដឹងនូវវិធីកាន់យកនូវនិមិត្តដោយអាការ ១១ យ៉ាងគឺ**

**១-វណ្ណតោ** *កំណត់ឲ្យដឹងថា "នេះជាសរីរៈរបស់មនុស្សសម្បុរស ឬខ្មៅ ជាដើម" ។*

**២-លិង្គតោ** *កំណត់ឲ្យដឹងថា "នេះជាសរីរៈរបស់មនុស្សស្ថិតនៅក្នុងបឋមវ័យ មជ្ឈិមវ័យ ឬ បច្ឆិមវ័យ " ។*

**៣-សណ្ឋានតោ** *កំណត់ឲ្យដឹងថា "នេះជាសណ្ឋានក្បាល ឬសណ្ឋានកជាដើម" ។*

**៤-ទិសតោ** ក្នុងសរីរៈនេះតាំងអំពីផ្ចិតចុះទៅ ចាត់ជាទិសខាងក្រោម អំពីផ្ចិតឡើងលើចាត់ជាទិសខាងលើ ត្រូវកំណត់ឲ្យដឹងថា "នេះជាទិសខាងក្រោម នេះជាទិសខាងលើ" ឬកំណត់ឲ្យដឹងថា "អញឈរនៅក្នុងទិសនេះ អសុភនៅក្នុងទិសនេះ" ។

**៥-ឱកាសតោ** កំណត់ឲ្យដឹងថា "ដៃនៅក្នុងឱកាសនេះ ជើងនៅក្នុងឱកាសនេះ" ជាដើម ឬកំណត់ឲ្យដឹងថា "អញឈរនៅក្នុងឱកាសនេះ អសុភនៅក្នុងឱកាសនេះ " ។

**៦-បរិច្ឆេទតោ** កំណត់ឲ្យដឹងថា "សរីរៈនេះខាងក្រោម ត្រឹមបាទជើង ខាងលើត្រឹមចុងសក់ ជុំវិញត្រឹមស្បែកក្នុងចន្លោះនេះ ពេញដោយសាកអសុភ ៣២ ប្រការ" ឬកំណត់ឲ្យដឹងថា "ដៃត្រឹមនេះ ជើងត្រឹមនេះ" ជាដើម ។

**៧-សន្ធតោ** កំណត់ឲ្យដឹងទីតនៃសរីរៈទាំង ១៨០

**៨-វិវរតោ** កំណត់ឲ្យដឹងទីចន្លោះរបស់អសុភមានចន្លោះដៃ ចន្លោះជើង ចន្លោះពោះជាដើម ។

**៩-និន្នតោ** កំណត់ឲ្យដឹងទីទំនាបក្នុងសរីរៈរបស់អសុភ មានរណ្ដៅភ្នែក និងក្នុងមាត់ជាដើម ឬកំណត់ឲ្យដឹងថា "អញឈរនៅក្នុងទីទំនាប ឯអសុភស្ថិតនៅក្នុងទីទួល" ។

**១០-ឧទ្ធតតោ** កំណត់ឲ្យដឹងទីខ្ពស់ក្នុងសរីរៈរបស់អសុភ មាន ជង្គង់ និងទ្រូងជាដើម ឬកំណត់ឲ្យដឹងថា "អញឈរនៅក្នុងទីខ្ពស់ ឯអសុភស្ថិតនៅក្នុងទីទំនាប " ។

**១១-សមន្តតោ** ត្រូវបញ្ជូនញាណឲ្យប្រព្រឹត្តទៅសព្វក្នុងសរីរៈ អសុភទាំងមូល បើត្រង់ណាតាំងឡើងប្រាកដ សឹមកំណត់ធ្វើទុកក្នុង ចិត្តត្រង់ណោះ ។

**ត្រង់ដែលថា រៀនយកនូវវិធីពិចារណាតាមផ្លូវដែលដើរទៅ ដើរមក នោះដូចម្ដេច ?**

ក្នុងវិធីពិចារណាតាមផ្លូវ ដែលដើរទៅនឹងដើរមកនោះ ត្រង់វិធី ពិចារណាតាមផ្លូវដែលដើរទៅ បានពោលមកហើយក្នុងវិធីដើរទៅ កាន់អសុភនិមិត្តខាងដើម នឹងពោលតែវិធីពិចារណាតាមផ្លូវដែលដើរ មក ក៏ឯវិធីពិចារណាតាមផ្លូវដែលដើរមកនោះគឺ កាលបើព្រះយោគី បានកាន់យកនូវនិមិត្តដោយប្រពៃហើយ តែមិនទាន់បានសម្រេចកិច្ច ដល់ទីបំផុតរបស់ភាវនា ត្រូវថយត្រឡប់មកកាន់ទីសេនាសនៈវិញ ក្នុងពេលដែលដើរមកនោះ ត្រូវធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាននោះ ជា ដរាប ត្រូវដើរប្រុងស្មារតីសង្រួមឥន្ទ្រីយ៍ទាំង ៦ ពេលដែលចេញ ចាកព្រៃស្មសានមកត្រូវកំណត់ផ្លូវ កំណត់ទិស កំណត់វត្ថុជិតខាងឲ្យ សព្វគ្រប់ ដូចកាលដែលដើរចូលទៅ លុះមកដល់ទីសេនាសនៈ

ហើយ បើទីងចង្រ្កមក្តី ទីងអង្គុយក្តី ត្រូវអធិដ្ឋានទីចង្រ្កម តាក់តែង ទីអង្គុយ ឲ្យបែរមុខឆ្ពោះទៅកាន់ទីដែលអសុភតម្កល់នៅ ហើយត្រូវ ពិចារណាបញ្ជូនចិត្តនឹកទៅរកអសុភដែលខ្លួនចម្រើននោះ ។

**វិធីដែលនឹងកំណត់នូវនិមិត្តជិតខាងជាដើមនេះ មានប្រយោជន៍ យ៉ាងណាខ្លះ ?**

វិធីកំណត់និមិត្តជិតខាង នឹងមិនវង្វេងភ្លេចស្មារតីក្នុងពេល ដែលអសុភសម្តែងនូវអាការគួរស្បើម ។

វិធីកាន់យកនូវនិមិត្តដោយអាការ ១១ យ៉ាង ដើម្បីនឹងចង ក្រៀកទុកនូវកម្មដ្ឋានឲ្យជាបច្ច័យដល់ឧគ្គហនិមិត្ត បដិភាគនិមិត្ត និង អប្បនាឈាន ដរាបដល់អរហត្តផលជាទីបំផុត បើចម្រើននូវ វិបស្សនាតទៅទៀត ។

វិធីពិចារណាតាមផ្លូវដែលដើរទៅនិងដើរមក ដើម្បីញុំាងវិថី របស់កម្មដ្ឋានឲ្យសម្រេច ក្នុងពេលដែលព្រះយោគីចម្រើនបាននូវ ឧគ្គហនិមិត្ត ត្រឡប់ទៅកាន់ទីសេនាសនៈវិញ បើនិមិត្តនោះវិនាស បាត់ទៅហើយ ព្រះយោគីរឭកសាតាមលំអាននោះ ក៏នឹងត្រឡប់កើត ឡើងវិញ ។

កាលព្រះយោគី បានរៀនយកនូវវិធីទាំងពួងដូចពោលមកនេះ ក្នុងសំណាក់នៃកល្យាណមិត្តសព្វគ្រប់ហើយ បើឃើញ ឬឮដំណឹង

ថា អសុភដែលហើមពោរពងឡើងមាននៅក្នុងទីណា ក៏គប្បីដើរទៅកាន់ទីនោះ ប្រព្រឹត្តតាមលំអានដែលពោលមក លុះទៅដល់ហើយត្រូវចម្រើនឈរ ឬអង្គុយក៏បាន កុំឲ្យឆ្ងាយពេក ជិតពេក ឲ្យល្មមតែក្រឡេកមើលទៅឃើញអសុភច្បាស់ ត្រូវសង្រួមថា "អញមុខជានឹងរួចចាកសំសារទុក្ខ ដោយបដិបទានេះជាពិត" ត្រូវសម្គាល់នូវអសុភហាក់ដូចជាដួងកែវ ត្រូវតាំងសេចក្តីគោរពឲ្យណាស់ ត្រូវមានសេចក្តីពេញចិត្តឲ្យណាស់ ត្រូវចងក្រៀកចិត្តទុកក្នុងអារម្មណ៍នោះ ហើយបើកភ្នែក សំឡឹងមើលកំណត់ធ្វើទុកក្នុងចិត្តថា "**ឧទ្ធុមាតកំ បដិក្កូលំ ឧទ្ធុមាតកំ បដិក្កូលំ** : អសុភហើមពោរពងឡើង មុខគួរឲ្យខ្ពើមៗ" ហើយធ្មេចភ្នែកនឹករំពឹងកំណត់ ធ្វើទុកក្នុងចិត្តដូចដែលដល់ ១ រយចប់ក្តី ១ ពាន់ចប់ក្តី ដរាបដល់កាន់យកនូវនិមិត្តបានដោយល្អ ឧគ្គហនិមិត្តកើតឡើង បើកភ្នែកក៏ឃើញ ធ្មេចភ្នែកចុះទៅវិញក៏ឃើញដូចគ្នា លុះចេញចាកអំពីទីនោះទៅកាន់ទីសេនាសនៈរបស់ខ្លួនវិញ ក៏ត្រូវធ្វើទុកក្នុងចិត្តឲ្យរឿយៗ លុះត្រាតែបដិភាគ-និមិត្តកើតឡើង ។

ឧគ្គហនិមិត្ត ក្នុងឧទ្ធុមាតកអសុភនេះ តាំងឡើងមានទំនងប្លែកមុខគួរឲ្យខ្ពើម សម្តែងអាការគួរឲ្យស្ញើម ឯបដិភាគនិមិត្តប្រាកដឡើង ហាក់ដូចជាបុរសមានអវយវៈតូចធំយ៉ាងថ្លោស បរិភោគឆ្អែត

ហើយដេកនៅ លំដាប់នោះ នីវរណធម៌និងកិលេសរបស់ព្រះយោគីអង្គនោះ ក៏ទ្រោមស្ងប់ទៅជាលំដាប់ ចិត្តសោតក៏តម្កល់នៅមាំដោយឧបចារសមាធិ កាលបើព្រះយោគីសេពនូវនិមិត្តនោះជារឿយៗ ពុំបានលះបង់ព្យាយាម ក៏នឹងបានសម្រេចដល់អប្បនាឈាន តែក្នុងកម្មដ្ឋាននេះ មានអំណាចឲ្យសម្រេចបានតែត្រឹមបឋមជ្ឈានប៉ុណ្ណោះ មិនមានអំណាចឲ្យសម្រេចដល់អប្បនាឈាន ជាន់លើទៀតបានឡើយ ទោះបីអសុភទាំង ៩ ខាងចុងក៏ដោយ ។

## ២ វិនីលកអសុភ

បន្ទាប់មកអំពីឧទ្ធុមាតកអសុភ នឹងពណ៌នាក្នុងអសុភទាំង ៩ ខាងចុងតទៅ ។

ក៏ក្នុងអសុភទាំង ៩ នេះ មានវិធីទាំងពួងដូចគ្នានឹងឧទ្ធុមាតក-អសុភ ស្ទើរតែនឹងទាំងអស់ នៅមានសេចក្តីដែលប្លែកគ្នានោះបន្តិចបន្តួច ហេតុនោះនឹងពណ៌នាតែសេចក្តីណាដែលប្លែកគ្នាប៉ុណ្ណោះ ឯសេចក្តីឯទៀត គប្បីជ្រាបតាមន័យដែលពោលមកក្នុងឧទ្ធុមាតក-អសុភឯណោះចុះ ។

តែក្នុងអសុភទាំង ៩ នេះ នឹងពោលនូវវិនីលកអសុភជាមុន ហើយត្រូវពណ៌នានូវអសុភដ៏សេសតរៀងទៅ ។

*ក៏ក្នុងវិនីលកអសុភនេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា* "**វិនីលកំ បដិក្កូលំ វិនីលកំ បដិក្កូលំ** *អសុភហើមមានពណ៌ខៀវ មុខគួរឲ្យខ្ពើម ៗ" ។*

*ឧគ្គហនិមិត្តក្នុងវិនីលកអសុភនិមិត្តនេះ ប្រាកដឡើងនៅមានពណ៌ពពាលៗ ដោយច្រើន ឯបដិភាគនិមិត្ត ប្រាកដឡើងតាមពណ៌ដែលផ្សាយឡើង ច្រើនពណ៌ក្រហម-ស-ខៀវ ពណ៌ណាមួយផ្សាយឡើងច្រើនក៏ប្រាកដ ដូច្នោះ ។*

## ៣ វិបុព្វកអសុភ

*ក្នុងវិបុព្វកអសុភនេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា* "**វិបុព្វកំ បដិក្កូលំ វិបុព្វកំ បដិក្កូលំ** : *អសុភហើមមានខ្ទុះហូរទៅខាងលើ ខាងក្រោម មុខគួរឲ្យខ្ពើមៗ" ។*

*ឧគ្គហនិមិត្ត ក្នុងវិបុព្វកអសុភនេះ ប្រាកដឡើងដូចខ្ទុះកំពុងហូរចេញ ឯបដិភាគនិមិត្ត ប្រាកដឡើងទ្រង់ស្ងប់ ជ្រៀបមិនកម្រើក ។*

## ៤ វិច្ឆិទ្ទកអសុភ

កីឯវិច្ឆិទ្ទកអសុភនេះ តែងមាននៅក្នុងមណ្ឌលនៃទីចម្បាំងក្នុងដងព្រៃដែលចោរតែងនៅអាស្រ័យ ក្នុងទីដែលពិឃាដមនុស្សទោស ឬក្នុងព្រៃដែលជាទីលំនៅ នៃសត្វសាហាវមានសីហៈជាដើម ហេតុនោះ បើព្រះយោគីស្វែងរកបានក្នុងប្រទេសណាមួយ ហើយអសុភនោះ ដាច់ចេញឃ្លាតឆ្ងាយអំពីគ្នាឆ្ងាយ ត្រូវប្រមូលអារម្មណ៍ឲ្យមូលពិចារណារួបចូលជាមួយគ្នា ពុំនោះនឹងប្រើគេឲ្យប្រមូល ឬនឹងប្រមូលខ្លួនឯងឲ្យមូលគ្នាមកដោយឈើច្រត់ជាដើមក៏បាន កុំតែចាប់ពាល់ដោយដៃ ហើយត្រូវបរិកម្មកំណត់ទុកក្នុងចិត្តថា "**វិច្ឆិទ្ទកំ បដិក្កូលំ វិច្ឆិទ្ទកំ បដិក្កូលំ** អសុភដែលគេកាត់ដាច់ពាក់កណ្តាលខ្លួន មុខគួរឲ្យខ្ពើមៗ" ។

ឧគ្គហនិមិត្ត ក្នុងវិច្ឆិទ្ទកអសុភនេះ ប្រាកដឡើងហាក់ដូចជាដាច់ពាក់កណ្តាល ឯបដិភាគនិមិត្ត ប្រាកដដូចជាពេញបរិបូណ៌ឡើងវិញ ។

## ៥ វិក្ខាយិតកអសុភ

ក្នុងវិក្ខាយិតកអសុភនេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "**វិក្ខាយិតកំ បដិក្កូលំ វិក្ខាយិតកំ បដិក្កូលំ** អសុភដែលសត្វកកេរស៊ីមានសំណាមរលុះរលួយផ្សេងៗ មុខគួរឲ្យខ្ពើមៗ" ។

ឧគ្គហនិមិត្តក្នុងវិក្ខាយិតកអសុភនេះ ប្រាកដឡើងនៅដូចស្នាមដែលសត្វកកេរស៊ីក្នុងទីនោះៗ ឯបដិភាគនិមិត្តប្រាកដឡើងនៅពេញបរិបូណ៌ដូចដើម ។

## ៦ វិក្ខិត្តកអសុភ

ក្នុងវិក្ខិត្តកអសុភនេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "**វិក្ខិត្តកំ បដិក្កូលំ វិក្ខិត្តកំ បដិក្កូលំ** អសុភដែលគេកាត់ដាច់ចេញពីគ្នាជាកំណាត់ៗ រាត់រាយទៅផ្សេងៗ មុខគួរឲ្យខ្ពើមៗ" ។

ឧគ្គហនិមិត្ត ក្នុងវិក្ខិត្តកអសុភនេះ ប្រាកដឡើងនៅមានជាចន្លោះៗ នៃអវយវៈដែលប្រាកដ ឯបដិភាគនិមិត្តប្រាកដឡើងពេញបរិបូណ៌ដូចដើម ។

## ៧ ហតវិក្ខិត្តកអសុភ

ក្នុងហតវិក្ខិត្តកអសុភនេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "**ហតវិក្ខិត្តកំ បដិក្កូលំ ហតវិក្ខិត្តកំ បដិក្កូលំ** អសុភដែលគេកាប់សាប់មានស្នាមរាំមៗ មុខគួរឲ្យខ្ពើមៗ " ។

ឧគ្គហនិមិត្ត ក្នុងហតវិក្ខិត្តកអសុភនេះ ប្រាកដឡើងនៅមានស្នាមមុខរបួស ឯបដិភាគនិមិត្ត ប្រាកដឡើងពេញបរិបូរណ៍ដូចដើម ។

## ៨ លោហិតកអសុភ

កំឯលោហិតកអសុភនេះព្រះយោគី រមែងស្វែងរកបានក្នុងមណ្ឌលនៃចម្បាំងជាដើម ដូចពោលមកហើយក្នុងវិច្ឆិទ្ទកអសុភ តែត្រូវចម្រើនបានតែក្នុងពេលដែលឈាមកំពុងហូរចេញ អំពីមុខរបួសដែលគេប្រហារ ពុំនោះនឹងចម្រើនយកនិមិត្តក្នុងឈាមដែលហូរចេញអំពីមុខបួស ឬពកដែលបែកធ្លាយជាដើម ក្រៅអំពីអសុភស្លាប់ក៏បាន ត្រូវបរិកម្មកំណត់ទុកក្នុងចិត្តថា "**លោហិតកំ បដិក្កូលំ លោហិតកំ បដិក្កូលំ** អសុភមានឈាមហូរស្រោចស្រប់ មុខគួរឲ្យខ្ពើមៗ" ។

ឧគ្គហនិមិត្ត ក្នុងលោហិតកអសុភនេះ ប្រាកដឡើងមានអាការញ័រដូចជាផ្ទាំងសំពត់មានពណ៌ក្រហម ដែលខ្យល់បក់មកត្រូវ ឯបដិភាគនិមិត្តប្រាកដឡើង មានសភាពស្ងប់មិនមានកម្រើក ។

## ៩ បុឡុវកអសុភ

ក្នុងបុឡុវកអសុភនេះ ត្រូវចម្រើនយកនិមិត្តក្នុងកាលដែលដង្កូវកំពុងហូរចេញតាមទ្វារទាំង ៩ ឬក្នុងកាលដែលសរីរៈអសុភនោះ រលួយរបេះចេញចាកគ្នាអស់ហើយ នៅសល់តែដង្កូវផ្តុំគ្នាជាគំនរ ដូចគំនរបាយស្រូវសាលីដូច្នោះក៏បាន ទុកណាជាសរីរៈនៃ

អសុភនោះ ជាសរីរៈរបស់ឆ្កែក្តី ចចកក្តី មនុស្សក្តី គោ ក្របី ដំរី សេះ ឬ ពស់ថ្លាន់ជាដើមក្តី ក៏គួរចម្រើនបានដូចគ្នា ត្រូវបរិកម្ម កំណត់ធ្វើទុកក្នុងចិត្តថា "**បុឡុវកំ បដិកូលំ បុឡុវកំ បដិកូលំ** អសុភមានដង្កូវចុះ ហូរចេញតាមទ្វារទាំង ៩ មុខគួរឲ្យខ្ពើមៗ " ។

ឧគ្គហនិមិត្ត ក្នុងបុឡុវកអសុភនេះ ប្រាកដឡើងមានអាការញ័រ ឯបដិភាគនិមិត្ត ប្រាកដឡើងទ្រង់ស្ងប់ដូចដុំបាយនៃស្រូវសាលី ។

## ១០ អដ្ឋិកអសុភ

ក៏ឯអដ្ឋិកអសុភនេះ ទោះបីគង់នៅជារាងឆ្អឹងទាំងមូលក្តី ជ្រុះរង្គោះចេញទៅដោយឡែកៗ អំពីគ្នាក្តី សូម្បីនៅសល់តែឆ្អឹង ១ កំណាត់ ២ កំណាត់ ពុកផុយដូចម្តេចក្តី ក៏គួរចម្រើនយកនិមិត្តបានដូចគ្នាទាំងអស់ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "**អដ្ឋិកំ បដិកូលំ អដ្ឋិកំ បដិកូលំ** អសុភមានតែរាងឆ្អឹងខ្ចាត់ខ្ចាយរាត់រាយទៅផ្សេងៗ មុខគួរឲ្យខ្ពើមៗ" ។

ឧគ្គហនិមិត្ត ក្នុងអដ្ឋិកអសុភនេះ ប្រាកដឡើងនៅមានជាចន្លោះៗ ឯបដិភាគនិមិត្ត ប្រាកដឡើងពេញបរិបូរណ៍ ។

ន័យម្យ៉ាងទៀតថា "ឧគ្គហនិមិត្តប្រាកដឡើងគួរឲ្យខ្ពើម គួរឲ្យខ្លាច ឯបដិភាគនិមិត្តប្រាកដឡើង គួរឲ្យកើតបីតិនិងសោមនស្ស" ។

អសុភកម្មដ្ឋានទាំង ១០ នេះ កាលបើព្រះយោគីចម្រើនបាន ដល់បដិភាគនិមិត្តក្នុងអសុភណាមួយហើយ នីវរណធម៌ទាំង ៥ មាន កាមច្ឆន្ទៈជាដើម ក៏ព្រះយោគីអង្គនោះ លះបានជាវិក្ខម្ភនប្បហាន ព្រមគ្នានឹងបដិភាគនិមិត្តកើត ហើយអង្គឈានទាំង ៥ ក៏កើតឡើង ផង ខណៈនោះ ព្រះយោគីក៏ចូលដល់ឧបចារជ្ឈាន ហើយតទៅទៀត នឹងអាចចូលបានដល់អប្បនាឈាន តែចូលបានតែត្រឹមបឋមជ្ឈាន ប៉ុណ្ណោះ ទុកណាជាព្រះយោគីខំសង្វាតព្យាយាមចម្រើនតទៅទៀត ដូចម្តេចក៏មិនអាចនឹងចូលដល់ឈានជាន់លើទៀតបាន មិនអាចនឹង ញុំាងគុណវិសេសមានទិព្វសោតធាតុ និងទិព្វចក្ខុជាដើមឲ្យកើតឡើង បានឡើយ គ្រាន់តែឃើញគំនរអសុភប្រាកដឡើងពេញផែនដី ប៉ុណ្ណោះ តែបើព្រះយោគីទាញយកវិបស្សនាមកចម្រើនផ្អែបផង ក៏ នឹងបានសម្រេចនូវលោកុត្តរធម៌ ដរាបដល់ព្រះអរហត្តជាទីបំផុត ។

ចប់ អសុភកម្មដ្ឋាន ១០ ។

## ៨.៥ កាយគតាសតិ

*ទ្វត្តឹសាការកម្មដ្ឋាន គឺកម្មដ្ឋានដែលត្រូវតម្កល់ស្មារតីចុះក្នុងអាការ ៣២ ដែលមាននៅក្នុងកាយ ដោយធ្វើទុកក្នុងចិត្តថាជាបដិកូលមុខគួរឲ្យខ្ពើម ហៅថា "កាយគតាសតិកម្មដ្ឋាន" ។*

*កាលបើព្រះយោគី មានប្រាថ្នាដើម្បីចម្រើននូវកាយគតាសតិ-កម្មដ្ឋាននេះ គប្បីរៀនយកនូវឧគ្គហកោសល្ល គឺ វិធីដែលឆ្លាសក្នុងឧគ្គហ ៧ យ៉ាង និងមនសិការកោសល្ល គឺវិធីដែលឆ្លាសក្នុងមនសិការ ១០ យ៉ាង ក្នុងសំណាក់នៃអាចារ្យដែលជាកល្យាណមិត្តជាមុន ។*

ឧគ្គហកោសល្ល ៧ យ៉ាងនោះអ្វីខ្លះ ? អធិប្បាយដូចម្ដេច ?

ឧគ្គហកោសល្ល ៧ យ៉ាងនោះ គឺ :

**១-វចសា** *ឆ្លាសដោយវាចាដែលស្វាធ្យាយក្នុងអាការទាំង ៣២*

**២-មនសា** *ឆ្លាសដោយចិត្តដែលកំណត់ស្វាធ្យាយតាមក្នុងអាការទាំង ៣២*

**៣-វណ្ណតោ** *ឆ្លាសដោយកំណត់ពណ៌របស់អាការនោះៗ*

**៤-សណ្ឋានតោ** *ឆ្លាសដោយកំណត់សណ្ឋានរបស់អាការនោះៗ*

**៥-ទិសតោ** *ឆ្លាសដោយកំណត់ទិសដែលអាការនោះៗតម្កល់នៅ ។*

**៦.ឱកាសតោ** *ច្បាស់ដោយកំណត់ឱកាសដែលអាការនោះៗ តម្កល់នៅ ។*

**៧.បរិច្ឆេទតោ** *ច្បាស់ដោយកំណត់ទីជុំវិញរបស់អាការនោះៗ នឹងភាពដែលអាការនោះៗ មិនច្រឡំគ្នា ។*

អធិប្បាយ : ត្រង់ឧគ្គហកោសល្លទី ១ ត្រូវហាត់ស្វាធ្យាយដោយវាចា ឱ្យស្ទាត់ក្នុងអាការទាំង ៣២ ។

ក៏អាការទាំង ៣២ នោះលោកចាត់ទុកជា ៦ ពួកគឺ :

*ពួកទី១ ឈ្មោះ តចបញ្ចកៈ មានអាការ ៥ គឺ* ***កេសា*** *សក់ទាំងឡាយ* ***លោមា*** *រោមទាំងឡាយ* ***នខា*** *ក្រចកទាំងឡាយ* ***ទន្តា*** *ធ្មេញទាំងឡាយ* ***តចោ*** *ស្បែក ។*

*ពួកទី២ ឈ្មោះ វក្កបញ្ចកៈ មានអាការ ៥ គឺ* ***មំសំ*** *សាច់* ***ន្ហារូ*** *សរសៃទាំងឡាយ* ***អដ្ឋី*** *ឆ្អឹងទាំងឡាយ* ***អដ្ឋិមិញ្ជំ*** *ខួរក្នុងឆ្អឹង* ***វក្កំ*** *ទាច ។*

*ពួកទី៣ ឈ្មោះ បប្ផាសបញ្ចកៈ មានអាការ ៥ គឺ* ***ហទយំ*** *បេះដូង* ***យកនំ*** *ថ្លើម* ***កិលោមកំ*** *វៀវ* ***បិហកំ*** *ក្រពះ* ***បប្ផាសំ*** *សួត ។*

ពួកទី៤ ឈ្មោះ មត្ថលុង្គបញ្ចកៈ មានអាការ ៥ គឺ **អន្តំ** ពោះវៀនធំ **អន្តគុណំ** ពោះវៀនតូច **ឧទរិយំ** អាហារថ្មី **ករីសំ** អាហារចាស់ **មត្ថលុង្គំ** ខួរក្នុងក្បាល ។

ពួកទី៥ ឈ្មោះ មេទចក្កៈ មានអាការ ៦ គឺ **បិត្តំ** ប្រមាត់ **សេម្ហំ** ស្លេស្ម **បុព្វោ** ខ្ទុះ **លោហិតំ** ឈាម **សេទោ** ញើស **មេទោ** ខ្លាញ់ខាប់ ។

ពួកទី៦ ឈ្មោះ មុត្តចក្កៈ មានអាការ ៦ គឺ **អស្សុ** ទឹកភ្នែក **វសា** ខ្លាញ់រាវ **ខេឡោ** ទឹកមាត់ **សិង្ឃាណិកា** ទឹកសម្បោរ **លសិកា** ទឹករំអិល **មុត្តំ** ទឹកមូត្រ ។

ត្រូវហាត់ស្វាធ្យាយក្នុងពួកទី ១ ជាអនុលោមបដិលោមឲ្យស្ទាត់ជាមុន សន្សឹមឆ្លងចូលទៅក្នុងពួកទី ២ លុះបានស្ទាត់ក្នុងពួកទី២ ហើយត្រូវស្វាធ្យាយភ្ជាប់មកនឹងពួកទី ១ ខាងដើមវិញ ជាអនុលោមបដិលោមដូចគ្នា ត្រាតែបានស្ទាត់ហើយសន្សឹមឆ្លងចូលទៅក្នុងពួកខាងចុងៗ ទៀតជាលំដាប់តទៅ ។

ត្រូវហាត់ឧគ្គហកោសល្លទី ២ ត្រូវហាត់ស្វាធ្យាយដោយចិត្តឲ្យដូចជាស្វាធ្យាយដោយវាចាគឺថា ត្រូវលើកចិត្តឡើងកំណត់នូវអាការនោះៗ តាមលំអានដែលស្វាធ្យាយដោយវាចា ព្រោះថាស្វាធ្យាយដោយវាចា ជាបច្ច័យដល់កិរិយាស្វាធ្យាយដោយចិត្ត ។

*ត្រង់ទី៣ ត្រូវរៀនកំណត់នូវពណ៌របស់អាការនោះៗឲ្យដឹងថា "អាការនេះ មានពណ៌ដូច្នេះៗ" គ្រប់អាការទាំងអស់ ។*

*ត្រង់ទី៤ ត្រូវរៀនកំណត់នូវសណ្ឋានទ្រង់ទ្រាយរបស់អាការទាំងនោះឲ្យដឹងថា "អាការនេះ មានសណ្ឋានបែបនេះៗ" គ្រប់អាការទាំងអស់ ។*

*ត្រង់ទី៥ ត្រូវរៀនកំណត់ឲ្យដឹងថា អាការណាតម្កល់នៅក្នុងទិសណា ទិសខាងលើ ឬទិសខាងក្រោម ព្រោះក្នុងសរីរប្បទេសនេះ លោកចាត់ជាទិសមាន ២ គឺទិសខាងលើតាំងអំពីផ្ចិតឡើងទៅ ទិសខាងក្រោមតាំងអំពីផ្ចិតចុះមក ។*

*ត្រង់ទី៦ ត្រូវរៀនកំណត់ឲ្យដឹងថា អាការណាតម្កល់នៅក្នុងទីឱកាសបន្ទោះត្រង់ណាៗ គ្រប់អាការទាំង ៣២ ។*

*ត្រង់ទី៧ ត្រូវរៀនកំណត់ឲ្យដឹងទីបំផុតជុំវិញរបស់អាការនោះៗ អាការណាមានទីបំផុតត្រឹមណា ទល់គ្នានឹងអាការណាហើយ នឹងរៀនកំណត់ឲ្យដឹងថា អាការទាំងនោះដោយឡែកៗពីគ្នា មិនមានប្រទាំគ្នាឡើយ ។*

មនសិការកោសល្ល វិធីដែលឆ្លាសក្នុងមនសិការ ១០ យ៉ាងនោះ ដូម្ដេច ?

មនសិការកោសល្ល វិធីដែលឆ្លាសក្នុងមនសិការ ១០ យ៉ាង នោះ គឺ :

**១. អនុបុព្វតោ** *ត្រូវធ្វើទុកក្នុងចិត្តតាមលំដាប់នៃកោដ្ឋាស តាំងអំពីសាធ្យាយជាដំបូងរៀងទៅ មិនត្រូវធ្វើទុកក្នុងចិត្តផ្ទោះៗដោយអន្លើៗ ឡើយ ។*

**២. នាតិសីឃតោ** *ត្រូវធ្វើទុកក្នុងចិត្តមិនឲ្យរហាស់រួសរាន់ពេក*

**៣. នាតិសណិកតោ** *ត្រូវធ្វើទុកក្នុងចិត្ត មិនឲ្យយឺតយូរពេក ។*

**៤. វិក្ខេបបដិពាហនតោ** *កាលបើចិត្តលះបង់នូវកម្មដ្ឋាន ហើយរាទៅរកអារម្មណ៍ដទៃជាខាងក្រៅ ត្រូវធ្វើទុកក្នុងចិត្តទប់មិនឲ្យរាថយទៅវិញបាន ។*

**៥. បណ្ណត្តិសមតិក្កមនតោ** *ត្រូវធ្វើទុកក្នុងចិត្តកន្លងនូវបញ្ញត្តិដែលលោកហៅថា "សក់ រោម" ជាដើម ហើយតាំងចិត្តទុកថាជាបដិកូលៗ ប៉ុណ្ណោះ ។*

**៦. អនុបុព្វមុញ្ចនតោ** *ត្រូវធ្វើទុកក្នុងចិត្តរៀងតាមលំដាប់នៃកោដ្ឋាស កាលបើកោដ្ឋាសណាមិនប្រាកដឡើង ត្រូវលះបង់ចេញ ហើយធ្វើទុកក្នុងចិត្តតែកោដ្ឋាសណាដែលប្រាកដឡើង ។*

**៧.អប្បនាតោ** ត្រូវឲ្យដឹងកោដ្ឋាសដែលនាំមកនូវអប្បនា គឺត្រូវឲ្យដឹងថា "អាការទាំង ៣២ មានសក់ជាដើម សុទ្ធតែមានអំណាចនឹងញ៉ាំងអប្បនាចិត្ត ឲ្យកើតឡើងបានទាំងអស់" ។

**៨.អធិចិត្តតោ** ត្រូវឲ្យដឹងអធិចិត្តសូត្រដែលព្រះមានព្រះភាគទ្រង់សម្ដែងថា "ត្រូវឲ្យធ្វើទុកក្នុងចិត្តសព្វៗ កាល នូវនិមិត្ត ៣ យ៉ាងគឺ : សមាធិនិមិត្ត ១ បគ្គហនិមិត្ត ១ ឧបេក្ខានិមិត្ត ១ " ។

**៩.សីតភាវតោ** ត្រូវឲ្យដឹងនូវសីតភាវសូត្រ ដែលព្រះមាន-ព្រះភាគ ទ្រង់សម្ដែងថា "ភិក្ខុដែលប្រកបដោយធម៌ ៦ យ៉ាង គួរធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបាន" ។

**១០.សត្តពោជ្ឈង្គកោសល្លសុត្តតោ** ត្រូវឲ្យដឹងនូវសត្តពោជ្ឈង្គកោសល្លសូត្រ ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងថា "ត្រូវឲ្យចម្រើននូវពោជ្ឈង្គទាំង ៧ ពោជ្ឈង្គណាមួយក្នុងពេលដែលចិត្តកំពុងរួញរាជាដើម " ។

ព្រះយោគី កាលបើបានរៀនយកនូវឧគ្គហកោសល្ល ៧ យ៉ាង និងមនសិការកោសល្ល ១០ យ៉ាង ដូចពោលមកនេះបានកំណត់ពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ គ្រប់កោដ្ឋាស មានសក់ជាដើម រួចហើយត្រូវធ្វើទុកក្នុងចិត្តថា ជាបដិកូលដោយស្ថាន ៥ យ៉ាង កុំឲ្យរហ័សពេកនិងយឺតយូរពេកជាដើម ។

បដិកូលដោយស្ថាន ៥ យ៉ាងនោះដូចម្តេច ?

បដិកូលដោយស្ថាន ៥ យ៉ាងនោះគឺ :

**១.វណ្ណតោ** *បដិកូលដោយពណ៌ ។*

**២.សណ្ឋានតោ** *បដិកូលដោយសណ្ឋាន ។*

**៣.គន្ធតោ** *បដិកូលដោយក្លិន ។*

**៤.អាសយតោ** *បដិកូលដោយទីអាស្រ័យនៅ ។*

**៥.ឱកាសតោ** *បដិកូលដោយឱកាសដែលប្រតិស្ឋាន ។*

*កាលបើព្រះយោគី បានធ្វើទុកក្នុងចិត្តថាជាបដិកូលដោយស្ថានទាំង ៥ យ៉ាងនេះ ដរាបដល់កោដ្ឋាសដែលមាននៅក្នុងកាយទាំងប៉ុន្មាន តាំងឡើងប្រាកដស្មើគ្នា មិនមុនមិនក្រោយ គ្រាន់តែធ្វើមនសិការជាអនុលោមថា "កេសា" ប៉ុណ្ណោះ មនសិការនោះក៏រត់ទៅទល់ដល់ "មុត្តំ" ជាទីបំផុតធ្វើមនសិការជាបដិលោមថា "មុត្តំ" ប៉ុណ្ណោះ មនសិការនោះ ក៏រត់ត្រឡប់មកទល់ដល់ "កេសា" ជាខាងដើមវិញ សូម្បីធ្វើមនសិការក្នុងកាយរបស់បុគ្គលដទៃជាខាងក្រៅ ក៏ប្រាកដឡើងដូចគ្នា បើមនុស្សនិងសត្វតិរច្ឆានជាដើម ដើរមកចំពោះមុខ ក៏លះបង់នូវអាការជាសត្វ ប្រាកដឡើងជាគំនរនៃកោដ្ឋាស*

ទាំងអស់ ទឹកនិងភោជនដែលសត្វទាំងនោះផឹក បរិភោគចូលទៅក៏ប្រាកដហាក់ដូចជាដាច់ចុះទៅក្នុងគំនរនៃកោដ្ឋាសទាំង ៣២ ។

បើព្រះយោគី ធ្វើទុកក្នុងចិត្តដោយបដិកូលឲ្យរឿយៗ តាមមនសិការកោសល្លវិធីទាំង ១០ យ៉ាង លំដាប់មកអប្បនាចិត្តក៏នឹងកើតឡើង ។

ក៏ក្នុងអនុស្សតិកម្មដ្ឋានទាំង ១០ ឧគ្គហនិមិត្តនិងបដិភាគនិមិត្តមិនបានកើតគ្រប់ទាំងអស់ឡើយ គឺកើតតែក្នុងកាយគតាសតិកម្មដ្ឋានប៉ុណ្ណោះឯង ។

តែឧគ្គហនិមិត្តក្នុងកាយគតាសតិកម្មដ្ឋាននេះ ឃើញអាការទាំង ៣២ តាំងឡើងប្រាកដដោយពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ ឯបដិភាគនិមិត្ត ប្រាកដឡើងដោយបដិកូលគ្រប់អាការទាំងអស់ ។

បើព្រះយោគី សេពនូវបដិភាគនិមិត្តនោះ ដោយច្រើនចម្រើនឲ្យរឿយៗទៅ អប្បនាចិត្តក៏នឹងកើតឡើង តែកើតបានតែត្រឹមបឋមជ្ឈានប៉ុណ្ណោះ ដូចក្នុងអសុភកម្មដ្ឋានដែរ ។

ចប់ កាយគតាសតិ ។

# ៨.៦ អានាបានស្សតិ

*កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវអានាបានស្សតិកម្មដ្ឋាន គប្បីធ្វើនូវបុព្វកិច្ចមានជម្រះសីលរបស់ខ្លួនឲ្យបរិសុទ្ធជាដើម ហើយរៀនយកនូវកម្មដ្ឋានឲ្យប្រកបដោយសន្ធិ ៥ យ៉ាង ក្នុងសំណាក់នៃអាចារ្យដែលជាកល្យាណមិត្តជាមុន រួចហើយសឹមចម្រើន ។*

សន្ធិ ៥ យ៉ាងនោះដូចម្តេច ?

សន្ធិ ៥ យ៉ាងនោះ គឺ :

**១-ឧគ្គហោ** *ត្រូវរៀនយកនូវគម្ពីរដែលសម្តែងអំពីកម្មដ្ឋាននេះ ឲ្យបានចេះដឹងសេចក្តីអធិប្បាយសព្វគ្រប់ ។*

**២-បរិបុច្ឆនា** *ត្រូវសាកសួរអាចារ្យឲ្យច្បាស់លាស់ ត្រង់សេចក្តីណាដែលនៅមានសង្ស័យ ។*

**៣-ឧបដ្ឋានំ** *ត្រូវតម្កល់ទុកនូវនិមិត្តដែលចម្រើនបានកើតឡើងហើយ ។*

**៤-អប្បនា** *ត្រូវរៀនឲ្យដឹងថា "ដែលនឹងដល់នូវកម្មដ្ឋាននេះនោះ យ៉ាងនេះៗ" ។*

**៥. លក្ខណំ** ត្រូវរៀនឲ្យដឹងនូវលក្ខណៈនៃកម្មដ្ឋាននេះ ថា "ដែលទីងអាចចម្រើនបានដល់នូវអប្បនានោះ ដោយអំណាចនៃគណនាវិធី អនុពន្ធនាវិធី និងផុសនាវិធី " ។

ក្នុងគម្ពីរសារត្ថទីបនីដីកា លោកពោលទុកថា ៖

ពាក្យថា **មានសន្ធិ ៥** គឺ មាន ៥ ប្រការ អធិប្បាយថា មាន ៥ ចំណែក ។ ពាក្យថា **ការរៀនកម្មដ្ឋាន** បានដល់ ការរៀនគម្ពីរកម្មដ្ឋាន ។ ការសាកសួរសេចក្ដីនៃគម្ពីរកម្មដ្ឋាននោះ ឈ្មោះថា ការសាកសួរកម្មដ្ឋាន ។ ម្យ៉ាងទៀត ការរៀនកម្មដ្ឋានដោយគម្ពីរ និងដោយសេចក្ដី ឈ្មោះថា ការរៀន ។ ការសាកសួរចំណុចដែលសង្ស័យក្នុងគម្ពីរ និងសេចក្ដីនោះ ឈ្មោះថា ការសាកសួរ ។ ពាក្យថា **សេចក្ដីប្រាកដនៃកម្មដ្ឋាន** បានដល់ សេចក្ដីប្រាកដនៃនិមិត្ត គឺការចូលទៅទ្រទ្រង់ទុក ព្រោះនិមិត្តនេះប្រាកដយ៉ាងនេះដល់យោគាវចរដែលប្រកបរឿយៗ នូវភាវនាយ៉ាងនេះ ។ ការកៀកជាប់នៃកម្មដ្ឋាន ក៏ដូចគ្នាតែម្យ៉ាង រមែងញ៉ាំងឈានឲ្យប្រាកដយ៉ាងនេះ ។ ពាក្យថា **លក្ខណៈនៃកម្មដ្ឋាន** បានដល់ ការញ៉ាំងភាវនាឲ្យឈានទៅមុខ ដោយអំណាចគណនាវិធីអនុពន្ធនាវិធី និងផុសនាវិធី ហើយដល់ឋបនាវិធី គឺថ្នាក់អប្បនា ឬការដល់ទីបំផុតដោយអំណាច ការកំណត់ជាដើម សូម្បីក្រៃលែងជាងនោះ ព្រោះដូច្នេះ ទើបជាការកំណត់សភាវៈនៃកម្មដ្ឋាន ។ ដោយហេតុនោះ

*លោកអាចារ្យទើបពោលថា មានអធិប្បាយថា ការពិចារណាសភាពនៃកម្មដ្ឋាន ។*

*ក្នុងគម្ពីរវិសុទ្ធិមគ្គ លោកពោលទុកថា ៖*

*លុះព្រះយោគីបានរៀនយកនូវកម្មដ្ឋាន ប្រកបដោយសន្ធិទាំង ៥ នេះ ស្ទាត់ហើយ ត្រូវចូលទៅកាន់សេនាសនៈដ៏សមគួរអង្គុយនៅឲ្យស្រួល រឭកដល់គុណព្រះរតនត្រៃ ញ៉ាំងចិត្តឲ្យជ្រះថ្លាជាមុនហើយ សន្សំធ្វើទុកក្នុងចិត្ត តាមលំអានដែលរៀនមកអំពីសំណាក់នៃអាចារ្យ កុំឲ្យភ្លេចត្រង់បទណានីមួយឡើយ ។*

មនសិការវិធី គឺ វិធីដែលត្រូវធ្វើទុកក្នុងចិត្តនូវអានាបាន-ស្សតិកម្មដ្ឋាននេះ មាន ៨ យ៉ាង ។

មនសិការវិធីទាំង ៨ យ៉ាងនោះអ្វីខ្លះ ? អធិប្បាយដូចម្ដេច ?

មនសិការវិធីទាំង ៨ យ៉ាងនោះគឺ :

**១-គណនា** *កិរិយារាប់នូវខ្យល់អស្សាសៈ បស្សាសៈ*

**២-អនុពន្ធនា** *កិរិយាចងក្រៀកស្មារតីបញ្ជូនទៅតាមខ្យល់អស្សាសៈ បស្សាសៈ ។*

**៣-ផុសនា** *ទីដែលខ្យល់អស្សាសៈ បស្សាសៈពាល់ត្រូវ ។*

**៤.ឋបនា** *កិរិយាតម្កល់ចិត្តទុកក្នុងអារម្មណ៍ដោយប្រពៃ បានដល់ អប្បនា ។*

**៥.សល្លក្ខណា** *កិរិយាកំណត់នូវអនិច្ចាទិលក្ខណៈ បានដល់ វិបស្សនាបញ្ញា ។*

**៦.វិវដ្ដនា** *កិរិយាវិលត្រឡប់ចាកបវត្តធម៌ និងនិមិត្តធម៌ បានដល់ មគ្គ ៤ ។*

**៧.បារិសុទ្ធិ** *ការៈស្អាតដោយជុំវិញចាកសង្កិលេសធម៌ បានដល់ ផល ៤ ។*

**៨.បដិបស្សនា** *ប្រាជ្ញាដែលពិចារណាឃើញនូវលក្ខណៈ តាមលំដាប់នៃវិបស្សនា បានដល់ បច្ចវេក្ខណញ្ញាណ ១៩ ក្នុងមនសិការវិធីទាំង ៨ នេះ ពីត្រឹមទី ១ ដល់ទី ៤ សម្រាប់ព្រះយោគី ដែលជាអាទិកម្មិកៈ ពីត្រឹមទី៥ ដល់ទី៨ សម្រាប់ព្រះយោគីដែល បានចតុក្កជ្ឈាន និងបញ្ចកជ្ឈានហើយ ។*

*ត្រង់គណនាវិធីទី ១ អធិប្បាយថា ព្រះយោគីដែលជាអាទិកម្មិកៈ កាលដែលធ្វើទុកនូវកម្មដ្ឋាននេះ គប្បីធ្វើទុកក្នុងចិត្តដោយ កិរិយារាប់ជាមុន ។*

ក៏វិធីដែលរាប់នោះ មិនត្រូវរាប់ឲ្យតិចជាង ៥ ព្រោះទីឱកាសចង្អៀត ចិត្តនឹងញាប់ញ័រ មិនត្រូវរាប់ឲ្យច្រើនលើសជាង ១០ ព្រោះចិត្តនឹងអាស្រ័យនៅតែក្នុងវិធីរាប់ប៉ុណ្ណោះ មិនត្រូវបង្អង់ត្រង់ចន្លោះៗ ព្រោះចិត្តប្រាល់ ត្រូវរាប់ដើមដំបូងរង្វើលៗ គួបខ្យល់ចេញ និងខ្យល់ចូល រាប់ទៅជាគូៗ ខ្យល់ណាដែលប្រាកដនៅត្រង់ក្តោងប្រមុះ ត្រូវចាប់រាប់ខ្យល់នោះមុនគេ ថា " មួយៗ ពីរៗ ។ល។ ប្រាំបួនៗ ដប់ៗ " ដរាបដល់ខ្យល់អស្សាសៈបស្សាសៈ ប្រាកដឡើង ។

លុះដល់ខ្យល់អស្សាសៈបស្សាសៈ ប្រព្រឹត្តទៅកាន់តែរហ័សឡើង ត្រូវរាប់ក៏ឲ្យកាន់តែញាប់ឡើងទៀត ហើយមិនត្រូវចាប់យកខ្យល់ ដែលចេញមកអំពីខាងក្នុង នឹងចូលទៅអំពីខាងក្រៅមករាប់ឡើយ ត្រូវចាប់យកតែខ្យល់ដែលប៉ះត្រូវដល់ទ្វារប្រមុះប៉ុណ្ណោះ មករាប់ថា "មួយ ពីរ បី បួន ប្រាំ ។ មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ។ មួយ ពីរ ។ល។ ប្រាំមួយ ប្រាំពីរ ។ មួយ ពីរ ។ល។ ប្រាំពីរ ប្រាំបី ។ មួយ ពីរ ។ល។ ប្រាំបី ប្រាំបួន ។ មួយ ពីរ ។ល។ ប្រាំបួន ដប់" ។

កាលបើកម្មដ្ឋាន ជាប់នៅដោយកិរិយារាប់យ៉ាងនេះហើយ ចិត្តក៏តម្កល់នៅមាំ មានអារម្មណ៍តែមួយយ៉ាងឯក មិនតែប៉ុណ្ណោះ ដោយអំណាចដែលតម្កល់ទុកនូវស្មារតី ចម្រើនត្រង់ឱកាសដែលខ្យល់

អស្សាសៈបស្សាសៈ ប៉ះពាល់ត្រូវយ៉ាងនេះ ភាវនាក៏នឹងបាន សម្រេចមិនខាន ។

ត្រង់អនុពន្ធនាវិធីទី ២ អធិប្បាយថា កាលបើព្រះយោគី ធ្វើទុកក្នុងចិត្តដោយកិរិយារាប់រួចហើយ ត្រូវបញ្ឈប់ហើយបញ្ជូនស្មារតីទៅតាមខ្យល់អស្សាសៈបស្សាសៈ ធ្វើទុកក្នុងចិត្តកុំឲ្យមានចន្លោះ តែមិនត្រូវធ្វើទុកក្នុងចិត្តដោយអំណាចខាងដើម និងពាក់កណ្ដាល និងខាងចុងថា "ខ្យល់ដង្ហើមចេញ ផ្ចិតជាខាងដើម បេះដូងជាកណ្ដាល ចុងច្រមុះជាខាងចុង ខ្យល់ដង្ហើមចូល ចុងច្រមុះជាខាងដើម បេះដូងជាកណ្ដាល ផ្ចិតជាខាងចុង" ដូច្នេះឡើយ ព្រោះជាហេតុនាំឲ្យចិត្តរាយមាយ ។

ត្រង់ផុសនាវិធីទី ៣ មិនមែនជាផ្សេងគ្នាចាកគណនាវិធី និងអនុពន្ធនាវិធីនោះឡើយ គឺសំដៅយកត្រង់បញ្ជូនស្មារតីទៅតាមវិធីនៃកិរិយារាប់ហើយស្ទង់ ពិចារណាធ្វើទុកក្នុងចិត្តមិនឲ្យមានចន្លោះ ត្រង់ឱកាស ដែលខ្យល់អស្សាសៈបស្សាសៈ ពាល់ត្រូវហើយនោះប៉ុណ្ណោះឯង ។

ត្រង់ឋបនាវិធីទី ៤ អធិប្បាយថា កាលដែលព្រះយោគីរាប់នូវខ្យល់អស្សាសៈ បស្សាសៈ ត្រង់កន្លែងដែលប៉ះពាល់ត្រូវទ្វារហើយ ធ្វើទុកក្នុងចិត្តនូវខ្យល់នោះៗ ដោយរាប់ផង ដោយកំណត់តែ

ត្រង់ទីដែលខ្យល់មកប៉ះពាល់ត្រូវផង រួចហើយបង្អង់រាប់ក្នុងទីនោះ តាំងបញ្ជូនស្មារតីទៅកាន់ខ្យល់អស្សាសៈបស្សាសៈ ទាំងនោះ បើនិមិត្តណាប្រាកដឡើង គួរល្មមញុំាងអប្បនាចិត្តឲ្យកើតឡើងបាន ក៏តម្កល់ចិត្តទុកតែក្នុងនិមិត្តនោះប៉ុណ្ណោះ ។

ត្រង់ទី ៥ - ៦ - ៧ - ៨ អធិប្បាយថា ព្រះយោគីដែលបានដល់ចតុក្កជ្ឈាន និងបញ្ចកជ្ឈានហើយ បើមានប្រាថ្នាដើម្បីចម្រើននូវកម្មដ្ឋាននេះ ដោយសល្លក្ខណាវិធី គឺវិធីនៃវិបស្សនាញាណ និងវិវដ្តនាវិធី គឺវិធីនៃអរិយមគ្គទាំង ៤ ឲ្យបានដល់នូវបារិសុទ្ធិ គឺព្រះអរិយផលទាំង ៤ ហើយនឹងតម្កល់នៅក្នុងភាវៈជាព្រះអរហន្ត ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ អ្នកដល់នូវទីបំផុតនៃបដិបស្សនា គឺបច្ចវេក្ខណញ្ញាណមានប្រភេទ ១៩ យ៉ាងនោះ ក៏គប្បីធ្វើឈាននោះឲ្យស្ទាត់ដោយវសីទាំង ៥ ហើយកំណត់នូវនាមនិងរូប ចម្រើននូវវិបស្សនាតទៅទៀត នឹងបានសម្រេចដូចសេចក្តីប្រាថ្នា ។

ក៏ក្នុងអានាបានស្សតិកម្មដ្ឋាននេះ បើព្រះយោគីជាអាទិកម្មិកៈ តម្កល់ចិត្តក្នុងឱកាសដែលខ្យល់អស្សាសៈបស្សាសៈ ពាល់ត្រូវជាប្រក្រតី ញុំាងមនសិការឲ្យប្រព្រឹត្តទៅរឿយៗ ដោយឧបាយនៃប្រាជ្ញាតាមលំអាននៃមនសិការវិធីទាំង ៤ ខាងដើម មិនយូរប៉ុន្មានឡើយ ខ្យល់អស្សាសៈបស្សាសៈ ទាំងឡាយនោះ ក៏នឹងប្រាកដឡើងហើយ

ឧគ្គហនិមិត្តនិងបដិភាគនិមិត្ត ក៏នឹងកើតឡើងផង តែថានិមិត្តទាំង ២ យ៉ាងនោះ ក្នុងកម្មដ្ឋាននេះ លោកសម្តែងគួបចូលជាមួយគ្នា ពុំបានញែកឲ្យឃើញដោយឡែកៗ អំពីគ្នាឡើយ ។

ព្រះយោគីអង្គខ្លះ ដែលញុំាងសុខសម្ផស្សឲ្យកើតឡើងបាន និមិត្តតាំងឡើងប្រាកដដូចប៉ុយគក៏មាន ដូចប៉ុយកប្បាសក៏មាន ដូចទរខ្យល់ក៏មាន[១] ដូចដួងផ្កាយក៏មាន ដូចដួងកែវមណីក៏មាន ដូចដួងកែវមុក្តាក៏មាន បើព្រះយោគីអង្គខ្លះ ដែលញុំាងសម្ផស្សឲ្យកើតឡើងរឹង និមិត្តតាំងឡើងប្រាកដដូចគ្រាប់កប្បាសក៏មាន ដូចជក់ធ្វើដោយឈើខ្លឹមក៏មាន ដូចសរសៃសង្វារកែវក៏មាន ដូចចង្កោមផ្កាក៏មាន ដូចសំណុំផ្សែងក៏មាន ដូចសរសៃពីងពាងក៏មាន ដូចផ្ទៃពលាហកក៏មាន ដូចផ្កាឈូកក៏មាន ដូចកង់នៃរថក៏មាន ដូចមណ្ឌលនៃព្រះចន្ទ្រក៏មាន ដូចមណ្ឌលនៃព្រះអាទិត្យក៏មាន [២] ។

ចាប់ដើមអំពីនិមិត្តកើតឡើងយ៉ាងនេះ នីវរណធម៌ និងកិលេសរបស់ព្រះយោគីអង្គនោះ ក៏ទ្រោមស្ងប់ទៅ សតិក៏ប្រុងឡើង ហើយចិត្តសោតក៏តម្កល់នៅមាំដោយឧបចារសមាធិ ។

---

(១) នេះជាពាក្យកេចិអាចារ្យ ។ (២) នេះជាពាក្យវិនិច្ឆ័យក្នុងអដ្ឋកថា ។

*បើព្រះយោគីរក្សាទុកនូវនិមិត្តនោះ ឲ្យល្អដោយរក្ខណាវិធីធ្វើទុកក្នុងចិត្តឲ្យរឿយៗ ដោយអប្បនាកោសល្លវិធី ហើយប្រកបព្យាយាមឲ្យស្មើ កុំតែធ្វើទុកក្នុងចិត្តដោយពណ៌ និងពិចារណាដោយលក្ខណៈ ក៏នឹងអាចញ៉ាំងអប្បនាឈានឲ្យកើតឡើងបាន ទាំងចតុក្ក-ន័យ និងបញ្ចកន័យ ដូចក្នុងកសិណទាំង ១០ ដែរ ។*

## អានាបានស្សតិក្នុងវិនយបិដក

*(វិនយបិដក ភាគ១ ទំព័រ២២៨)*

*គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់យាងចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ទ្រង់គង់ប្រថាប់លើអាសនៈដែលគេតាក់តែងថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយទើបត្រាស់នឹងពួកភិក្ខុដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយអានាបានស្សតិសមាធិនេះឯង ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនជាប្រក្រតីហើយ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ គឺជាធម៌ដោយឡែកផង ជាគ្រឿងនៅនាំមកនូវសេចក្តីសុខផង តែងញ៉ាំងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងៗ ឲ្យសាបសូន្យទៅផង ឲ្យស្ងប់រម្ងាប់ផង ដោយទំនងដ៏សមគួរ ។ល។*

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តាំងសតិ ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។

ភិក្ខុនោះមានសតិដកដង្ហើមចេញ

មានសតិដកដង្ហើមចូល

កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង

ឬកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថាអាត្មាអញ ដកដង្ហើមចូលវែង

កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី

ឬក៏កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី

(ភិក្ខុ) សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ

សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំងពួង ហើយដកដង្ហើមចូល

*សិក្សាថា អាត្មាអញនឹងនូវរម្ងាប់កាយសង្ខារ (អស្សាស-បស្សាសៈ) ហើយដកដង្ហើមចេញ*

*សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារហើយដកដង្ហើមចូល ។*

*សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវបីតិ (គឺសេចក្តីឆ្អែតកាយ ឆ្អែតចិត្ត) សឹមដកដង្ហើមចេញ*

*សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវបីតិ សឹមដកដង្ហើមចូល*

*សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវសុខ (គឺសុខកាយសុខចិត្ត) សឹមដកដង្ហើមចេញ*

*សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវសុខ សឹមដកដង្ហើមចូល*

*សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវចិត្តសង្ខារ (គឺវេទនា និងសញ្ញា) សឹមដកដង្ហើមចេញ*

*សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវចិត្តសង្ខារ សឹមដកដង្ហើមចូល*

*សិក្សាថា អាត្មាអញនឹងរម្ងាប់ចិត្តសង្ខារ សឹមដកដង្ហើមចេញ*

*សិក្សាថា អាត្មាអញនឹងរម្ងាប់ចិត្តសង្ខារ សឹមដកដង្ហើមចូល*

សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវចិត្ត សឹមដកដង្ហើមចេញ

សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវចិត្ត សឹមដកដង្ហើមចូល

សិក្សាថា អាត្មាអញនឹងធ្វើចិត្តឲ្យរីករាយ សឹមដកដង្ហើមចេញ

សិក្សាថា អាត្មាអញនឹងធ្វើចិត្តឲ្យរីករាយ សឹមដកដង្ហើមចូល

សិក្សាថា អាត្មាអញនឹងតាំងចិត្តខ្ជាប់ សឹមដកដង្ហើមចេញ

សិក្សាថា អាត្មាអញនឹងតាំងចិត្តខ្ជាប់ សឹមដកដង្ហើមចូល

សិក្សាថា អាត្មាអញនឹងដោះចិត្តឲ្យផុតស្រឡះ សឹមដកដង្ហើមចេញ

សិក្សាថា អាត្មាអញនឹងដោះចិត្តឲ្យផុតស្រឡះ សឹមដកដង្ហើមចូល

សិក្សាថា អាត្មាអញនឹងពិចារណាដោយសភាពជារបស់មិនទៀង សឹមដកដង្ហើមចេញ

សិក្សាថា អាត្មាអញនឹងពិចារណាដោយសភាពជារបស់មិនទៀង សឹមដកដង្ហើមចូល

សិក្សាថា អាត្មាអញនឹងពិចារណាដោយសភាពឥតរាគៈ សឹមដកដង្ហើមចេញ

សិក្សាថា អាត្មាអញនឹងពិចារណាដោយសភាពឥតរាគៈ សឹមដកដង្ហើមចូល

សិក្សាថា អាត្មាអញនឹងពិចារណាដោយសភាពរលត់ទៅ សឹមដកដង្ហើមចេញ

សិក្សាថា អាត្មាអញនឹងពិចារណាដោយសភាពរលត់ទៅ សឹមដកដង្ហើមចូល

សិក្សាថា អាត្មាអញនឹងពិចារណារឿយៗ ដោយកិរិយាលះបង់នូវសេចក្ដីប្រកាន់ សឹមដកដង្ហើមចេញ

សិក្សាថា អាត្មាអញនឹងពិចារណារឿយៗ ដោយកិរិយាលះបង់នូវសេចក្ដីប្រកាន់ សឹមដកដង្ហើមចូល ។

## អ ដ្ឋ ក ថា

បណ្ដាបទទាំងនោះ បទថា អយម្បិ ខោ ភិក្ខវេ ជាដើមនេះ មានយោជនាដូចតទៅនេះ ជាដំបូងថា ៖

ម្នាលភិក្ខុទាំងឡាយ មិនមែនអសុភភាវនាតែម្យ៉ាងប៉ុណ្ណោះ រមែងប្រព្រឹត្តទៅដើម្បីលះកិលេសទេ, ម្យ៉ាងទៀត សូម្បីអានាបាន-ស្សតិសមាធិនេះឯង ដែលភិក្ខុអប់រំ ធ្វើឲ្យច្រើនហើយ រមែងជាគុណ

ស្ងប់ ប្រណីត ត្រជាក់ នៅជាសុខ និងញុំាងបាបអកុសលធម៌ដែលកើតឡើងហើយៗ ឲ្យអន្តរធានស្ងប់ទៅដោយឆាប់រហ័ស ។

ក៏ក្នុងពាក្យថា អានាបានស្សតិសមាធិជាដើមនេះ មានអត្ថវណ្ណនាដូចតទៅនេះ ៖

សតិកំណត់ខ្យល់ដកដង្ហើមចូលនិងខ្យល់ដកដង្ហើមចេញ ឈ្មោះថា **អានាបានស្សតិ** ។ សមពិតដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រ ពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គថា ខ្យល់ដកដង្ហើមចូលឈ្មោះថា **អាន:** មិនមែនបស្សាស:, ខ្យល់ដកដង្ហើមចេញ ឈ្មោះថា **បាន:** មិនមែនអស្សាស:, សតិចូលទៅតាំងនៅ ដោយអំណាចខ្យល់ដកដង្ហើមចូល សតិចូលទៅតាំងនៅដោយអំណាចខ្យល់ដកដង្ហើមចេញ រមែងប្រាកដដល់បុគ្គលដែលដកដង្ហើមចូល រមែងប្រាកដដល់បុគ្គលដែលដកដង្ហើមចេញ ។ ចិត្តមានអារម្មណ៍តែមួយ ដែលកើតឡើងព្រមនឹងសតិដែលកំណត់ខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញនោះ ឈ្មោះថា **សមាធិ** ។ ក៏ទេសនានេះ លោកពោលទុកដោយគោល គឺសមាធិ មិនមែនដោយគោល គឺសតិទេ ។ ព្រោះដូច្នោះ ក្នុងបទថា **អានាបានស្សតិសមាធិ** នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា សមាធិដែលប្រកបដោយអានាបានស្សតិ ឬសមាធិក្នុងអានាបានស្សតិ ឈ្មោះថា **អានាបានស្សតិសមាធិ** ។

បទថា **ដែលបុគ្គលចម្រើនហើយ**, គឺឲ្យកើតឡើង ឬឲ្យចម្រើនហើយ ។

បទថា **ធ្វើឲ្យច្រើនជាប្រក្រតីហើយ**, គឺ ធ្វើរឿយៗ ។

ពីរបទថា សន្តោ ចេវ បណីតោ ច គឺជាគុណស្ងប់ផង ជាគុណប្រណីតផងនោះឯង ។ ក្នុងបទទាំងពីរគប្បីជ្រាប សេចក្តីពិតប្រាកដដោយ **ឯវ** សទ្ទ ។ លោកពោលអធិប្បាយទុកយ៉ាងណា ? លោកពោលអធិប្បាយទុកថា ពិតមែន អានាបានស្សតិសមាធិនេះ នឹងជាធម៌មិនស្ងប់ ឬមិនប្រណីត ដោយបរិយាយណាៗ ដូចអសុភ-កម្មដ្ឋានដែលជាកម្មដ្ឋានស្ងប់ និងប្រណីត ដោយអំណាចការចាក់ធ្លុះតែម្យ៉ាង តែមិនស្ងប់ មិនប្រណីត ដោយអំណាចអារម្មណ៍ ព្រោះមានអារម្មណ៍គ្រោតគ្រាត និងព្រោះមានអារម្មណ៍បដិកូលដូច្នោះ ក៏ទេ ។

មួយទៀត អានាបានស្សតិសមាធិនេះឯង ស្ងប់ គឺរម្ងាប់ រលត់អស់ ព្រោះមានអារម្មណ៍ស្ងប់ខ្លះ ព្រោះមានអង្គ គឺការចាក់ធ្លុះ ស្ងប់ខ្លះ ប្រណីត គឺមិនធ្វើឲ្យខូចសេចក្តីត្រេកអរ ព្រោះមានអារម្មណ៍ប្រណីតខ្លះ ព្រោះមានអង្គប្រណីតខ្លះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យថា ស្ងប់ និងប្រណីត ។

ក៏ក្នុងពាក្យថា **ជាធម៌មិនប្រឡូកប្រឡំផង ជាគ្រឿងនាំមកនូវសេចក្តីសុខផង** នេះ មានវិនិច្ឆ័យដូច្នេះ ៖

អានាបានស្សតិសមាធិនោះ មិនមានទោសជាគ្រឿងស្រោច; ព្រោះដូច្នោះ ទើបឈ្មោះថា ត្រជាក់ គឺមិនមានគ្រឿងស្រោច មិនលាយច្រឡំ ជាផ្នែកមួយផ្សេងដទៃ មិនទូទៅ ។ ម្យ៉ាងទៀត សេចក្ដីស្ងប់ដោយបរិកម្ម ឬដោយឧបចារក្នុងអានាបានស្សតិសមាធិនេះ មិនមាន ។ អធិប្បាយថា ជាធម៌ស្ងប់និងប្រណីត ដោយសភាពរបស់ខ្លួនតែម្ដង ចាប់តាំងពីធ្វើទុកក្នុងចិត្តខាងដើម ។ តែអាចារ្យពួកខ្លះ ពោលថា បទថា អសេចនកោ សេចក្ដីថា មិនមានគ្រឿងស្រោច គឺ មានឱជៈ មានរសឆ្ងាញ់ដោយសភាពពិតតែម្យ៉ាង ។ ដោយអត្ថដូចពោលមកយ៉ាងនេះ អានាបានស្សតិសមាធិនេះ បណ្ឌិតគប្បីជ្រាបថា ត្រជាក់និងនៅជាសុខ ព្រោះប្រព្រឹត្តទៅដើម្បីឲ្យបានសេចក្ដីសុខផ្លូវកាយ និងផ្លូវចិត្ត ក្នុងខណៈដែលចូលដល់ហើយៗ ។

បទថា វូបសមេតិ សេចក្ដីថា រមែងឲ្យស្ងប់ទៅដោយល្អ ។ ម្យ៉ាងទៀត អធិប្បាយថា អានាបានស្សតិសមាធិនេះ រមែងដល់សេចក្ដីចម្រើនដោយអរិយមគ្គតាមលំដាប់ ព្រោះមានចំណែកនៃការចាក់ធ្លុះ រមែងកាត់ផ្ដាច់ដោយល្អ គឺរមែងស្ងប់រម្ងាប់បាន ។

ក្នុងពាក្យថា កថំ ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

ពាក្យថា កថំ ជាពាក្យសួរ គឺភាពជាអ្នកប្រាថ្នានឹងញុំាងអានាបានស្សតិសមាធិភាវនាឲ្យពិស្ដារ ដោយប្រការផ្សេងៗ ។

ពាក្យថា ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ ជាពាក្យសម្តែងខែអត្ថនៃធម៌ដែលត្រូវសួរ ព្រោះភាពជាអ្នកប្រាថ្នានឹងញ៉ាំងអានាបានស្សតិសមាធិនោះឲ្យពិស្តារ ដោយប្រការផ្សេងៗ ។ សូម្បីក្នុងបទទីពីរ ក៏ន័យនោះ ។

ក៏ក្នុងពាក្យថា ***ដែលបុគ្គលចម្រើនហើយ តើដូចម្តេច ?*** ជាដើមនេះ មានសេចក្តីសង្ខេបដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលភិក្ខុអប់រំហើយ ដោយប្រការណា ដោយអាការណា ដោយវិធីណា ? ធ្វើឲ្យច្រើនហើយដោយប្រការដូចម្តេច ? ទើបជាគុណស្ងប់ប្រណីត ត្រជាក់ នៅជាសុខនិងញ៉ាំងបាបអកុសលធម៌ដែលកើតឡើងហើយៗ ឲ្យអន្តរធានទៅដោយឆាប់រហ័ស ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់ញ៉ាំងសេចក្តីនោះឲ្យពិស្តារ ទើបត្រាស់ថា ឥធ ភិក្ខវេ ជាដើម ។

បណ្តាបទទាំងនោះ បទថា ឥធ ភិក្ខវេ មានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិតមែន ឥធ សព្ទនេះ ក្នុងបទថា ភិក្ខវេ នេះ សម្តែងសាសនាដែលជាទីអាស្រ័យរបស់បុគ្គលដែលឲ្យអានាបានស្សតិសមាធិកើតឡើងដោយប្រការទាំងពួង និងបដិសេធសេចក្តីមិនមានយ៉ាងនោះក្នុងសាសនាដទៃ ។ សមពិតដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា “***ឥធេវ ភិក្ខវេ បឋមោ សមណោ***

*ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ* : ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ (គឺសោតាបន្ន) មានតែក្នុងសាសនានេះ, សមណៈទី ២ (គឺសកទាគាមី) ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ (គឺអនាគាមី) ក៏មានតែក្នុង-សាសនានេះ, សមណៈ ទី ៤ (គឺអរហន្ត) ក៏មានតែក្នុងសាសនានេះ, បរប្បវាទ (វាទៈនៃគ្រូដទៃ)អំពីសំណាក់នៃបុគ្គលដទៃ រមែងសូន្យចាកពួកសមណៈ(នេះ)" ។ ព្រោះហេតុនោះ លោកទើបពោលទុកថា ភិក្ខុក្នុងសាសនានេះ ។

ពាក្យថា អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា នេះ សម្តែងសភាពនៃភិក្ខុនោះ ដែលជ្រើសរើសរកសេនាសនៈដ៏សមគួរដល់ការចម្រើនអានាបានស្សតិសមាធិ ។

ព្រោះថា ចិត្តរបស់ភិក្ខុនេះធ្លាប់ផ្សាយទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើមអស់កាលដ៏យូរមកហើយ ទើបមិនប្រាថ្នាឡើងកាន់អារម្មណ៍របស់អានាបានស្សតិសមាធិ ច្រើនតែត្រាច់ទៅក្រៅផ្លូវប៉ុណ្ណោះ ដូចរថដែលគេទឹមដោយគោខូច ដូច្នោះ ។ ព្រោះដូច្នោះ អ្នកកង្វាលគោត្រូវការបង្ហឹកកូនគោខូច ផឹកទឹកដោះ ទាំងអស់របស់មេគោខូចធំធាត់ហើយ គប្បីផ្តាច់ចេញចាកមេគោ បោះបង្គោលធំ ទុកក្នុងទីសមគួរមួយ ហើយយកខ្សែចងទុកត្រង់បង្គោលនោះ, គ្រានោះកូនគោនោះរបស់គេ ឆ្វេឆ្វាទៅខាងនេះទៅខាងណោះ មិនអាចគេច

ចៀសទៅបានគប្បីឈរផ្អែក ឬដេកផ្អែកបង្គោលនោះឯង យ៉ាងណាមិញ; ភិក្ខុសូម្បីរូបនេះ ក៏យ៉ាងនោះដែរ ប្រាថ្នានឹងទូន្មានបង្ហឹកចិត្តដែលត្រូវទោសប្រទូស្តហើយ ដែលចម្រើនដោយការផឹករសនៃអារម្មណ៍មានរូបជាដើមមកយូរហើយ គប្បីផ្តាច់ចាកអារម្មណ៍ មានរូបជាដើមហើយចូលទៅកាន់ព្រៃ ឬគល់ឈើ ឬផ្ទះស្ងាត់ហើយគប្បីយកខ្សែ គឺសតិចងទុកត្រង់បង្គោល គឺខ្យល់អស្សាសៈ និងបស្សាសៈនោះ កាលបើដូច្នោះ ចិត្តរបស់លោកនោះ សូម្បីនឹងច្រូចឆ្វាទៅខាងនេះទៅខាងណោះ ក៏ដោយកាលមិនបានទទួលអារម្មណ៍ដែលធ្លាប់សន្សំមកក្នុងកាលមុនមិនអាចនឹងកាត់ខ្សែ គឺសតិចេញទៅបាន រមែងផ្តោតចិត្តស្ថិតក្នុងអារម្មណ៍ជាប់នោះឯង ដោយអំណាចឧបចារនិងអប្បនា ។ ព្រោះហេតុនោះ ព្រះបូរាណាចារ្យទាំងឡាយ ទើបពោលថា "នរជនកាលនឹងបង្ហឹកកូនគោ គប្បីចងជាប់ទុកត្រង់បង្គោល យ៉ាងណា ភិក្ខុក្នុងសាសនានេះ គប្បីយកសតិចងចិត្តរបស់ខ្លួនទុកត្រង់អារម្មណ៍ឲ្យមាំ យ៉ាងនោះ" ។

សេនាសនៈនោះ រមែងជាស្ថានទីសមគួរដល់ការចម្រើនអានាបានស្សតិសមាធិនោះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ខ្ញុំព្រះករុណាទើបពោលថា ពាក្យនេះ សម្តែងសភាពដែលភិក្ខុនោះជ្រើសរើសរកសេនាសនៈដ៏សមគួរដល់ការចម្រើនអានាបានស្សតិសមាធិ ។ម្យ៉ាងទៀត ព្រោះអានាបានស្សតិកម្មដ្ឋាននេះ ជាកំពូល

ក្នុងប្រភេទនៃកម្មដ្ឋាន ជាបទដ្ឋាននៃការសម្រេចគុណវិសេស និងជាសុខក្នុងវិហារធម៌ក្នុងបច្ចុប្បន្នរបស់ព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវក ដែលព្រះយោគាវចរមិនលះជាយស្រុកដែលអឺងកងដោយសំឡេងស្ត្រី បុរស ដំរី និងសេះជាដើម នឹងចម្រើនឲ្យដល់ព្រមមិនងាយធ្វើបាន ព្រោះសំឡេងជាបន្លាដល់ឈាន; តែក្នុងព្រៃដែលមិនមែនស្រុកព្រះយោគាវចរកំណត់កម្មដ្ឋាននេះហើយ ញ៉ាំងចតុត្ថជ្ឈាន ដែលមានខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ជាអារម្មណ៍ឲ្យកើតហើយ ធ្វើឈាននោះឯងឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយបានសម្រេចព្រះអរហត្ត ដែលជាផលដ៏ប្រសើរក្រៃលែងនឹងធ្វើបានងាយ; ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងសេនាសនៈដែលសមគួរដល់ភិក្ខុនោះ ទើបត្រាស់ព្រះពុទ្ធវចនៈមានជាដើមថា អរញ្ញគតោ វា ដូច្នេះ ។ ព្រោះថា ព្រះមានព្រះភាគដូចជាអាចារ្យដែលចេះវិទ្យាដឹងជ័យភូមិ ឃើញផ្ទៃដីដែលនឹងសាងនគរ ហើយពិចារណាដោយច្បាស់ល្អហើយចង្អុលថា "សូមព្រះអង្គសាងព្រះនគរក្នុងទីនេះ" កាលនគរសម្រេចហើយដោយសួស្ដី រមែងបានមហាសក្ការៈអំពីរាជត្រកូល យ៉ាងណា, ព្រះមានព្រះភាគនោះទ្រង់ពិចារណាសេនាសនៈដ៏សមគួរដល់ប្រយោគាវចរហើយ ទ្រង់ចង្អុលថា "កម្មដ្ឋានដែលកុលបុត្រអ្នកមានសេចក្ដីព្យាយាម គប្បីប្រារព្ធព្យាយាមក្នុងទីនេះ", តអំពីនោះ កាលព្រះយោគាវចរប្រកប-

កម្មដ្ឋានទៅក្នុងសេនាសនៈនោះហើយ បានសម្រេចព្រះអរហត្តដោយលំដាប់ រមែងបានមហាសក្ការៈថា "ព្រះមានព្រះភាគអង្គនោះ ជាសម្មាសម្ពុទ្ធពិត" យ៉ាងនោះដែរ ។ ចំណែកភិក្ខុនេះលោកហៅថា ដូចជាខ្លាធំ អែបពួនអាស្រ័យស្មៅក្រាស់ៗ ព្រៃស្តុក ឬញកភ្នំ នៅក្នុងព្រៃ រមែងចាប់ពួកម្រឹគ មានក្របីព្រៃ ឈ្លូស (ឬប្រើស) និងជ្រូក-ជាដើម (ជាអាហារ) យ៉ាងណាមិញ ពួកភិក្ខុព្យាយាមចម្រើនកម្មដ្ឋាននៅក្នុងសេនាសនៈមានព្រៃជាដើមនេះ ក៏យ៉ាងនោះដែរ បណ្ឌិតគប្បីជ្រាបថា រមែងតោងបាននូវសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគា-មិមគ្គ អរហត្តមគ្គ និងអរិយផល ដោយលំដាប់ ។ ព្រោះដូច្នោះព្រះបូរាណាចារ្យទាំងឡាយ ទើបពោលថា

> "ដែលឈ្មោះថា ខ្លាធំ រមែងលបចាប់ពួកម្រឹគ (ជាអាហារ) យ៉ាងណាមិញ កុលបុត្រដែលប្រកបសេចក្តីព្យាយាមបំពេញ-វិបស្សនានេះ ក៏យ៉ាងនោះដែរ ចូលទៅកាន់ព្រៃហើយ រមែង-តោងបាននូវផលដ៏ឧត្តម" ។

ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងអរញ្ញសេនាសនៈដែលជាភូមិគួរដល់ការប្រកបដោយបញ្ញាវាងវៃ ដើម្បីសេចក្តីចម្រើនឈានទៅមុខរបស់ព្រះយោគាវចរនោះ ទើបត្រាស់ព្រះពុទ្ធវចនៈមានជាដើមថា អរញ្ញគតោ វា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា អរញ្ញគតោ វា សេចក្ដីថា ទៅកាន់ព្រៃដែលសប្បាយដល់ការពួនសម្ងំកន្ទែងណាមួយ ក្នុងបណ្ដាព្រៃដែលមានលក្ខណៈ ដូចដែលពោលទុកយ៉ាងនេះថា ដែលឈ្មោះថាព្រៃ បានដល់ ស្ថានទីខាងក្រៅពីសរសេខឿនចេញទៅនោះទាំងអស់ឈ្មោះថា ព្រៃ និងថា សេនាសនៈយ៉ាងជិតបំផុតចម្ងាយប្រមាណ ៥០០ ជង្ឃ ឈ្មោះថា សេនាសនៈព្រៃ ។

បទថា រុក្ខមូលគតោ វា សេចក្ដីថា ទៅកាន់ទីជិតដើមឈើ ។

បទថា សុញ្ញាគារគតោ វា សេចក្ដីថា ទៅកាន់ឱកាសដែលស្ងាត់ ដែលទំនេរ ។ តែក្នុងអធិការនេះ សូម្បីកិក្ខុវៀរព្រៃ និងគល់ឈើចេញ, ទៅកាន់សេនាសនៈ ៧ យ៉ាងដ៏សេស ក៏គួរហៅបានថា ទៅកាន់ផ្ទះស្ងាត់ ។

ព្រះមានព្រះភាគ គ្រាទ្រង់ចង្អុលសេនាសនៈដែលសមគួរដល់ការចម្រើនអានាបានស្សតិ ដែលសមគួរដល់រដូវទាំង ៣ និងសមគួរដល់ធាតុនិងចរិយាដល់កិក្ខុនោះយ៉ាងនោះហើយ កាលនឹងទ្រង់ប្រាប់ឥរិយាបថដែលស្ងប់ ដែលជាចំណែកនៃសេចក្ដីមិនរួញរា និងមិនរវើរវាយ ទើបត្រាស់ថា និសីទតិ (អង្គុយ) ដូច្នេះ ។ ក្រោយមកកាលទ្រង់សម្ដែងការៈនៃការអង្គុយជាឥរិយាបថតាំងមាំ ការដែលខ្យល់អស្សាសៈ បស្សាសៈប្រព្រឹត្តទៅស្រួល និងឧបាយគ្រឿងកំណត់

ចាប់អារម្មណ៍ដល់ភិក្ខុនោះ ទើបត្រាស់ព្រះពុទ្ធវចនៈមានជាដើមថា បល្លង្កំ អាភុញ្ជិត្វា (អង្គុយពែនភ្នែន) ដូច្នេះ ។

ពាក្យថា ឧជុំ កាយំ បណិធាយ មានសេចក្តីថា តាំងរាងកាយចំណែកលើឲ្យត្រង់ គឺ ឲ្យឆ្អឹងខ្នង ១៨ កំណាត់ ទល់ទិចុងបំផុតត្រួតបន្តគ្នា ។ ពិតមែន កាលភិក្ខុអង្គុយដោយអាការយ៉ាងនោះហើយ ស្បែក សាច់ និងសរសៃ រមែងមិនកោង ។ វេលានោះវេទនាទាំងឡាយដែលគប្បីកើតឡើងដល់លោកក្នុងខណៈៗ ព្រោះសេចក្តីកោងនៃស្បែកសាច់និងសរសៃទាំងនោះជាបច្ច័យនុ៎ះឯង រមែងមិនកើតឡើង ។ កាលវេទនាទាំងនោះមិនកើតឡើង ចិត្តក៏មានអារម្មណ៍តែមួយ, កម្មដ្ឋានមិនធ្លាក់ទៅ រមែងចូលដល់សេចក្តីចម្រើនរុងរឿង ។

ពាក្យថា បរិមុខំ សតឹ ឧបដ្ឋបេត្វា (តម្កល់ស្មារតីឲ្យមានមុខឆ្ពោះត្រង់) មានសេចក្តីថា តាំងសតិឲ្យបែរមុខចំពោះកម្មដ្ឋាន ។ម្យ៉ាងទៀត ក៏ក្នុងពាក្យថា បរិមុខំ សតឹ ឧបដ្ឋបេត្វា នេះ គប្បីឃើញសេចក្តីតាមន័យដែលព្រះធម្មសេនាបតីសារីបុត្រ ពោលទុកក្នុងគម្ពីរបដិសម្ភិទានោះឯងយ៉ាងនេះថា ស័ព្ទថា បរិ មានការកំណត់កាន់យកជាអត្ថ, ស័ព្ទថា មុខំ មានការនាំចេញជាអត្ថ, ស័ព្ទថា សតិ មានការចូលទៅតាំងទុកជាអត្ថ; ព្រោះហេតុនោះ លោកទើបពោលថា "តាំងសតិ ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ក្នុងបទថា បរិមុខំ

សតី នោះ មានសេចក្ដីសង្ខេបដូច្នេះថា ធ្វើសតិជាគ្រឿងនាំចេញ ដែលខ្លួនកំណត់កាន់យកហើយ ។

## អធិប្បាយវិធីអប់រំសតិ ៣២ យ៉ាង

ពាក្យថា សោ សតោវ អស្សសតិ (ភិក្ខុនោះ មានសតិដកដង្ហើមចេញ) មានសេចក្ដីថា ភិក្ខុនោះអង្គុយយ៉ាងនោះ និងតាំងសតិទុកយ៉ាងនោះហើយ កាលមិនលះសតិនោះ ឈ្មោះថា មានសតិដកដង្ហើមចូល ឈ្មោះថា មានសតិដកដង្ហើមចេញ ។ មានពាក្យអធិប្បាយថា ជាអ្នកអប់រំសតិ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងអាការជាគ្រឿងអប់រំសតិទាំងនោះ ទើបត្រាស់ព្រះពុទ្ធវចនៈថា ទីឃំ វា អស្សសន្តោ (កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អញដកដង្ហើមចេញវែង) ជាដើម ។ សមពិត ដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកក្នុងវិភង្គចំពោះនៃពីរពាក្យនេះថា សោ សតោវ អស្សសតិ សតោ បស្សសតិ (ភិក្ខុនោះ) មានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល) ។

នៅក្នុងគម្ពីរបដិសម្ភិទាលោកសម្ដែងថា ភិក្ខុរមែងជាអ្នកអប់រំសតិ ដោយអាការ ៣២ យ៉ាង គឺ សតិរបស់ភិក្ខុអ្នកដឹងសេចក្ដីដែល

ចិត្តមានអារម្មណ៍តែមួយមិនរវើរវាយ ដោយអំណាចខ្យល់ដកដង្ហើមចូលវែង រមែងតាំងមាំ, លោកឈ្មោះថា ជាអ្នកអប់រំសតិដោយសតិនោះ ដោយញាណនោះ, សតិរបស់ភិក្ខុអ្នកដឹងសេចក្តីដែលចិត្តមានអារម្មណ៍តែមួយ មិនរវើរវាយដោយអំណាចខ្យល់ដកដង្ហើមចេញវែងរមែងតាំងមាំ, លោកឈ្មោះថា ជាអ្នកអប់រំសតិដោយសតិនោះ ដោយញាណនោះ ។ល។ សតិរបស់ភិក្ខុអ្នកដឹងសេចក្តីដែលចិត្តមានអារម្មណ៍តែមួយ មិនរវើរវាយដោយអំណាចភាពជាអ្នកពិចារណាឃើញសេចក្តីលះបង់ដកខ្យល់ដង្ហើមចូល ... ដោយអំណាចភាពជាអ្នកពិចារណាឃើញសេចក្តីលះបង់ ដកដង្ហើមចេញ រមែងតាំងមាំ, លោកឈ្មោះថា ជាអ្នកអប់រំសតិ ដោយសតិនោះ ដោយញាណនោះ ។

## មតិខ្យល់ដកដង្ហើមចូលនិងចេញ តាមអដ្ឋកថាវិន័យនិងព្រះសូត្រ

បណ្តាបទទាំងនោះ ពីរបទថា ទីឃំ វា អស្សសន្តោ (កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អញដកដង្ហើមចេញវែង) បានដល់កាលឲ្យខ្យល់ដកដង្ហើមចេញវែងប្រព្រឹត្តទៅ ។ ក្នុងអដ្ឋកថាវិន័យលោកពោលទុកថា ខ្យល់ដែលចេញទៅខាងក្រៅ ឈ្មោះថា អស្សាសៈ គឺខ្យល់ដកដង្ហើមចេញ ។ ខ្យល់ដែលចូលទៅខាងក្នុង ឈ្មោះថា បស្សាសៈ គឺខ្យល់ដកដង្ហើមចូល ។ ចំណែកក្នុងអដ្ឋកថា នៃព្រះសូត្រទាំងឡាយ មកដោយប្រាសលំដាប់គ្នា ។

បណ្តាខ្យល់ទាំងពីរនោះ ក្នុងវេលាដែលសត្វអ្នកដេកនៅក្នុងគភ៌ សូម្បីគ្រប់ប្រភេទចេញចាកផ្ទៃម្តាយ ខ្យល់ខាងក្នុងពោះចេញទៅខាងក្រៅមុន ខាងក្រោយខ្យល់ខាងក្រៅនាំយកល្អងដែលល្អិតចូលទៅខាងក្នុង ប៉ះខ្ទប់ពិតានហើយរលត់ទៅ ។ គប្បីជ្រាបខ្យល់អស្សាសៈ និងបស្សាសៈយ៉ាងនេះសិន ។ ចំណែកសេចក្តីដែលខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលទាំងនោះ មានរយៈវែងនិងខ្លី គប្បីជ្រាបដោយអំណាចនៃកាល ។ ដូចយ៉ាងថា ទឹកឬខ្សាច់ ផ្សាយចេញទៅ មានរយៈ គឺឱកាសតាំងនៅ គេហៅថា ទឹកវែង ខ្សាច់វែង ទឹកខ្លី ខ្សាច់ខ្លី យ៉ាងណា ខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញសូម្បីដែលល្អិតស្មោញក៏យ៉ាងនោះ ញ៉ាំងប្រទេសដែលវែងក្នុងខ្លួនដំរីនិងខ្លួនពស់ពោលគឺ អត្តភាពរបស់ដំរីនិងពស់ទាំងនោះ ឲ្យពេញសន្សឹមៗ ហើយក៏ចេញទៅសន្សឹមៗ ; ព្រោះដូច្នោះ ទើបលោកហៅថា វែង ។ ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ញ៉ាំងប្រទេសដែលខ្លី ពោលគឺអត្តភាពនៃសុនខ និងទន្សាយជាដើម ឲ្យពេញរហ័សហើយក៏ចេញរហ័សដូចគ្នា; ព្រោះដូច្នោះ ទើបលោកហៅថា ខ្លី ។ តែបណ្តាមនុស្សទាំងឡាយ មានមនុស្សពួកខ្លះដកដង្ហើមចេញ និងដកដង្ហើមចូលវែងដោយអំណាចរយៈកាល(វែង) ដូចដំរី និងពស់ជាដើម ពួកខ្លះដកដង្ហើមចេញនិងដកដង្ហើមចូលខ្លី ដូចសុនខនិងទន្សាយជាដើម; ព្រោះដូច្នោះខ្យល់ដកដង្ហើមចូលនិងដកដង្ហើមចេញ របស់មនុស្សទាំងនោះ

*ដោយអំណាចកាលដែលចេញនិងចូលអស់វេលាយូរ គប្បីជ្រាបថា វែង ដែលចេញនិងចូលអស់វេលាតិច គប្បីជ្រាបថា ខ្លី ។*

**ចម្រើនអានាបានស្សតិកម្មដ្ឋាន រមែងបានបាមោជ្ជៈជាដើម**

*ក្នុងខ្យល់ដកដង្ហើមចូលនិងចេញនោះ ភិក្ខុនេះកាលដកដង្ហើមចេញនិងដកដង្ហើមចូលវែង ដោយអាការ ៩ យ៉ាង រមែងដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញដកដង្ហើមចូលវែង ។ ក៏កាលលោកដឹងច្បាស់យ៉ាងនេះ គប្បីជ្រាបថា ការចម្រើនកាយានុបស្សនាសតិប្បដ្ឋាន រមែងសម្រេចដោយអាការណានីមួយ ដូចន័យដែលព្រះធម្មសេនា-បតីសារីបុត្រ ពោលទុកក្នុងបដិសម្ភិទា[១] ថា "ភិក្ខុកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង តើដូចម្ដេច ។ ភិក្ខុដកចេញនូវដង្ហើមចេញវែង ក្នុងចំណែកនៃកាលវែង ដកចូលនូវដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង ដកចេញក្ដី ដកចូលក្ដី នូវដង្ហើមចេញឬដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង កាលភិក្ខុដកចេញក្ដី ដកចូលក្ដី នូវដង្ហើមចេញឬដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង (ច្រើនដង) ឆន្ទៈ (ចំណង់អ្វីមួយ) រមែងកើតឡើង ភិក្ខុដកចេញនូវដង្ហើមចេញវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃ-*

---

*[១] ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៩៨/១២១ ។*

កាលវែង ដោយអំណាចនៃឆន្ទៈ ដកចូលនូវដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ ។ កាលភិក្ខុដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ (ច្រើនដង) បាមោជ្ជៈ រមែងកើតឡើង ភិក្ខុដកចេញនូវដង្ហើមចេញវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមោជ្ជៈ ដកចូលនូវដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមោជ្ជៈ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមោជ្ជៈ កាលភិក្ខុដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមោជ្ជៈ (ច្រើនដង) ចិត្តក៏ឃ្លាតចេញ អំពីដង្ហើមចេញឬដង្ហើមចូលវែង ឧបេក្ខាក៏តាំងនៅស៊ប់ នេះកាយគឺដង្ហើមចេញនិងដង្ហើមចូលវែង ដោយអាការ ៩ យ៉ាង ដែលឈ្មោះថា ឧបដ្ឋាន, សតិ ឈ្មោះថា អនុបស្សនាញាណ, កាយ ឈ្មោះថា ឧបដ្ឋាន មិនមែនឈ្មោះថាសតិទេ, សតិ ឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង ពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ

លោកពោលថា កាយានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការ-ដូច្នេះ ។

សូម្បីក្នុងបទដែលកំណត់ដោយខ្យល់ខ្លី ក៏មានន័យដូចគ្នា ។ ចំណែកសេចក្តីប្លែកគ្នា មានដូចតទៅនេះ ៖

ក្នុងបទដែលកំណត់ដោយខ្យល់វែងនោះ លោកពោលទុកថា "ដកចូលនូវដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង" ដូច្នេះ យ៉ាងណា ក្នុងបទដែលកំណត់ ដោយខ្យល់ខ្លីនេះ ក៏មានពាក្យដែលមកក្នុងបាលីថា "ដកចូលនូវដង្ហើមចូលខ្លី ក្នុងចំណែកនៃកាលខ្លី" ដូច្នោះ ។ ព្រោះហេតុនោះ គប្បីប្រកបដោយអំណាចនៃបទដែលកំណត់ថា ខ្លីនោះ ដរាបដល់ពាក្យថា ព្រោះហេតុនោះ ទើបលោកពោលថា "ការចម្រើនសតិប្បដ្ឋាន គឺការពិចារណាឃើញកាយក្នុងកាយ" ។ ភិក្ខុនេះ កាលដឹងច្បាស់ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលដោយអាការ ៩ យ៉ាងទាំងនេះ ក្នុងចំណែកនៃកាលវែងនិងក្នុងចំណែកនៃកាលខ្លី ដូចពណ៌នាមកដូច្នេះ បណ្ឌិតគប្បីជ្រាបថា "ភិក្ខុកាលដកដង្ហើមចូលវែង រមែងដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ល។ ឬកាលដកដង្ហើមចេញខ្លី រមែងដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី" ដូច្នេះ ។ ម្យ៉ាងទៀត កាលភិក្ខុនោះដឹងយ៉ាងនេះ វណ្ណៈ (គឺ អាការ) ទាំង ៤ គឺខ្យល់ដកដង្ហើមចូលវែងនិងខ្លី សូម្បីខ្យល់ដកដង្ហើមចេញ ក៏យ៉ាងនោះ រមែងប្រព្រឹត្តទៅត្រង់ចុងច្រមុះរបស់ភិក្ខុដូច្នេះឯង ។

ពាក្យថា សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ (ភិក្ខុសិក្សាថា អាត្មាអញ នឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចេញ, សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចូល) មានអធិប្បាយថា លោករមែងកំណត់ថា "យើងនឹងធ្វើខាងដើម កណ្ដាល និងទីបំផុតនៃកងខ្យល់ដកដង្ហើមចេញ-ទាំងអស់ ឲ្យដឹងច្បាស់ គឺ ធ្វើឲ្យប្រាកដដកដង្ហើមចេញ (និង) រមែង-កំណត់ថា "យើងនឹងធ្វើខាងដើម កណ្ដាល និងទីបំផុតនៃកងខ្យល់ដកដង្ហើមចូលទាំងអស់ឲ្យដឹងច្បាស់ គឺធ្វើឲ្យប្រាកដដកដង្ហើមចូល" ។ កាលភិក្ខុធ្វើឲ្យដឹងច្បាស់ គឺធ្វើឲ្យប្រាកដដោយអាការយ៉ាងនោះ រមែងដកដង្ហើមចេញនិងដកដង្ហើមចូល ដោយចិត្តដែលសម្បយុត្តដោយញាណ; ព្រោះដូច្នោះ លោកទើបពោលថា រមែងសិក្សាថា "អាត្មាអញនឹងដកដង្ហើមចេញ នឹងដកដង្ហើមចូល" ។

ពិតមែន ខាងដើមក្នុងកងខ្យល់ដកដង្ហើមចូល ឬក្នុងកងខ្យល់ដកដង្ហើមចេញដែលសុះទៅយ៉ាងល្អិត (ស្ងប់) រមែងប្រាកដដល់ភិក្ខុមួយរូប, តែកណ្ដាល និងទីបំផុត មិនប្រាកដ, លោកអាចកំណត់បានចំពោះតែខាងដើមប៉ុណ្ណោះ រមែងលំបាកក្នុងកណ្ដាលនិងទីបំផុត ។ មួយរូបទៀត រមែងប្រាកដតែកណ្ដាល, ឯខាងដើម និងទីបំផុត មិនប្រាកដ, លោកអាចកំណត់បានចំពោះតែត្រង់កណ្ដាលប៉ុណ្ណោះ រមែង

លំបាកក្នុងខាងដើមនិងទីបំផុត ។ មួយរូបទៀត រមែងប្រាកដតែទីបំផុត, ឯខាងដើម និងកណ្តាល មិនប្រាកដ, លោកអាចកំណត់បានចំពោះទីបំផុតប៉ុណ្ណោះ រមែងលំបាកក្នុងខាងដើម និងកណ្តាល ។ មួយរូបទៀត រមែងប្រាកដបានសួម្បីទាំងអស់ លោកអាចកំណត់បានសួម្បីទាំងអស់ រមែងមិនលំបាកក្នុងចំណែកណាៗ ។ ព្រះមានព្រះភាគ កាលនឹងទ្រង់ពន្យល់ថា ដែលភិក្ខុគប្បីជាអ្នកដឹងដូច្នោះ ទើបត្រាស់ថា "ភិក្ខុសិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចេញ; សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចូល" ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា *សិក្ខតិ* **(ភិក្ខុ)សិក្សាថា** សេចក្តីថា រមែងប្រារព្ធព្យាយាម គឺព្យាយាមយ៉ាងនោះ ។ ម្យ៉ាងទៀត ក្នុងបទថា *សិក្ខតិ* នេះ គប្បីឃើញសេចក្តីយ៉ាងនេះថា សេចក្តីសង្រួមរបស់ភិក្ខុដែលជាយ៉ាងនោះ នេះឈ្មោះថា អធិសីលសិក្ខា ក្នុងអធិការពោលអំពីអានាបានស្សតិភាវនានេះ សមាធិរបស់លោក អ្នកជាយ៉ាងនោះ នេះឈ្មោះថា អធិចិត្តសិក្ខា បញ្ញារបស់លោកអ្នកជាយ៉ាងនោះ នេះឈ្មោះថា អធិបញ្ញាសិក្ខា លោករមែងកំណត់ គឺរមែងសេពសោយ ចម្រើនធ្វើឲ្យច្រើននូវសិក្ខា ៣ យ៉ាង ដូចពណ៌នាមកនេះ ដោយសតិនោះ ដោយមនសិការនោះ ក្នុងអារម្មណ៍នោះ ។ ព្រោះថា ដោយន័យមុន បណ្តាពីរន័យនោះ ភិក្ខុគប្បីដកដង្ហើមចេញនិងដកដង្ហើមចូល

តែម្យ៉ាងប៉ុណ្ណោះ មិនត្រូវធ្វើកិច្ចយ៉ាងណាមួយដទៃទៀយ តែចាប់ផ្ដើមតាំងពីវេលាដែលដឹងច្បាស់ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលនេះទៅ គួរធ្វើសេចក្ដីព្យាយាម ក្នុងអាការដែលឲ្យញាណកើតឡើងជាដើម; ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបថា ក្នុងន័យមុននោះ ព្រះមានព្រះភាគ ត្រាស់បាលីទុកដោយអំណាចជាវត្តមានកាលថា រមែងកំណត់ដឹងច្បាស់ថា អញដកដង្ហើមចេញ រមែងកំណត់ដឹងច្បាស់ថា អញដកដង្ហើមចូលប៉ុណ្ណោះ ហើយលើកព្រះបាលីឡើងដោយអំណាចពាក្យដែលជាអនាគតកាល ដោយន័យមានជាដើមថា "សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចេញ" ដូច្នេះ ដើម្បីនឹងទ្រង់សម្ដែងអាការដែលឲ្យញាណកើតឡើងជាដើមដែលគួរធ្វើចាប់ផ្ដើមតាំងពីកាលនេះទៅ ។

## ភិក្ខុកំណត់កម្មដ្ឋានហើយ កាយសង្ខារនើបស្ងប់

ពាក្យថា បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ បស្សសិស្សាមីតិ សិក្ខតិ (**ភិក្ខុសិក្សាថា អាត្មាអញរម្ងាប់កាយសង្ខារ (គឺខ្យល់អស្សាសបស្សាសៈ) សឹមដកដង្ហើមចេញ, រម្ងាប់កាយសង្ខារ សឹមដកដង្ហើមចូល**), សេចក្ដីថា លោករមែងកំណត់ថា អញនឹងជាអ្នកស្ងប់គឺ រម្ងាប់រលត់ បានដល់ឲ្យកាយសង្ខារដ៏គ្រោតគ្រាតស្ងប់ទៅ ដកដង្ហើមចេញដកដង្ហើមចូល ។ ក្នុងពាក្យថា **នឹងជាអ្នករម្ងាប់កាយសង្ខារដ៏គ្រោតគ្រាត** នោះ គប្បី

ជ្រាបសភាពដែលខ្យល់ជារបស់គ្រោតគ្រាតនិងល្អិត និងសេចក្ដីស្ងប់យ៉ាងនេះ គឺ ៖

ក៏ក្នុងកាលមុនគឺ ក្នុងវេលាដែលភិក្ខុនេះមិនទាន់បានកំណត់កម្មដ្ឋាន កាយនិងចិត្ត នៅមានសេចក្ដីខ្វល់ខ្វាយ នៅគ្រោតគ្រាតកាលកាយនិងចិត្តដែលជារបស់គ្រោតគ្រាត មិនទាន់ស្ងប់ សូម្បីខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ក៏ជារបស់គ្រោតគ្រាត គឺប្រព្រឹត្តទៅលើសកម្លាំង ច្រមុះមិនល្មមដកដង្ហើម ត្រូវឈរដកដង្ហើមចូលខ្លះដកដង្ហើមចេញតាមផ្លូវមាត់ខ្លះ តែកាលណា កាយក្ដី ចិត្តក្ដី ជារបស់ដែលលោកកំណត់ហើយ កាលនោះ កាយនិងចិត្តនោះ ទើបជារបស់ស្ងប់រម្ងាប់ ។ កាលកាយនិងចិត្តនោះ ស្ងប់ហើយ ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល រមែងប្រព្រឹត្តទៅល្អិត គឺជាសភាពដល់អាការដែលនិងត្រូវសង្កេតមើលថា "មានឬទេហ្ន៎" ។ ប្រៀបដូចខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលរបស់បុរសអ្នករត់ចុះអំពីភ្នំ ឬអ្នកដាក់របស់ធ្ងន់ចុះអំពីសីសៈហើយឈរ រមែងជារបស់គ្រោតគ្រាតច្រមុះមិនល្មមដកដង្ហើម ត្រូវឈរដកដង្ហើមចេញខ្លះ ដកដង្ហើមចូលខ្លះតាមទ្វារមាត់ ក្នុងកាលណា គេបន្ទោបង់សេចក្ដីខ្វល់ខ្វាយនោះចេញងូតនិងផឹកទឹកហើយ យកសំពត់សើមគ្របត្រង់ទ្រូង ដេកសម្រាកនៅក្រោមម្លប់ឈើត្រជាក់ៗ; កាលនោះ ខ្យល់ដកដង្ហើមចេញនិងដក

ដង្ហើមចូលនោះរបស់គេ ទើបជាខ្យល់ល្អិត គឺដល់អាការដែល និង ត្រូវសង្កេតមើលថា "មានឬទេហ្ន៎" យ៉ាងណា ក្នុងកាលមុន គឺក្នុង វេលាដែលភិក្ខុនេះមិនទាន់បានកំណត់កម្មដ្ឋាន កាយនិងចិត្ត ។ល។ គឺ ដល់អាការដែលត្រូវគន់រកថា "មានឬទេហ្ន៎" យ៉ាងនោះដែរ ។ សេចក្តី នោះព្រោះហេតុអ្វី ? ព្រោះសេចក្តីពិតជាយ៉ាងនោះ ក្នុងកាលមុនគឺ ក្នុងវេលាដែលលោកមិនទាន់បានកំណត់កម្មដ្ឋាន ការនឹកដល់ ការ ប្រមូលមក ការមនសិការ និងការពិចារណាថា យើងនឹងរម្ងាប់កាយ សង្ខារចំណែកគ្រោតគ្រាតៗ ដូច្នេះ មិនមានដល់លោកនោះទេ, តែក្នុង វេលាដែលលោកកំណត់ហើយ ទើបមាន ។ ព្រោះហេតុនោះ ក្នុង វេលាដែលកំណត់កម្មដ្ឋាន កាយសង្ខាររបស់លោកនោះ ទើបជារបស់ ល្អិតជាងវេលាដែលមិនទាន់បានកំណត់ ។ ព្រោះហេតុនោះ ព្រះបូរា-ណាចារ្យទាំងឡាយ ទើបពោលទុកថា

> កាលកាយនិងចិត្តនៅរសាប់រសល់ កាយសង្ខាររមែង-ប្រព្រឹត្តទៅលើសប្រមាណ កាលកាយនិងចិត្ត មិនរសាប់ រសល់ កាយសង្ខារ រមែងប្រព្រឹត្តទៅល្អិត ។

## កាយសង្ខារល្អិតទៅតាមលំដាប់

កាយសង្ខារសូម្បីក្នុងវេលាកំណត់ក៏នៅគ្រោតគ្រាត ក្នុងឧបចារនៃបឋមជ្ឈានល្អិត ។ សូម្បីក្នុងឧបចារនៃបឋមជ្ឈាននោះ ក៏នៅគ្រោតគ្រាត ក្នុងបឋមជ្ឈានល្អិត ។

ក្នុងបឋមជ្ឈាន និងក្នុងឧបចារនៃទុតិយជ្ឈាននៅគ្រោតគ្រាត ក្នុងទុតិយជ្ឈានល្អិត ។ ក្នុងទុតិយជ្ឈាននិងក្នុងឧបចារនៃទុតិយជ្ឈានក៏នៅគ្រោតគ្រាត ក្នុងតតិយជ្ឈានល្អិត ។ ក្នុងតតិយជ្ឈាន និងឧបចារនៃចតុត្ថជ្ឈានក៏នៅគ្រោតគ្រាត ក្នុងចតុត្ថជ្ឈានល្អិតក្រៃលែងណាស់ ដល់ការមិនប្រព្រឹត្តទៅតែម្តង ។ ពាក្យនេះ ជាមតិរបស់អាចារ្យអ្នកពោលទីឃនិកាយ និងសំយុត្តនិកាយ ។ ចំណែកអាចារ្យទាំងឡាយអ្នកពោលមជ្ឈិមនិកាយ រមែងប្រាថ្នាសេចក្តីល្អិតជាងគ្នា សូម្បីក្នុងឧបចារនៃឈានជាន់ខ្ពស់ៗ ឡើងទៅជាងឈានជាន់ទាបៗ យ៉ាងនេះ គឺកាយសង្ខារដែលប្រព្រឹត្តទៅក្នុងបឋមជ្ឈាន នៅជារបស់គ្រោតគ្រាត ក្នុងឧបចារនៃទុតិយជ្ឈាន ទើបចាត់ថា ល្អិត ដូច្នេះជាដើម ។ ក៏មតិរបស់អាចារ្យទាំងអស់នោះឯង គួរជ្រាបដូច្នេះថា កាយសង្ខារដែលប្រព្រឹត្តទៅក្នុងវេលាដែលនៅមិនបានកំណត់ (កម្មដ្ឋាន) រមែងរម្ងាប់ទៅក្នុងវេលាដែលកំណត់ហើយ កាយសង្ខារដែលប្រព្រឹត្តទៅក្នុងវេលាដែលបានកំណត់ហើយ រមែងរម្ងាប់ទៅក្នុងឧបចារនៃបឋមជ្ឈាន

។ល។ កាយសង្ខារដែលប្រព្រឹត្តទៅក្នុងឧបចារនៃចតុត្ថជ្ឈាន រមែងរម្ងាប់ទៅក្នុងចតុត្ថជ្ឈាន ។ ក្នុងសមថៈ មានន័យប៉ុណ្ណេះ ។

ចំណែកក្នុងវិបស្សនា គប្បីជ្រាបន័យដូច្នេះ ៖

កាយសង្ខារដែលប្រព្រឹត្តទៅក្នុងកាលមិនទាន់បានកំណត់ នៅគ្រោតគ្រាត ក្នុងការកំណត់មហាភូតរូបល្អិត សូម្បីការកំណត់មហាភូតរូបនោះ ក៏នៅគ្រោតគ្រាត ក្នុងការកំណត់ឧបាទាយរូបល្អិត សូម្បីការកំណត់ឧបាទាយរូបនោះ ក៏នៅគ្រោតគ្រាត ក្នុងការកំណត់រូបទាំងអស់ល្អិត សូម្បីការកំណត់រូបទាំងអស់នោះ ក៏នៅគ្រោតគ្រាត ។ ក្នុងការកំណត់អរូបនិងល្អិត, សូម្បីការកំណត់អរូបនោះ ក៏នៅគ្រោតគ្រាត, ក្នុងការកំណត់រូបនិងអរូបល្អិត, សូម្បីការកំណត់រូបនិងអរូបនោះ ក៏នៅគ្រោតគ្រាត ក្នុងការកំណត់បច្ច័យល្អិត, សូម្បីការកំណត់បច្ច័យនោះ ក៏នៅគ្រោតគ្រាត ក្នុងការឃើញនាមរូបព្រមទាំងបច្ច័យល្អិត, សូម្បីការឃើញនាមរូបព្រមទាំងបច្ច័យនោះ ក៏នៅគ្រោតគ្រាត ក្នុងវិបស្សនាដែលប្រកបដោយលក្ខណៈ និងអារម្មណ៍ល្អិត, សូម្បីនោះក៏នៅគ្រោតគ្រាត ក្នុងវិបស្សនាដែលមានកម្លាំងថយចុះ, ក្នុងវិបស្សនាដែលមានកម្លាំងខ្លាំង ទើបបាត់ថា ល្អិត ។ ក្នុងវិបស្សនាន័យនោះ គប្បីជ្រាបសេចក្ដីស្ងប់ទៅនៃខ្យល់អស្សាសៈ និងបស្សាសៈមុនៗ ដោយខ្យល់អស្សាសៈនិងបស្សាសៈក្រោយៗ ដោយន័យដូចពោលហើយក្នុងសេចក្ដីខាងដើមនុ៎ះឯង ។

ក្នុងពាក្យថា **រម្ងាប់កាយសង្ខារដែលគ្រោតគ្រាត** នេះ គប្បីជ្រាបសេចក្តីដែលខ្យល់គ្រោតគ្រាតល្អិតនិងស្ងប់ទៅ ដោយន័យដូចពណ៌នាមកដូច្នេះឯង ។ ចំណែកក្នុងបដិសម្ភិទា ព្រះធម្មសេនាបតី-សារីបុត្រ ពោលសេចក្តីនៃបទនោះ ព្រមទាំងពាក្យចោទសួរ និងពាក្យឆ្លើយដោះស្រាយឲ្យច្បាស់យ៉ាងនេះ ៖

“បុគ្គលសិក្សាដូចម្តេច បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ។ កាយសង្ខារ តើដូចម្តេច ។ ពួកខ្យល់ដកដង្ហើមចេញវែង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ, បុគ្គលកាលរម្ងាប់ រំលត់បង្រ្កាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា ពួកខ្យល់ដកដង្ហើមចូលវែង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះ ជាប់ដោយកាយឈ្មោះថា កាយសង្ខារ, បុគ្គលកាលរម្ងាប់ រំលត់ បង្រ្កាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា; ពួកខ្យល់ដកដង្ហើមចេញខ្លី ដង្ហើមចូលខ្លី ឬដង្ហើមចេញ សម្រាប់បុគ្គលកំណត់ដឹងនូវកាយទាំងពួងដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះ ជាប់ដោយកាយ ឈ្មោះថាកាយសង្ខារ, បុគ្គលកាលរម្ងាប់ រំលត់ បង្រ្កាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា ។ ការឱន ការងាក ការទម្រេត ការឈមការរញ្ជួយ ការអន្ទះសា ការកម្រើក ការញាប់ញ័រ ណានៃកាយដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា បុគ្គលសិក្សាថា

អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ។ ការមិនឱន ការមិនផ្ងាក ការមិនទម្រេត ការមិនឈមការមិនរញ្ជួយ ការមិនអន្ទះសា ការមិនកម្រើក ការមិនញាប់ញ័រណានៃកាយ ដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារដ៏ល្អិតសុខុមមានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ។ បានឮថា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូលដោយអាការយ៉ាងនេះហើយ ។ កាលបើយ៉ាងនេះ ការប្រាកដនៃការបានខ្យល់មិនទាន់មាន ការប្រាកដនៃដង្ហើមចេញ និងដង្ហើមចូល ក៏មិនទាន់មាន ការប្រាកដនៃអានាបានស្សតិ ក៏មិនទាន់មាន ទាំងការប្រាកដនៃអានាបានស្សតិសមាធិ ក៏មិនទាន់មានទេ បណ្ឌិតទាំងឡាយ រមែងមិនចូលកាន់សមាបត្តិនោះផង មិនចេញចាកសមាបត្តិនោះផង ។ បានឮថា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ដោយអាការយ៉ាងនេះហើយ កាលបើយ៉ាងនេះ ការប្រាកដនៃការបានខ្យល់ក៏មាន ការប្រាកដនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល ក៏មាន ការប្រាកដនៃអានាបានស្សតិ ក៏មាន ទាំង

ការប្រាកដនៃអានាបានស្សតិសមាធិ ក៏មាន ទើបបណ្ឌិតទាំងឡាយ ចូលកាន់សមាបត្តិនោះផង ចេញចាកសមាបត្តិនោះផង ដំណើរនោះ ប្រៀបដូចជាអ្វី ប្រៀបដូចជារគាំង ដែលគេគោះ សំឡេងគ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង, ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្តនៃសំឡេងដ៏គ្រោតគ្រាត កាលបើសំឡេងគ្រោតគ្រាត បន្ទាប់មកសំឡេងដ៏ល្អិត រមែងប្រព្រឹត្តទៅជាខាងក្រោយ, ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្តនៃសំឡេងដ៏ល្អិត កាលសំឡេងដ៏ល្អិតរលត់ហើយ; បន្ទាប់មក ចិត្តរមែងប្រព្រឹត្តទៅជាខាងក្រោយ ព្រោះចិត្តមាននិមិត្ត (នៃសំឡេង)ដ៏ល្អិតជាអារម្មណ៍ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលដ៏គ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង ។ ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អនូវនិមិត្តនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាត កាលខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាតរលត់ហើយ, បន្ទាប់មកខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិត រមែងប្រព្រឹត្តទៅជាខាងក្រោយ, ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្តនៃខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលដ៏ល្អិត កាលខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិតរលត់ហើយ, បន្ទាប់មកចិត្តក៏មិនដល់នូវសេចក្តីរាយមាយ ក្នុងកាលខាងក្រោយ ព្រោះចិត្តយកនិមិត្តនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើម

ចូលដ៏ល្អិតជាអារម្មណ៍ ក៏យ៉ាងនោះដែរ ។ កាលបើយ៉ាងនេះ ការប្រាកដនៃការបានខ្យល់ ក៏មាន ការប្រាកដនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល ក៏មាន ការប្រាកដនៃអានាបានស្សតិ ក៏មាន ការប្រាកដនៃអានាបានស្សតិសមាធិ ក៏មាន បណ្ឌិតទាំងឡាយ រមែងចូលកាន់សមាបត្តិនោះផង រមែងចេញចាកសមាបត្តិនោះផង កាយគឺខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គលកាលរម្ងាប់នូវកាយសង្ខារ ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ, កាយឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថា សតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលរមែងពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ, ហេតុនោះលោកពោលថា កាយេ កាយានុបស្សនាសតិប្បដ្ឋានភាវនា (ការចម្រើនសតិប្បដ្ឋាន គឺការពិចារណាឃើញកាយក្នុងកាយ"[២] ដូច្នេះ ។

ក្នុងបទថា បស្សម្ភយំ កាយសង្ខារំ (រម្ងាប់កាយសង្ខារសឹមដកដង្ហើមចូល) នេះ មានការពណ៌នាតាមលំដាប់បទនៃបឋម-ចតុក្កៈ ដែលត្រាស់ទុកដោយអំណាចនៃកាយានុបស្សនា ត្រឹមតែប៉ុណ្ណេះសិន ។ តែព្រោះក្នុងអធិការនេះ ចតុក្កៈនេះប៉ុណ្ណោះ ត្រាស់ទុកដោយអំណាចនៃកម្មដ្ឋានរបស់កុលបុត្រអ្នកចាប់ផ្ដើមធ្វើ, ចំណែកចតុក្កៈ ៣ ទៀតក្រៅនេះ ត្រាស់ទុកដោយអំណាចនៃវេទនានុបស្សនា ចិត្តានុ-

[២] ខុទ្ទ. បដិ. មហាវគ្គ. ៧០. ១១៤ / ១៤៥ ។

*បស្សនា និងធម្មានុបស្សនារបស់កុលបុត្រអ្នកសម្រេចឈានហើយ ក្នុងបឋមចតុក្កៈនេះ; ដូច្នោះ កុលបុត្រ អ្នកប្រាថ្នានឹងចម្រើនកម្មដ្ឋាននេះ ហើយសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ដោយវិបស្សនាដែលមានអានាបានចតុត្ថជ្ឈានជាទីបដ្ឋាន គួរជ្រាបកិច្ចដែលខ្លួនគួរធ្វើមុនទាំងអស់ តាំងពីដើម ក្នុងអធិការនៃអានាបានស្សតិកម្មដ្ឋាននេះឯងដោយអំណាចនៃកុលបុត្រអ្នកចាប់ផ្តើមធ្វើ ។*

## **វិធីមនសិការអានាបានស្សតិកម្មដ្ឋាន ៨ យ៉ាង**

*ក៏ក្នុងពាក្យដែលខ្ញុំព្រះករុណាពោលថា គប្បីមនសិការអានាបានស្សតិកម្មដ្ឋាននេះ មានមនសិការវិធីដូចតទៅនេះ ៖*

*គឺ ការរាប់ ការតាមចង ការពាល់ត្រូវ ការបញ្ឈប់ទុក ការកំណត់ ការផ្លាស់ប្តូរ សេចក្តីបរិសុទ្ធិ និងការឃើញធម៌ទាំងនោះជាក់ច្បាស់ ។*

*ការរាប់ទុំះឯង ឈ្មោះថា* **គណនា** *(ការរាប់) ។*

*ការកំណត់តាម ឈ្មោះថា* **អនុពន្ធនា** *(ការតាមចង) ។*

*ឋានដែលខ្យល់ប៉ះត្រូវ ឈ្មោះថា* **ផុសនា** *(ការពាល់ត្រូវ) ។*

*សេចក្តីតម្កល់មាំឈ្មោះថា* **ឋបនា** *(ការបញ្ឈប់ទុក) ។*

*ការឃើញច្បាស់ ឈ្មោះថា* **សល្លក្ខណា** *(ការកំណត់) ។*

*មគ្គ ឈ្មោះថា* **វិវដ្ដនា** *(ការផ្លាស់ប្តូរ) ។*

*ផលឈ្មោះថា* **បារិសុទ្ធិ** *(សេចក្តីបរិសុទ្ធិ) ។*

ការពិចារណា ឈ្មោះថា **តេសញ្ច បដិបស្សនា** (ការឃើញធម៌ទាំងនោះ ជាក់ច្បាស់) ។

## អធិប្បាយវិធីរាប់ខ្យល់ដកដង្ហើមចេញចូល

បណ្ដាមនសិការវិធី មានការរាប់ជាដើមនោះ កុលបុត្រអ្នកចាប់ផ្ដើមបំពេញនេះ សេចក្ដីមនសិការកម្មដ្ឋាននេះដោយការរាប់មុន ។ កាលនឹងរាប់ មិនគួរឈប់រាប់តិចជាង ៥, មិនគួររាប់ឲ្យច្រើនជាង ១០, មិនគួរសម្ដែង (ការរាប់) ឲ្យដាច់ក្នុងចន្លោះ ។

ព្រោះកាលឈប់រាប់តិចជាង ៥ ចិត្តុប្បាទ រមែងក្ដៅក្រហាយក្នុងឱកាសចង្អៀត ដូចហ្វូងគោ ដែលរួមឃាំងទុកក្នុងក្រោលដែលចង្អៀតដូច្នោះ ។ កាលរាប់ច្រើនជាង ១០ ចិត្តុប្បាទក៏កង្វល់ដោយការរាប់ប៉ុណ្ណោះ ។ កាលសម្ដែង (ការរាប់) ឲ្យដាច់ក្នុងចន្លោះ ចិត្តរមែងខ្វល់ខ្វាយថា "កម្មដ្ឋានរបស់យើងដល់ទីបំផុតឬទេហ្ន៎" ។ ព្រោះដូច្នោះត្រូវវៀរទោសទាំងនេះចេញសិន សឹមរាប់ ។ កាលនឹងរាប់ គ្រាដំបូងគួររាប់ដោយវិធីរាប់យឺតៗ គឺ រាប់ដូចវិធីវាល់ស្រូវ ។ ពិតមែន អ្នកវាល់ស្រូវ វាល់ពេញនាឡិហើយប្រាប់ថា ១ ទើបចាក់ចុះ កាលវាល់ពេញទៀត ជួបសម្រាមយ៉ាងណាមួយ រើសវាចោលចេញ ទើបប្រាប់ថា ១-១ ។ ក្នុងពាក្យថា ២-២ ជាដើម ក៏ន័យនេះ ។ កុលបុត្រសូម្បីនេះ ក៏យ៉ាងនោះដែរ បណ្ដាខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ចំណែកណាប្រាកដ គប្បីចាប់យកចំណែកនោះ ហើយគប្បី

កំណត់ខ្យល់ដែលកំពុងចូងទៅៗ តាំងពីដើមថា ១-១ ទៅ ដរាបដល់ថា ១០-១០ កាលកុលបុត្រនោះរាប់ដោយវិធីយ៉ាងនេះ ខ្យល់អស្សាសៈ ដែលកំពុងចេញ និងខ្យល់បស្សាសៈ ដែលកំពុងចូលរមែងប្រាកដ ។

លំដាប់នោះ កុលបុត្រនេះគួរលះវិធីរាប់យឺតៗ គឺ រាប់ដូចវិធីវាល់ស្រូវនោះចេញ ហើយគប្បីរាប់ដោយវិធីរហ័សៗ គឺ រាប់ដូចវិធីនាយគោបាល ។ ពិតមែន នាយគោបាលអ្នកឆ្លាត យកដុំក្រួសដាក់ថ្នក់ ដៃកាន់ខ្សែនិងដំបងទៅកាន់ក្រោលពីព្រឹកព្រលឹម វាយគោត្រង់ខ្នងហើយ អង្គុយនៅលើសសរសន្ទះទ្វារ រាប់មេគោដែលមកដល់ទ្វារហើយ ៗ ដាក់ដុំក្រួសចុះទៅថា ១-២ ជាដើម ។ ហ្វូងគោដែលនៅលំបាកក្នុងឱកាសដែលចង្អៀតរហូតដល់អស់ ៣ យាមនៃរាត្រី កាលចេញ (ពីក្រោល) ច្រៀតបៀតគ្នានិងគ្នាប្រញាប់ចេញជាពួកៗ ។ នាយគោបាលនោះ រមែងរាប់យ៉ាងរហ័សតែម្តងថា ៣-៤-៥-១០ ជាដើម ។ សូម្បីកាលកុលបុត្រនេះ រាប់ដោយន័យមុនដូចពោលមកហើយនេះ ខ្យល់អស្សាសៈនិងបស្សាសៈ រមែងប្រាកដសញ្ចរទៅមកយ៉ាងរហ័ស ។ លំដាប់នោះលោកដឹងថា ខ្យល់អស្សាសៈ និងបស្សាសៈ រមែងសញ្ចរទៅមកយ៉ាងរហ័ស ហើយមិនកាន់យកខ្យល់ខាងក្នុង និងខាងក្រៅ គប្បីកំណត់យកតែខ្យល់ដែលមកដល់ចន្លោះៗប៉ុណ្ណោះ រាប់យ៉ាងរហ័សៗ តែម្តងថា

១-២-៣-៤-៥
១-២-៣-៤-៥-៦
១-២-៣-៤-៥-៦-៧
១-២-៣-៤-៥-៦-៧-៨
១-២-៣-៤-៥-៦-៧-៨-៩
១-២-៣-៤-៥៦-៧-៨-៩-១០ ។

ព្រោះថា ក្នុងកម្មដ្ឋានដែលជាប់ដោយការរាប់ ចិត្តរមែងមានអារម្មណ៍តែមួយបានដោយកម្លាំងនៃការរាប់ប៉ុណ្ណោះ ដូចការឈប់ទូកទូកក្នុងក្រសែទឹកហូរត្របាញ់ ដោយអំណាចដែលយកថ្នោលចាក់ទប់ដូច្នោះ ។ កាលលោករាប់រហ័សៗ យ៉ាងនេះកម្មដ្ឋាន រមែងប្រាកដដូចជាថា ដំណើរទៅមិនដាច់ ។ វេលានោះ គ្រាលោកដឹងថា “កម្មដ្ឋានដំណើរទៅមិនដាច់ខ្សែ”ហើយ កុំកំណត់ខ្យល់ទាំងខាងក្នុងនិងខាងក្រៅ គប្បីរាប់រហ័សៗ តាមន័យមុននុ៎ះឯង ។ កាលលោកបញ្ជូនចិត្តចូលទៅព្រមនឹងខ្យល់ដែលចូលទៅខាងក្នុង ឋានខាងក្នុង ត្រូវខ្យល់ប៉ះខ្ទប់ហើយ រមែងដូចជាពេញដោយខ្លាញ់ខាប់ដូច្នោះ ។ កាលនាំចិត្តចេញមកព្រមនឹងខ្យល់ដែលចេញមកខាងក្រៅ ចិត្តរមែងផ្សាយទៅក្នុងអារម្មណ៍យ៉ាងច្រើន ទាំងខាងក្នុង និងទាំងខាងក្រៅ ។ តែភាវនារមែងសម្រេចដល់អ្នកតាំងសតិទុក ក្នុងឱកាសដែលខ្យល់ពាល់ត្រូវចម្រើនប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាពោលថា “កុំកំណត់ខ្យល់ទាំងខាងក្នុងនិងខាងក្រៅ គប្បីរាប់រហ័សៗ តាមន័យមុននុ៎ះឯង” ។

សួរថា នឹងគប្បីរាប់ខ្យល់អស្សាសៈនិងបស្សាសៈនោះ យូរប៉ុនណា ?

ឆ្លើយថា គប្បីរាប់ទៅរហូតដល់សតិដែលវៀរចាកការរាប់នឹងតាំងមាំនៅក្នុងអារម្មណ៍ គឺខ្យល់អស្សាសៈនិងបស្សាសៈ ។ ព្រោះថាការរាប់ ក៏ដើម្បីនឹងកាត់វិតក្កៈដែលឆ្វេឆ្វាទៅខាងក្រៅ ហើយតាំងសតិទុកក្នុងអារម្មណ៍ គឺខ្យល់អស្សាសៈ និងបស្សាសៈប៉ុណ្ណោះ ។

## អធិប្បាយខាងដើមកណ្ដាលនិងទីបំផុតខ្យល់ដកដង្ហើមចេញចូល

ព្រះយោគាវចរ គ្រាមនសិការដោយការរាប់យ៉ាងនោះហើយ គប្បីមនសិការដោយការតាមចង ។ កិរិយាដែលឈប់សម្រាកការរាប់ហើយបញ្ជូនសតិទៅតាមខ្យល់អស្សាសៈ និងបស្សាសៈជាប់តគ្នាទៅ ឈ្មោះថា ការតាមចង ។ ក៏ឯការបញ្ជូនសតិទៅតាមនោះ មិនមែនដោយអំណាចការទៅតាមខាងដើម កណ្ដាល និងទីបំផុត (នៃខ្យល់អស្សាសៈ និងបស្សាសៈ) ទេ ។ ពិតមែន នាភិ (ផ្ចិត) ជាខាងដើមនៃខ្យល់ចេញទៅខាងក្រៅ ហទយៈ (បេះដូង) ជាកណ្ដាល នាសិក (ប្រមុះ) ជាទីបំផុត; ចុងនាសិកជាខាងដើមនៃខ្យល់ចូលទៅខាងក្នុង ហទយៈជាកណ្ដាល នាភិ ជាទីបំផុត ។ ក៏កាលព្រះយោគាវចរនោះទៅតាមខាងដើម កណ្ដាល និងទីបំផុត (នៃខ្យល់អស្សាសៈ និងបស្សាសៈ) នោះ ចិត្តដែលដល់សេចក្ដីរវើរវាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីខ្វល់ខ្វាយ និងដើម្បីសេចក្ដីញាប់ញ័រ ។ ដូចយ៉ាងដែលព្រះធម្មសេនាបតីសារីបុត្រ ពោលទុកថា

“កាលភិក្ខុផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចេញ ខាងដើម កណ្ដាល និងខាងចុង កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសាចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្នុង កាលភិក្ខុផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចេញចូល ខាងដើម កណ្ដាល និងខាងចុង កាយនិងចិត្តរមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសាចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្រៅ”[៣] ។

ព្រោះដូច្នោះ ព្រះយោគាវចរ កាលមនសិការដោយការតាមចង មិនគប្បីមនសិការដោយអំណាចនៃខាងដើម កណ្ដាល និងទីបំផុត ។ មួយទៀត គប្បីមនសិការដោយអំណាចការពាល់ត្រូវ និងដោយអំណាចការបញ្ឈប់ ព្រោះថា មិនមានការមនសិការជាផ្នែកមួយដោយអំណាចនៃការពាល់ត្រូវ និងការបញ្ឈប់ ដូចគ្នានឹងដោយអំណាចនៃការរាប់និងការតាមចង ។ តែព្រះយោគាវចរកាលរាប់នៅក្នុងឋានដែលខ្យល់ពាល់ត្រូវហើយៗ ទុំះឯងឈ្មោះថា មនសិការដោយការរាប់ និងការពាល់ត្រូវ ។ ព្រះយោគាវចរ កាលឈប់សម្រាកការរាប់ក្នុងឋានដែលខ្យល់ពាល់ត្រូវហើយៗ ទុំះឯង ប្រើសតិតាមចងខ្យល់អស្សាសៈនិងបស្សាសៈនោះ និងតាំងចិត្តទុកដោយអំណាចអប្បនា លោកហៅថា មនសិការដោយការតាមចង ការ

---
[៣] ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៧៦/៩១ ។

ពាល់ត្រូវនិងការបញ្ឈប់ ។ សេចក្តីនេះ គប្បីជ្រាបដោយសេចក្តីឧបមាដូចមនុស្សពិការ និងអ្នករក្សាទ្វារ ដែលលោកពោលទុកក្នុងអដ្ឋកថា និងដោយការឧបមាដូចរណារដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកក្នុងបដិសម្ភិទា ។

## សេចក្តីឧបមាដូចមនុស្សពិការយោលទោង

បណ្តាសេចក្តីឧបមា ៣ យ៉ាងនោះ សេចក្តីឧបមាដូចមនុស្សពិការយោលទោង មានដូចតទៅនេះ ៖

ប្រៀបដូចមនុស្សពិការយោលទោង ឲ្យដល់មាតា និងបុត្រដែលលេងយោលទោង ហើយអង្គុយនៅត្រង់គល់សសរទោងក្នុងទីនោះឯង កាលក្តារទោងយោលទៅមកដោយលំដាប់ រមែងឃើញទីបំផុតទាំងពីរខាង និងកណ្តាល តែមិនបានខ្វល់ខ្វាយដើម្បីនឹងមើលទីបំផុតទាំងពីរខាង និងកណ្តាល សូម្បីយ៉ាងណា ភិក្ខុនេះ ក៏យ៉ាងនោះដែរ ឈរត្រង់ជិតគល់សសរដែលចូលទៅចងទុកដោយអំណាចសតិហើយយោលទោងគឺ ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលអង្គុយនៅដោយសតិ ក្នុងនិមិត្តនោះឯង បញ្ជូនសតិទៅតាមខាងដើមកណ្តាល និងទីបំផុតនៃខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ក្នុងឋានដែលខ្យល់ប៉ះត្រូវហើយ ដែលបក់ចូងមកនិងចូងទៅដោយលំដាប់ និងតាំងចិត្តព្រងើយទុកក្នុងនិមិត្តនោះ និងមិនខ្វល់ខ្វាយដើម្បីនឹងក្រឡេកមើលខ្យល់ពួកនោះ ។ នេះជាសេចក្តីឧបមាដូចមនុស្សពិការ ។

## សេចក្តីឧបមាដូចអ្នករក្សាទ្វារ

ចំណែកសេចក្តីឧបមាដូចអ្នករក្សាទ្វារមានដូចតទៅនេះ ៖

អ្នករក្សាទ្វារនឹងមិនដេញដោលសួរបុរសទាំងឡាយ ទាំងខាងក្នុង និងខាងក្រៅព្រះនគរថា លោកជាអ្នកណា ? មកពីណា ? នឹងទៅណា ? ឬថា ក្នុងដៃរបស់លោកមានអ្វី ? ជាការពិត ពួកមនុស្សដែលដើរទៅទាំងខាងក្នុង និងខាងក្រៅព្រះនគរទាំងនោះ មិនមែននាទីរបស់អ្នករក្សាទ្វារនោះទេ តែគេរមែងដេញដោលសួរចំពោះមនុស្សដែលមកដល់ទ្វារហើយៗ ប៉ុណ្ណោះ យ៉ាងណា ខ្យល់ដែលចូលទៅខាងក្នុង និងខ្យល់ដែលចេញទៅខាងក្រៅ រមែងមិនជានាទីរបស់ភិក្ខុនេះ ក៏យ៉ាងនោះដែរ នឹងជានាទីចំពោះតែខ្យល់ដែលមកដល់រន្ធច្រមុះហើយៗ ប៉ុណ្ណោះ ។ នេះជាសេចក្តីឧបមាដូចអ្នករក្សាទ្វារ ។

## ការកំណត់ខ្យល់ដកដង្ហើម ប្រៀបដូចរណារ

ចំណែកសេចក្តីឧបមាដូចរណារ គួរជ្រាបចាប់ផ្តើមតាំងពីដើមទៅ ។ សមដូចពាក្យដែលលោកព្រះធម្មសេនាបតីសារីបុត្រ ពោលទុកថា "កាលបុគ្គលមិនស្គាល់នូវអារម្មណ៍របស់ចិត្តតែមួយ ការចម្រើននូវធម៌ ៣ ប្រការ គឺ និមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងមិនបាន (សម្រេចនូវភាវនា) ។ កាលបុគ្គលដឹងនូវអារម្មណ៍របស់ចិត្តតែមួយ ការចម្រើននូវធម៌ ៣ ប្រការ គឺ និមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងបាន(សម្រេចនូវភាវនា) ។

ធម៌ទាំង ៣ យ៉ាងនេះ មិនជាអារម្មណ៍នៃចិត្តតែមួយផង ធម៌ទាំង ៣ យ៉ាងនេះ មិនមែនជាមិនប្រាកដផង តើដូចម្តេច ។ ចិត្តមិនដល់នូវសេចក្តីរវើរវាយ ១ ព្យាយាមប្រាកដ ១ ភិក្ខុញ៉ាំងព្យាយាមឲ្យសម្រេចបាននូវគុណវិសេស ១ ។ ប្រៀបដូចដើមឈើដែលគេដាំលើផែនដីរាបស្មើ បុរសអារដើមឈើនោះ ដោយរណារ ស្មារតីរបស់បុរស រមែងតាំងឡើងចំពោះដើមឈើ ដោយអំណាចនៃធ្មេញរណារដែលពាល់ត្រូវ បុរសមិនធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារដែលទាញមកទាញទៅ ធ្មេញរណារដែលទាញមកក្តី ទាញទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាមរមែងប្រាកដផង បុរសរមែងញ៉ាំងព្យាយាមឲ្យសម្រេចបាននូវគុណវិសេសផង ឯការចូលទៅជិតចងនិមិត្ត ទុកដូចដើមឈើដែលគេដាំលើភូមិភាគដ៏រាបស្មើ, ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល ទុកដូចធ្មេញរណារ, ភិក្ខុតម្កល់ទុកនូវស្មារតីត្រង់ចុងច្រមុះ ឬទ្វារមាត់ ហើយអង្គុយមិនធ្វើទុកក្នុងចិត្តនូវខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល ទាំងដែលមកទាំងដែលទៅ ខ្យល់ដកដង្ហើមចេញនិងខ្យល់ដកដង្ហើមចូលដែលមកក្តី ដែលទៅក្តី មិនមែនមិនប្រាកដទេ ព្យាយាមរមែងប្រាកដផង ភិក្ខុញ៉ាំងព្យាយាមឲ្យសម្រេចបាននូវគុណវិសេសផង ប្រៀបដូចស្មារតីបុរសតាំងឡើងចំពោះដើម-ឈើ ដោយអំណាចនៃធ្មេញរណារដែលពាល់ត្រូវបុរសមិនធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារដែលទាញមកទាញទៅ ធ្មេញរណារដែលទាញ

មកក្តី ទាញទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាមប្រាកដផង បុរសញ៉ាំងព្យាយាមឲ្យសម្រេចបាននូវគុណវិសេសផង ។[4]

ការព្យាយាម តើដូចម្តេច ភិក្ខុមានព្យាយាមប្រារព្ធហើយ តែងមានកាយ និងចិត្តគួរដល់ការងារ, នេះឈ្មោះថា ការព្យាយាម ។ ការប្រកបព្យាយាម តើដូចម្តេច ។ ភិក្ខុមានព្យាយាមប្រារព្ធហើយ រមែងលះបង់នូវពួកឧបក្កិលេស មានវិតក្កៈស្ងប់រម្ងាប់, នេះឈ្មោះថា ការប្រកបព្យាយាម ។ គុណពិសេស តើដូចម្តេច ។ ភិក្ខុមានព្យាយាមប្រារព្ធហើយ រមែងលះបង់នូវពួកសញ្ញោជនៈ មានពួកអនុ-សយធម៌វិនាស នេះឈ្មោះថា គុណពិសេស ។ នេះធម៌ ៣ យ៉ាង ដែលមិនមែនជាអារម្មណ៍នៃឯកចិត្ត, នេះធម៌ ៣ យ៉ាង ដែលភិក្ខុមិនមែនជាមិនដឹង គឺ ចិត្តមិនដល់នូវសេចក្តីរាយមាយ ១ ព្យាយាមប្រាកដ ១ ភិក្ខុញ៉ាំងព្យាយាមឲ្យសម្រេចបាននូវគុណវិសេស ១ យ៉ាងនេះឯង ។[5]

> អានាបានស្សតិបុគ្គលណាបានបំពេញហើយ ចម្រើនហើយ
> ដោយប្រពៃ សន្សំហើយដោយលំដាប់ ឲ្យដូចព្រះពុទ្ធទ្រង់
> សម្តែងទុកហើយ, បុគ្គលនោះ រមែងញ៉ាំងលោកនេះ
> ឲ្យភ្លឺច្បាស់ ដូចជាព្រះចន្ទដែលផុតស្រឡះចាកពពក ។”[6]

---

[4] ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៩២/១០៥, ៩៣/១០៦ ។

[5] ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៩២/១០៥, ៩៣/១០៦ ។

[6] ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៩៤/១០៧ ។

សេចក្តីនេះឧបមាដូចរណារ ។ ក៏ក្នុងសេចក្តីឧបមាដូចរណារនេះ គប្បីជ្រាបថា ហេតុត្រឹមតែមិនដាក់ចិត្តដោយអំណាចខ្យល់ដកដង្ហើមចេញនិងខ្យល់ដកដង្ហើមចូល ដែលកន្ទងមកហើយៗ ប៉ុណ្ណោះជាប្រយោជន៍ដល់ភិក្ខុនោះ ។ កម្មដ្ឋាននេះកាលភិក្ខុខ្វះ មនសិការនិមិត្ត រមែងកើតឡើងដោយមិនយឺតយូរឡើយ និងបឋបនា ពោលគឺ អប្បនាដែលប្រកបដោយអង្គឈានដ៏សេស ក៏រមែងសម្រេច ។ តែសម្រាប់ភិក្ខុខ្វះ មានចាប់ផ្តើមតាំងពីវេលាមនសិការដោយអំណាចការរាប់ទុំះ ឯង គឺតាំងពីវេលាធ្វើទុកក្នុងចិត្តដោយអំណាចការរាប់ កាលសេចក្តីខ្វល់ខ្វាយផ្លូវកាយស្ងប់ទៅ ដោយអំណាចខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូលដែលគ្រោតគ្រាតរលត់ទៅដោយលំដាប់ កាយក្តីចិត្តក្តី រមែងជារបស់ស្រាល រាងកាយ រមែងដូចជាដល់អាការអណ្តែតឡើងទៅក្នុងអាកាស ដូចភិក្ខុដែលមានកាយរសាប់រសល់កាលអង្គុយចុះលើគ្រែឬតាំង គ្រែនិងតាំង រមែងទ្រេតទោរទៅ កម្រាលរមែងរួញជ្រួញៗ, តែកាលលោកមានកាយមិនរសាប់រសល់ អង្គុយចុះ គ្រែនិងតាំង រមែងមិនទ្រេត មិនទោរ កម្រាលក៏មិនរួញជ្រួញៗ, គ្រែតាំងដូចជាពេញដោយសំឡីគ, ព្រោះហេតុអ្វី ? ព្រោះហេតុថាកាយមិនរសាប់រសល់ រមែងជារបស់ស្រាលដូច្នោះ ។ កាលខ្យល់អស្សាសៈនិងបស្សាសៈដែលគ្រោតគ្រាតរលត់ទៅហើយ ចិត្តរបស់ភិក្ខុនោះមាននិមិត្ត គឺខ្យល់អស្សាសៈនិងបស្សាសៈដែលល្អិតជាអារម្មណ៍ រមែងប្រព្រឹត្តទៅ, សូម្បីកាលចិត្តនោះរលត់ទៅហើយ ចិត្ត

តៗ ទៅ ដែលមានអារម្មណ៍គឺ និមិត្តដែលល្អិតជាងចិត្តនោះ រមែងប្រព្រឹត្តទៅនោះឯង ។

សួរថា ចិត្តតៗ ទៅ រមែងប្រព្រឹត្តទៅយ៉ាងណា ?

ឆ្លើយថា ប្រៀបដូចបុរស យកកំណាត់ដែកជំគោះរគាំង ដោយការគោះត្រឹមតែម្តង សំឡេងខ្លាំងក៏កើតឡើង, ចិត្តរបស់បុរសនោះដែលមានសំឡេងខ្លាំង (គ្រោតគ្រាត) ជាអារម្មណ៍ គប្បីប្រព្រឹត្តទៅ, កាលសំឡេងខ្លាំងរលត់ទៅ តពីនោះខាងក្រោយចិត្តដែលមានសំឡេងល្អិតជាអារម្មណ៍ គប្បីប្រព្រឹត្តទៅ, សូម្បីកាលចិត្តដែលមាននិមិត្ត គឺសំឡេងល្អិតជាអារម្មណ៍នោះរលត់ទៅហើយ ចិត្តតៗ ទៅ ដែលមានអារម្មណ៍គឺ និមិត្តដែលល្អិតដរាបដល់ល្អិតជាងចិត្ត ដែលមាននិមិត្ត គឺសំឡេងល្អិត ជាអារម្មណ៍នោះ រមែងប្រព្រឹត្តទៅតែម្តង យ៉ាងណា, ចិត្តដែលមាននិមិត្ត គឺ ខ្យល់អស្សាសៈនិងបស្សាសៈជាអារម្មណ៍នោះ បណ្ឌិតគប្បីជ្រាបថា រមែងប្រព្រឹត្តទៅ យ៉ាងនោះ, សូម្បីសេចក្តីនេះសមពិត ដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រ ពោលទុកថា "ប្រៀបដូចជារគាំង ដែលគេគោះ សំឡេងគ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង", ដូច្នេះ ជាដើម ។ គួរឲ្យពិស្តារ ។ ដូចពួកកម្មដ្ឋានដទៃ រមែងប្រាកដច្បាស់ក្នុងលំដាប់ខ្ពស់ៗ ឡើងទៅ យ៉ាងណា, អានាបានស្សតិកម្មដ្ឋាននេះ មិនមែនយ៉ាងនោះទេ ។ តែអានាបានស្សតិកម្មដ្ឋាននេះ កាលភិក្ខុចម្រើនៗ ក្នុងលំដាប់ខ្ពស់ឡើងទៅ រមែងដល់ភាពជារបស់ល្អិត គឺ នឹងមិនដល់សូម្បីសេចក្តីប្រាកដ ។

ក៏កាលកម្មដ្ឋាននោះ មិនប្រាកដយ៉ាងនោះ ភិក្ខុនោះ មិនគួរទះកម្រាលស្បែក ក្រោកចាកអាសនៈចៀសចេញទៅទេ ។ មិនគួរក្រោកឡើងដោយគិតថា តើត្រូវធ្វើដូចម្ដេចហ្ន៎ ? យើងនឹងទៅសួរអាចារ្យ, ឬថាឥឡូវនេះ កម្មដ្ឋានរបស់យើងសាបសូន្យហើយ ។ ពិតមែន កាលលោកឲ្យឥរិយាបថកម្រើកដើរទៅ កម្មដ្ឋានរមែងប្រាកដជារបស់ថ្មីៗរឿយទៅ; ព្រោះហេតុនោះ គួរនៅអង្គុយដូចដើមនុ៎ះឯង នាំកម្មដ្ឋានមកពីទីដែលពាល់ត្រូវតាមប្រក្រតី ។

## ឧបាយជាហេតុនាំអានាបានស្សតិកម្មដ្ឋានមក

ក្នុងអធិការពោលអំពីអានាបានស្សតិកម្មដ្ឋាននោះ មានឧបាយជាគ្រឿងនាំមកដូចតទៅនេះ ៖

ពិតមែន ភិក្ខុនោះ ដឹងថា កម្មដ្ឋានមិនប្រាកដ គួរពិចារណាកំណត់យ៉ាងនេះថា ឈ្មោះថា ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលនេះ មាននៅក្នុងទីណា ? មិនមានក្នុងទីណា ? របស់អ្នកណាមាន ? របស់អ្នកណាមិនមាន ? ខាងក្រោយ កាលភិក្ខុនោះ ពិចារណាមើលយ៉ាងនេះ ក៏ដឹងបានថា ខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញនេះ (របស់ទារកដែលនៅ) ក្នុងផ្ទៃរបស់មាតា មិនមាន, ពួកជនអ្នកមុជទឹកក៏មិនមាន, ពួកអសញ្ញីសត្វ អ្នកស្លាប់ហើយ អ្នកចូលចតុត្ថជ្ឈានលោកអ្នកជល់ព្រមដោយរូបភព និងអរូបភព លោកអ្នកចូលនិរោធក៏មិនមានដូចគ្នា ហើយគប្បីដាស់តឿនខ្លួនឯងយ៉ាងនេះថា "នែបណ្ឌិត

ខ្លួនលោកមិនមែនអ្នកនៅក្នុងផ្ទៃរបស់មាតា មិនមែនអ្នកមុជទឹក មិនមែនជាអសញ្ញីសត្វ មិនមែនអ្នកស្លាប់ មិនមែនអ្នកចូលចតុត្ថជ្ឈាន មិនមែនអ្នកដល់ភាពជាសត្វក្នុងរូបភព និងអរូបភព មិនមែនអ្នកចូលនិរោធ មិនមែនឬ ? ខ្លួនលោកនៅមានខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលពិតៗ, តែខ្លួនលោកក៏មិនអាចនឹងកំណត់បាន ព្រោះនៅមានបញ្ញាទន់ខ្សោយ" ។

ក្រោយមក លោកគួរតាំងចិត្តទុក ដោយអំណាចទីដែលខ្យល់ពាល់ត្រូវដោយប្រក្រតីនុ៎ះឯងឲ្យមនសិការប្រព្រឹត្តទៅ ។ ពិតមែនខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលនេះ ប៉ះខ្ទប់ក្ពោងច្រមុះរបស់អ្នកមានច្រមុះវែងកន្លងទៅ, ប៉ះខ្ទប់បបូរមាត់ខាងលើរបស់អ្នកមានច្រមុះខ្លីកន្លងទៅ ។ ព្រោះដូច្នោះ លោកនោះ ទើបគួរតាំងនិមិត្តទុកថា "ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល រមែងប៉ះខ្ទប់ឋានឈ្មោះនេះ"។ សេចក្តីពិត ព្រះមានព្រះភាគ ទ្រង់អាស្រ័យអំណាចប្រយោជន៍នេះឯង ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលនូវអានាបានស្សតិរបស់ភិក្ខុដែលវង្វេងស្មារតី មិនប្រកបដោយបញ្ញាដឹងសព្វទេ" ។

ពិតមែន កម្មដ្ឋានយ៉ាងណាមួយ រមែងសម្រេចដល់អ្នកមានសតិ មានសេចក្តីដឹងខ្លួនប៉ុណ្ណោះ ក៏ពិតមែនហើយ, តែថា កម្មដ្ឋានយ៉ាងដទៃ ក្រៅអំពីអានាបានស្សតិកម្មដ្ឋាននេះ រមែងប្រាកដបានដល់អ្នកដែលមនសិការៈ ។ តែអានាបានស្សតិកម្មដ្ឋាននេះជាការៈធ្ងន់

ចម្រើនសម្រេចបានលំបាក ទាំងជាភូមិនៃមនសិការរបស់មហាបុរស ទាំងឡាយគឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធបុត្រប៉ុណ្ណោះ, មិនមែន ជាកម្មដ្ឋានថ្នាក់ទាប, ទាំងមិនមែនជាកម្មដ្ឋានដែលសត្វថោកទាបត្រូវ សេព, ជាកម្មដ្ឋានស្ងប់និងល្អិត ដោយប្រការដែលមហាបុរសទាំង ឡាយ រមែងធ្វើទុកក្នុងចិត្ត; ព្រោះដូច្នោះ ក្នុងអានាបានស្សតិកម្មដ្ឋាន នេះ ចាំបាច់ត្រូវប្រាថ្នាសតិនិងបញ្ញាដែលមានកម្លាំង ។ ដូចយ៉ាងថា ក្នុងវេលាដេរប៉ះសំពត់សាដកសាច់រលោង ស្ជុលក៏ចាំបាច់ត្រូវ ប្រាថ្នាយ៉ាងតូចៗ ស្ជុលអំបោះដែលដោតក្នុងរន្ធម្ជុល ក៏ចាំបាច់ត្រូវ ប្រាថ្នាសរសៃល្អិតជាងនោះ យ៉ាងណា, ក្នុងវេលាចម្រើនកម្មដ្ឋាននេះ ដែលដូចជាសំពត់សាដកសាច់រលោង ក៏យ៉ាងនោះដែរ ។ សតិមាន ចំណែកប្រៀបដោយម្ជុលក្តី បញ្ញាដែលសម្បយុត្តដោយសតិនោះ មានចំណែកប្រៀបដោយអំបោះដោតរន្ធម្ជុលក្តី ចាំបាច់ត្រូវប្រាថ្នា ឲ្យមានកម្លាំង ។

ក៏ឯភិក្ខុដែលប្រកបដោយសតិនិងបញ្ញានោះហើយ មិនចាំបាច់ ត្រូវស្វែងរក ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលនោះ ក្រៅអំពី ឱកាសដែលខ្យល់ពាល់ត្រូវដោយប្រក្រតី ។ ប្រៀបដូចអ្នកស្រែ ភ្ជួរ ស្រែហើយលែងពួកគោស្វាវ ឲ្យបែរមុខទៅកាន់ទីស្មៅ ហើយគប្បី អង្គុយសម្រាកនៅត្រង់ម្លប់ឈើ, គ្រានោះពួកគោស្វាវទាំងនោះចូល ព្រៃទៅដោយរហ័ស ទឹងមិនដើរតាមស្នាមជើងគោស្វាវទាំងនោះចូល ទៅកាន់ព្រៃ, តាមការពិត គេនឹងកាន់យកខ្សែនិងជន្លួញដើរត្រង់ទៅ

កាន់កំពង់ទឹកដែលគោស្ទាវទាំងនោះចុះតែម្ដង អន្ទយឬដេកចាំ ។ វេលានោះគេបានឃើញគោទាំងនោះ ដែលត្រាច់ទៅពេញមួយថ្ងៃ ហើយចុះទៅកាន់កំពង់ទឹក ងូតនិងផឹកទឹក ហើយឡើងមកឈរ ទើបយកខ្សែចងហើយយកជន្ទញចាក់ នាំទៅទឹម (នង្គ័ល) ធ្វើការងារទៀតយ៉ាងណា ភិក្ខុនោះ ក៏យ៉ាងនោះដែរ មិនចាំបាច់ត្រូវស្វែងរកខ្យល់ ដកដង្ហើមចេញនិងដកដង្ហើមចូល ក្រៅអំពីឱកាសដែលខ្យល់ប៉ះត្រូវដោយប្រក្រតី តែគប្បីកាន់យកខ្សែ គឺសតិ និងជន្ទញ គឺបញ្ញា ហើយតាំងចិត្តទុកក្នុងឱកាសដែលខ្យល់ពាល់ត្រូវដោយប្រក្រតី ញុំាងមនសិការឲ្យប្រព្រឹត្តទៅ ។ ព្រោះថា កាលលោកមនសិការយ៉ាងនោះ រយៈកាលមិនយូរឡើយខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលនោះ នឹងប្រាកដដូចពួកគោស្ទាវប្រាកដត្រង់កំពង់ទឹកដូច្នោះ ។

ក្នុងលំដាប់នោះ លោកគប្បីយកខ្សែ គឺ សតិចងប្រកបទុកក្នុងទីនោះឯង ហើយចាក់ដោយជន្ទញគឺ បញ្ញាតាមប្រកបកម្មដ្ឋានទៀត ។ កាលលោកប្រឹងប្រែងប្រកបយ៉ាងនោះ រយៈកាលមិនយូរឡើយ និមិត្តនឹងប្រាកដ ។ អាចារ្យពួកខ្លះពោលទុកថា

> “ក៏និមិត្តនេះ រមែងមិនប្រាកដដូចគ្នា ដល់ព្រះយោគាវចរគ្រប់រូប ។ មួយទៀត និមិត្តនោះ រមែងប្រាកដដល់ព្រះយោគា-វចររូបខ្លះ ដូចសំឡីគ ដូចសំឡីកប្បាស និងដូចក្រសែខ្យល់ឲ្យកើតសុខសម្ផស្ស” ។

ចំណែកវិនិច្ឆ័យក្នុងអដ្ឋកថា មានដូចតទៅនេះ ៖

ពិតមែន និមិត្តនេះ រមែងប្រាកដដល់ព្រះយោគាវចររូបខ្លះ ដូចដូងផ្កាយ ដូចក្ដួងកែវមណី និងដូចក្ដួងកែវមុក្ដា រូបខ្លះប្រាកដជារបស់មានសម្ផស្សគ្រោតគ្រាត ដូចគ្រាប់កប្បាស និងដូចបំណែកស្រួចតូចៗនៃឈើខ្លឹម, រូបខ្លះប្រាកដដូចជាខ្សែសង្វារវែង ដូចក្ដួងនៃផ្កា និងដូចផ្សែងភ្លើង, រូបខ្លះដូចសរសៃពីងពាងដែលធំ ដូចដុំពពកធំ ដូចផ្កាឈូក ដូចកង់រថ ដូចមណ្ឌលព្រះចន្ទ និងដូចមណ្ឌលព្រះអាទិត្យ ដូច្នោះ ។

ក៏ឯកម្មដ្ឋាននេះ មានតែម្យ៉ាងពិតៗ តែប្រាកដដោយសេចក្ដីផ្សេងគ្នា ព្រោះមានសញ្ញាផ្សេងគ្នា ដូចបណ្ដាភិក្ខុច្រើនរូប នៅអង្គុយស្វាធ្យាយព្រះសូត្រជាមួយគ្នា កាលភិក្ខុមួយរូប និយាយថា ព្រះសូត្រនេះ រមែងប្រាកដដល់ពួកលោក ដូចម្ដេច ? មួយរូបនិយាយថា រមែងប្រាកដដល់ខ្ញុំព្រះករុណា ដូចជាស្ទឹងហូរធ្លាក់ពីភ្នំធំ, រូបដទៃទៀតនិយាយថា រមែងប្រាកដដល់ខ្ញុំព្រះករុណា ដូចជាជួរព្រៃមួយកន្លែង, រូបដទៃទៀតនិយាយថា រមែងប្រាកដដល់ខ្ញុំព្រះករុណា ដូចជារុក្ខជាតិដែលប្រកបព្រមដោយការៈគឺ ផ្លែឈើ ដែលមានម្លប់ត្រជាក់បរិបូរណ៍ដោយមែក, ពិតមែន ព្រះសូត្ររបស់លោកទាំងនោះ ក៏ជាសូត្រតែមួយដូចគ្នាទុំះឯង តែប្រាកដដោយភាពជារបស់ផ្សេងគ្នា ព្រោះមានសញ្ញាផ្សេងគ្នា ដូច្នោះ ។ សេចក្ដីពិត កម្មដ្ឋាននេះ កើតអំពីសញ្ញា

មានសញ្ញាជាដើមហេតុ មានសញ្ញាជាដែនកើត; ព្រោះដូច្នោះ គប្បីជ្រាបថា រមែងប្រាកដដោយសេចក្ដីផ្សេងគ្នា ព្រោះមានសញ្ញាផ្សេងគ្នា ។

## ធម៌ ៣ យ៉ាងមានបរិបូរណ៍កម្មដ្ឋានទើបដល់អប្បនា

ក៏បណ្ដាខ្យល់ដកដង្ហើមចេញ ដកដង្ហើមចូល និងនិមិត្តនេះ ចិត្តដែលមានខ្យល់ដកដង្ហើមចេញជាអារម្មណ៍ មួយយ៉ាងផ្សេង ចិត្តដែលមានខ្យល់ដកដង្ហើមចូលជាអារម្មណ៍ ក៏ម្យ៉ាងផ្សេង ចិត្តដែលមាននិមិត្តជាអារម្មណ៍ ក៏ម្យ៉ាងផ្សេង ។ ពិតមែន កម្មដ្ឋានរបស់ភិក្ខុដែលមិនមានធម៌ ៣ យ៉ាងនេះ រមែងមិនដល់អប្បនា មិនដល់ឧបចារ ។ ចំណែកកម្មដ្ឋានរបស់ភិក្ខុដែលមានធម៌ ៣ យ៉ាងនេះ រមែងដល់អប្បនានិងឧបចារផង ។ សមពិត ដូចពាក្យដែលព្រះធម្មសេនាបតី-សារីបុត្រពោលទុកថា និមិត្ត ខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល មិនមែនជាអារម្មណ៍នៃចិត្តតែមួយ, និងកាលភិក្ខុមិនដឹងធម៌ ៣ ប្រការ រមែងមិនបានភាវនា (រមែងមិនសម្រេច), និមិត្តខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល មិនមែនជាអារម្មណ៍នៃចិត្តតែមួយ, និងកាលភិក្ខុដឹងនូវធម៌ ៣ ប្រការ រមែងបានភាវនា ។

អាចារ្យទាំងឡាយ អ្នកពោលទីឃនិកាយ បានពោលទុកយ៉ាងនេះមុនថា ក៏កាលនិមិត្តប្រាកដហើយយ៉ាងនោះ ភិក្ខុនោះគួរទៅសំណាក់របស់អាចារ្យ ហើយប្រាប់ថា និមិត្តបែបនេះ រមែងប្រាកដដល់ខ្ញុំព្រះករុណា ចំណែកអាចារ្យមិនគួរនិយាយថា នោះជានិមិត្ត

ឬថា មិនមែននិមិត្ត គួរនិយាយថា "រមែងជាយ៉ាងនោះឯង ណ៎ះអ្នក" ហើយគប្បីនិយាយថា "ចូរអ្នកមនសិការរឿយៗ" ។ ពិតមែន កាលអាចារ្យនិយាយថា "ជានិមិត្ត" លោកនឹងដល់សេចក្តីថយក្រោយ, កាលអាចារ្យនិយាយថា "មិនមែននិមិត្ត" លោកក៏នឹងអស់សង្ឃឹម; ព្រោះហេតុនោះ មិនគួរនិយាយសូម្បីទាំងពីរយ៉ាងនោះ គួរប្រកបអ្នកនោះទុកក្នុងមនសិការនុ៎ះឯង ។ ចំណែកអាចារ្យទាំងឡាយ អ្នកពោលមជ្ឈិមនិកាយបានពោលទុកថា លោកដែលអាចារ្យគប្បីនិយាយថា "នេះជានិមិត្តណ៎ះអ្នក សូមឲ្យអ្នកមនសិការកម្មដ្ឋានរឿយៗ ចុះណាសប្បុរស" ខាងក្រោយលោករូបនោះ គប្បីតាំងចិត្តទុកក្នុងនិមិត្តនុ៎ះឯង ចាប់ផ្តើមតាំងពីបដិភាគនិមិត្តកើតឡើងនេះ ភាវនានេះរបស់លោករូបនោះ រមែងកើតបាន ដោយអំណាចការតាំងទុកដោយប្រការយ៉ាងនេះ។ សមពិត ដូចពាក្យដែលព្រះបូរាណាចារ្យទាំងឡាយពោលទុកថា

> បុគ្គលអ្នកមានប្រាជ្ញា កាលតម្កល់ចិត្តទុកក្នុងនិមិត្ត ចម្រើនអស្សាសប្បស្សាសៈដែលមានអាការផ្សេងៗ ឈ្មោះថារមែងចងចិត្តរបស់ខ្លួនទុក ។

ចាប់តាំងអំពីនិមិត្តប្រាកដ ដោយន័យដូចពោលហើយនោះ នីវរណៈទាំងឡាយ រមែងជាការដែលព្រះយោគីនោះគ្របសង្កត់បានដោយពិត កិលេសទាំងឡាយ ស្ងប់ស្ងៀម សតិចូលទៅតាំងមាំតែម្តង ចិត្តក៏តាំងមាំដូចគ្នា ។

## ចិត្តរមែងតាំងមាំជាសមាធិដោយអង្គ ២

មែនពិត ចិត្តនេះ រមែងឈ្មោះថា ជាធម្មជាតិតាំងមាំ ដោយអង្គ ២ គឺ ដោយការលះនីវរណៈក្នុងឧបចារភូមិ ឬដោយសេចក្ដីប្រាកដនៃអង្គក្នុងបដិលាភភូមិ ។

បណ្ដាភូមិ ២ យ៉ាងនោះ ដែលឈ្មោះថា ឧបចារភូមិ បានដល់ឧបចារសមាធិ ។ ដែលឈ្មោះថា បដិលាភភូមិ បានដល់អប្បនាសមាធិ ។

សួរថា សមាធិទាំងពីរនោះ មានការធ្វើផ្សេងគ្នាយ៉ាងណា ?

ឆ្លើយថា ឧបចារសមាធិ ត្រាច់ទៅក្នុងកុសលវិថីហើយ ក៏ឈានចុះកាន់ភវង្គ ។ អប្បនាសមាធិ កាលព្រះយោគីអង្គុយយ៉ាងស៊ុបល្អរហូតអស់មួយថ្ងៃ ត្រាច់ទៅក្នុងកុសលវិថី សូម្បីរហូតអស់មួយថ្ងៃ ក៏មិនឈានចុះកាន់ភវង្គ ។ បណ្ដាសមាធិ ២ យ៉ាងនោះ ចិត្តរមែងជាធម្មជាតិតាំងមាំដោយឧបចារសមាធិ ព្រោះនិមិត្តប្រាកដ ។ ខាងក្រោយ ភិក្ខុនេះមិនគប្បីមនសិការនិមិត្តនោះដោយពណ៌ ទាំងមិនគប្បីពិចារណាដោយលក្ខណៈ ។ ក៏ម្យ៉ាងទៀត លោកកុំប្រមាទ គួររក្សានិមិត្តទុក ដូចព្រះមហេសីរបស់ក្សត្រិយ៍ ទ្រង់រក្សាគភ៌នៃស្ដេចចក្រពត្តិ និងដូចអ្នកស្រែរក្សាកួរនៃស្រូវសាលីនិងស្រូវដំណើបដូច្នោះ ។

ពិតមែន និមិត្តដែលរក្សាទុកបាន រមែងឲ្យផលដល់លោក ។ កាលព្រះយោគីរក្សានិមិត្តទុកបាន នឹងមិនមានសេចក្ដីសាបសូន្យចាកឧបចារជ្ឈានដែលខ្លួនបានហើយ ។ កាលមិនមានការរក្សា (និមិត្ត) ឈានដែលខ្លួនបានហើយៗ ក៏នឹងវិនាសទៅ ដូច្នេះឯង ។

## ឧបាយរក្សាអានាបានស្សតិកម្មដ្ឋាន

ក្នុងអធិការនៃអានាបានស្សតិកម្មដ្ឋាននោះ មានឧបាយសម្រាប់រក្សា ដូចតទៅនេះ ៖

ភិក្ខុនោះ គួរវៀរអសប្បាយ ៧ យ៉ាងទាំងនេះ គឺ អាវាស ១ គោចរ ១ ការសន្ទនា ១ បុគ្គល ១ ភោជន ១ រដូវ ១ ឥរិយាបថ ១ ហើយសេពសប្បាយ ៧ យ៉ាងទាំងនោះឯង មនសិការនិមិត្តនោះរឿយៗ ។ ព្រះយោគីនោះ គ្រាធ្វើនិមិត្តឲ្យរឹងមាំដោយការសេពសប្បាយយ៉ាងនោះហើយ គួររង់ចាំសេចក្ដីចម្រើនបរិបូណ៌ឡើង បំពេញសេចក្ដីព្យាយាមមិនលះបោលអប្បនាកោសល ១០ យ៉ាងទាំងនេះ គឺ ធ្វើវត្ថុឲ្យស្អាត ១ ផ្គងឥន្ទ្រិយឲ្យប្រព្រឹត្តទៅស្មើ ១ ឆ្លាតក្នុងនិមិត្ត ១ គ្របសង្កត់ចិត្តក្នុងសម័យដែលគួរគ្របសង្កត់ ១ ផ្គងចិត្តក្នុងសម័យដែលគួរផ្គង ១ លួងលោមចិត្តឲ្យរីករាយក្នុងសម័យដែលគួរលួងលោមចិត្តឲ្យរីករាយ ១ សម្លឹងមើលចិត្តក្នុងសម័យដែលគួរសម្លឹងមើល ១ វៀរបុគ្គលដែលមានចិត្តមិនតាំងមាំ ១ សេពបុគ្គល

ដែលមានចិត្តតាំងមាំ ១ បង្អោនទៅក្នុងសមាធិនោះ ១ កាលព្រះយោគីនោះប្រឹងប្រែងប្រកបតាមន័យដូចពោលមកយ៉ាងនេះ មនោទ្វារាវជ្ជនៈ ដែលមាននិមិត្តជាអារម្មណ៍ កាត់ភវង្គហើយក៏កើតឡើងក្នុងខណៈដែលគួរពោលថា អប្បនា នឹងកើតឡើងក្នុងកាលឥឡូវនេះ ។ ក៏កាលមនោទ្វារាវជ្ជនៈនោះរលត់ទៅ ។ បណ្ដាជវនៈទាំងឡាយ ៤ ឬ ៥ ដួង តោងយកអារម្មណ៍នោះឯងត្រាច់ទៅ ដែលជវនៈដួងដំបូងឈ្មោះបរិកម្ម, ទី ២ ឈ្មោះឧបចារ, ទី ៣ ឈ្មោះអនុលោម, ទី ៤ ឈ្មោះគោត្រភូ, ទី ៥ ឈ្មោះអប្បនាចិត្ត ។ ម្យ៉ាងទៀត ដួងដំបូងហៅថា បរិកម្មនិងឧបចារ ទី ២ ហៅថា អនុលោម, ទី ៣ ហៅថា គោត្រភូ, ទី ៤ ហៅថា អប្បនាចិត្ត ។ ពិតមែន ជវនៈ ដួងទី ៤ ប៉ុណ្ណោះ ពេលខ្លះទី ៥ រមែងប្រព្រឹត្តទៅ មិនដល់ដួងទី ៦ ឬទី ៧ ព្រោះអាសន្នភវង្គ (ភវង្គជិតអប្បនា) ធ្លាក់ទៅ ។ ចំណែកព្រះគោទត្តត្ថេរ អ្នកជំនាញអភិធម្មពោលទុកថា កុសលធម៌ទាំងឡាយ រមែងជាធម៌មានកម្លាំងដោយអាសេវនបច្ច័យ; ព្រោះដូច្នោះ ជវនៈ រមែងដល់ទី ៦ ឬទី ៧ ។ ពាក្យនោះត្រូវជំទាស់ក្នុងអដ្ឋកថាទាំងឡាយ ។ ក្នុងជវនចិត្តទាំងនោះ ចិត្តដែលជាបុព្វភាគ ជាកាមាវចរ ចំណែកអប្បនាចិត្តជារូបាវចរ ។ បឋមជ្ឈានដែលលះអង្គ ៥ ប្រកបដោយអង្គ ៥ បរិបូរណ៍ដោយលក្ខណៈ ១០ មានសេចក្ដីល្អ ៣ រមែងជាការដែលព្រះយោគីនេះសម្រេចហើយ ដោយន័យដូចពោលមកដូច្នេះ ។ លោកញុំាងអង្គឈានទាំងឡាយ មានវិតក្កៈជាដើមឲ្យស្ងប់រម្ងាប់ក្នុងអារម្មណ៍

នោះឯង រមែងសម្រេចឈានទី ២ ទី ៣ និងទី ៤ ។ និងដោយហេតុមានប្រមាណត្រឹមនេះ លោករមែងជាអ្នកដល់ទីបំផុតនៃភាវនាដោយអំណាចនៃការបញ្ឈប់ ។ ក្នុងអធិការនេះ មានសង្ខេបកថាប៉ុណ្ណេះ ចំណែកអ្នកសិក្សាដែលត្រូវការសេចក្តីពិស្តារ គប្បីកាន់យកអំពីបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គចុះ ។ ចំណែកក្នុងកាយានុបស្សនានេះ ភិក្ខុដែលសម្រេចចតុត្ថជ្ឈានហើយយ៉ាងនោះ មានសេចក្តីប្រាថ្នានឹងចម្រើនកម្មដ្ឋាន ដោយអំណាចការកំណត់និងការផ្លាស់ប្តូរ ហើយសម្រេចសេចក្តីបរិសុទ្ធិ ធ្វើឈាននោះឯង ឲ្យដល់សេចក្តីជំនាញ (វសី)ដោយអាការ ៥ យ៉ាង ពោលគឺ **អាវជ្ជនៈ** ការរំពឹង, **សមាបជ្ជនៈ** ការចូល, **អធិដ្ឋានៈ** ការតាំងចិត្ត, **វុដ្ឋានៈ** ការចេញ, និង **បច្ចវេក្ខណៈ** ការពិចារណាហើយកំណត់រូប និងអរូបថា រូបមានអរូបជាប្រធាន ឬអរូបមានរូបជាប្រធាន, ហើយចាប់ផ្តើមតាំងវិបស្សនា ។

សួរថា ផ្តើមតាំងវិបស្សនាយ៉ាងណា ?

ឆ្លើយថា ពិតមែន ព្រះយោគីនោះ គ្រាចេញចាកឈានហើយកំណត់អង្គឈាន រមែងឃើញហទយៈវត្ថុ ដែលជាទីអាស្រ័យនៃអង្គឈានទាំងនោះ រមែងឃើញភូតរូប ដែលជាទីអាស្រ័យនៃហទយៈវត្ថុនោះ និងរមែងឃើញករជកាយសូម្បីទាំងអស់ ដែលជាទីអាស្រ័យនៃភូតរូបទាំងនោះ ។ ក្នុងលំដាប់នៃការឃើញនោះ លោករមែងកំណត់រូបនិងអរូបថា អង្គឈានចាត់ជាអរូប, (ហទយៈ) វត្ថុជាដើម

ចាត់ជារូប ។ មយ៉ាងទៀត លោកនោះ លុះចេញចាកសមាបត្តិហើយ កំណត់កូតរូបទាំង ៤ ដោយអំណាចបឋវីធាតុជាដើម ក្នុងបណ្តាចំណែកទាំងឡាយមានសក់ជាដើម និងរូបដែលអាស្រ័យកូតរូបនោះ រមែងឃើញវិញ្ញាណព្រមទាំងសម្បយុត្តធម៌ ដែលមានរូបតាមដែលខ្លួនកំណត់ហើយជាអារម្មណ៍ ឬមានរូបវត្ថុ និងទ្វារតាមដែលខ្លួនកំណត់ហើយជាអារម្មណ៍ ។ លំដាប់នោះ លោករមែងកំណត់ថា កូតរូបជាដើម ចាត់ជារូប, វិញ្ញាណដែលមានសម្បយុត្តធម៌ ចាត់ជាអរូប ។ មយ៉ាងទៀត កាលលោកចេញចាកសមាបត្តិហើយ រមែងឃើញថា ករជ្ជកាយ និងចិត្តជាទីកើតឡើងនៃខ្យល់អស្សាសៈ និងបស្សាសៈ ។ ដូចយ៉ាងថា កាលស្នប់របស់ជាងមាសនៅសប់ ខ្យល់រមែងសញ្ចរទៅមក ព្រោះអាស្រ័យការសប់ និងសេចក្តីព្យាយាមដែលកើតអំពីការសប់នោះរបស់បុរស យ៉ាងណា, ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល រមែងចូលចេញ ព្រោះអាស្រ័យកាយនិងចិត្តក៏យ៉ាងនោះដែរ ។ លំដាប់នោះ លោកកំណត់ខ្យល់ដកដង្ហើមចេញដកដង្ហើមចូល និងកាយថា ជារូប, កំណត់ចិត្តនោះនិងធម៌ដែលសម្បយុត្តដោយចិត្តថា ជាអរូប ។ កាលលោកកំណត់នាមរូបដោយអាការយ៉ាងនោះហើយ រមែងស្វែងរកបច្ច័យនៃនាមរូបនោះ ។ លោកកាលស្វែងរក ក៏បានឃើញបច្ច័យមានអវិជ្ជា និងតណ្ហាជាដើមនោះហើយ រមែងឆ្លងផុតពីការសង្ស័យ ប្រារព្ធការប្រព្រឹត្តទៅនៃនាមរូបក្នុងកាលទាំង ៣ ចេញបាន ។ លោកនោះឆ្លងសេចក្តីសង្ស័យ

បានហើយ លើកត្រៃលក្ខណ៍ឡើងដោយអំណាចពិចារណាកលាបៈ លះវិបស្សនូបក្កិលេស ១០ យ៉ាង មានឱភាសជាដើម ដែលកើតឡើងហើយក្នុងចំណែកខាងដើម ដោយឧទយព្វយានុបស្សនា (ការពិចារណាឃើញការកើត និងការរលត់) កំណាត់បដិបទាញាណដែលរួចផុតពីឧបក្កិលេសថា ជាមគ្គ លះការកើតចេញ ដល់ភង្គានុបស្សនា (ការពិចារណាឃើញការរលត់) នឿយណាយប្រាសចាកតម្រេករួចផុតពីសង្ខារទាំងពួង ដែលប្រាកដជារបស់គួរខ្លាច ដោយពិចារណាឃើញការរលត់ជាប់តគ្នាទៅ បានសម្រេចអរិយមគ្គទាំង ៤ តាមលំដាប់ ហើយតាំងនៅក្នុងព្រះអរហត្តផលដល់ទីបំផុតនៃបច្ចវេក្ខណ-ញ្ញាណ ១៩ យ៉ាង ជាកំពូលនៃទក្ខិណេយបុគ្គលក្នុងលោក ព្រមទាំងទេវលោក ។ ក៏ការចម្រើនអានាបានស្សតិសមាធិ របស់ភិក្ខុដែលប្រកបក្នុងអានាបានស្សតិកម្មដ្ឋាននោះ ចាប់ផ្តើមតាំងពីការរាប់ ដរាបដល់មគ្គផលជាទីបំផុត ចប់បរិបូណ៌ត្រឹមតែប៉ុណ្ណោះឯង ។

នេះពណ៌នាបឋមចតុក្កៈដោយអាការគ្រប់យ៉ាង ក៏ព្រោះក្នុង ៣ ចតុក្កៈក្រៅនេះ ដែលឈ្មោះថា ន័យនៃការចម្រើនកម្មដ្ឋានមួយផ្នែករមែងមិនមាន; ព្រោះដូច្នោះ អ្នកសិក្សាគួរជ្រាបសេចក្តីនៃ ៣ ចតុក្កៈទាំងនោះ ដោយន័យដូចដែលបានពណ៌នាតាមបទនុ៎ះឯង ។

បទថា បីតិបដិសំវេទី (**នឹងកំណត់ដឹងច្បាស់នូវបីតិ**) សេចក្តីថា លោករមែងកំណត់ថា យើងនឹងធ្វើបីតិឲ្យដឹងច្បាស់ គឺធ្វើឲ្យ

ប្រាកដដកដង្ហើមចេញ ដកដង្ហើមចូល ។ បណ្តាបីតិនិងសុខទាំងនោះ បីតិ រមែងជាការដែលភិក្ខុដឹងច្បាស់ហើយដោយអាការ ២ យ៉ាង គឺ ដោយអារម្មណ៍ និងដោយការឈ្វាស ។

សួរថា បីតិ រមែងជាការភិក្ខុដឹងច្បាស់ហើយ ដោយអារម្មណ៍ យ៉ាងណា ?

ឆ្លើយថា ភិក្ខុនោះ រមែងចូលឈានទាំង ២ (បឋមជ្ឈាន និង ទុតិយជ្ឈាន) ដែលមានបីតិ, បីតិឈ្មោះថា ជាការដែលភិក្ខុនោះ ដឹងច្បាស់ហើយដោយអារម្មណ៍ ដោយការបានឈានក្នុងខណៈចូល សមាបត្តិ ព្រោះអារម្មណ៍ជាធម្មជាតិដែលភិក្ខុនោះដឹងច្បាស់ហើយ ។

សួរថា បីតិដែលភិក្ខុដឹងច្បាស់ហើយដោយសេចក្តីមិនល្ងង់ យ៉ាងណា ?

ឆ្លើយថា ភិក្ខុនោះចូលឈានទាំង ២ ដែលមានបីតិ ចេញចាក ឈានហើយ រមែងពិចារណា បីតិដែលសម្បយុត្តដោយឈាន ដោយ ការអស់ ការសាបសូន្យ, បីតិឈ្មោះថា ដែលភិក្ខុនោះ ដឹងច្បាស់ ហើយ ដោយសេចក្តីមិនវង្វេង ព្រោះចាក់ធ្លុះលក្ខណៈ ក្នុងខណៈ នៃវិបស្សនា ។ សេចក្តីនេះ សមពិត ដូចពាក្យដែលព្រះធម្មសេនាបតី សារីបុត្រ ពោលទុកក្នុងបដិសម្ភិទាថា "កាលបុគ្គលដឹងច្បាស់នូវភាព នៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃ ដង្ហើមចេញវែង សតិក៏តម្កល់មាំ, បីតិនោះ ឈ្មោះថា បុគ្គលដឹង ច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ, កាលបុគ្គលដឹង

ច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចដង្ហើមចូលវែង សតិក៏តម្កល់មាំ, បីតិនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ, កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចដង្ហើមចេញខ្លី ដោយអំណាចដង្ហើមចូលខ្លី; ដោយអំណាចដង្ហើមចេញនៃអ្នកកំណត់ដឹងនូវកាយទាំងពួង ដោយអំណាចដង្ហើមចេញរបស់អ្នករម្ងាប់នូវកាយសង្ខារ ដោយអំណាចដង្ហើមចូលរបស់អ្នករម្ងាប់នូវកាយសង្ខារ សតិក៏តម្កល់មាំ, បីតិនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ, កាលបុគ្គលរំពឹង បីតិនោះ ឈ្មោះថា គេដឹងច្បាស់ហើយ, កាលបុគ្គលដឹង .... កាលឃើញ កាលពិចារណា កាលអធិដ្ឋាននូវចិត្ត កាលជឿស៊ប់ដោយសទ្ធា កាលផ្គងនូវវីរិយៈ កាលប្រុងទុកនូវសតិ កាលតម្កល់នូវចិត្ត កាលដឹងច្បាស់ដោយបញ្ញា កាលត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង កាលលះបង់នូវធម៌ដែលគួរលះបង់ កាលចម្រើននូវធម៌ដែលគួរចម្រើន កាលធ្វើឲ្យច្បាស់នូវធម៌ដែលគួរធ្វើឲ្យច្បាស់ បីតិនោះ ឈ្មោះថា គេដឹងច្បាស់ហើយ,[១] ។ សូម្បីបទដ៏សេស ក៏គប្បីជ្រាបដោយសេចក្ដីតាមន័យនេះឯង ។

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ១១៦/១៥១ ។

តែក្នុងពីរបទនេះមានសេចក្ដីគ្រាន់តែប្លែកគ្នា ដូចតទៅនេះ ៖

គប្បីជ្រាបភាពជាអ្នកដឹងច្បាស់នូវសុខ ដោយអំណាចនៃឈាន ៣, គប្បីជ្រាបភាពជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ ដោយអំណាចនៃឈានទាំង ៤ ។ ខន្ធ ២ មានវេទនាជាដើម ឈ្មោះថា ចិត្តសង្ខារ ។ ក៏បណ្ដាពីរបទនេះ ក្នុងសុខប្បដិសំវេទិបទ ព្រះសារីបុត្រថេរៈពោលទុកក្នុងបដិសម្ភិទា ដើម្បីសម្ដែងភូមិនៃវិបស្សនាថា ពាក្យថា សុខ បានដល់ សុខ ២ យ៉ាង គឺ កាយិកសុខ ១ ចេតសិកសុខ ១ ។

ពីរបទថា បស្សម្ភយំ ចិត្តសង្ខារំ (រម្ងាប់ចិត្តសង្ខារ) សេចក្ដីថា រម្ងាប់ គឺ រលត់ចិត្តសង្ខារដែលគ្រោតគ្រាតៗ ចេញ សេចក្ដីរលត់ចិត្តសង្ខារនោះ គប្បីជ្រាបដោយពិស្ដារតាមន័យដូចដែលពោលហើយក្នុងកាយសង្ខារនោះឯង ។

ម្យ៉ាងទៀត បណ្ដាបទទាំងនេះ ក្នុងបីតិបទ លោកពោលវេទនាទុកដោយបីតិជាប្រធាន, ក្នុងសុខបដិសំវេទិបទ លោកពោលវេទនាទុកដោយសរូបតែម្ដង, ក្នុងចិត្តសង្ខារនៃបទទាំងពីរ ជាការលោកពោលវេទនាដែលសម្បយុត្តដោយសញ្ញាទុក ព្រោះព្រះបាលីថា "សញ្ញានិងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះជាប់ចំពោះដោយចិត្ត ដោយអំណាចផ្ដើមចេញវែង ឈ្មោះថា ចិត្តសង្ខារ"[១] ដូច្នេះ ចតុក្កៈនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ដោយវេទនា-នុបស្សនាន័យ ដោយប្រការយ៉ាងនេះ ។

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៣០. ១១៨/១៥៣ ។

សូម្បីក្នុងចតុក្កៈទី ៣ មានវិនិច្ឆ័យដូច្នេះ ៖

បណ្ឌិតគប្បីជ្រាបភាពជាអ្នកដឹងច្បាស់ចិត្ត ដោយអំណាចនៃឈាន ៤ ។

ពីរបទថា អភិប្បមោទយំ ចិត្តំ (នឹងធ្វើចិត្តឲ្យរីករាយ) សេចក្តីថា ភិក្ខុ រមែងកំណត់ថា យើងនឹងញុំាងចិត្តឲ្យរីករាយបានដល់ ឲ្យរីករាយដកដង្ហើមចេញដកដង្ហើមចូល ។

ក្នុងពីរបទនោះ សេចក្តីរីករាយ រមែងកើតបាន ដោយអាការ ២ យ៉ាងគឺ ដោយអំណាចសមាធិ និងដោយអំណាចវិបស្សនា ។

សួរថា សេចក្តីរីករាយ រមែងកើតបាន ដោយអំណាចសមាធិយ៉ាងណា ?

ឆ្លើយថា ភិក្ខុរមែងចូលឈានទាំង ២ (បឋមជ្ឈាន និងទុតិយជ្ឈាន) ដែលមានបីតិ ។ លោកនោះ រមែងឲ្យចិត្តរីករាយដោយបីតិដែលសម្បយុត្តក្នុងខណៈ នៃសមាបត្តិ ។

សួរថា សេចក្តីរីករាយ រមែងកើតបាន ដោយអំណាចវិបស្សនាយ៉ាងណា ?

ឆ្លើយថា កាលភិក្ខុចូលឈានទាំង ២ ដែលមានបីតិ ចេញចាកឈានហើយពិចារណានូវបីតិដែលសម្បយុត្តដោយឈាន ដោយការអស់ទៅ សូន្យទៅ ។ លោកធ្វើបីតិសម្បយុត្តដោយឈានឲ្យជាអារម្មណ៍ ក្នុងខណៈនៃវិបស្សនាយ៉ាងនោះហើយ ឲ្យចិត្តរីករាយ

វីកកាយទៅ ។ អ្នកបដិបត្តិយ៉ាងនោះ លោកហៅថា រមែងកំណត់ថា យើងនឹងញុំាងចិត្តឲ្យរីករាយដកដង្ហើមចេញដកដង្ហើមចូល ។

ពីរបទថា សមាទហំ ចិត្តំ (នឹងតាំងចិត្តខ្ជាប់) សេចក្តីថា តម្កល់ចិត្តទុកស្មើ គឺតាំងចិត្តទុកស្មើក្នុងអារម្មណ៍ ដោយអំណាចនៃឈានមានបឋមជ្ឈានជាដើម ។ បើថា កាលលោកចូលឈានទាំងនោះហើយចេញចាកឈាន ពិចារណានូវចិត្តដែលសម្បយុត្តដោយឈានដោយការអស់ទៅ សូន្យទៅ ចិត្តដែលមានអារម្មណ៍តែមួយខណៈ (ខណិកសមាធិ) រមែងកើតឡើង ព្រោះការចាក់ធ្លុះលក្ខណៈក្នុងខណៈនៃវិបស្សនា ភិក្ខុដែលតម្កល់ចិត្តទុកស្មើ គឺតាំងចិត្តទុកស្មើក្នុងអារម្មណ៍ សូម្បីដោយអំណាចនៃចិត្តមានអារម្មណ៍តែមួយខណៈដែលកើតឡើងហើយយ៉ាងនោះ លោកក៏ហៅថា រមែងកំណត់ថា យើងនឹងតាំងចិត្តទុកមាំ ដកដង្ហើមចេញដកដង្ហើមចូល ។

ពីរបទថា វិមោចយំ ចិត្តំ (នឹងដោះចិត្តឲ្យផុតស្រឡះ) សេចក្តីថា កាលផ្ចាស់ប្តូរ កាលរំដោះចិត្តឲ្យផុតពីនីវរណៈទាំងឡាយ ដោយបឋមជ្ឈាន គឺកាលដោះលែងចិត្តឲ្យផុតចាកវិតក្កវិចារ ដោយទុតិយ-ជ្ឈាន ចាកបីតិដោយតតិយជ្ឈាន ចាកសុខនិងទុក្ខដោយចតុត្ថជ្ឈាន ។ ឬក៏ថា លោកចូលឈានទាំងនោះ ហើយចេញមកពិចារណានូវចិត្តដែលសម្បយុត្តដោយឈាន ដោយអស់ទៅ សូន្យទៅក្នុងខណៈនៃវិបស្សនា លោកនោះដោះ គឺដកចិត្តឲ្យផុតចាកនិច្ចសញ្ញា (សេចក្តី

សម្គាល់ថា ទៀង) ដោយអនិច្ចានុបស្សនា (សេចក្តីពិចារណាឃើញថា មិនទៀង), ដោះ គឺ ដកចិត្តឲ្យផុតពីសុខសញ្ញា (សេចក្តីសម្គាល់ថា ជាសុខ) ដោយទុក្ខានុបស្សនា (សេចក្តីពិចារណាឃើញថា ជាទុក្ខ), ចាកអត្តសញ្ញា (សេចក្តីសម្គាល់ថា ជាខ្លួន) ដោយអនត្តា-នុបស្សនា (សេចក្តីពិចារណាឃើញថា មិនមែនខ្លួន), ចាកនន្ទិ (សេចក្តីត្រេកត្រអាល) ដោយនិព្វិទានុបស្សនា (ការពិចារណាឃើញសេចក្តីនឿយណាយ), ចាករាគៈ (សេចក្តីតម្រេក) ដោយវិរាគានុបស្សនា (សេចក្តីពិចារណាឃើញធម៌គ្រឿងប្រាសចាកតម្រេក), ចាកសមុទ័យ (តណ្ហាដែលនាំទុក្ខឲ្យកើត) ដោយនិរោធានុបស្សនា (សេចក្តីពិចារណាឃើញធម៌ជាគ្រឿងរលត់), ចាកអាទាន (សេចក្តីប្រកាន់) ដោយបដិ-និស្សគ្គានុបស្សនា (ការពិចារណាឃើញធម៌ជាគ្រឿងលះបង់នូវឧបធិ) ដកដង្ហើមចេញ និងដកដង្ហើមចូល ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា “សិក្សាថា អាត្មាអញនឹងដោះចិត្តឲ្យរួច (ចាកនីវរណធម៌ជាដើម)នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងដោះចិត្តឲ្យរួច (ចាកនីវរណធម៌ជាដើម) នឹងដកដង្ហើមចូល”[១] ។ ចតុក្កៈនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃចិត្តានុបស្សនាយ៉ាងនេះ ។

---

១. មជ្ឈិ. មជ្ឈិ. ២៣. ១៤៦/២៤២-២៤៣ ; មជ្ឈិ. ឧប. ២៦. ២៨៨/៣៦១, ២៨៩/៣៦៥; សំយុ. មហា. ៣៩. ៧/៦ ។

ចំណែកក្នុងចតុក្កៈទី ៤ មានវិនិច្ឆ័យដូច្នេះ ៖

ក្នុងបទថា អនិច្ចានុបស្សី **(នឹងពិចារណា ដោយសភាពជារបស់មិនទៀង)** នេះ គប្បីជ្រាបអនិច្ចំ (របស់មិនទៀង) គប្បីជ្រាបអនិច្ចតា (ភាពជារបស់មិនទៀង) គប្បីជ្រាបអនិច្ចានុបស្សនា (ការពិចារណាឃើញរបស់មិនទៀង) គប្បីជ្រាបអនិច្ចានុបស្សី (អ្នកពិចារណាឃើញរបស់មិនទៀង) ជាមុន ។

ក្នុងលក្ខណៈ ៤ យ៉ាង មាន អនិច្ចំ ជាដើមនោះ គឺ

ដែលឈ្មោះថា អនិច្ចំ (របស់មិនទៀង) បានដល់ បញ្ចក្ខន្ធ ព្រោះហេតុអ្វី ? ព្រោះហេតុថា បញ្ចក្ខន្ធមានសេចក្តីកើតឡើង មានសេចក្តីសាបសូន្យទៅ និងមានការប្រព្រឹត្តទៅដោយប្រការដទៃ ។

ដែលឈ្មោះថា អនិច្ចតា (ភាពជារបស់មិនទៀង) បានដល់បញ្ចក្ខន្ធទាំងនោះ មានការកើតឡើង មានការសាបសូន្យទៅ មានការប្រព្រឹត្តទៅដោយប្រការដទៃ ឬមានហើយត្រឡប់ជាមិនមានវិញ; អធិប្បាយថា បញ្ចក្ខន្ធទាំងនោះ កើតឡើងហើយ មិនតាំងនៅដោយអាការនោះៗឯង បែកធ្លាយព្រោះការរលត់គ្រប់ខណៈ ។

ដែលឈ្មោះថា អនិច្ចានុបស្សនា (ពិចារណាឃើញថា មិនទៀង) បានដល់ ការពិចារណាឃើញក្នុងបញ្ចក្ខន្ធទាំងឡាយ មានរូបជាដើមថា មិនទៀងដោយអំណាចនៃភាពជារបស់មិនទៀងនោះ ។

ដែលឈ្មោះថា អនិច្ចានុបស្សី (ជាអ្នកពិចារណាឃើញថា មិនទៀង) បានដល់ បុគ្គលដែលប្រកបដោយអនុបស្សនានោះ ។ ព្រោះហេតុនោះ បុគ្គលមានអនុបស្សនាហើយយ៉ាងនេះ ក៏ដកដង្ហើមចូល និងដកដង្ហើមចេញ បណ្ឌិតគប្បីជ្រាបក្នុងអធិការនេះថា "សិក្សាថា អាត្មាអញ នឹងពិចារណា(នូវបញ្ចក្ខន្ធថា) មិនទៀង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងពិចារណា (នូវបញ្ចក្ខន្ធថា) មិនទៀង ហើយដកដង្ហើមចូល"[១] ។

ចំណែកវិរាគៈ ក្នុងបទថា វិរាគានុបស្សី (នឹងពិចារណាដោយសភាពឥតរាគៈ) នេះ មាន ២ យ៉ាង គឺ ខយវិរាគៈ អស់សេចក្ដីតម្រេក គឺ សេចក្ដីអស់ទៅ ១ អច្ចន្តវិរាគៈ ប្រាសចាកតម្រេកដោយចំណែកមួយ ១ បណ្ដាវិរាគៈ ២ យ៉ាងនោះ ការបែកធ្លាយទៅមួយខណៈៗនៃសង្ខារទាំងឡាយ ឈ្មោះថា ខយវិរាគៈ ។ ព្រះនិព្វាន ឈ្មោះថា អច្ចន្តវិរាគៈ ។ វិបស្សនានិងមគ្គដែលប្រព្រឹត្តទៅដោយអំណាចនៃការឃើញវិរាគៈទាំង ២ យ៉ាងនោះ ឈ្មោះថា វិរាគានុបស្សនា (ការពិចារណាឃើញការប្រាសចាកតម្រេក) ។ ព្រះយោគាវចរជាអ្នកប្រកបដោយអនុបស្សនាសូម្បីទាំង ២ យ៉ាងនោះ ដកដង្ហើមចេញនិងដកដង្ហើមចូល បណ្ឌិតគប្បីជ្រាបថា រមែងកំណត់ថា យើងនឹងពិចារណាឃើញវិរាគៈដកដង្ហើមចេញដកដង្ហើមចូល ។

---

១. មជ្ឈិ. មជ្ឈិ. ២៣. ១៤៦/២៤២-២៤៣ ។

សូម្បីក្នុងបទថា និរោធានុបស្សី ក៏មានន័យដូចគ្នានេះ ។ បដិនិស្សគ្គៈ (រលាស់ចេញនូវឧបធិ) សូម្បីក្នុងបទថា **បដិនិស្សគ្គានុបស្សី** (ទីង ពិចារណាឲ្យរឿយៗ ដោយកិរិយាលះបង់នូវសេចក្តីប្រកាន់) ។ នេះក៏មាន ២ យ៉ាងគឺ **បរិច្ចាគបដិនិស្សគ្គៈ** ការរលាស់ចេញ គឺការលះបង់ ១ **បក្ខន្ទនបដិនិស្សគ្គៈ** ការរលាស់ចេញ គឺការស្ទុះទៅ ១ ។ ការពិចារណាឃើញ គឺសេចក្តីលះបង់ទុំះឯង ឈ្មោះថា បដិនិស្សគ្គានុបស្សនា ។

ពាក្យថា **បដិនិស្សគ្គានុបស្សនា** នោះ ជាឈ្មោះនៃវិបស្សនា និងមគ្គ ។ ពិតមែន វិបស្សនា ព្រះមានព្រះភាគត្រាស់ហៅថា **បរិច្ចាគបដិនិស្សគ្គៈ** ព្រោះរមែងលះកិលេសទាំងឡាយព្រមទាំងខន្ធាភិសង្ខារ ដោយអំណាចតទង្គប្បហាន និងថា **បក្ខន្ទនបដិនិស្សគ្គៈ** ព្រោះរមែងត្រាច់ទៅក្នុងព្រះនិព្វាន ដែលខុសពីសង្ខារនោះ ហេតុដែលបង្អោនទៅក្នុងព្រះនិព្វាននោះ ព្រោះឃើញទោសនៃសង្ខតធម៌ ។ មគ្គព្រះមានព្រះភាគត្រាស់ហៅថា **បរិច្ចាគបដិនិស្សគ្គៈ** ព្រោះរមែងលះកិលេសព្រមទាំងខន្ធាភិសង្ខារ ដោយអំណាចសមុច្ឆេទប្បហាន និងថា **បក្ខន្ទនបដិនិស្សគ្គៈ** ព្រោះរមែងត្រាច់ទៅក្នុងព្រះនិព្វាន ដោយការធ្វើឲ្យជាអារម្មណ៍ ។ ក៏វិបស្សនាញាណនិងមគ្គញ្ញាណសូម្បីទាំង ២ ព្រះមានព្រះភាគត្រាស់ហៅថា អនុបស្សនា ព្រោះសម្លឹងឃើញញាណខាងដើមៗ ក្នុងកាលជាខាងក្រោយ ។ ភិក្ខុជាអ្នកប្រកប ដោយបដិនិស្សគ្គានុបស្សនាទាំង ២ យ៉ាងនោះ ដកដង្ហើមចូល និង

ដកដង្ហើមចេញ បណ្ឌិតគប្បីជ្រាបថា “សិក្សាថា អាត្មាអញនឹងជាអ្នកមានប្រក្រតីសម្លឹងឃើញញាណឈ្មោះបដិនិស្សគ្គៈ ក្នុងកាលជាខាងក្រោយ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងជាអ្នកមានប្រក្រតីសម្លឹងឃើញញាណ ឈ្មោះបដិនិស្សគ្គៈ ក្នុងកាលជាខាងក្រោយ ហើយដកដង្ហើមចូល” ដូច្នេះ ។

ពាក្យថា ឯវំ ភាវិតោ **(ដែលបុគ្គលបានចម្រើនហើយយ៉ាងនេះ)** សេចក្តីថា ចម្រើនហើយដោយអាការយ៉ាងនេះ គឺ ដោយអាការ ១៦ យ៉ាង ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ។

ចប់ អានាបានស្សតិ ។

## ៨.៧ ឧបសមានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវឧបសមានុស្សតិកម្មដ្ឋាន គប្បីចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ ហើយរលឹកដល់គុណរបស់ព្រះនិព្វាន ដែលជាគ្រឿងរម្ងាប់បង់នូវសំសារទុក្ខទាំងពួង តាមលំអានព្រះពុទ្ធដីកាដូច្នេះជាដើមថា **"យាវតា ភិក្ខវេ ធម្មា សង្ខតា វា អសង្ខតា វា វិរាគោ តេសំ ធម្មានំ អគ្គមក្ខាយតិ** ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ទោះជាសង្ខតក្តី ជាអសង្ខតក្តី មានតែវិរាគធម៌ គឺព្រះនិព្វានឯង ប្រាកដជាប្រសើរដោយវិសេសជាងធម៌ទាំងឡាយនោះ **យទិទំ មទនិម្មទនោ**

**បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្តុបច្ឆេទោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ** : *វិរាគធម៌នេះ ជាគ្រឿងញាំញីនូវសេចក្តីស្រវឹង ជាគ្រឿងបណ្តេញបង់នូវសេចក្តីស្រេកឃ្លានក្នុងកាម ជាគ្រឿងដកឡើងនូវសេចក្តីអាល័យក្នុងកាមគុណ ជាគ្រឿងកាត់បង់នូវតេភូមិកវដ្ត ជាគ្រឿងអស់ទៅនៃតណ្ហា ជាគ្រឿងលាចាកតណ្ហា ជាទីរលត់ទៅនៃតណ្ហា ចេញរួចស្រឡះហើយចាកព្រៃស្បាតគឺតណ្ហា ” ។*

*ឧបសមានុស្សតិកម្មដ្ឋាននេះ មានអំណាចឲ្យសម្រេចបានតែត្រឹមឧបចារជ្ឈាន ដូចក្នុងពុទ្ធានុស្សតិជាដើមដែរ ។*

*ចប់ ឧបសមានុស្សតិ*

*ចប់ កម្មដ្ឋានទាំង ៦ ។*

## ៩.សេនាសនៈទោស ១៨ យ៉ាង

*ពាក្យថា វៀរចាកសេនាសនៈទោស ១៨ យ៉ាង បានដល់វៀរចាកទោសរបស់សេនាសនៈ ១៨ យ៉ាងនោះ គឺ ៖*

១-មហាត្តំ *វិហារធំ,*

២-នវត្តំ *វិហារថ្មី,*

៣-ជិណ្ណាត្តំ *វិហារចាស់,*

៤-បន្ថនិស្សិតត្តំ *វិហារជាប់ផ្លូវដើរ*

៥–សោណ្ឌិ *វិហារមានស្រះទឹក,*

៦–បណ្ណំ *វិហារមានស្លឹកឈើ,*

៧–បុប្ផំ *វិហារមានផ្កាឈើ,*

៨–ផលំ *វិហារមានផ្លែឈើ,*

៩–បត្ថនិយតា *វិហារមានអ្នកប្រាថ្នា,*

១០–នគរសន្និស្សិតា *វិហារនៅក្នុងក្រុង,*

១១–ទារុសន្និស្សិតតា *វិហារជាប់ព្រៃ,*

១២–ខេត្តសន្និស្សិតតា *វិហារជាប់ស្រែ,*

១៣–វិសភាគានំ បុគ្គលានំ អត្ថិតា *វិហារមានបុគ្គលជាវិសភាគគ្នានៅ,*

១៤–បត្ថនសន្និស្សិតតា *វិហារជាប់កំពង់ទឹក,*

១៥–បច្ចន្តសន្និស្សិតតា *វិហារជាប់ជាយដែន,*

១៦–រជ្ជសីមន្តរសន្និស្សិតតា *វិហារជាប់ចន្លោះព្រំដែន,*

១៧–អសប្បាយតា *វិហារមិនជាទីសប្បាយដល់ចិត្ត,*

១៨–កល្យាណមិត្តានំ អលាភោ *វិហារមិនមានកល្យាណមិត្ត ។*

*ក៏សេនាសនៈដែលប្រកបដោយទោស ១៨ យ៉ាងនេះ យ៉ាងណាមួយ មិនសមគួរដល់ភាវនា, ព្រោះហេតុអ្វី ? ។ល។*

## ១០.វិហារដែលសមគួរ

ពាក្យថា វិហារដែលប្រកបដោយអង្គសេនាសនៈ ៥ បានដល់ វិហារដែលប្រកបដោយអង្គនៃសេនាសនៈ ៥ យ៉ាង មានភាពជាវិហារដែលមិនឆ្ងាយពីស្រុកពេក មិននៅជិតស្រុកពេក ជាដើម ។ សេចក្ដីនេះ សមដូចព្រះបាលីដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ សេនាសនៈប្រកបដោយអង្គ៥ដូចម្ដេច?

ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងព្រះសាសនានេះ មិនឆ្ងាយពេក មិនជិតពេក ល្មមទៅមកស្រួល មិនអ៊ូរអរក្នុងវេលាថ្ងៃ មិនសូវមានសំឡេងគឹកកងក្នុងវេលាយប់ មិនមានសម្ផស្ស ដោយរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់តូចពស់ធំ ។ វិហារនោះ មានចីវរបិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យ ភេសជ្ជបរិក្ខារតែងកើតមានឡើងដល់ភិក្ខុដែលនៅក្នុងសេនាសនៈនោះ មិនលំបាក ។ មានភិក្ខុជាថេរៈដែលនៅក្នុងសេនាសនៈនោះ ជាពហុស្សូត ឆ្លៀវឈ្លាសក្នុងនិកាយទាំង ៥ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិការមែងនៅក្នុងសេនាសនៈនោះ ។ ភិក្ខុចូលទៅរកភិក្ខុជាថេរៈទាំងនោះម្ដងៗ ហើយសួរ ប្រឹក្សាថា បពិត្រលោកម្ចាស់ដ៏ចម្រើនន័យនេះ តើដូចម្ដេច? សេចក្ដីអធិប្បាយន័យរបស់បទនេះតើដូចម្ដេច? បណ្ដាលោកម្ចាស់ទាំងនោះ រមែងពន្យល់ឲ្យដឹងសេចក្ដីដែលមិន

ទាន់ដឹងច្បាស់ ធ្វើឲ្យងាយនូវសេចក្ដីដែលជ្រាលជ្រៅផង បន្ទោបង់នូវសេចក្ដីសង្ស័យក្នុងធម៌ទាំងឡាយផង ជាទីតាំងនៃការសង្ស័យច្រើនប្រការចេញបាន ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈប្រកបដោយអង្គ ៥ ប្រការយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ក្នុងព្រះបាលីនេះ សេចក្ដីថា មិនឆ្ងាយ-ពេក មិនជិតពេក ទៅមកស្រួលជាអង្គ ១, ពេលថ្ងៃ មិនអ៊ូរអរពេលយប់ មិនមានសំឡេងខ្លាំង ជាអង្គ ១, មិនមានរបោម មូសខ្យល់ កំដៅថ្ងៃ ពស់តូច ពស់ធំ ជាអង្គ ១, មានចីវរ បិណ្ឌបាតសេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ជាអង្គ ១, មួយវិញទៀតក្នុងសេនាសនៈនោះឯង មានពួកភិក្ខុជាថេរៈគង់នៅ ។ល។ លោករមែងបន្ទោបង់នូវសេចក្ដីសង្ស័យបានងាយ ជាអង្គ ១ ។ គប្បីជ្រាប អង្គ (នៃសេនាសនៈ) ៥ យ៉ាងនេះឯង ។

(ចាកគម្ពីរសារត្ថទីបនីដីកា ២ / ៣០៥)

# ១១-សិក្ខាព្រះសូត្រ

## ១-មរណស្សតិសូត្រ ទី១

*សម័យមួយ ព្រះមានព្រះភាគ កាលគង់នៅក្នុងគិញ្ជកាវសថ: (ប្រាសាទឥដ្ឋ) ជិតនាទិកគ្រាម ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ* **មរណស្សតិ** *ដែលភិក្ខុចម្រើនហើយ ធ្វើឲ្យច្រើនហើយ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានចម្រើនមរណស្សតិឬទេ ។*

*កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិ ។*

*ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។*

*បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎* **អាត្មាអញគប្បីរស់នៅអស់យប់និងថ្ងៃ** *អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន*

(ក្នុងសាសនារបស់ព្រះអង្គ) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។

ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ **អាត្មាអញគប្បីរស់នៅអស់ ១ ថ្ងៃ** អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។

ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិដូចម្តេច ។

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ **អាត្មាអញគប្បីរស់នៅអស់កន្លះថ្ងៃ** អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។

ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា **ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតម្តង** អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ច-ការឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។

ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា **ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅបានត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតពាក់កណ្តាល** អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។

ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា **ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅបានត្រឹមខណៈដែលទំពាពំនូតបាយ ៤ ឬ ៥ ពំនូតលេបចូលទៅ** អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។

ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា **ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅត្រឹមខណៈទំពាលេប(បាយ) អស់ ១ ពំនូត** អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។

ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ **អាត្មាអញគប្បីរស់នៅត្រឹម**

ខណៈដែលដកដង្ហើមចូលហើយចេញ ឬដកដង្ហើមចេញហើយ- ចូល អាត្មាអញគប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

កាលបើពួកភិក្ខុនោះ ក្រាបទូលយ៉ាងនេះហើយ ព្រះមាន- ព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុទាំងនោះ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញគប្បីរស់នៅអស់យប់ និងថ្ងៃ អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញគប្បីរស់នៅអស់ ១ ថ្ងៃ អាត្មាអញគប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅអស់កន្លះថ្ងៃ អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញគប្បីរស់នៅត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតម្តង អាត្មា

អញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញគប្បីរស់នៅត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតពាក់កណ្តាល អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅត្រឹមខណៈទំពាពំនូតបាយ ៤ ឬ ៥ ពំនូត លេបចូលទៅ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអម្បាលនេះ ហៅថា មានសេចក្តីប្រមាទនៅឡើយ ចម្រើនមរណស្សតិ ដើម្បីធ្វើឲ្យអស់អាសវៈទាំងឡាយយឺតយូរទេ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅត្រឹមខណៈទំពាលេបបាយ ១ ពំនូត អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅត្រឹមខណៈដែលដកដង្ហើមចូលហើយចេញ ឬដក

ដង្ហើមចេញហើយចូល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអម្បាលនេះ ហៅថា មិនមានសេចក្តីប្រមាទ ចម្រើនមរណស្សតិ ដើម្បីឲ្យអស់អាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ត្រូវសិក្សាយ៉ាងនេះថា ពួកយើងនឹងមិនមានសេចក្តីប្រមាទ នឹងចម្រើនមរណស្សតិ ដើម្បីធ្វើឲ្យអស់អាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះណា៎ ។

## ២‿ការចម្រើនមរណស្សតិសូត្រ ទី២

សម័យមួយ ព្រះមានព្រះភាគ កាលគង់នៅក្នុងគិញ្ជកាវសថៈ ជិតនាទិកគ្រាម ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ។បេ។ ម្នាលភិក្ខុទាំងឡាយ មរណស្សតិដែលភិក្ខុចម្រើនហើយ សន្សំរឿយៗហើយ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ចុះមរណស្សតិដែលភិក្ខុចម្រើនហើយតើដូចម្តេច សន្សំរឿយៗ ហើយ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត តើដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើថ្ងៃកន្លងទៅហើយ យប់មកដល់វិញ តែងពិចារណាដូច្នេះថា ហេតុនៃសេចក្ដីស្លាប់របស់អាត្មាអញមានច្រើនណាស់តើ (ដូចជា) ពស់ចឹកអាត្មាអញក្ដី ខ្ទួយទិចអាត្មាអញក្ដី ក្អែបខាំអាត្មាអញក្ដី អាត្មាអញនឹងស្លាប់ អន្តរាយនោះនឹងមានដល់អាត្មាអញ ព្រោះហេតុតែពស់ចឹកជាដើមនោះ អាត្មាអញភ្លាត់ជួលក្ដី កត្តដែលអាត្មាអញបរិភោគហើយហល់ក្ដី ប្រមាត់របស់អាត្មាអញកម្រើកក្ដី ស្លេស្មរបស់អាត្មាអញកម្រើកក្ដី កងខ្យល់ដូចសស្ត្រាវុធរបស់អាត្មាអញកម្រើកក្ដី ពួកមនុស្សព្យាយាមសម្លាប់អាត្មាអញក្ដី ពួកអមនុស្សព្យាយាមសម្លាប់អាត្មាអញក្ដី អាត្មាអញនឹងស្លាប់ អន្តរាយនោះ នឹងមានដល់អាត្មាអញ ព្រោះហេតុតែភ្លាត់ជួលជាដើមនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវពិចារណាថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាល**ក្នុងរាត្រី** អកុសលធម៌ដ៏លាមកនោះ អាត្មាអញមិនទាន់បានលះបង់នៅឡើយ មានដែរឬទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុពិចារណាដឹងយ៉ាងនេះថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាល **ក្នុងរាត្រី** អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះបង់ហើយ នៅមានមែន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវធ្វើឆន្ទៈផង សេចក្ដីព្យាយាមផង ឧស្សាហៈផង សេចក្ដីខ្នះខ្នែងផង សេចក្ដីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បី

*លះបង់នូវអកុសលធម៌ដ៏លាមកនោះចេញឲ្យដាច់ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលមានសំពត់ឆេះក្តី មានក្បាលឆេះក្តី ត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួយរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំងដើម្បីនឹងលត់សំពត់នោះផង លត់ក្បាលនោះផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួយរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីនឹងលះអកុសលធម៌ដ៏លាមកទាំងនោះចេញឲ្យដាច់ យ៉ាងនោះដែរ, ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុពិចារណាដឹងយ៉ាងនេះថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាលក្នុងរាត្រី អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះហើយ មិនមានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីជាអ្នកសិក្សារៀយៗ ទាំងថ្ងៃទាំងយប់ ក្នុងកុសលធម៌ទាំងឡាយដោយបីតិនិងបាមោជ្ជៈនោះចុះ ។*

**មួយទៀត** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើយប់កន្លងទៅហើយ ថ្ងៃមកដល់វិញ តែងពិចារណាដូច្នេះថា ហេតុនៃសេចក្តីស្លាប់របស់អាត្មាអញមានច្រើនណាស់តើ (ដូនជា) ពស់ចឹកអាត្មាអញក្តី ខ្ទួយទិចអាត្មាអញក្តី ក្អែបខាំអាត្មាអញក្តី អាត្មាអញនឹងស្លាប់ អន្តរាយនោះ នឹងមានដល់អាត្មាអញ ព្រោះហេតុតែពស់ចឹកជាដើមនោះ (ឬមួយ) អាត្មាអញភ្ញាត់ជួលក្តី កត្តដែលអាត្មាអញ*

បរិភោគហើយហល់ក្តី ប្រមាត់របស់អាត្មាអញកម្រើកក្តី ស្លេស្ម របស់អាត្មាអញកម្រើកក្តី កងខ្យល់ដូចសស្ត្រាវុធ របស់អាត្មាអញកម្រើកក្តី ពួកមនុស្សព្យាយាមសម្លាប់អាត្មាអញក្តី ពួកអមនុស្សព្យាយាមសម្លាប់អាត្មាអញក្តី អាត្មាអញនឹងស្លាប់ អន្តរាយនោះនឹងមានដល់អាត្មាអញ ព្រោះហេតុតែភ្ជាត់ជួលជាដើមនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវពិចារណាថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាលក្នុងវេលាថ្ងៃ អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះបង់ហើយ មានដែរឬទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុពិចារណាដឹងយ៉ាងនេះថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាល ក្នុងវេលាថ្ងៃ អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះបង់នៅឡើយ នៅមានមែន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីនឹងលះអកុសលធម៌ដ៏លាមកទាំងនោះចេញឲ្យដាច់ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលមានសំពត់ឆេះក្តី មានក្បាលឆេះក្តី ត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីនឹងលត់សំពត់ ឬក្បាលនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង

ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំងដើម្បីនឹងលះអកុសលធម៌ ដ៏លាមកទាំងនោះ ចេញឲ្យបាត់យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុ ពិចារណាដឹងយ៉ាងនេះថា កុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញដែលធ្វើមរណកាលក្នុងវេលាថ្ងៃ អកុសល-ធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះហើយ មិនមានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីជាអ្នកសិក្សារឿយៗ ទាំងថ្ងៃទាំងយប់ ក្នុងកុសលធម៌ទាំងឡាយ ដោយបីតិនិងបាមោជ្ជៈនោះចុះ ។

ម្នាលភិក្ខុទាំងឡាយ មរណស្សតិ ដែលភិក្ខុចម្រើនហើយយ៉ាងនេះ សន្សំរឿយៗហើយយ៉ាងនេះ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត ។

(សុត្តន្ត. ភាគ៤៨ ទំព័រ៣០៩-៣២១)

# ៣~ករណីយមេត្តសូត្រ

## ប្រយោជន៍របស់ការតាំងសូត្រ

ឥឡូវនេះ ដល់លំដាប់ការពណ៌នាសេចក្ដីរបស់មេត្តសូត្រ ដែលលើកតាំងទុកក្នុងលំដាប់តអំពីនិធិកណ្ឌសូត្រ ។ ក្នុងទីនេះ ខ្ញុំនឹងពោលប្រយោជន៍របស់ការតាំងមេត្តសូត្រនោះហើយ តពីនោះ គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនេះថា មេត្តសូត្រនោះ អ្នកណាពោល ពោលកាលណា ពោលទីណា និងពោលព្រោះហេតុអ្វី ? ជម្រះនិទានហើយ ទើបធ្វើការពណ៌នាសេចក្ដីរបស់មេត្តសូត្រនោះ ។

ក្នុងមេត្តសូត្រនោះ ព្រោះហេតុដែលត្រាស់បុញ្ញសម្បទាមានទាន សីលជាដើម ដោយនិធិកណ្ឌសូត្រ ។ កាលបុគ្គលធ្វើមេត្តាក្នុងសត្វទាំងឡាយ បុញ្ញសម្បទានោះ រមែងមានផលច្រើនដរាបដល់អាចឲ្យសម្រេចពុទ្ធភូមិបាន ដូច្នោះ ខ្ញុំទើបលើកមេត្ត-សូត្រឡើងតាំងក្នុងទីនេះ ដើម្បីសម្ដែងថាមេត្តាជាឧបការៈដល់បុញ្ញសម្បទានោះ ឬព្រោះហេតុដែលខ្ញុំម្ចាស់ គ្រាសម្ដែងកម្មដ្ឋានដែលអាចលះទោសៈ ដោយទុក្ខីឯព្យាការ សម្រាប់ជនទាំងឡាយអ្នករាប់អានព្រះសាសនា ដោយសរណៈហើយ តាំងនៅក្នុងសីលដោយសិក្ខាបទទាំងឡាយ និងអាចលះមោហៈ ដោយកុមារបញ្ហា ទើបសម្ដែងថាការប្រព្រឹត្តិសរណៈជាដើមនោះ ជាមង្គល និងរក្សា

ខ្ទង់ឯងដោយមង្គលសូត្រ សម្តែងការរក្សាអ្នកដទៃដែលសមគួរដល់មង្គលនោះ ដោយរតនសូត្រ សម្តែងការឃើញភូតពួកខ្លះក្នុងបណ្តាភូតទាំងឡាយដែលពោលទុកក្នុងរតនសូត្រ និងសេចក្តីវិបត្តិរបស់ពួកជនដែលប្រមាទក្នុងបុញ្ញសម្បត្តិ ដូចដែលពោលហើយ ដោយតិរោកុឌ្ឌសូត្រ និងសម្តែងសម្បត្តិដែលជាបដិបក្ខចំពោះវិបត្តិ ដែលពោលទុកក្នុងតិរោកុឌ្ឌសូត្រ ដោយនិធិកណ្ឌសូត្រ តែមិនទាន់បានសម្តែងកម្មដ្ឋានដែលអាចលះទោសៈ ដូច្នោះដើម្បីសម្តែងកម្មដ្ឋានដែលអាចលះទោសៈនោះ ខ្ញុំម្ចាស់ទើបលើកមេត្តសូត្រនេះឡើង តាំងទុកក្នុងទីនេះ ។ កាលជាដូច្នោះ ខុទ្ទកបាឋៈទើបរមែងបរិបូរណ៍ដោយល្អ ពាក្យដែលពោលមកដូច្នេះ ជាប្រយោជន៍នៃការតាំងមេត្តសូត្រនោះទុកក្នុងទីនេះ ។

## ការជម្រះនិទាន

ឥឡូវនេះ ខ្ញុំលើកមាតិកាជាប្រធាននេះទុកថា គប្បីជ្រាបការចន្លុលបង្ហាញបទទាំងនេះថា មេត្តសូត្រនេះ អ្នកណាពោល ពោលកាលណា ពោលទីណា និងពោលព្រោះហេតុអ្វី ខ្ញុំជម្រះនិទានហើយ ទើបធ្វើការពណ៌នាសេចក្តីរបស់មេត្តសូត្រនោះដូច្នេះ ។

ក្នុងមាតិកាប្រធាននោះ គប្បីជ្រាបការចន្លុលបង្ហាញបទទាំងនេះ និងការជម្រះនិទានដោយសង្ខេបយ៉ាងនេះមុនថា មេត្តសូត្រនេះ ព្រះមានព្រះភាគ តែមួយព្រះអង្គត្រាស់ ព្រះសាវកជាដើម

មិនបានពោល ។ ក៏ប៉ុន្តែថា កាលណាភិក្ខុទាំងឡាយ ត្រូវទេវតាទាំងឡាយរុករួនខាងក្នុងហិមវន្ត ទើបនាំគ្នាមកគាល់ព្រះមានព្រះ-ភាគ កាលនោះ ព្រះមានព្រះភាគ ទើបត្រាស់មេត្តសូត្រនោះដើម្បីការពារ និងដើម្បីជាកម្មដ្ឋានសម្រាប់ភិក្ខុទាំងនោះ ។

ចំណែកសេចក្តីពិស្តារ គប្បីជ្រាបយ៉ាងនេះ ។ សម័យមួយតិថីជិតចូលចាំវស្សា ព្រះមានព្រះភាគ ទ្រង់គង់នៅក្រុងសាវត្ថី ។ សម័យនោះ ភិក្ខុទាំងឡាយចេញចាកក្រុងផ្សេងៗ ជាច្រើន ទទួលកម្មដ្ឋាន ក្នុងសំណាក់ព្រះមានព្រះភាគហើយ ប្រាថ្នានឹងចូលវស្សាក្នុងទីនោះៗ ទើបចូលគាល់ព្រះមានព្រះភាគ ។ បានឮថា សម័យនោះ ព្រះមានព្រះភាគ ត្រាស់កម្មដ្ឋានទាំងឡាយ ដែលអនុកូលដល់ចរិតចំនួន ៨៤,០០០ ប្រភេទ ដោយន័យនេះគឺ អសុភកម្ម-ដ្ឋាន ១១ យ៉ាង គឺអសុភដែលមានវិញ្ញាណ និងមិនមានវិញ្ញាណសម្រាប់អ្នករាគចរិត, កម្មដ្ឋានមានមេត្តាកម្មដ្ឋានជាដើម ៤ យ៉ាងសម្រាប់អ្នកទោសចរិត, កម្មដ្ឋានមានមរណស្សតិកម្មដ្ឋានជាដើមសម្រាប់អ្នកមោហចរិត, កម្មដ្ឋានមានពុទ្ធានុស្សតិកម្មដ្ឋានជាដើមសម្រាប់សទ្ធាចរិត ។ កម្មដ្ឋានមានចតុធាតុវវត្ថានកម្មដ្ឋានជាដើមសម្រាប់អ្នកពុទ្ធិចរិត[១] ។

---

១- ក្នុងគម្ពីរវិសុទ្ធិមគ្គ និង គម្ពីរសារត្ថទីបនីដីកាថា មរណស្សតិ ១ ឧបសមា-នុស្សតិ ១ ចតុធាតុវវត្ថាន ១ អាហារេ បដិកូលសញ្ញា ១ កម្មដ្ឋាននេះ សម្រាប់

*លំដាប់នោះ ភិក្ខុប្រមាណ ៥០០ រូប រៀនកម្មដ្ឋានក្នុងសំណាក់ព្រះមានព្រះភាគ កំពុងស្វែងរកសេនាសនៈដែលជាទីសប្បាយ និងគោចរគ្រាម ដើរទៅតាមលំដាប់ បានជួបភ្នំថ្មស្រដៀងកែវមណី ពណ៌ផ្ទៃមេឃក្រម៉ៅ ប្រដាប់ដោយព្រៃពណ៌ខៀវ មានម្លប់ត្រជាក់ មានភូមិភាគឃ្លាតដោយដីខ្សាច់ដូចផ្ទៃប្រាក់សំណាញ់មុក្តា ឡោមព័ទ្ធដោយជលាល័យ (ស្រះទឹក) ដ៏ស្អាតត្រជាក់ល្អ ជាប់ជាមួយនឹងព្រៃហិមវន្ត ក្នុងបច្ចន្តប្រទេស ។ ភិក្ខុទាំងនោះសម្រាកមួយយប់ក្នុងទីនោះ កាលរាត្រីព្រឹកព្រហាមភ្លឺស្វាង ធ្វើសរីរកិច្ចហើយ ក៏នាំគ្នាចូលទៅកាន់ស្រុកមួយកន្លែងជិតៗនុ៎ះឯង ដើម្បីបិណ្ឌបាត ។ ពួកអ្នកស្រុកប្រកបដោយត្រកូល ១,០០០ ត្រកូលដែលអាស្រ័យនៅកុះករ សូម្បីក្នុងពួកអ្នកស្រុកនោះ មនុស្សទាំងឡាយមានបសាទសទ្ធា ពួកគេឃើញភិក្ខុទាំងឡាយប៉ុណ្ណោះ ក៏កើតបីតិសោមនស្ស ព្រោះការឃើញបព្វជិតក្នុងបច្ចន្តប្រទេសរកបានលំបាក និមន្តភិក្ខុទាំងនោះឲ្យឆាន់ហើយ ក៏សូមអង្វរថា លោកម្ចាស់ សូមលោកនៅក្នុងទីនេះរហូតអស់ត្រៃមាសចុះ ហើយជួយគ្នាសាងកុដិសម្រាប់ធ្វើសេចក្តីព្យាយាម ៥០០*

---

បុគ្គលជាពុទ្ធិចរិត ។ អនាបានស្សតិ ១ ប៉ុណ្ណោះ សម្រាប់បុគ្គលជាមោហចរិត និងវិតក្កចរិត ។ បណ្តាកសិណ ១០ វៀរកសិណ ៤ គឺ នីលកសិណ ១ បីតកសិណ ១ លោហិតកសិណ ១ ឱទាតកសិណ ១ កសិណដ៏សេសមានបឋវីកសិណជាដើម និងអរុប្ប ៤ សមគួរដល់បុគ្គលគ្រប់ចរិត ។

ខ្ទង់ ចាត់ចែងគ្រឿងឧបករណ៍គ្រប់យ៉ាង មានគ្រែ តាំង ក្អមទឹក-ឆាន់ ទឹកប្រើប្រាស់ជាដើម ក្នុងទីនោះ ។

ព្រឹកឡើង ភិក្ខុទាំងឡាយចូលទៅកាន់ស្រុកដទៃដើម្បីបិណ្ឌ-បាត ។ មនុស្សទាំងឡាយ ក្នុងពួកអ្នកស្រុកសូម្បីនោះ ក៏ទំនុកបម្រុងយ៉ាងនោះដូចគ្នា អង្វរឲ្យនៅចាំវស្សា ។ ភិក្ខុទាំងឡាយទទួលនិមន្តដោយមានកតិកាថា កាលមិនមានអន្តរាយ ទើបនាំគ្នាចូលទៅកាន់ដងព្រៃនោះ ជាអ្នកប្រារព្ធសេចក្តីព្យាយាម រហូតដល់អស់ទាំងពេលយប់ពេលថ្ងៃ វាយរគាំងប្រាប់យាមជាអ្នកច្រើនដោយយោនិសោមនសិការ ទើបចូលទៅអង្គុយទៀបគល់ឈើ ។ រុក្ខទេវតាទាំងឡាយ ត្រូវតេជរបស់ពួកភិក្ខុដែលមានសីលកម្ចាត់តេជចេញហើយ ក៏ចុះពីវិមានរបស់ខ្លួនៗ នាំពួកក្មេងៗ ត្រាច់ទៅខាងណេះផង ខាងណោះផង ប្រៀបដូចកាលព្រះរាជា ឬរាជ-មហាមាត្យទៅកាន់ទីនៅរបស់អ្នកស្រុក គោងឱកាសដែលដាក់ក្នុងផ្ទះទាំងឡាយរបស់ពួកអ្នកស្រុក ពួកអ្នកស្រុក ក៏ត្រូវចេញចាកស្រុកទៅនៅទីដទៃ ក៏បានតែសម្លឹងមើលនៅឆ្ងាយៗ ដោយប្រាថ្នាថា កាលណាហ្ន៎លោកនឹងទៅ ទេវតាទាំងឡាយ ត្រូវលះបោលវិមានរបស់ខ្លួនៗ បែកខ្ញែកគ្នាទៅ បានតែសម្លឹងមើលនៅឆ្ងាយៗដោយប្រាថ្នាថា កាលណាហ្ន៎លោកទើបនឹងទៅ ក៏ដូច្នោះដែរ ។ អំពីនោះ ទេវតាទាំងឡាយក៏រួមគិតគ្នាយ៉ាងនេះថា ភិក្ខុទាំងឡាយចូលវស្សាដំបូងហើយ នឹងនៅជាមួយគ្នារហូតដល់អស់ត្រៃមាស

ពិត តែពួកយើងមិនអាចនឹងនាំពួកក្មេងនៅផ្សងព្រេង ដោយលំបាកបានយូរទេ ពួកយើងនឹងសម្តែងអារម្មណ៍ដែលគួរខ្លាចដល់ភិក្ខុទាំងឡាយ ។ ទេវតាទាំងនោះ ទើបនិម្មិតរូបយក្ខ ដែលគួរខ្លាចឈរខាងមុខៗ វេលាភិក្ខុទាំងឡាយធ្វើសមណធម៌ ពេលកណ្តាលយប់ និងធ្វើសំឡេងដែលគួរភ័យខ្លាច ព្រោះឃើញរូបទាំងនោះ និងបានឮសំឡេងនោះ បេះដូងរបស់ភិក្ខុទាំងឡាយ ក៏គ្រវីគ្រវាត់ ភិក្ខុទាំងនោះមានសម្បុរស្លេកស្លាំង និងកើតជារោគស្គមលឿង ។ ដោយហេតុនោះ ភិក្ខុទាំងនោះទើប មិនអាចធ្វើចិត្តឲ្យមានអារម្មណ៍តែមួយបាន កាលចិត្តមិនមានអារម្មណ៍តែមួយ តក់ស្លុតរឿយៗ ព្រោះសេចក្តីខ្លាច សតិរបស់ភិក្ខុទាំងនោះ ក៏វង្វេងទៅ អំពីនោះមកអារម្មណ៍ដែលស្អុយៗ ក៏ជួបប្រសព្វដល់ភិក្ខុទាំងនោះ ដែលមានសតិវង្វេងភ្លេចហើយ, ខួរក្បាលរបស់ភិក្ខុទាំងនោះ ក៏ដូចត្រូវក្លិនស្អុយនោះបៀតបៀន រោគឈឺចុកចាប់សីសៈ ក៏កើតយ៉ាងធ្ងន់ ។ ភិក្ខុទាំងនោះ ក៏មិនព្រមប្រាប់រឿងនោះដល់គ្នានឹងគ្នា ។

តមកថ្ងៃមួយ កាលភិក្ខុគ្រប់រូបប្រជុំគ្នាក្នុងវេលាទំនុកបម្រុងព្រះសង្ឃត្ថេរៈ ។ ព្រះសង្ឃត្ថេរៈក៏សួរថា អ្នកមានអាយុ កាលពួកលោកចូលទៅក្នុងដងព្រៃនេះ សម្បុរឃើញបរិសុទ្ធិផូរផង់ក្រៃលែង ២-៣ ថ្ងៃ ទាំងឥន្ទ្រិយក៏ថ្លាផូរផង់ តែឥឡូវនេះ ក្នុងទីនេះ ពួកលោកស្គមស្គាំង សម្បុរស្លេកស្លាំងមានរោគស្គមលឿង ក្នុងទីនេះពួកលោកមិនមានសេចក្តីសប្បាយឬ ។ លំដាប់នោះ ភិក្ខុ

មួយរូបពោលថា លោកម្ចាស់ ពេលយប់ ខ្ញុំឃើញ និងបានឮអារម្មណ៍គួរខ្លាចយ៉ាងនេះៗ ស្រូបយកតែក្លិនដូច្នេះ ដោយហេតុនោះ ចិត្តរបស់ខ្ញុំទើបមិនតាំងមាំជាសមាធិ ។ ភិក្ខុទាំងនោះ គ្រប់រូបទើបនាំគ្នាប្រាប់រឿងនោះដោយឧបាយនេះដូចគ្នា ។ ព្រះសង្ឃ-ត្ថេរៈ ពោលថា អ្នកមានអាយុ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តការចូលចាំវស្សាទុក ២ យ៉ាង ក៏សេនាសនៈនេះមិនជាទីសប្បាយដល់ពួកយើង មកចុះអ្នកមានអាយុ ពួកយើងនឹងនាំគ្នាទៅគាល់ព្រះមានព្រះភាគ ទូលសួរដល់សេនាសនៈដែលជាទីសប្បាយដទៃៗ ភិក្ខុទាំងនោះ ទទួលពាក្យព្រះថេរៈថា ល្អណាស់ករុណា គ្រប់រូបក៏រក្សាសេនាសនៈ កាន់បាត្រចីវរមិនប្រាប់លាអ្នកណាមួយក្នុងត្រកូលទាំងឡាយ នាំគ្នាចារិកទៅកាន់ក្រុងសាវត្ថី ក៏ដល់ក្រុងសាវត្ថីដោយលំដាប់ ហើយក៏នាំគ្នាចូលគាល់ព្រះមានព្រះភាគ ។

ព្រះមានព្រះភាគ ទ្រង់ឃើញភិក្ខុទាំងនោះទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបញ្ញត្តសិក្ខាបទទុកថា ភិក្ខុមិនគប្បីត្រាច់ចារិកទៅខាងក្នុងវស្សា ហេតុអ្វីពួកលោកទើបនាំគ្នាចារិក ។ ភិក្ខុទាំងនោះ ទើបក្រាបទូលរឿងទាំងអស់ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ កាលទ្រង់នឹករំពឹងក៏ទ្រង់មិនឃើញសេនាសនៈដែលជាទីសប្បាយដទៃសម្រាប់ភិក្ខុទាំងនោះ ទូទាំងជម្ពូទ្វីប ដោយហោចទៅសូម្បីត្រឹមតែតាំងមានជើង ៤ ដូច្នេះ ទើបត្រាស់ប្រាប់ភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ សេនាសនៈជាទីសប្បាយដទៃ

សម្រាប់ពួកលោកមិនមានទេ ម្នាលភិក្ខុទាំងឡាយ ពួកលោកចូរទៅ នៅក្នុងទីនោះឯងចុះ នឹងសម្រេចធម៌ជាទីអស់អាសវៈ ពួកលោក ចូរទៅអាស្រ័យសេនាសនៈនោះទុំៈឯង នៅជាមួយគ្នាចុះ តែបើថា ពួកលោកប្រាថ្នាសេចក្ដីមិនមានភ័យអំពីទេវតាទាំងឡាយ ក៏ចូរ នាំគ្នារៀនព្រះបរិត្តនេះ ។ ព្រោះថា ព្រះបរិត្តនេះនឹងជាគ្រឿង ការពារផង ជាកម្មដ្ឋានផង សម្រាប់អ្នកទាំងឡាយ ដូច្នេះហើយទើប ត្រាស់ព្រះសូត្រនេះ ។

តែអាចារ្យពួកដទៃទៀត ពោលថា ព្រះមានព្រះភាគ ត្រាស់ ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ទៅចុះ ពួកលោកចូរចូល ទៅអាស្រ័យសេនាសនៈនោះឯង នៅជាមួយគ្នាចុះ ហើយទើប ត្រាស់ថា ភិក្ខុដែលនៅព្រៃគួរស្គាល់បរិហារ ។ បរិហារយ៉ាងណា ។ បរិហារយ៉ាងនេះ គឺផ្សាយមេត្តា ២ វេលា គឺធ្វើវេលាល្ងាច និង ព្រឹក ធ្វើព្រះបរិត្ត ២ វេលា ចម្រើនអសុភ ២ វេលា ចម្រើន មរណស្សតិ ២ វេលា និងនឹកដល់មហាសំវេគវត្ថុទាំង ៨ ពីរវេលា ជាតិ ជរា ព្យាធិ មរណៈ អបាយទុក្ខ ៤ ឈ្មោះមហាសំវេគវត្ថុ ៨ ។

មួយទៀត ជាតិជរាព្យាធិមរណៈ ៤ អបាយទុក្ខជាគម្រប់ ៥ ទុក្ខមានវដ្ដៈជាមូលក្នុងអតីត ១ ទុក្ខមានវដ្ដៈជាមូលក្នុងអនាគត ១ ទុក្ខមានការស្វែងរកអាហារជាមូលក្នុងបច្ចុប្បន្ន ១ ។ ព្រះមានព្រះ ភាគ គ្រាទ្រង់ប្រាប់ការបរិហារយ៉ាងនេះហើយ ទើបបានត្រាស់ ព្រះសូត្រនេះ ដើម្បីជាមេត្តា ដើម្បីជាព្រះបរិត្ត និងដើម្បីឈាន

ដែលជាបាទនៃវិបស្សនាដល់ភិក្ខុទាំងនោះ ។ គប្បីជ្រាបការបន្ថុល បន្ទាញបទទាំងនេះថា **យេន វុត្តំ យទា យត្ថ យស្មា ចេ** និង ការជម្រះនិទាន ដោយប្រការដូច្នេះ ។

មាតិកាដំបូងនោះណា ខ្ញុំតាំងទុកថា **យេន វុត្តំ យទា យត្ថ យស្មា ចេតេស ទីបនា និទានំ សោធយិត្វា** ។ មាតិកាដំបូងនោះ ជាការដែលខ្ញុំពោលពិស្ដារហើយ ដោយអាការទាំងពួង ដោយ កថាមានប្រមាណប៉ុណ្ណោះ ។

## ពណ៌នាគាថាទី ១

ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច
សក្កោ ឧជូ ច សុហុជូ ច សុវចោ ចស្ស មុទុ
អនតិមានី,

កិច្ចណា (ដែលព្រះអរិយៈ) បានត្រាស់ដឹងនូវបទដ៏ស្ងប់ រម្ងាប់ គឺព្រះនិព្វាន(បានធ្វើហើយ) កិច្ចនោះ កុលបុត្រអ្នកឈ្លាស ក្នុង ប្រយោជន៍គួរធ្វើ (កុលបុត្រនោះ) ជាអ្នកអាចហ៊ានផង ត្រង់ ដោយកាយនិងវាចាផង ត្រង់ល្អដោយចិត្តផង គេប្រដៅងាយផង មានសុភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង,

ឥឡូវនេះ នឹងផ្ដើមពណ៌នាសេចក្ដីនៃព្រះសូត្រនោះ ដែល ធ្វើការជម្រះនិទានហើយយ៉ាងនេះ ព្រោះខ្ញុំពោលទុកថា ទើបនឹង ធ្វើការពណ៌នាសេចក្ដីនៃព្រះសូត្រនោះដូច្នេះ ។ ក្នុងគាថានោះ នឹង

ផ្ដើមពណ៌នាបទនៃគាថានេះថា ករណីយមត្ថកុសលេន ជាមុន ដូច្នេះ ។ បទថា ករណីយំ ប្រែថា គប្បីធ្វើអធិប្បាយថា គួរដល់ការធ្វើ ។ បដិបទា ឈ្មោះថា **អត្ថ** ឬប្រយោជន៍ដល់ខ្លួនយ៉ាងណាមួយ ប្រយោជន៍នោះទាំងអស់ លោកហៅថា អត្ថៈ ព្រោះមិនមានកិលេសដូចសត្រូវ ឈ្មោះថា **ករណីយៈ** ព្រោះបុគ្គលគប្បីចូលដល់ ។ ដែលអ្នកឆ្លាតក្នុងប្រយោជន៍ ឈ្មោះថា **អត្ថកុសលៈ** លោកអធិប្បាយថា ដែលអ្នកឈ្លាសក្នុងប្រយោជន៍ ។ បទថា យំ ជាបឋមាវិភត្តិសម្ដែងសេចក្ដីមិនពិតប្រាកដ ។ បទ តំ ជាទុតិយាវិភត្តិ សម្ដែងសេចក្ដីពិតប្រាកដ ។ ឬថាពាក្យថា យំ តំ សូម្បីទាំងពីរជាបឋមាវិភត្តិ ។ ពាក្យថា សន្តំ បទំ ជាទុតិយាវិភត្តិ ។

បណ្ដាពាក្យទាំងពីរនោះ ដែលឈ្មោះថា **សន្តៈ** ព្រោះជាលក្ខណៈដែលមានឈ្មោះថា **បទៈ** ព្រោះបុគ្គលគប្បីដល់ ពាក្យនេះជាឈ្មោះរបស់ព្រះនិព្វាន ។ បទថា អភិសមេច្ច ប្រែថា សម្រេចហើយ ។ អ្នកណារមែងអាច ហេតុនោះ អ្នកនោះឈ្មោះថា **សក្កៈ** អ្នកអាច លោកអធិប្បាយថា អ្នកអាច អ្នកអាចហ៊ាន ។ បទថា ឧជុ បានដល់ អ្នកប្រកបដោយភាពត្រង់ ។ អ្នកណាត្រង់ដោយល្អ ហេតុនោះ អ្នកនោះឈ្មោះថា **សុហុជូ** អ្នកត្រង់ដោយល្អ ។ សេចក្ដីប្រដៅងាយមានក្នុងអ្នកនោះ ហេតុនោះ អ្នកនោះឈ្មោះថា **សុវចោ** អ្នកប្រដៅងាយ ។ បទថា អស្ស ប្រែថា គប្បីមាន

គប្បីជា ។ បទថា មុទុ បានដល់ អ្នកប្រកបដោយភាពទន់ភ្លន់ ។ អ្នកណាមិនមានអតិមានះ ហេតុនោះ អ្នកនោះឈ្មោះថា អនតិមានី មិនមានអតិមានះ ។

ចំណែកការពណ៌នាសេចក្តីក្នុងគាថាទី ១ មានដូច្នេះ ។

នឹងវិនិច្ឆ័យក្នុងពាក្យថា ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច នេះមុន ។ ករណីយៈ ក៏មាន អករណីយៈ ក៏មាន ។ ក្នុងពីរយ៉ាងនោះដោយសង្ខេប សិក្ខា ៣ ឈ្មោះថា **ករណីយៈ** ។ សីលវិបត្តិ ទិដ្ឋិវិបត្តិ អាចារវិបត្តិ អាជីវវិបត្តិ ដូចពោលមកយ៉ាងនេះជាដើម ឈ្មោះថា **អករណីយៈ** ។ មួយទៀត អត្ថកោសលក៏មាន អនត្ថកោសលក៏មាន ។ ក្នុង ២ យ៉ាងនោះ អ្នកណាបួសក្នុងព្រះសាសនានេះ មិនប្រកបខ្លួនទុកដោយប្រពៃ ជាអ្នកមានសីលដាច់ អាស្រ័យអនេសនៈ គឺការស្វែងរកចិញ្ចឹមជីវិតដែលមិនសមគួរ ២១ យ៉ាងគឺ ឲ្យឫស្សី ១ ឲ្យស្លឹកឈើ ១ ឲ្យផ្កាឈើ ១ ឲ្យផ្លែឈើ ១ ឲ្យឈើស្ទន់ ១ ឲ្យទឹកលុបមុខ ១ ឲ្យវត្ថុសម្រាប់ងូត ១ ឲ្យគ្រឿងលំអិតសម្រាប់លាបខ្លួន ១ ឲ្យដីស្អិត ១ ការប្រព្រឹត្តបន្ទាបបន្ទន់កាយវាចា ១ ការពោលពាក្យពិតខ្លះមិនពិតខ្លះ ដូចជាសម្ងួសណ្តែកបាយ ១ ផ្កាប់ផ្គន់ត្រកូល ១ ទទួលបម្រើគ្រហស្ថដោយកម្លាំងស្មង ១ ធ្វើពេទ្យរក្សាជម្ងឺ ១ ធ្វើខ្លួនជាទូត ១ ទទួលខ្លួនជាអ្នកបម្រើគ្រហស្ថ ឲ្យគេប្រើទៅមក ១

ឲ្យបិណ្ឌបាតដល់គ្រហស្ថ ប្រាថ្នាផលតបខាងក្រោយ ១ ការឲ្យទៅឲ្យមក ១ រៀនវិជ្ជា ធ្វើជាគ្រូមើលទីដីជយភូមិ ១ រៀនវិជ្ជា ធ្វើជាគ្រូមើលនក្ខត្តឫក្ស ១ រៀនវិជ្ជាធ្វើជាគ្រូទាយលក្ខណៈ ។ និងប្រព្រឹត្តអគោចរ ៦ គឺទៅកាន់សំណាក់ស្រីពេស្យា ១ ស្រីមេម៉ាយ ១ ស្រីក្រមុំចាស់ ឬក្រមុំជំទង់ ១ បណ្ឌកៈ ១ ភិក្ខុនី ១ រោងស្រា ១ ។ ប្រឡូកប្រឡំដោយគ្រហស្ថ គឺព្រះរាជា អមាត្យរបស់ព្រះរាជា តិរ្ថិយ សាវកតិរ្ថិយ ដោយការប្រឡូកប្រឡំដែលមិនសមគួរ ។ សេពគប់ចូលជិតត្រកូលដែលមិនមានបសាទសទ្ធា មិនដូចជាអណ្តូងទឹកជេរនិងបរិភាស ប្រាថ្នាតែវត្ថុដែលមិនមានប្រយោជន៍ មិនជួយសង្គ្រោះ មិនសប្បាយ មិនរួចផុតយោគៈដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អ្នកនេះឈ្មោះថា **អ្នកឈ្វាសក្នុងវត្ថុដែលមិនមានប្រយោជន៍** ។

មួយទៀត អ្នកណាបួសក្នុងព្រះសាសនានេះ ប្រកបខ្លួនដោយប្រពៃ លះអនេសនៈប្រាថ្នាតែនឹងតាំងនៅក្នុងចតុបារិសុទ្ធិ-សីល បំពេញបាតិមោក្ខសំវរសីល ដោយសទ្ធាជាសំខាន់ បំពេញឥន្ទ្រិយសំវរសីល ដោយសតិជាសំខាន់ បំពេញអាជីវបារិសុទ្ធិ-សីល ដោយសេចក្តីព្យាយាមជាសំខាន់ បំពេញការសេពបច្ច័យដោយបញ្ញាជាសំខាន់ ភិក្ខុនេះឈ្មោះថា **អ្នកឆ្លាតក្នុងប្រយោជន៍** ។

មួយទៀត ភិក្ខុណាជម្រះបាតិមោក្ខសំវរសីល ដោយជម្រះអាបត្តិ ៧ កង ជម្រះឥន្ទ្រិយសំវរសីល ដោយមិនឲ្យអភិជ្ឈាជាដើម

កើតក្នុងអារម្មណ៍ដែលប៉ះខ្ទប់ក្នុងទ្វារ ៦ ជម្រះអាជីវបារិសុទ្ធិសីល ដោយវៀរអនេសនៈ និងសេពតែបច្ច័យដែលវិញ្ញូជនសរសើរ និងដែលព្រះពុទ្ធ និងសាវករបស់ព្រះពុទ្ធសរសើរ ជម្រះការសេពបច្ច័យ ដោយការពិចារណាបច្ច័យតាមដែលពោលហើយ និងជម្រះសម្បជញ្ញៈ ដោយការពិចារណា ដោយជាសាត្ថកសម្បជញ្ញៈជាដើម ក្នុងការផ្លាស់ឥរិយាបថទាំង ៤ សូម្បីភិក្ខុនេះ ក៏ឈ្មោះថាអ្នកឈ្លាសក្នុងប្រយោជន៍ ។

មួយទៀត ភិក្ខុណាដឹងថា សំពត់សៅហ្មង អាស្រ័យទឹកប្រៃក៏ធ្វើឲ្យស្អាតបាន កញ្ចក់អាស្រ័យផេះ ក៏ធ្វើឲ្យស្អាតបាន មាសអាស្រ័យឡសម្រាប់ដុតរំលាយលោហធាតុ ក៏ធ្វើឲ្យផូរផង់បានយ៉ាងណា សីលអាស្រ័យញាណ ក៏ផូរផង់បានដូច្នោះ ហើយជម្រះដោយទឹកគឺញាណ ក៏ធ្វើសីលឲ្យបរិសុទ្ធិបាន ។

យថា ច កិកី សកុណិកា អណ្ឌំ, ចមរី មិគោ វាលធិំ, ឯកបុត្តិកា នារី បិយំ ឯកបុត្តកំ, ឯកនយនោ បុរិសោ តំ ឯកនយនញ្ច រក្ខតិ, តថា អតិវិយ អប្បមត្តោ អត្តនោ សីលក្ខន្ធំ រក្ខតិ, សាយំ ចាតំ បច្ចវេក្ខមានោ អណុមត្តម្បិ វជ្ជំ ន បស្សតិ ។

ប្រៀបដូចជាសត្វត្រដេវរ៉ិច រក្សាពង, សត្វទ្រាយចាមរី រក្សារោមកន្ទុយ, នារីមានបុត្រម្នាក់ រក្សាបុត្រម្នាក់ដែលគួរស្រឡាញ់,

បុរសមានភ្នែកតែម្ខាង រក្សាភ្នែកតែម្ខាងនោះ, យ៉ាងណា អ្នកមិនប្រមាទដ៏ក្រៃលែង ក៏រក្សាសីលខន្ធរបស់ខ្លួនដូច្នោះ, គេពិចារណាទាំងល្ងាច ព្រឹក ក៏មិនជួបទោសសូម្បីប្រមាណតិច ។

សូម្បីអ្នកនេះ ក៏ឈ្មោះថា **អ្នកឈ្លាសក្នុងប្រយោជន៍** ។

មួយទៀត អ្នកណាតាំងនៅក្នុងសីលដែលមិនធ្វើសេចក្តីក្តៅក្រហាយ រមែងផ្គងបដិបទាគ្រឿងគ្របសង្កត់កិលេស ។ គ្រាផ្គងបដិបទានោះហើយ រមែងធ្វើបរិកម្មក្នុងកសិណ គ្រាធ្វើបរិកម្មក្នុងកសិណហើយ រមែងញ៉ាំងសមាបត្តិទាំងឡាយឲ្យកើត សូម្បីអ្នកនេះ ក៏ឈ្មោះថា **អ្នកឈ្លាសក្នុងប្រយោជន៍** ។

មួយទៀត អ្នកណាចេញចាកសមាបត្តិ ពិចារណាសង្ខារទាំងឡាយ រមែងសម្រេចព្រះអរហត្ត អ្នកនេះឈ្មោះថា ប្រសើរលើសជាងអ្នកឈ្លាសក្នុងប្រយោជន៍ ។ ជនទាំងនេះណា ជាអ្នកឈ្លាសក្នុងប្រយោជន៍ដែលលោកសរសើរហើយ ដោយត្រឹមតែតាំងនៅក្នុងសីល ដែលមិនធ្វើសេចក្តីក្តៅក្រហាយ ឬដោយត្រឹមតែផ្គងបដិបទាគ្រឿងគ្របសង្កត់កិលេស ជនទាំងនោះ លោកប្រាថ្នាថា អ្នកឈ្លាសក្នុងប្រយោជន៍ក្នុងអត្ថនេះ ។ ក៏ភិក្ខុទាំងនោះក៏ជាយ៉ាងនោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ភិក្ខុទាំងនោះ ទើបត្រាស់ដោយទេសនាជាបុគ្គលាធិដ្ឋាន មួយយ៉ាងថា ករណីយមត្ថកុសលេន ដែលអ្នកឈ្លាសក្នុងប្រយោជន៍គប្បីធ្វើដូច្នេះ ។

តអំពីនោះ កាលភិក្ខុទាំងនោះ កើតសេចក្តីសង្ស័យថា កិច្ចអ្វីដែលត្រូវធ្វើ ព្រះមានព្រះភាគ ទើបត្រាស់ថា យន្តំ សន្តំ បទំ អភិសមេច្ច ។ ក្នុងពាក្យនេះមានអធិប្បាយដូច្នេះ ។ ព្រះពុទ្ធ និង អនុពុទ្ធទាំងឡាយ តែងសរសើរកិច្ចដែលអ្នកប្រាថ្នានឹងសម្រេចសន្តបទ ដោយការចាក់ធ្លុះនូវនិព្វានបទដ៏ស្ងប់ ។ ក៏ក្នុងពាក្យនេះគប្បីជ្រាបថា ពាក្យថា យំ ខ្ញុំម្ចាស់ពោលទុកខាងដើមបទគាថានេះនោះហើយ រមែងប្រព្រឹត្តទៅដោយអធិការថា ករណីយំ គឺ តំ សន្តំ បទំ អភិសមេច្ច ។ តែព្រោះហេតុដែលសេចក្តីនេះ មានបាឋៈដែលត្រូវថែមពាក្យដែលនៅសល់ ដូច្នោះ ខ្ញុំទើបពោលថា វិហរិតុកាមេន ។

ម្យ៉ាងទៀត ក្នុងពាក្យនេះ គប្បីជ្រាបអធិប្បាយយ៉ាងនេះថា ពាក្យថា សន្តំ បទំ អភិសមេច្ច រមែងប្រព្រឹត្តទៅដោយអធិការថា កិច្ចនោះណាដែលអ្នកប្រាថ្នានឹងដឹងបទគឺព្រះនិព្វាន សន្ត ស្ងប់ដោយលោកិយបញ្ញា ដោយបានស្តាប់មកជាដើម នឹងសម្រេចបទគឺនិព្វាននោះគប្បីធ្វើ ។ ន័យមួយទៀត គ្រាកាលត្រាស់ថា ករ- ណីយមត្ថកុសលេន កាលភិក្ខុទាំងឡាយច្រើននាំគ្នាគិតថាអ្វី ទើបត្រាស់ថា យន្តំ សន្តំ បទំ អភិសមេច្ច ។ ន័យនោះគប្បីជ្រាបអធិប្បាយយ៉ាងនេះថា កិច្ចណាដែលបុគ្គលដឹងបទដ៏ស្ងប់ ដោយ

លោកិយបញ្ញាហើយគប្បីធ្វើ គប្បីប្រកបកិច្ចនោះ ក៏គួរធ្វើ លោកអធិប្បាយថា កិច្ចនោះគួរដល់ការធ្វើទាំងនោះ ។

សួរថា កិច្ចនោះគឺអ្វី ។ ឆ្លើយថា កិច្ចអ្វីដទៃគប្បីមាននៅក្រៅពីឧបាយសម្រេចនិព្វានបទនោះ ។ កិច្ចនោះខ្ញុំបានពោលទុកហើយ ដោយបទដើមដែលសម្ដែងសិក្ខា ៣ ព្រោះអត្ថថា គួរដល់ការធ្វើក៏ពិតមែន សូម្បីយ៉ាងនោះ ក្នុងការពណ៌នាសេចក្ដីនៃពាក្យនោះ ខ្ញុំក៏បានពោលហើយថា **ករណីយះ** ក៏មាន **អករណីយះ** ក៏មាន ។ ក្នុងពីរយ៉ាងនោះដោយសង្ខេប សិក្ខា ៣ ឈ្មោះថា **ករណីយះ** ។ តែព្រោះទ្រង់សម្ដែងទុកសង្ខេបពេក បណ្ដាភិក្ខុទាំងនោះ ពួកខ្លះក៏ដឹងច្បាស់ ពួកខ្លះក៏មិនដឹងច្បាស់ ។ អំពីនោះ កាលត្រាស់កិច្ចណាដែលភិក្ខុអ្នកនៅព្រៃគួរធ្វើឲ្យប្លែក ដើម្បីឲ្យពួកភិក្ខុដែលមិនដឹងច្បាស់ ឲ្យបានដឹងច្បាស់ ទើបទ្រង់ញ៉ាំងកិច្ចនោះឲ្យពិស្ដារ ត្រាស់កន្លះគាថានេះមុនថា សក្កោ ឧជូ ច សុហុជូ ច សុវចោ ចស្ស មុទុ អនតិមានី ។

លោកអធិប្បាយទុកយ៉ាងណា ។ លោកអធិប្បាយថា ភិក្ខុដែលនៅព្រៃ ប្រាថ្នានឹងសម្រេចសន្តបទនៅ ឬសម្រេចសន្តបទនោះ ដោយលោកិយបញ្ញាហើយ បដិបត្តិដើម្បីសម្រេចសន្តបទនោះ មិនអាល័យក្នុងកាយនិងជីវិត ព្រោះប្រកបដោយបធានិយង្គៈ ២ និង ៤ ប្រការ គប្បីជាអ្នកអាចបដិបត្តិដើម្បីត្រាស់ដឹងសច្ចៈ ករណីយកិច្ចដែលគួរធ្វើណាៗ នោះណាមិនថា ខ្ពស់ទាប

របស់សព្រហ្មចារី ក្នុងការបរិកម្មកសិណ សមាទានវត្តជាដើម និង ក្នុងការជួសជុលបាត្រចីវរជាដើមរបស់ខ្លួន ក៏គប្បីអាច គប្បីឧស្សាហ៍ មិនខ្ជិលច្រអូស អាចក្នុងករណីយកិច្ចទាំងនោះ និងក្នុងកិច្ចដូច្នោះយ៉ាងដទៃក៏ដូចគ្នា ។ សូម្បីកាលជាអ្នកអាច ក៏គប្បីជាអ្នកត្រង់ដោយការប្រកបដោយបធានិយង្គៈទី ៣ ។ សូម្បីកាលជាអ្នកអាច ក៏គប្បីជាអ្នកត្រង់ដោយល្អ ដោយជាអ្នកត្រង់តែមួយ ឬដោយជាអ្នកត្រង់ក្នុងកាលនៅកំលោះ ដោយមិនដល់នូវសេចក្តីសន្ទោស តែធ្វើមិនធូរថយរឿយៗ រហូតដល់អស់ជីវិត ។ ឬថាឈ្មោះថា ត្រង់ ព្រោះធ្វើដោយសេចក្តីមិនអួតថាល្អ ឈ្មោះថាត្រង់ ព្រោះមិនមានមាយា ។ ឬថា ឈ្មោះថា ត្រង់ ព្រោះលះសេចក្តីកោងផ្លូវកាយនិងវាចា ឈ្មោះថា ពិត ឈ្មោះថា ត្រង់ល្អ ព្រោះមិនអត់ទ្រាំចំពោះលាភ ដែលកើតព្រោះគុណមិនមានពិត ។ គប្បីឈ្មោះថា ជាអ្នកត្រង់ និងត្រង់ល្អ ដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ដោយសិក្ខា ២-៣ ប្រការខាងដើម និងដោយបយោគសុទ្ធិ និង អាសយសុទ្ធិ ដោយប្រការដូច្នេះ ។

ភិក្ខុមិនមែនគប្បីជាអ្នកត្រង់ និងល្អតែម្យ៉ាង ដែលពិតគប្បីជាអ្នកប្រដៅងាយទៀតផង ។ ក៏បុគ្គលណាត្រូវគេពោលប្រាប់ថា លោកមិនគួរធ្វើអំពើនេះ ក៏និយាយថា អំពើអ្វីដែលអ្នកឃើញហើយ ពាក្យអ្វីដែលអ្នកបានឮហើយ អ្នកណាឮពាក្យខ្ញុំហើយទៅនិយាយ ជាឧបជ្ឈាយ៍ ឬអាចារ្យ ឬមិត្រធ្លាប់ឃើញគ្នាមួយជង

មួយកាល ឬក៏មិត្រធ្លាប់សេពគប់រកគ្នា (របស់ខ្ញុំ) ឬបៀតបៀនអ្នកជាស់តឿននោះ ដោយការនៅអង្គុយស្ងៀម ឬព្រមទទួលហើយក៏មិនធ្វើតាមយ៉ាងនោះ អ្នកនោះឈ្មោះថា នៅឆ្ងាយពីការសម្រេចគុណវិសេស ។ ចំណែកអ្នកណា ត្រូវលោកទូន្មាន ក៏ពោលថា ល្អណាស់លោកម្ចាស់ លោកនិយាយល្អ ។ ដែលឈ្មោះថា ទោសរបស់ខ្លួនជារបស់ឃើញបានលំបាក លោកឃើញខ្ញុំមានសភាពបែបនេះ មេត្តាអាស្រ័យសេចក្តីអាណិត ពោលទៀតចុះ ខ្ញុំមិនបានទទួលឱវាទអំពីសំណាក់លោកយូរ និងបដិបត្តិតាមដែលលោកទូន្មាន អ្នកនោះឈ្មោះថា នៅមិនឆ្ងាយពីការសម្រេចគុណវិសេស ព្រោះដូច្នោះ បុគ្គលទទួលពាក្យរបស់អ្នកដទៃហើយ ធ្វើយ៉ាងនេះ គប្បីឈ្មោះថា ជាអ្នកប្រដៅងាយ ។

មួយទៀត ជាអ្នកប្រដៅងាយយ៉ាងណា ក៏គប្បីជាអ្នកទន់ភ្លន់យ៉ាងនោះ ។ បទថា មុទុ សេចក្តីថា ភិក្ខុត្រូវពួកគ្រហស្ថប្រើក្នុងការជាទូត និងការទទួលខ្លួនជាអ្នកបម្រើត្រកូលឲ្យគេប្រើទៅមកជាដើម ក៏មិនធ្វើសភាពទន់ភ្លន់ ជាអ្នករឹងរុះក្នុងកិច្ចនោះ តែគប្បីជាអ្នកទន់ភ្លន់ក្នុងវត្តបដិបត្តិ និងព្រហ្មចរិយទាំងអស់ អត់ធន់ចំពោះការមិនទទួលបម្រើក្នុងកិច្ចនោះ ដូចមាសដែលជាងតាក់តែងដោយល្អ ។ ម្យ៉ាងទៀត បទថា មុទុ បានដល់ ជាអ្នកមិនមានមុខក្រញូវ គឺជាអ្នកមានមុខរីករាយ ចរចាតែពាក្យដែលឲ្យកើតសុខ ទទួលភ្ញៀវ គប្បីដូចជាអ្នកចុះកាន់កំពង់ទឹកដែលល្អ ដោយ

សប្បាយ មិនមែនតែជាអ្នកទន់ភ្លន់តែម្យ៉ាង គប្បីជាអ្នកមិនមាន អតិមានះ មើលងាយគេផង ។ មិនគប្បីមើលងាយអ្នកដទៃ ដោយវត្ថុនៃការមើលងាយ មានជាតិ និងគោត្រជាដើម គប្បីមានចិត្តស្មើ ដោយក្នុងចណ្ឌាល ដូចព្រះសារីបុត្តត្ថេរៈ ដូច្នោះ ។

## ពណ៌នាគាថាទី ២

សន្តុស្សកោ ច សុភរោ ច
អប្បកិច្ចោ ច សល្លហុកវុត្តិ
សន្តិន្ទ្រិយោ ច និបកោ ច
អប្បគព្ភោ កុលេសុ អននុគិទ្ធោ ។

សន្តោសផង គេចិញ្ចឹមងាយផង មានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាលព្រម (មានបរិក្ខារតិច)ផង មានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង មិនឃ្នើសឃ្នងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង ។

ព្រះមានព្រះភាគត្រាស់ករណីយកិច្ចដោយចំពោះយ៉ាងក្រៃលែងរបស់ភិក្ខុដែលនៅព្រៃ ដែលប្រាថ្នានឹងសម្រេចសន្តបទ ឬបដិបត្តិដើម្បីសម្រេចសន្តបទនោះ យ៉ាងនេះហើយ មានពុទ្ធប្រាថ្នានឹងត្រាស់ក្រៃលែងឡើងទៅជាងនោះទៀត ទើបត្រាស់គាថាទី ២ ថា សន្តុស្សកោ ច ជាដើម ។

ក្នុងគាថាទី ២ នោះ ភិក្ខុឈ្មោះថា **សន្តោស** ព្រោះសន្តោសដោយសន្តោស ១២ យ៉ាង មានប្រភេទដែលពោលទុកហើយក្នុងមង្គល នេះថា សន្តុដ្ឋី ច កតញ្ញុតា នេះ ។ ន័យម្យ៉ាងទៀត ភិក្ខុណារមែងត្រេកអរ ហេតុនោះ ភិក្ខុនោះឈ្មោះថា **តុស្សកៈ** អ្នកត្រេកអរ ភិក្ខុដែលត្រេកអរដោយខ្លួនឯង អ្នកត្រេកអរដោយរបស់ដែលមានអ្នកត្រេកអរដោយអាការស្មើ ហេតុនោះ ទើបឈ្មោះថា **សន្តុស្សកៈ** អ្នកសន្តោស ។ ក្នុងលក្ខណៈ ៣ យ៉ាងនោះ បច្ច័យ ៤ ដែលលោកលើកឡើងសម្តែងក្នុងមណ្ឌលឧបសម្ប័ទយ៉ាងនេះថា បិណ្ឌិយាលោបភោជនំ និស្សាយ អាស្រ័យភោជន គឺដុំបាយដែលរកមកដោយស្មងជើងជាដើម និងខ្លួនក៏ទទួលទុកហើយ ឈ្មោះថា របស់ខ្លួន ។

ភិក្ខុមិនសម្តែងអាការខុសប្រក្រតី ក្នុងវេលាទទួល និងក្នុងវេលាបរិភោគ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបច្ច័យរបស់ខ្លួននោះ ល្អក៏ដោយ មិនល្អក៏ដោយ ដែលគេថ្វាយដោយគោរព និងមិនគោរពក៏ដោយ ហៅថា អ្នកត្រេកអរដោយរបស់ខ្លួន ។ របស់ណាបានមកហើយ មានដល់ខ្លួន របស់នោះឈ្មោះថា មាន ។ ភិក្ខុត្រេកអរដោយរបស់មាននោះនុ៎ះឯង មិនប្រាថ្នារបស់ក្រៅអំពីនោះ លះភាពជាអ្នកប្រាថ្នាលើសចំណែកចេញ (ប្រាថ្នាច្រើន) ហៅថា អ្នកត្រេកអរដោយរបស់ដែលមាន ។ ការលះភាពត្រេកអរប្រទូសរ៉ាយក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា ស្មើ ។

ភិក្ខុត្រេកអរក្នុងអារម្មណ៍ទាំងពួង ដោយអាការស្មើនោះ ហៅថា អ្នកត្រេកអរដោយអាការស្មើ ។

ឈ្មោះថា *សុភរៈ* គេចិញ្ចឹមដោយងាយ ។ លោកអធិប្បាយថា អ្នកដែលគេចិញ្ចឹមងាយ ។ ភិក្ខុណាកាលមនុស្សយកបាត្របញ្ចុះពេញដោយបាយស្រូវសាលី និងសាច់ជាដើមថ្វាយហើយ សម្ដែងការៈគេចមុខចេញ និងចិត្តចេញ និយាយថា ពួកលោកឲ្យអ្វី មើលងាយបិណ្ឌបាតនោះចំពោះមុខគេ ឲ្យដល់សាមណេរ និងគ្រហស្ថជាដើម ភិក្ខុនោះឈ្មោះថា **ទុព្ភរៈ** អ្នកដែលគេចិញ្ចឹមលំបាក ។ មនុស្សទាំងឡាយ ឃើញភិក្ខុនោះហើយ ក៏វៀរបង់ចេញចាកឆ្ងាយតែម្ដង ដោយពោលថា ភិក្ខុចិញ្ចឹមលំបាក អ្នកណាក៏មិនអាចចិញ្ចឹមរក្សាបាន ។ ចំណែកភិក្ខុណា បានរបស់សៅហ្មង ឬប្រណីតយ៉ាងណាមួយ តិចឬច្រើន មានចិត្តល្អ មុខថ្លាផូរផង់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ភិក្ខុនោះឈ្មោះថា **សុភរៈ** អ្នកចិញ្ចឹមងាយ ។ មនុស្សទាំងឡាយឃើញភិក្ខុនោះហើយ ជាអ្នកស្និទ្ធស្នាលយ៉ាងក្រៃលែង ក៏ប្ដេជ្ញាទទួលចិញ្ចឹមថា ព្រះគុណម្ចាស់របស់យើងចិញ្ចឹមងាយ ត្រេកអរតែរបស់បន្តិចៗ ពួកខ្ញុំហ្នឹងឯងនឹងចិញ្ចឹមលោក ។ ភិក្ខុបែបនោះ លោកប្រាថ្នាថា **ជាសុភរៈ** ចិញ្ចឹមងាយក្នុងទីនេះ ។

កិច្ចរបស់ភិក្ខុនោះតិច ហេតុនោះ ភិក្ខុនោះឈ្មោះថា អប្ប-កិច្ចោ **អ្នកមានកិច្ចតិច** មិនមែនអ្នកខ្វល់ខ្វាយដោយកិច្ចច្រើនយ៉ាង

ដូចជាអ្នកមានការងារជាទីត្រេកអរ អ្នកមានការនិយាយ ជាទីត្រេកអរ អ្នកមានគ្នីគ្នាជាទីត្រេកអរជាដើម, ម្យ៉ាងទៀត ជាអ្នកវៀរកិច្ច មានការងារកសាងថ្មី ការបរិភោគរបស់សង្ឃ ការប្រៀនប្រដៅសាមណេរ និងអារាមិកជនជាដើម ទូទៅទាំងវិហារ ។ លោកអធិប្បាយថា ធ្វើការកោរសក់ កាត់ក្រចក ប៉ះបាត្រ ជួសជុលចីវរជាដើមរបស់ខ្លួន ក្រៅពីកិច្ចគឺសមណធម៌ ។

ការប្រព្រឹត្តិរបស់ភិក្ខុនោះស្រាល ហេតុនោះ ភិក្ខុនោះឈ្មោះថា **សល្លហុកវុត្តិ** អ្នកមានការប្រព្រឹត្តស្រាល ភិក្ខុអ្នកមានបរិក្ខារច្រើនរូបខ្លះ វេលាចេញធ្វើដំណើរក៏ឲ្យមហាជន លើកបាត្រចីវរកម្រាល ប្រេង ដុំស្កអំពៅជាដើមជាច្រើន ទូលលើក្បាលខ្លះក្រដៀតនឹងចង្កេះខ្លះ ជាដើមយ៉ាងណា ភិក្ខុណាមិនជាយ៉ាងនោះរមែងជាអ្នកមានបរិក្ខារតិច រក្សាត្រឹមតែសមណបរិក្ខារ ៨ យ៉ាង មានបាត្រ ចីវរជាដើមប៉ុណ្ណោះ វេលាដើរផ្លូវ ក៏កាន់ធ្វើដំណើរទៅដូចជាសត្វបក្សីមានតែស្លាប ភិក្ខុបែបនោះ លោកប្រាថ្នាថា អ្នកមានការប្រព្រឹត្តិស្រាលក្នុងទីនេះ ។ ឥន្ទ្រិយទាំងឡាយរបស់ភិក្ខុនោះស្ងប់ ហេតុនោះ ភិក្ខុនោះឈ្មោះថា អ្នកមានឥន្ទ្រិយស្ងប់ ។ លោកអធិប្បាយថា អ្នកមានឥន្ទ្រិយមិនរវើរវាយដោយអំណាចរាគៈជាដើម ក្នុងឥដ្ឋារម្មណ៍ជាដើម ។ បទថា និបកោ បានដល់អ្នកជាវិញ្ញូជន អ្នកជាក់ច្បាស់ មានបញ្ញា អធិប្បាយថា អ្នកប្រកបដោយបញ្ញាជាគ្រឿងតាមរក្សាសីល ដោយបញ្ញាកំណត់ដឹងបច្ច័យ

៤ មានចីវរជាដើម និងដោយបញ្ញាកំណត់ដឹងសប្បាយ ៧ យ៉ាង មានអាវាសសប្បាយជាដើម ។

អ្នកមិនឃ្នើសឃ្នង ហេតុនោះ ទើបឈ្មោះថា អប្បគព្ភោ អ្នកមិនឃ្នើសឃ្នង អធិប្បាយថា វៀរចាកការឃ្នើសឃ្នងផ្លូវកាយ ៨ ឋាន ចាកការឃ្នើសឃ្នងវាចា ៤ ឋាន និងចាកការឃ្នើសឃ្នងផ្លូវចិត្តច្រើនឋាន ។ ការធ្វើមិនសមគួរផ្លូវកាយ ក្នុងសង្ឃ គណៈ បុគ្គល រោងឆាន់ រោងភ្លើង កំពង់ងូតទឹក ផ្លូវបិណ្ឌបាត និងការចូលកាន់ចន្លោះផ្ទះ ឈ្មោះថា ការឃ្នើសឃ្នងផ្លូវកាយ ៨ ឋាន គឺជាដើមយ៉ាងនេះថា ភិក្ខុរបខ្វះក្នុងព្រះសាសនានេះ អង្គុយត្របោមក្បាលជង្គង់ ឬយកជើងប៉ះដោយជើង ក្នុងកណ្ដាលជំនុំសង្ឃ ។ ត្រង់កណ្ដាលគណៈ ក្នុងទីប្រជុំបរិស័ទ ៤ ក៏ដូចគ្នា ក្នុងបុគ្គលដែលចាស់ជាងក៏ដូចគ្នា ។ ចំណែកក្នុងរោងឆាន់ ភិក្ខុមិនឲ្យអាសនៈដល់ភិក្ខុចាស់ ហាមអាសនៈដល់ភិក្ខុថ្មី ក្នុងរោងភ្លើង ក៏ដូចគ្នា ។ ក៏ក្នុងរោងភ្លើងនោះ ភិក្ខុមិនសូមឱកាសភិក្ខុដែលចាស់ជាង ធ្វើការដុតភ្លើងជាដើម ។ ចំណែកក្នុងកំពង់ងូតទឹក លោកពោលពាក្យនេះថា មិនត្រូវប្រកាន់ថាថ្មី ចាស់ គប្បីងូតទឹកបានតាមលំដាប់របស់អ្នកមកដល់ ភិក្ខុកាលមិនអើពើ មកខាងក្រោយ ក៏ចុះទឹកបៀតបៀនភិក្ខុចាស់ និងភិក្ខុថ្មី ។ ចំណែកក្នុងផ្លូវបិណ្ឌបាត ភិក្ខុទៅខាងមុខៗ យកដៃប៉ះខ្នប់ដៃភិក្ខុដែលចាស់ជាង ដើម្បីប្រាថ្នាអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ និងអាហារដ៏ប្រសើរ ។ ក្នុងការ

ចូលទៅកាន់ចន្លោះផ្ទះ ក៏មានជាដើមយ៉ាងនេះថា ភិក្ខុចូលទៅមុនភិក្ខុចាស់, ធ្វើការលេងផ្លូវកាយជាមួយនឹងភិក្ខុកំលោះ ។ ការថ្លែងវាចាមិនសមគួរក្នុងសង្ឃ គណៈ បុគ្គល និងចន្លោះផ្ទះ ឈ្មោះថាឃ្លើសឃ្លងវាចា ៤ ឋាន គឺជាដើមយ៉ាងនេះថា ភិក្ខុរបខ្លះ ក្នុងព្រះសាសនានេះ មិនសូមឱកាសក្នុងកណ្តាលសង្ឃពោលធម៌ ។ ក្នុងគណៈ ក្នុងបុគ្គលដែលចាស់ជាង មានប្រការដូចដែលពោលមកមុនហើយ ក៏ដូចគ្នា ។ ក្នុងទីនោះ ភិក្ខុត្រូវមនុស្សទាំងឡាយសួរបញ្ហា មិនសូមឱកាសភិក្ខុដែលចាស់ជាង ក៏ឆ្លើយបញ្ហា ។ ចំណែកក្នុងចន្លោះផ្ទះ ភិក្ខុពោលជាដើមយ៉ាងនេះថា មានអ្វីក្នុងផ្ទះឯណោះ បបរឬរបស់គួរទំពាស៊ី ឬរបស់ស៊ី លោកនឹងឲ្យអ្វីដល់យើង ថ្ងៃនេះយើងនឹងទំពា នឹងស៊ីអ្វី នឹងផឹកអ្វី ។

សូម្បីមិនមានសេចក្តីល្មើសផ្លូវកាយវាចា ក្នុងឋានៈនុ៎ះៗ តែក៏មានវិតក្កដែលមិនសមគួរផ្សេងៗ មានកាមវិតក្កជាដើម ផ្លូវចិត្តឈ្មោះថា ការឃ្លើសឃ្លងផ្លូវចិត្តមានច្រើនឋាន ។

បទថា កុលេសុ អននុគិទ្ធោ សេចក្តីថា ភិក្ខុចូលទៅរកត្រកូលទាំងនោះឯណា មិនជាប់ដោយសេចក្តីចង់បានបច្ច័យ ឬដោយការប្រឡូកប្រឡំដែលមិនសមគួរក្នុងត្រកូលទាំងនោះ លោកអធិប្បាយថា មិនសោយសោកជាមួយផង មិនរីករាយជាមួយផង, កាលត្រកូលទាំងនោះប្រសព្វសេចក្តីសុខ ក៏មិនសុខផង, កាលត្រកូលទាំងនោះប្រសព្វសេចក្តីទុក្ខ ក៏មិនមានទុក្ខផង ឬកាល

*ករណីយកិច្ចទាំងឡាយកើតឡើង ក៏មិនចូលប្រកបដោយខ្លួនឯងៗ ក៏ពាក្យណាថា **អស្ស** ដែលត្រាស់ទុកក្នុងពាក្យនេះថា **សុវចោ អស្ស** នៃគាថានេះ ពាក្យនោះ គប្បីប្រកបចូលទឹងបទគ្រប់បទ យ៉ាងនេះថា* សន្តុស្សកោ ច អស្ស សុភរោ ច អស្ស ។

## ពណ៌នាគាថាទី ៣

ន ច ខុទ្ទំសមាចរេ កិញ្ចិ
យេន វិញ្ញូ បរេ ឧបវទេយ្យុំ
សុខិនោ វា ខេមិនោ ហោន្តុ
សព្វេ សត្តា ភវន្តុ សុខិតត្តា

*វិញ្ញូជនទាំងឡាយ គួរតិះដៀលជនទាំងឡាយដទៃ ដោយកម្មណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមក សូម្បីតិចតួច (ហើយគួរផ្សាយមេត្តាចិត្តចំពោះពពួកសត្វថា) សត្វទាំងឡាយទាំងពួង សូមឲ្យមានសេចក្ដីសុខ ឲ្យមានសេចក្ដីក្សេម ឲ្យមានខ្លួនដល់នូវសេចក្ដីសុខចុះ ។*

*ព្រះមានព្រះភាគ គ្រាត្រាស់ប្រាប់ករណីយសូម្បីក្រៃលែងជាងនោះ ដោយចំពោះយ៉ាងក្រៃលែងដល់ភិក្ខុអ្នកនៅព្រៃ ដែលប្រាថ្នាសម្រេចសន្តបទហើយ ឬប្រាថ្នាទឹងបដិបត្តិដើម្បីសម្រេចសន្តបទនោះ យ៉ាងនេះហើយ ឥឡូវនេះ មានព្រះពុទ្ធប្រាថ្នានឹង*

ត្រាស់ប្រាប់អករណីយ ទើបត្រាស់កន្ទះគាថាថា ន ច ខុទ្ទំ-សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ ។

កន្ទះគាថានោះ មានសេចក្ដីដូច្នេះ ភិក្ខុកាលធ្វើករណីយនេះយ៉ាងនោះ ក៏មិនគប្បីប្រព្រឹត្តកាយទុច្ចរិត វចីទុច្ចរិតនិងមនោទុច្ចរិតដែលហៅថា **ខុទ្ទៈ** គឺលាមក កាលមិនប្រព្រឹត្ត មិនមែនប្រព្រឹត្តតែកម្មគ្រោតគ្រាតតែម្យ៉ាង សូម្បីកម្មបន្តិចបន្តួចណាមួយ ក៏មិនប្រព្រឹត្ត លោកអធិប្បាយថា មិនប្រព្រឹត្តកម្មលាមក ទាំងមានប្រមាណតិច ទាំងតូច ។

អំពីនោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងទោសដែលឃើញបានខ្លួនឯង ក្នុងការប្រព្រឹត្តិកម្មលាមកនោះថា យេន វិញ្ញូ បរេ ឧបវទេយ្យុំ ។ ក៏ក្នុងពាក្យនេះ ព្រោះហេតុដែលអ្នកមិនមែនវិញ្ញូជនពួកដទៃ មិនកាន់យកជាប្រមាណ ព្រោះអវិញ្ញូជនទាំងនោះ នៅធ្វើកម្មមិនមានទោស ឬមានទោស មានទោសតិច ឬមានទោសច្រើន ។ ចំណែកវិញ្ញូជនទាំងឡាយប៉ុណ្ណោះ កាន់យកជាប្រមាណបាន ព្រោះវិញ្ញូជនទាំងនោះ កាលពិចារណារឿយៗហើយ រមែងតិះដៀលអ្នកដែលគួរតិះដៀល សរសើរអ្នកដែលគួរសរសើរ ។ ដូច្នោះ ទើបត្រាស់ថា វិញ្ញូ បរេ ។

ព្រះមានព្រះភាគ កាលត្រាស់ឧបចារនៃកម្មដ្ឋាន ផ្សេងដោយករណីយនិងអករណីយ ដោយចំពោះយ៉ាងក្រៃលែងដល់ភិក្ខុអ្នក

នៅព្រៃ ដែលប្រាថ្នានឹងសម្រេចសន្តបទហើយនៅ ឬប្រាថ្នាបដិបត្តិ ដើម្បីសម្រេចសន្តបទនោះ និងដល់ពួកភិក្ខុដែលប្រាថ្នានឹងទទួលកម្មដ្ឋានសូម្បីគ្រប់រូប ដោយលើកភិក្ខុដែលនៅព្រៃជាសំខាន់ ដោយពីរគាថាកន្លះនេះ យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្ដើមត្រាស់មេត្តាកថាដោយន័យថា សុខិនោ វា ខេមិនោ ហោន្តុ ជាដើម ដើម្បីជាបរិត្តកម្ចាត់ភ័យអំពីទេវតានោះ និងដើម្បីជាកម្មដ្ឋាន ដោយឈានជាបាទនៃវិបស្សនាដល់ភិក្ខុទាំងនោះ ។

បណ្ដាបទទាំងនោះ បទថា សុខិនោ បានដល់ អ្នកដល់ព្រមដោយសេចក្ដីសុខ ។ បទថា ខេមិនោ ប្រែថា អ្នកមានសេចក្ដីក្សេម ។ លោកអធិប្បាយថា អ្នកមិនមានភ័យ មិនមានឧបទ្រវៈ, បទថា សព្វេ បានដល់ មិនមានសេសសល់ឡើយ ។ បទថា សត្តា បានដល់ សត្វមានជីវិត ។ បទថា សុខិតត្តា បានដល់ អ្នកមានចិត្តដល់នូវសេចក្ដីសុខ ។ ក៏ក្នុងពាក្យនេះ គប្បីជ្រាបថា ឈ្មោះថា អ្នកមានសេចក្ដីសុខ ដោយសុខផ្លូវកាយ ។ ឈ្មោះថា មានចិត្តដល់នូវសេចក្ដីសុខ ដោយសុខផ្លូវចិត្ត, ឈ្មោះថា មានសេចក្ដីក្សេម សូម្បីដោយសុខទាំងពីរនោះ ឬដោយប្រាសចាកភ័យ និងឧបទ្រវៈទាំងពួង ។ ក៏ព្រោះហេតុអ្វីទើបត្រាស់យ៉ាងនេះ ។ ក៏ដើម្បីសម្ដែងអាការនៃមេត្តាភាវនា ។ ក៏កាលជាយ៉ាងនេះ ទើបគួរចម្រើនមេត្តាថា “សូមសត្វទាំងពួងចូរមាននូវសេចក្ដីសុខ”

ដូច្នេះខ្លះ ថា "ចូរមានសេចក្តីក្សេម" ដូច្នេះខ្លះ ថា "ចូរជាអ្នកមានខ្លួនដល់សេចក្តីសុខ" ដូច្នេះខ្លះ ។

## ពណ៌នាគាថាទី ៤

យេ កេចិ បាណភូតត្ថិ
តសា វា ថាវរា វា អនវសេសា
ទីឃា វា យេ មហន្តា វា
មជ្ឈិមា រស្សកា អណុកថូលា

សត្វមានជីវិតទាំងឡាយណាមួយ ឥតមានសេសសល់ ទោះសត្វមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី មាំមួនគឺឥតមានតណ្ហាក្តី សត្វទាំងឡាយណា មានកាយវែងក្តី ធំក្តី មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី មានកាយស្គម ឬធាត់ក្តី ។

ព្រះមានព្រះភាគ ត្រាស់សម្តែងមេត្តាភាវនាដោយសង្ខេប តាំងពីឧបចារៈដរាបដល់អប្បនាជាទីបំផុតយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងមេត្តាភាវនានោះសូម្បីដោយពិស្តារ ទើបត្រាស់ពីរគាថាថា យេ កេចិ ជាដើម ។ មួយវិញទៀត ព្រោះហេតុដែលចិត្តត្រូវសន្សំនៅក្នុងអារម្មណ៍ច្រើនៗ រមែងមិនឈប់ក្នុងអារម្មណ៍តែមួយដោយខាងដើមប៉ុណ្ណោះ តែនឹងត្រាច់ជាប់តាមប្រភេទអារម្មណ៍ដោយលំដាប់ ដូច្នោះទើបត្រាស់ពីរគាថាថា យេ

កោចិ ជាដើម ដើម្បីចិត្តដែលត្រាច់ជាប់តាមទៅ ហើយឈប់ក្នុងអារម្មណ៍ដែលជាប្រភេទនៃទុកៈពួកពីរនៃសត្វ និងតិកៈពួកបីនៃសត្វ មាន**តសថាវរទុកៈ**ជាដើម ។ ម្យ៉ាងទៀត ព្រោះហេតុដែលអារម្មណ៍ណារបស់អ្នកណា ជាអារម្មណ៍ដែលប្រាកដច្បាស់ ហើយចិត្តរបស់អ្នកនោះ រមែងតាំងនៅជាសុខក្នុងអារម្មណ៍នោះ ដូច្នោះ អារម្មណ៍ណារបស់ភិក្ខុរូបណា បណ្ដាភិក្ខុទាំងនោះ ប្រាកដច្បាស់ហើយ ព្រះមានព្រះភាគ មានពុទ្ធប្រាថ្នានឹងឲ្យចិត្តរបស់ភិក្ខុរូបនោះ តាំងនៅក្នុងអារម្មណ៍នោះ ទើបត្រាស់ពីរគាថាថា យេ កោចិ ជាដើម ដែលសម្ដែងសេចក្ដីផ្សេងនៃអារម្មណ៍ជាទុកៈ និង តិកៈ មាន**តសថាវរទុកៈ** ជាដើម ។

សេចក្ដីពិត ក្នុងពីរគាថានោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងទុកៈពួកពីរនៃសត្វ ៤ ទុកៈ គឺ **តសថាវរទុកៈ** ពួកពីរនៃសត្វអ្នកតក់ស្លុត និងមាំមួន (មិនតក់ស្លុត) **ទិដ្ឋាទិដ្ឋទុកៈ** ពួកពីរនៃសត្វដែលខ្លួនឃើញហើយ និងដែលខ្លួនមិនទាន់ឃើញ **ទូរសន្តិកទុកៈ** ពួកពីរនៃសត្វដែលកើតហើយ និងអ្នកស្វែងរកទីកើត ។ និងទ្រង់សម្ដែងតិកៈពួកបីនៃសត្វ ៣ តិកៈ គឺ**ទីឃរស្សមជ្ឈិមតិកៈ** តិកៈពួកបីនៃសត្វដែលមានអត្តភាពវែង ខ្លី និងកណ្ដាល **មហន្តាណុកមជ្ឈិមតិកៈ** ពួកបីនៃសត្វដែលមានអត្តភាពធំ តូច និងកណ្ដាល **ថូលាណុកមជ្ឈិមតិកៈ** ពួកបីនៃសត្វដែលមានអត្តភាពធាត់ ស្គម និងកណ្ដាល ដោយ**មជ្ឈិមបទ**ជាទីកើតប្រយោជន៍ ក្នុង ៣ តិកៈ

និង*អណុកថូលបទ* ដែលជាទីកើតប្រយោជន៍ ក្នុង ២ តិកៈ ដោយ ៦ បទ មាន**ទីឃបទ**ជាដើម ។ បណ្ដាបទទាំងនោះ បទថា យេ កេចិ ជាពាក្យសម្ដែងថា មិនមានចំណែកសេសសល់ឡើយ ។ ពួកសត្វដែលកើតហើយគឺ **បាណៈ** ឈ្មោះថា **បាណភូតៈ** ។ ម្យ៉ាងទៀត សត្វទាំងឡាយរមែងស្រឡះចិត្ត ហេតុនោះ ទើបឈ្មោះថា **បាណៈ** ។ ទ្រង់កាន់យកបញ្ចវោការសត្វ ដែលជាប់ដោយអស្សាសបស្សាសៈ (ខ្យល់ដកដង្ហើមចេញចូល) ដោយបទនេះ ។ សត្វទាំងឡាយរមែងកើត ហេតុនោះទើបឈ្មោះថា **ភូត** ។ ទ្រង់កាន់យកឯកវោការសត្វ និង ចតុវោការសត្វ ដោយបទនេះ ។ បទថា **អត្ថិ** ប្រែថា មាន មានព្រម ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសត្វទាំងពួង ដែលទ្រង់សង្គ្រោះដោយទុកៈ និងតិកៈរួមគ្នា ដោយពាក្យថា យេ កេចិ បាណភូតត្ថិ នេះ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សង្គ្រោះសត្វទាំងនោះសូម្បីទាំងអស់ សម្ដែងដោយទុកៈនេះថា តសា វា ថាវរា វា អនវសេសា ។

ក្នុងទុកៈនេះ សត្វទាំងឡាយ រមែងតក់ស្លុត ហេតុនោះទើបឈ្មោះថា **តសា** ពាក្យនេះជាឈ្មោះរបស់សត្វទាំងឡាយ អ្នកមានតណ្ហា និងមានភ័យ ។ សត្វទាំងឡាយ រមែងមាំមួន ហេតុនោះ ទើបឈ្មោះថា **ថាវរា** ពាក្យនេះ ជាឈ្មោះរបស់ព្រះអរហន្ត

ទាំងឡាយ អ្នកលះតណ្ហា លះភ័យបានហើយ ។ ចំណែកនៅសល់របស់សត្វទាំងនោះ មិនមាន ហេតុនោះទើបឈ្មោះថា **អនវសេសា** លោកអធិប្បាយថា សូម្បីគ្រប់សត្វ ។ ក៏ពាក្យណា ត្រាស់ទុកចុងនៃគាថាទី ២ ពាក្យនោះ គប្បីភ្ជាប់នឹងគ្រប់ទុកៈ និងតិកៈ ។ បទថា យេ កេចិ បាណភូតត្ថិ សេចក្ដីថា សត្វទាំងឡាយដែលតក់ស្លុតខ្វាចក្តី ដែលមាំមួនក្ដី មិននៅសេសសល់ឡើយ សត្វសូម្បីទាំងនេះទាំងអស់ ចូរជាអ្នកមានខ្លួនដល់នូវសេចក្ដីសុខ ។ ពួកសត្វដែលកើតហើយក្ដី ស្វែងរកទីកើតក្ដី ត្រឹមណា សត្វទាំងអស់សូម្បីទាំងនេះត្រឹមនោះ ចូរជាអ្នកមានខ្លួនដល់នូវសេចក្ដីសុខចុះដោយប្រការដូច្នេះ ។

ឥឡូវនេះ បណ្ដាបទទាំង ៦ **ទីឃា វា** ជាដើម ដែលសម្ដែងតិកៈ ៣ ពួក មានទីឃរស្សមជ្ឈិមតិកៈជាដើម ។ បទថា ទីឃា បានដល់ សត្វដែលមានអត្តភាពវែង មាននាគ ត្រី សត្វទន្សងជាដើម ពិតមែន អត្តភាពរបស់នាគទាំងឡាយក្នុងមហាសមុទ្រសូម្បីមានប្រមាណច្រើនរយព្យាម ។ អត្តភាពរបស់ត្រី និងសត្វទន្សងជាដើម ក៏មានប្រមាណច្រើនយោជន៍ ។

បទថា មហន្តា បានដល់ សត្វមានអត្តភាពធំ ក្នុងទឹកក៏មានត្រី និងអណ្ដើកជាដើម, លើគោកក៏មានស្ដេចដំរីជាដើម, ក្នុងអមនុស្ស ក៏មានទានវៈជាដើម និងត្រាស់ថា រាហូជាកំពូល

របស់សត្វដែលមានអត្តភាពទាំងឡាយ ។ ពិតមែន អត្តភាពរបស់រាហូនោះ កម្ពស់ ៤,៨០០ យោជន៍ ដៃ ១,២០០ យោជន៍ ចន្លោះចញ្ចើម ៥០ យោជន៍ ចន្លោះម្រាមដៃក៏ដូចគ្នា បាតដៃ ២០០ យោជន៍ ។ បទថា មជ្ឈិមា បានដល់ អត្តភាពរបស់សេះ គោ ក្របី ជ្រូកជាដើម ។ បទថា រស្សកា បានដល់ សត្វទាំងឡាយមានខ្នាតទាប ត្រង់កណ្ដាលវែង មានមនុស្សតឿជាដើម ក្នុងជាតិនោះៗ ។ បទថា អណុកា បានដល់ សត្វទាំងឡាយដែលមានអត្តភាពល្អិត ឬតូចជាដើម ដែលកើតក្នុងទឹកជាដើម មិនជាអារម្មណ៍របស់មំសចក្ខុ ជាវិស័យរបស់ទិព្វចក្ខុ ឬពួកសត្វចៃជាដើម ។ មួយទៀត សត្វពួកណាមានខ្នាតទាប ត្រង់កណ្ដាលធំ និងត្រង់កណ្ដាលធាត់ ក្នុងជាតិនោះៗ សត្វទាំងនោះ គប្បីជ្រាបថាតូច ។ បទថា ថូលា បានដល់ សត្វទាំងឡាយដែលមានអត្តភាពមូល មានគ្រុំ ខ្យង ជាដើម ។

## ពណ៌នាគាថាទី ៥

ទិដ្ឋា វា យេ ច អទិដ្ឋា
យេ ច ទូរេ វសន្តិ អវិទូរេ
ភូតា វា សម្ភវេសី វា
សព្វេ សត្តា ភវន្តុ សុខិតត្តា ។

សត្វទាំងឡាយណា ដែលយើងឃើញហើយក្តី មិនឃើញហើយក្តី សត្វទាំងឡាយណានៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី សត្វទាំងអស់ (នោះ) ចូរមានខ្លួនជាសុខចុះ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងសត្វទាំងឡាយមិនមានសេសសល់ដោយតិកៈ ៣ តិកៈយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សង្គ្រោះដោយទុកៈ ៣ ទុកៈ ថា ទិដ្ឋា វា យេ ច អទិដ្ឋា ជាដើម ។

បណ្តាបទទាំងនោះ បទថា ទិដ្ឋា បានដល់ សត្វពួកណាធ្លាប់ឃើញមកដោយប្រាកដដល់ភ្នែករបស់ខ្លួន ។ បទថា អទិដ្ឋា បានដល់ សត្វពួកណាតាំងនៅក្នុងសមុទ្រដទៃ ភ្នំដទៃ និងចក្រវាឡដទៃជាដើម ។ តែព្រះមានព្រះភាគ ទ្រង់សម្តែងសត្វដែលនៅឆ្ងាយ និងមិនឆ្ងាយ អត្តភាពរបស់ខ្លួនដោយទុកៈនេះថា យេ ច ទូរេ វសន្តិ អវិទូរេ ។ សត្វទាំងនោះ គប្បីជ្រាបដោយសត្វមិនមានជើង និងសត្វជើង ២ ។ ក៏ពួកសត្វដែលនៅនឹងកាយរបស់ខ្លួន ហៅថា **អវិទូរេ** នៅមិនឆ្ងាយ ពួកសត្វដែលនៅក្រៅកាយ ហៅថា **ទូរេ** នៅឆ្ងាយ ។ មួយទៀត ពួកសត្វដែលនៅខាងក្នុងឧបចារ ហៅថា នៅមិនឆ្ងាយ ។ ដែលនៅខាងក្រៅឧបចារ ហៅថា នៅឆ្ងាយ ។ ដែលនៅក្នុងព្រះវិហារ តាមជនបទ ទ្វីប

ចក្រវាឡ ហៅថា នៅមិនឆ្ងាយ ដែលនៅក្នុងចក្រវាឡដទៃ ហៅថា នៅឆ្ងាយ ។

បទថា ភូតា បានដល់ កើតហើយ កើតឡើងហើយ ។ ព្រះខីណាស្រពពួកណាកើតហើយទុំះឯង មិនរាប់ថានឹងកើតទៀត ពាក្យនោះ ជាឈ្មោះរបស់ព្រះខីណាស្រពទាំងនោះ ។ សត្វពួកណា ស្វែងរកទីកើត ។ ហេតុនោះសត្វទាំងនោះ ឈ្មោះថា **សម្ភវេសី** ។ ពាក្យនេះ ជាឈ្មោះរបស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ ដែលកំពុងស្វែងរកទីកើត សូម្បីក្នុងអនាគត ព្រោះភវសញ្ញោជនៈ មិនទាន់អស់ ។ មា៉ងទៀត បណ្តាកំណើត ៤ ពួកសត្វដែលជា អណ្ឌជៈ (កើតក្នុងពង) និងជលាពុជៈ (កើតក្នុងគភ៌) មិនទាន់ទម្លាយសំបកពង និងកើតចេញមកដរាបណា ដរាបនោះ ក៏ឈ្មោះថា **សម្ភវេសី** ។ ដែលទម្លាយសំបកពង និងកើតហើយចេញមកខាងក្រៅ ឈ្មោះថា **ភូត** ។ ពួកសត្វដែលជា សំសេទជៈ និងឱបបាតិកៈ ឈ្មោះថា **សម្ភវេសី** ក្នុងខណៈបឋមចិត្ត តាំងពីខណៈទុតិយចិត្តទៅ ឈ្មោះថា **ភូតៈ** ។ ឬសត្វទាំងឡាយកើតដោយឥរិយាបថណា មិនទាន់ផ្លាស់ឥរិយាបថជាដទៃទៅអំពីឥរិយាបថនោះដរាបណា ដរាបនោះ នៅឈ្មោះថា **សម្ភវេសី** ក្រៅអំពីនោះទៅ ឈ្មោះថា **ភូតៈ** ។

## ពណ៌នាគាថាទី ៦

ន បរោ បរំ និកុព្វេថ នាតិមញ្ញេថ កត្ថចិ នំ កិញ្ចិ

ព្យារោសនា បដិឃសញ្ញា នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ ។

*សត្វដទៃមិនគួរកំហែងបៀតបៀតនូវសត្វដទៃឡើយ មិនគួរមើលងាយគេតិចតួចក្នុងទីណាមួយឡើយ មិនគួរប្រាថ្នានូវសេចក្តីទុក្ខដល់គ្នានឹងគ្នា ព្រោះសេចក្តីក្រេវក្រោធ និង សេចក្តីចង្អៀតចង្អល់ក្នុងចិត្តឡើយ ។*

*ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនាក្នុងសត្វទាំងឡាយ ដោយប្រាថ្នាតែនឹងឲ្យចូលដល់ប្រយោជន៍សុខ របស់ភិក្ខុទាំងនោះ ដោយប្រការផ្សេងៗ ដោយ ២ គាថាកន្លះថា* សុខិនោ វា *ជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងមេត្តាភាវនានោះ សូម្បីដោយប្រាថ្នាឲ្យចេញទៅអំពីវត្ថុដែលមិនជាប្រយោជន៍ និងទុក្ខ ទើបត្រាស់ថា* ន បរោ បរំ និកុព្វេថ ។ *នេះជាបាឋៈចាស់ តែបច្ចុប្បន្ន សូត្រថា* បរំ ហិ *ដូច្នេះ ក៏មានបាឋៈនេះមិនល្អ ។*

*បណ្តាបទទាំងនោះ បទថា* បរោ *បានដល់ ជនដទៃ ។ បទថា* និកុព្វេថ *បានដល់ មិនបញ្ឆោតបន្ទំ ។ បទថា* នាតិមញ្ញេថ *បានដល់ មិនសម្គាល់កន្លងទៅ (មិនមើលងាយ) ។ បទថា* កត្ថចិ *បានដល់ ក្នុងឱកាសណាមួយ គឺក្នុងស្រុក ឬក្នុងគាម-*

ខេត្ត កណ្ដាលញាតិ ឬកណ្ដាលបុគ្គល ដូច្នេះជាដើម ។ បទថា នំ ប្រែថា នោះ ។ បទថា កិញ្ចិ បានដល់ អ្នកណាម្នាក់ គឺក្សត្រិយ៍ ឬព្រាហ្មណ៍ គ្រហស្ថ ឬ បព្វជិត ដែលដល់នូវសេចក្ដីសុខ ឬ ដែលដល់នូវសេចក្ដីទុក្ខ ដូច្នេះ ជាដើម ។ បទថា ព្យារោសនា បដិឃសញ្ញា បានដល់ ព្រោះសេចក្ដីក្រេវក្រោធ ដោយកាយ-វិការ និងវចីវិការ និងព្រោះចងគំនុំដោយមនោវិការ ។ ព្រោះកាលគួរនឹងត្រាស់ថា ព្យារោសនាយ បដិឃសញ្ញាយ តែក៏ត្រាស់ចេញថា ព្យារោសនា បដិឃសញ្ញា ដូចកាលគួរនឹងត្រាស់ថា សម្មទញ្ញាយ វិមុត្តា តែក៏ត្រាស់ថា សម្មទញ្ញា វិមុត្តា និងដូចកាលគួរនឹងត្រាស់ថា អនុបុព្វសិក្ខាយ អនុបុព្វ-កិរិយាយ អនុបុព្វបដិបទាយ តែក៏ត្រាស់ថា អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា ដូច្នោះ ។

បទថា នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ សេចក្ដីថា មិនគប្បីប្រាថ្នាសេចក្ដីទុក្ខដល់គ្នានឹងគ្នា ។ លោកអធិប្បាយទុកយ៉ាងណា ។ លោកអធិប្បាយទុកថា មិនមែនចម្រើនមេត្តាដោយមនសិការជាដើមថា "សុខិនោ វា ខេមិនោ វា ហោន្តុ សូមសត្វទាំងឡាយ ចូរមានសេចក្ដីសុខ មានសេចក្ដីក្សេមចុះ" ដូច្នេះ តែម្យ៉ាង ដែលពិត គប្បីមនសិការយ៉ាងនេះថា "អហោវត យោ

កោចិ បរបុគ្គលោ យំ កញ្ចិ បរបុគ្គលំ វញ្ចនាទីហិ និកតីហិ ន និកុព្វេថ, ជាតិអាទីហិ ច នវហិ មានវត្ថូហិ កត្ថចិ បទេសេ កញ្ចិ បរបុគ្គលំ នាតិមញ្ញេយ្យ, អញ្ញមញ្ញស្ស ច ព្យារោសនាយ វា បដិឃសញ្ញាយ វា ទុក្ខំ ន ឥច្ឆេយ្យា : *ឱហ្ន៎ បុគ្គលដទៃឯណានីមួយ មិនគប្បីកំហែង បុគ្គលដទៃយ៉ាងណាមួយ ដោយកិរិយាកោងកាច មានបោក បញ្ឆោតជាដើម, មិនគប្បីមើលងាយបុគ្គលដទៃយ៉ាងណាមួយ មិនថាក្នុងប្រទេសណាមួយ ដោយវត្ថុនៃមានះ ៩ យ៉ាង មានជាតិ ជាដើម, និងមិនគប្បីប្រាថ្នាសេចក្ដីទុក្ខដល់គ្នានឹងគ្នា ព្រោះសេចក្ដី ក្រេវក្រោធ ឬព្រោះសេចក្ដីចង្អៀតចង្អល់” ដូច្នេះទៀតផង ។*

## ពណ៌នាគាថាទី ៧

មាតា យថា និយំ បុត្តំ អាយុសា ឯកបុត្តមនុរក្ខេ
ឯវម្បិ សព្វភូតេសុ មានសម្ភាវយេ អបរិមាណំ ។

*មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយ ដោយអាយុ (ស្មើដោយជីវិត) យ៉ាងណាមិញ បុគ្គលគួរចម្រើនមេត្តាចិត្ត មិនមានប្រមាណ ចំពោះសត្វទាំងឡាយទាំងពួងយ៉ាងនោះឯង ។*

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនាដោយអត្ថ ដោយប្រាថ្នាឲ្យគេចេញទៅពីវត្ថុមិនជាប្រយោជន៍ និងទុក្ខយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងមេត្តាភាវនានោះនុ៎ះឯង ដោយឧបមា ទើបត្រាស់ថា មាតា យថា និយំ បុត្តំ ជាដើម ។

គាថានោះមានសេចក្តីថា មាតាគប្បីរក្សាបុត្រក្នុងខ្លួន គឺបុត្រដែលកើតក្នុងខ្លួន កើតអំពីទ្រូង គប្បីថ្នាក់ថ្នមបុត្រនោះដែលមានតែម្នាក់ប៉ុណ្ណោះ ដោយអាយុ គឺព្រមលះបង់សូម្បីជីវិតរបស់ខ្លួនថ្នមបុត្រនោះ ដើម្បីហាមការពារទុក្ខមកដល់បុត្រនោះ យ៉ាងណាភិក្ខុគប្បីធ្វើចិត្តដែលប្រកបដោយមេត្តានេះឲ្យចម្រើន គឺឲ្យកើតរឿយៗ ឲ្យពង្រីកទៅ និងញុំាងមេត្តាភាវនានោះចម្រើន មិនមានប្រមាណ ដោយកាន់យកសត្វមិនមានប្រមាណជាអារម្មណ៍ ឬដោយផ្សាយទៅមិនមានសេសសល់ សូម្បីតែក្នុងសត្វមួយ ។

## ពណ៌នាគាថាទី ៨

មេត្តញ្ច សព្វលោកស្មឹ មានសម្ភាវយេ អបរិមាណំ
ឧទ្ធំ អធោ ច តិរិយញ្ច អសម្ពាធំ អវេរំ អសបត្តំ ។

បុគ្គលគួរចម្រើនមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅក្នុងលោកទាំងអស់ គឺក្នុងទីខាងលើផង ខាងក្រោមផង ខាងទទឹង គឺត្រង់កណ្តាលផង ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនាដោយអាការទាំងពួងយ៉ាងនេះ ឥឡូវនេះ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនានោះនុ៎ះឯង ទើបត្រាស់ថា មេត្តញ្ច សព្វលោកស្មឹ ជាដើម ។

ក្នុងគាថានោះ ឈ្មោះថា **មិត្ត** ព្រោះស្រឡាញ់ និងរក្សា អធិប្បាយថា ហួងហែង ព្រោះមានអធ្យាស្រ័យប្រាថ្នាប្រយោជន៍ និងរក្សាឲ្យផុតពីការមកដល់របស់វត្ថុមិនជាប្រយោជន៍ ។ ភាពជាមិត្ត ឈ្មោះថា **មេត្តា** ។ បទថា សព្វលោកស្មឹ បានដល់ ក្នុងសត្វលោកមិនមានសេសសល់ឡើយ ។ មានក្នុងចិត្ត ហេតុនោះទើបឈ្មោះថា **មានសៈ** ។ ក៏ពាក្យថា មានសំ នោះ លោកពោលយ៉ាងនេះក៏ព្រោះប្រកបនឹងចិត្ត ។ បទថា ភាវយេ ប្រែថា ឲ្យចម្រើន ។ ប្រមាណរបស់មានសៈនោះ មិនមាន ហេតុនោះទើបឈ្មោះថា **អបរិមាណ** ។ លោកពោលយ៉ាងនេះ ក៏ព្រោះមេត្តាមានសត្វមិនមានប្រមាណជាអារម្មណ៍ ។ បទថា ឧទ្ធំ ប្រែថា ខាងលើ ។ ទ្រង់កាន់យកអរូបភពដោយបទនោះ ។ បទថា អធោ ប្រែថា ខាងក្រោម ។ ទ្រង់កាន់យកកាមភពដោយបទនោះ ។ បទថា តិរិយំ បានដល់ ខាងទទឹង ។ ទ្រង់កាន់យករូបភពដោយបទនោះ ។ បទថា អសម្ពាធំ បានដល់ វៀរចាកសេចក្តីចង្អៀត ។ លោកអធិប្បាយថា មានព្រំដែនដែលបែកហើយ (មិនមានព្រំដែន) ។ សត្រូវ

លោកហៅឈ្មោះថា **ព្រំដែន** អធិប្បាយថា ប្រព្រឹត្តទៅក្នុងទីមិន
មានព្រំដែននោះ ។ បទថា អវេរំ បានដល់ វៀរចាកពៀរវេរា
អធិប្បាយថា វៀរចាកសេចក្ដីប្រាកដនៃចេតនា បង្កពៀរ សូម្បី
ក្នុងចន្លោះៗ ។ បទថា អសបត្តំ បានដល់ ប្រាសចាកសត្រូវ ។
ពិតមែន បុគ្គលដែលនៅដោយមេត្តា រមែងជាទីស្រឡាញ់របស់
មនុស្ស ជាទីស្រឡាញ់របស់ពួកអមនុស្ស ។ សត្រូវណានីមួយ
របស់គេ រមែងមិនមាន ។ ដោយហេតុនោះ **មានសះវត្ថុ**ដែលមាន
ក្នុងចិត្តរបស់គេនោះ លោកទើបហៅថា **អសបត្តៈ** ព្រោះប្រាស
ចាកសត្រូវ ។ ក៏ពាក្យដែលថាសត្រូវ សត្រូវជាពាក្យដោយ
បរិយាយ ។ ការពណ៌នាសេចក្ដីតាមបទ មានប៉ុណ្ណេះ ចំណែកការ
សម្ដែងសេចក្ដីដែលប្រាថ្នាក្នុងទីនេះ មានដូច្នេះ ។

គប្បីចម្រើន ផ្សាយមេត្តាដែលត្រាស់ទុកថា ឯវម្បិ សព្វ-
ភូតេសុ មានសំ ភាវយេ អបរិមាណំ ដូច្នេះ ផ្សាយមេត្តា
ដែលមាននៅក្នុងចិត្ត មិនមានប្រមាណ ឲ្យសម្រេចដល់សេចក្ដី
រីកលូតលាស់ល្អបរិបូរណ៍ក្នុងលោកទាំងពួង ។ ធ្វើយ៉ាងណា ។
គឺផ្សាយមេត្តានោះ មិនសេសសល់ទាំងខាងលើ ខាងក្រោម
ខាងទទឹង គឺត្រង់កណ្ដាលផង, ខាងលើ តាំងពីភវគ្គព្រហ្មចុះមក,
ខាងក្រោម តាំងពីអវិចីនរកឡើងទៅ, ខាងទទឹង តាំងពីទិសដែល
នៅសេសសល់ ។ ឬខាងលើ ក៏បានដល់ អរូបធាតុ ខាងក្រោម

ក៏បានដល់ កាមធាតុ ខាងទទឹង ក៏បានដល់ រូបធាតុ ។ ក៏ឯកាល ចម្រើនមេត្តានៅយ៉ាងនេះ ធ្វើមិនឲ្យមានសេចក្ដីចង្អៀត ពៀរវេរា និងសត្រូវ គប្បីចម្រើនមេត្តានោះដោយប្រការដែលមិនមាន-សេចក្ដីចង្អៀត មិនមានពៀរ និងមិនមានសត្រូវ ។ ឬថា មេត្តានោះដល់ការនាសម្បទាជាគុណ ឈ្មោះថា មិនចង្អៀត ព្រោះជាឱកាសលោកទាំងពួង (គឺ ៣១ ភូមិ) ជាគុណឈ្មោះថា មិនមានពៀរ ព្រោះកម្ចាត់សេចក្ដីអាឃាតរបស់ខ្លួនក្នុងសត្វដទៃចេញ ជាគុណឈ្មោះថា មិនមានសត្រូវ ព្រោះកម្ចាត់សេចក្ដីអាឃាតរបស់សត្វដទៃក្នុងខ្លួនចេញ ក៏គប្បីចម្រើនផ្សាយមេត្តា ដែលមានក្នុងចិត្តនោះ ដែលមិនចង្អៀត ដែលមិនមានពៀរ ដែលមិនមានសត្រូវ មិនមានប្រមាណទៅក្នុងលោកទាំងពួង ដោយកំណត់ទិសទាំងបី គឺខាងលើ ខាងក្រោម និងខាងទទឹង ។

## ពណ៌នាគាថាទី ៩

តិដ្ឋញ្ចរំ និសិន្នោ វា សយានោ វា
យាវ តស្ស វិគតមិទ្ធោ
ឯតំ សតឹ អធិដ្ឋេយ្យ
ព្រហ្មមេតំ វិហារំ ឥធមាហុ ។

(បុគ្គលអ្នកចម្រើនមេត្តាចិត្តនោះ) ទោះឈរក្ដី ដើរក្ដី អង្គុយក្ដី ដេកក្ដី ជាអ្នកមានសេចក្ដីងោកងក់ទៅប្រាសហើយ គឺជាអ្នក

មិនដេកលក់អស់កាលត្រឹមណា គួរតម្កល់នូវសតិនោះ អស់កាលត្រឹមនោះ បណ្ឌិតទាំងឡាយពោលនូវកិរិយានុ៎ះ ថាជាព្រហ្មវិហារក្នុងសាសនានេះ ។

ព្រះមានព្រះភាគ ត្រាទ្រង់សម្តែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ កាលទ្រង់សម្តែងសេចក្តីមិនមានឥរិយាបថពិតប្រាកដរបស់អ្នកប្រកបរឿយៗ នូវការចម្រើនមេត្តានោះ ទើបត្រាស់ថា តិដ្ឋំ ចរំ ។បេ។ អធិដ្ឋេយ្យ ដូច្នេះ ។

គាថានោះមានសេចក្តីថា អ្នកចម្រើនមេត្តា កាលចម្រើនមេត្តាមានក្នុងចិត្តនេះយ៉ាងនេះ មិនត្រូវកំណត់ឥរិយាបថយ៉ាងណាមួយ ដូចក្នុងបាលីថា អង្គុយផ្គត់ភ្នែនតាំងកាយឲ្យត្រង់ តាមសប្បាយ ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី កាលធ្វើការសម្រាលអាពាធដោយឥរិយាបថទដទៃៗ ជាអ្នកប្រាសចាកសេចក្តីងោកងក់ គឺជាអ្នកមិនដេកលក់អស់កាលត្រឹមណា ក៏គប្បីតាំងសតិក្នុងមេត្តាឈាននោះទុកត្រឹមនោះ ។

ន័យមួយទៀត ព្រះមានព្រះភាគ ត្រាទ្រង់សម្តែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងភាពជាអ្នកជំនាញ ទើបត្រាស់ថា តិដ្ឋំ ចរំ ជាដើម ។ ពិតមែន អ្នកជំនាញហើយ ប្រាថ្នានឹងតាំងសតិក្នុងមេត្តាឈាននុ៎ះ ដោយឥរិយាបថត្រឹមណា ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ក៏រមែងបាន ។ ន័យមួយទៀត អ្នកជំនាញ ទោះឈរក្តី ដើរក្តី អង្គុយក្តី

ដេកក្តី ព្រោះហេតុនោះ ការឈរជាដើម រមែងមិនធ្វើអន្តរាយដល់អ្នកនោះ ។ មួយទៀត អ្នកជំនាញប្រាថ្នានឹងតាំងសតិមាំ ទុកក្នុងមេត្តាឈាននេះត្រឹមណា ក៏ត្រូវជាអ្នកប្រាសចាកសេចក្តីងោកងក់ ទើបតាំងសតិទុកបានត្រឹមនោះ ។ ការយឺតយូរក្នុងមេត្តាឈាននោះរបស់អ្នកនោះ រមែងមិនមាន ដោយហេតុនោះ ទើបត្រាស់ថា ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកប្រាសចាកសេចក្តីងោកងក់អស់កាលត្រឹមណា ក៏គប្បីតាំងសតិនោះទុកត្រឹមនោះ ។

គាថានោះ មានអធិប្បាយដូច្នេះ អ្នកជំនាញគប្បីចម្រើនមេត្តាដែលត្រាស់ទុកថា មេត្តញ្ច សព្វលោកស្មិំ មានសំ ភាវយេ ដោយប្រការដែលអ្នកជំនាញ មិនចាំបាច់ត្រូវអើពើដោយឥរិយាបថ បណ្តាឥរិយាបថមានឈរជាដើម ឬដល់ឥរិយាបថមានឈរជាដើម ប្រាថ្នានឹងតាំងសតិក្នុងមេត្តាឈាននោះត្រឹមណា ជាអ្នកប្រាសចាកសេចក្តីងោកងក់ហើយ ក៏គប្បីតាំងសតិនោះទុកត្រឹមនោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីជាអ្នកជំនាញក្នុងមេត្តាភាវនាយ៉ាងនេះ ទ្រង់ប្រកបភិក្ខុទុកក្នុងមេត្តាវិហារ ការនៅដោយមេត្តានោះថា ឯតំ សតឹ អធិដ្ឋេយ្យ គប្បីតាំងសតិនោះទុក ឥឡូវនេះ កាលទ្រង់សរសើរការនៅនោះ ទើបត្រាស់ថា ព្រហ្មមេតំ វិហារំ ឥធមាហុ ។

គាថានោះ មានសេចក្ដីថា ការនៅដោយមេត្តានេះណា ទ្រង់សរសើរតាំងអំពីព្រះពុទ្ធតម្រាស់ថា សុខិនោ វា ខេមិនោ វា ហោន្តុ ចូរជាអ្នកមានសេចក្ដីសុខ ឬមានសេចក្ដីក្សេម ដរាបដល់ព្រះពុទ្ធតម្រាស់ថា ឯតំ សតឹ អធិដ្ឋេយ្យ គប្បីតាំងសតិនោះទុកត្រឹមនោះ ។ អ្នកប្រាជ្ញទាំងឡាយពោលការនៅនោះថា **ព្រហ្មវិហារ** ការនៅដូចជាព្រហ្ម ពោលការនៅនោះថា **សេដ្ឋវិហារ** ការនៅយ៉ាងប្រសើរបំផុត ក្នុងព្រះសាសនា គឺក្នុងធម្មវិន័យរបស់ព្រះអរិយៈនេះ ព្រោះមិនមានទោសក្នុងការនៅដូចទិព្វ នៅដូចជាព្រហ្ម នៅដូចព្រះអរិយៈ និងនៅដោយឥរិយាបថវិហារ និងការនៅដោយមេត្តានោះ ធ្វើប្រយោជន៍ទាំងដល់ ខ្លួនឯងទាំងដល់អ្នកដទៃ ។ ព្រោះហេតុដែលសេចក្ដីស្ងប់ជាប់តគ្នា មិនត្រូវជ្រៀតជ្រែក ដូច្នោះ អ្នកចម្រើនមេត្តា ឈរក្ដី ដើរក្ដី អង្គុយក្ដី ដេកក្ដី មិនទាន់ដេកលក់ត្រឹមណា ក៏គប្បីតាំងសតិនោះទុកត្រឹមនោះ ។

## ការពណ៌នាគាថាទី ១០

ទិដ្ឋិញ្ច អនុបគម្ម សីលវា ទស្សនេន សម្បន្នោ
កាមេសុ វិនេយ្យ គេធំ ន ហិ ជាតុគព្ភសេយ្យំ
បុនរេតីតិ

(បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិនផប់នឹងទិដ្ឋិ ជាអ្នក

មានសីល ប្រកបដោយទស្សនសម្បត្តិ គឺសោតាបត្តិមគ្គ (តទៅទៀត) បន្ទោបង់នូវសេចក្តីជាប់ជំពាក់ក្នុងកាមទាំងឡាយហើយ រមែងមិនមកកាន់គព្ភសេយ្យទៀតឡើយ ។

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងមេត្តាភាវនាប្រការផ្សេងៗ ដល់ភិក្ខុទាំងនោះយ៉ាងនេះហើយ ឥឡូវនេះ ព្រោះហេតុដែលមេត្តាជិតចំពោះអត្តទិដ្ឋិ សេចក្តីឃើញថាខ្លួន ព្រោះមានសត្វជាអារម្មណ៍ ដូច្នោះ កាលទ្រង់សម្តែងការសម្រេចអរិយភូមិ ធ្វើមេត្តាឈាននោះឯង ឲ្យជាបាទដល់ភិក្ខុទាំងនោះ ដោយលើកការហាម ការប្រកាន់ទិដ្ឋិឡើងនាំមុខ ទើបទ្រង់ចប់ទេសនាដោយគាថានេះថា ទិដ្ឋិញ្ច អនុបគម្ម ជាដើម ។

គាថានេះ មានសេចក្តីថា ការនៅដោយមេត្តាឈាននេះណា ទ្រង់សរសើរទុកថា ព្រហ្មមេតំ វិហារំ ឥធមាហុ អ្នកប្រាជ្ញទាំងឡាយពោលការនៅនោះថា ព្រហ្មវិហារក្នុងព្រះធម៌វិន័យនេះ អ្នកចម្រើនមេត្តា ចេញចាកការនៅដោយមេត្តាឈាននោះហើយ កំណត់ [នាម] ធម៌ មានវិតក្កវិចារជាដើមក្នុងមេត្តាឈាននោះ និងរូបធម៌តាមលំអាននៃធម៌ ដែលជាទីអាស្រ័យនៅជាដើមរបស់ [នាម] ធម៌ទាំងនោះ ហើយកំណត់នាមរូបនេះ ក៏មិនប្រកាន់ទិដ្ឋិយ៉ាងនេះថា រូបនាមនេះជាគំនរសង្ខារ បុគ្គលរមែងប្រកាន់មិនបានថា សត្វ(មាន)ក្នុងសង្ខារនេះដូច្នេះទេ ជាអ្នកមានសីល ដោយលោកុត្តរសីលតាមលំដាប់ ដល់ព្រមដោយទស្សនៈ ដល់ព្រម

ដោយសម្មាទិដ្ឋិ ក្នុងសោតាបត្តិមគ្គ ដែលប្រកបដោយលោកុត្តរ-សីល តពីនោះ ក៏នាំចេញ កម្ចាត់រម្ងាប់សេចក្តីជំពាក់ចិត្ត ក្នុងកាមទាំងឡាយគឺ កិលេសកាមដែលលះមិនទាន់បាន ដោយការធ្វើឲ្យស្រាលខ្លះ ដោយសកទាគាមិមគ្គ និងអនាគាមិមគ្គ និងដោយការលះមិនឲ្យមានសេសសល់ឡើយ ក៏រមែងមិនចូលដល់ការដេកក្នុងគភ៌មាតាទៀត គឺមិនត្រូវដេកក្នុងគភ៌ទៀតយ៉ាងពិតប្រាកដបានដល់ កើតក្នុងពួកទេវតាជាន់សុទ្ធាវាសទាំងឡាយ សម្រេចព្រះអរហត្ត ហើយបរិនិព្វានក្នុងជាន់សុទ្ធាវាសនោះនុ៎ះឯង ។

ព្រះមានព្រះភាគ កាលទ្រង់ចប់ទេសនាយ៉ាងនេះហើយត្រាស់ចំពោះភិក្ខុទាំងនោះថា “ចូរទៅចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរនៅក្នុងដងព្រៃនោះឯង និងចូរវាយគងក្នុងថ្ងៃធម្មស្សវនៈ ៨ ថ្ងៃ ចំពោះ ១ ខែ ហើយចូរសូត្រព្រះសូត្រនេះចូរធ្វើធម្មកថា ពោលធម៌ សន្ទនាធម៌ អនុមោទនា, ចូរសេពចម្រើនធ្វើឲ្យច្រើននូវកម្មដ្ឋាននេះៗឯង ពួកអមនុស្សស្រុម្បីទាំងនោះ នឹងមិនសម្តែងអារម្មណ៍គួរខ្លាចនោះ នឹងជាអ្នកប្រាថ្នាល្អប្រាថ្នាប្រយោជន៍ដល់អ្នកទាំងឡាយពិតប្រាកដ” ភិក្ខុទាំងនោះទទួលព្រះពុទ្ធតម្រាស់ហើយ ក្រោកចាកពីអាសនៈក្រាបថ្វាយបង្គំហើយធ្វើប្រទក្សិណទៅក្នុងដងព្រៃនោះ ហើយធ្វើតាមដែលទ្រង់ទូន្មានគ្រប់ប្រការ ។ ទេវតាទាំងឡាយកើតបីតិសោមនស្សថាព្រះគុណម្ចាស់ទាំងឡាយស្មាត់ជំនាញល្អ ប្រាថ្នាប្រយោជន៍ដល់

ពួកយើង ។ ក៏នាំគ្នារក្សា បោសសេនាសនៈខ្ទង់ឯង ចាត់ចែង ទឹកក្តៅ បរិកម្មខ្លួន ប្របាច់ជើង ចាត់ចែងរក្សា ភិក្ខុសូម្បីទាំងនោះ ក៏នាំគ្នាចម្រើនមេត្តា ធ្វើមេត្តានោះឲ្យជាបាទ ផ្តើមវិបស្សនា ក៏សម្រេចព្រះអរហត្ត ដែលជាផលដ៏កំពូល ខាងក្នុងត្រៃមាសនោះឯង គ្រប់រូបទាំងអស់ បវារណាដោយវិសុទ្ធិបវារណា ក្នុងថ្ងៃមហាបវារណា ចេញវស្សានោះឯង ។

ព្រះតថាគតជាម្ចាស់នៃធម៌ ទ្រង់ឈ្លាសក្នុងប្រយោជន៍ ត្រាស់ករណីយមេត្តសូត្រ ដែលមានប្រយោជន៍ដោយប្រការដូច្នេះ ។ ភិក្ខុទាំងឡាយ អ្នកមានបញ្ញាបរិបូរណ៍ បានទទួលសេចក្តីស្ងប់នៃហឫទ័យដ៏យ៉ាងក្រៃលែង ក៏សម្រេចសន្តបទ ។ ព្រោះដូច្នោះឯង វិញ្ញូជនអ្នកប្រាថ្នានឹងសម្រេចសន្តបទ ដែលជាអមតៈ ដែលគួរអស្ចារ្យ ដែលព្រះអរិយៈស្រឡាញ់ ក៏គប្បីធ្វើករណីយដែលមានប្រយោជន៍ផ្សេងដោយសីល សមាធិ បញ្ញា ដែលគ្មានមន្ទិល ជាប់មិនដាច់ហោង ។

ចប់ អដ្ឋកថាមេត្តសូត្រ

នៃអដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះថា បរមត្ថជោតិកា ។

## ៤-បឋមធម្មវិហារិកសូត្រ

*(សុត្តន្តបិដក ភាគ៥៤ ទំព័រ១៧៨)*

*គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គេតែងនិយាយថា ភិក្ខុមានប្រក្រតីនៅដោយធម៌ ភិក្ខុមានប្រក្រតីនៅដោយធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុមានប្រក្រតីនៅដោយធម៌ ដោយហេតុប៉ុន្មានយ៉ាង ។*

*ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះរៀនទូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ។ ភិក្ខុនោះញុំាងថ្ងៃឲ្យកន្លងទៅ ដោយការរៀនទូវធម៌នោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះហៅថា ជាអ្នកច្រើនដោយបរិយត្តិធម៌ មិនហៅថា ជាអ្នកមានប្រក្រតីនៅដោយធម៌ទេ ។*

*មួយទៀត ភិក្ខុសម្ដែងធម៌តាមទំនងដែលខ្លួនបានចេះដឹងមកតាមទំនងដែលខ្លួនបានរៀនមក ដល់បុគ្គលទាំងឡាយដទៃ ដោយសេចក្ដីពិស្ដារ ភិក្ខុនោះញុំាងថ្ងៃឲ្យកន្លងទៅ ដោយការបញ្ញត្តិនូវ*

ធម៌នោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះ ហៅថា ជាអ្នកច្រើនដោយបញ្ញត្តិ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។

មួយទៀត ភិក្ខុធ្វើនូវការស្វាធ្យាយនូវធម៌ តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ដោយសេចក្តីពិស្តារ ភិក្ខុនោះញុំាងថ្ងៃឲ្យកន្លងទៅ ដោយការស្វាធ្យាយនោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះ ហៅថា ជាអ្នកច្រើនដោយការស្វាធ្យាយ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។

មួយទៀត ភិក្ខុត្រិះរិះពិចារណាដោយចិត្ត ជញ្ជឹងដោយចិត្តចំពោះធម៌តាមទំនងដែលខ្លួនបានចេះដឹងមក តាមទំនងដែលខ្លួនបានរៀនមក ។ ភិក្ខុនោះញុំាងថ្ងៃឲ្យកន្លងទៅ ដោយការត្រិះរិះនូវធម៌ទាំងនោះ លះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ មិនបានប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុនេះ ហៅថា ជាអ្នកច្រើនដោយការត្រិះរិះនូវធម៌ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។

ភិក្ខុក្នុងសាសនានេះ រៀននូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ។ ភិក្ខុនោះ មិនបានញុំាងថ្ងៃឲ្យកន្លងទៅ ដោយការរៀននូវធម៌នោះ

មិនលះបង់នូវការសម្ងំនៅក្នុងទីស្ងាត់ ប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង ។ ភិក្ខុជាអ្នកនៅដោយធម៌យ៉ាងនេះឯង ។

ភិក្ខុច្រើនដោយការរៀន តថាគតបានសម្ដែងហើយ អ្នកច្រើនដោយការបញ្ញត្តិ តថាគតបានសម្ដែងហើយ អ្នកច្រើនដោយការស្វាធ្យាយ តថាគតបានសម្ដែងហើយ អ្នកច្រើនដោយការត្រិះរិះ តថាគតបានសម្ដែងហើយ អ្នកមានប្រក្រតីនៅដោយធម៌ តថាគតបានសម្ដែងហើយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុ អំពើណាដែលសាស្ដា ជាអ្នកស្វែងរកនូវប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្ដីអនុគ្រោះ គួរធ្វើដល់សាវកទាំងឡាយ អំពើនេះ តថាគតក៏បានធ្វើហើយដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុ ទីនុ៎ះជារុក្ខមូលសេនាសនៈ ទីនុ៎ះជាសុញ្ញាគារសេនាសនៈ ។ អ្នកទាំងឡាយចូរចម្រើន (នូវសមថៈនិងវិបស្សនា) អ្នកទាំងឡាយចូរកុំប្រមាទ អ្នកទាំងឡាយចូរកុំមានសេចក្ដីក្ដៅក្រហាយ ក្នុងកាលជាខាងក្រោយឡើយ នេះជាពាក្យប្រៀនប្រដៅរបស់តថាគតដល់អ្នកទាំងឡាយ ។

ចប់ ធម្មវិហារិកសូត្រ ទី១ ។

# អដ្ឋកថា

បទថា ទិវសំ អតិនាមេតិ បានដល់ ធ្វើវេលាថ្ងៃមួយឲ្យកន្លងទៅ ។ បទថា រិញ្ចតិ បដិសល្លានំ បានដល់ លះបង់ការនៅតែម្នាក់ឯងចេញ ។ បទថា ទេសេតិ បានដល់ ពោលប្រកាស ។ បទថា ធម្មបញ្ញត្តិយា បានដល់ ដោយការបញ្ញត្តិធម៌ ។ បទថា ធម្មំ បរិយាបុណាតិ បានដល់ រៀនសូត្រ សិក្សាពោលធម៌ គឺសច្ចៈ ៤ ដោយនវង្គសត្ថុសាសនៈ (ពាក្យទូន្មានរបស់ព្រះសាស្តា ៩ ចំណែក) ។ បទថា ន រិញ្ចតិ បដិសល្លានំ បានដល់ មិនលះបង់ការនៅតែម្នាក់ឯង ។ បទថា អនុយុញ្ជតិ អជ្ឈត្តំ ចេតោសមថំ បានដល់ សេព ចម្រើនចិត្តសមាធិ ខាងក្នុងខ្លួនឯង គឺប្រកបខ្វល់ខ្វាយក្នុងសមថកម្មដ្ឋាន ។ បទថា ហិតេ-សិនា ប្រែថា អ្នកស្វែងរកប្រយោជន៍ ។ បទថា អនុកម្បកេន ប្រែថា ដោយអនុគ្រោះ ។ បទថា អនុកម្បំ ឧបាទាយ បានដល់ កំណត់ លោកអធិប្បាយថា អាស្រ័យនូវសេចក្តីអនុគ្រោះដោយចិត្តក៏មាន ។ បទថា កតំ វោ មយា តំ សេចក្តីថា តថាគតសម្តែងបុគ្គល ៥ ប្រភេទនេះ ក៏ធ្វើករណីយកិច្ចនោះ ដល់អ្នកទាំងឡាយហើយ ។ ពិតមែន ព្រះសាស្តាអ្នកអនុគ្រោះ ក៏មាន-កិច្ច គឺការសម្តែងធម៌ដែលមិនវិបរីតត្រឹមតែប៉ុណ្ណោះឯង ។

លំដាប់អំពីនេះទៅ ឈ្មោះថា ការបដិបត្តិជាកិច្ចរបស់សាវក អ្នកស្តាប់ទាំងឡាយ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើប ត្រាស់ថា ម្នាលភិក្ខុ នេះគល់ឈើ ។ល។ ជាអនុសាសនី ពាក្យ ទូន្មាន ដូច្នេះ ។ ក៏ក្នុងព្រះតម្រាស់នោះ ទ្រង់សម្តែងសេនាសនៈគឺ គល់ឈើដោយបទថា **រុក្ខមូលានិ** គល់ឈើនេះ ។ ទ្រង់សម្តែង ស្ថានទីស្ងាត់ចាកពីមនុស្ស ដោយបទថា **សុញ្ញាគារានិ** (ផ្ទះស្ងាត់) នេះ មួយទៀត ទ្រង់ប្រាប់សេនាសនៈដែលសមគួរ ដល់ការ បំពេញព្យាយាមស្ងួម្បីដោយបទទាំងពីរ ឈ្មោះថា ទ្រង់ប្រគល់ មត៌កឲ្យ ។ បទថា **ឈាយថ** បានដល់ លោកទាំងឡាយ ចូរសម្លឹង ពិនិត្យអារម្មណ៍ ៣៨ ប្រការ ដោយការសម្លឹងពិនិត្យ ដោយ អារម្មណ៍ និងសម្លឹងពិនិត្យខន្ធ អាយតនៈជាអាទិ ដោយជារបស់ មិនទៀងជាដើម ដោយការសម្លឹងពិនិត្យដោយលក្ខណៈ លោក អធិប្បាយថា ចូរចម្រើនសមថៈនិងវិបស្សនា ។ បទថា មា បមាទត្ថ ប្រែថា កុំប្រមាទឡើយ ។ បទថា មា បច្ឆា វិប្បដិ- សារិនោ អហុវត្ថ សេចក្តីថា កាលទ្រង់សម្តែងសេចក្តីនេះថា សាវកពួកណា វេលានៅជាកំលោះ វេលាមិនមានរោគ វេលា សម្បូរណ៍ដោយសប្បាយ មានបាយជាទីសប្បាយជាដើម វេលា ដែលនៅចំពោះមុខព្រះសាស្តា លះបង់ការដាក់ចិត្តដោយឧបាយ នៃប្រាជ្ញា រវល់តែប្រកបសុខក្នុងការដេកលក់ ជាអាហាររបស់

*សង្រ្គោះបុគ្គលដល់អស់ទាំងថ្ងៃទាំងយប់ ប្រមាទធ្វេសប្រហែសមក អំពីមុន ខាងក្រោយសាវកទាំងនោះ វេលាដល់ទុក្ខជរា គ្រាំគ្រា មានរោគ ជិតស្លាប់ វេលាវិបត្តិ និងវេលាដែលព្រះសាស្តា បរិនិព្វានហើយ កាលរលឹកដល់ការនៅដោយសេចក្តីប្រមាទមក អំពីមុននោះ មើលឃើញការធ្វើកាលៈ (សេចក្តីស្លាប់) ប្រភេទមាន បដិសន្ធិថាជាភារៈ ក៏ក្តៅក្រហាយចិត្ត ; ចំណែកលោកទាំងឡាយ កុំជាដូច្នោះឡើយ ដូច្នេះ ទើបត្រាស់ថា អ្នកទាំងឡាយ ចូរកុំមាន សេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។ បទថា* អយំ វោ អម្ហាកំ អនុសាសនី *សេចក្តីថា វាចានេះថា ពួកលោកចូរ សម្លឹងពិនិត្យ ចូរកុំប្រមាទ ជាអនុសាសនី លោកអធិប្បាយថា ជាឱវាទអំពីយើង សម្រាប់អ្នកទាំងឡាយ ដូច្នេះ ។*

*ចប់ អដ្ឋកថាបឋមធម្មវិហារិកសូត្រ ។*

## ៥_ទុតិយធម្មវិហារិកសូត្រ

*គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះ ចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយ អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គ ដ៏ចម្រើន គេតែងនិយាយថា ភិក្ខុមានប្រក្រតីនៅដោយធម៌ ភិក្ខុ*

មានប្រក្រតីនៅដោយធម៌ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុ មានប្រក្រតីនៅដោយធម៌ ដោយហេតុប៉ុន្មានយ៉ាង ។

ព្រះដ៏មានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀនទូវធម៌គឺ សុត្តៈ ... វេទល្លៈ តែភិក្ខុនោះ មិនដឹងច្បាស់អត្ថដ៏លើសលប់របស់ធម៌នោះ ដោយបញ្ញាឡើយ ។ ភិក្ខុនេះ ហៅថា ជាអ្នកច្រើនដោយបរិយត្តិធម៌ មិនហៅថា ជាអ្នកនៅដោយធម៌ទេ ។បេ។

ភិក្ខុក្នុងសាសនានេះ រៀនទូវធម៌គឺ សុត្តៈ ... វេទល្លៈ តែភិក្ខុនោះដឹងច្បាស់នូវអត្ថដ៏លើសលប់របស់ធម៌នោះដោយបញ្ញា ។

ភិក្ខុជាអ្នកមានប្រក្រតីនៅដោយធម៌ យ៉ាងនេះឯង ។ ភិក្ខុ ។បេ។ នេះជាពាក្យប្រៀនប្រដៅរបស់តថាគតដល់អ្នកទាំងឡាយ។

ចប់ ធម្មវិហារិកបុគ្គលសូត្រ ទី ២ ។

(សុត្តន្ត. អង្គុ. ភាគ៤៤ ទំព័រ១៧៨-១៨១)

## អដ្ឋកថា

បទថា ឧត្តរិំ ចស្ស បញ្ញាយ អត្ថំ ឆប្បជានាតិ សេចក្តីថា មិនដឹងសេចក្តីរបស់ធម៌នោះ ដោយមគ្គបញ្ញាព្រមទាំងវិបស្សនា ក្រៅលែងឡើងជាងបរិយត្តិនោះ ។ អធិប្បាយថា

មិនឃើញ មិនចាក់ធ្លុះសច្ចៈ ៤ ។ ក្នុងវារៈក្រៅនោះ ក៏ន័យនេះដូចគ្នា ។

ឯវមេតេសុ ទ្វីសុបិ សុត្តេសុ ពហុស្សុតភិក្ខុ វិបស្សនាកម្មិកោ សោតាបន្នោ សកទាគាមី អនាគាមី ខីណាសវោតិ ឆ ជនា ធម្មវិហារិនោ នាមាតិ វេទិតព្វា។

ជន ៦ ពួកគឺ ភិក្ខុពហុស្សូត អ្នកបំពេញវិបស្សនាកម្មដ្ឋាន ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះខីណាស្រព គប្បីជ្រាបថា ជាធម្មវិហារី (អ្នកនៅដោយធម៌) ក្នុងព្រះសូត្រសូម្បីទាំងពីរនេះ ដោយប្រការដូច្នេះ ។

ចប់ អដ្ឋកថាទុតិយធម្មវិហារិកសូត្រ ។

## ៦_ឆន្ទសូត្រ

(សុត្តន្តបិដក ៣៨ / ២៩១)

[៤៧៣] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអាស្រ័យនូវឆន្ទៈហើយ បាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ។ នេះហៅថា ឆន្ទៈសមាធិ ។ ភិក្ខុនោះញ៉ាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញ៉ាំងធម៌ទាំងឡាយជាអកុសលដ៏លាមកដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ។ ញ៉ាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំង

ព្យាយាមមាំ ដើម្បីលះបង់នូវធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធ ព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ។ ញុំាងឆន្ទៈ ឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសលដែលកើតឡើងហើយ ឲ្យស្ថិត-ស្ថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែកើតធំទូលាយ ចម្រើនបរិបូរណ៍ ។ នេះហៅថា បធានសង្ខារ ។ នេះហៅថា ឆន្ទៈផង នេះហៅថា ឆន្ទៈ-សមាធិផង នេះហៅថា បធានសង្ខារផង ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិបាទប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ។

[៤៧៤] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអាស្រ័យនូវវីរិយៈហើយ បាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ។ នេះហៅថា វីរិយសមាធិ ។ ភិក្ខុនោះ ។បេ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសលដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែកើតធំទូលាយ ចម្រើនបរិបូរណ៍ ។ នេះហៅថា បធានសង្ខារ ។ នេះហៅថា វីរិយៈផង នេះហៅថា វីរិយសមាធិផង នេះហៅថា បធានសង្ខារផង ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុ

ទាំងឡាយ នេះហៅថា ឥទ្ធិបាទប្រកបដោយវីរិយសមាធិ និង បធានសង្ខារ ។

[៤៧៥] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអាស្រ័យនូវចិត្តហើយ បាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ។ នេះហៅថា ចិត្តសមាធិ ។ ភិក្ខុនោះ ។បេ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសលដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែកើតជំទូលាយ ចម្រើនបរិបូរណ៍ ។ នេះហៅថា បធានសង្ខារ ។ នេះហៅថា ចិត្តផង នេះហៅថា ចិត្តសមាធិផង នេះហៅថា បធានសង្ខារផង ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិបាទប្រកបដោយចិត្តសមាធិ និង បធានសង្ខារ ។

[៤៧៦] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអាស្រ័យនូវវីមំសាហើយបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ។ នេះហៅថា វីមំសាសមាធិ ។ ភិក្ខុនោះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ។បេ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តឡើង តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសលដែលកើតឡើងហើយ ឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែកើត

ធំទូលាយ ចម្រើនពេញបរិបូរណ៍ ។ នេះហៅថា បធានសង្ខារ ។ នេះហៅថា វីមំសាផង នេះហៅថា វីមំសាសមាធិផង នេះហៅថា បធានសង្ខារផង ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។

## អដ្ឋកថាឆន្ទសូត្រ

ឆន្ទសូត្រទី ៣ សេចក្តីពេញចិត្ត គឺសេចក្តីជាអ្នកប្រាថ្នានឹងធ្វើ ឈ្មោះថា ឆន្ទៈ ។

ពាក្យថា **អាស្រ័យហើយ** បានដល់ ធ្វើឲ្យជាទីអាស្រ័យ អធិប្បាយថា ធ្វើឲ្យជាអធិបតី (ធំក្រៃលែង) ។ គ្រឿងតាក់តែងដែលជាសេចក្តីព្យាយាម ឈ្មោះថា បធានសង្ខារ, ពាក្យនេះជាឈ្មោះរបស់សេចក្តីព្យាយាម ដែលហៅឈ្មោះថា សេចក្តីព្យាយាមដ៏ប្រពៃដែលធ្វើកិច្ចបួនយ៉ាងឲ្យសម្រេច ។

សេចក្តីពេញចិត្តក្នុងពាក្យជាដើមថា ឥតិ អយំ ច ឆន្ទោ ជាឆន្ទសមាធិប្រកបដោយឆន្ទៈនិងបធានសង្ខារ, សូម្បីបធានសង្ខារ ក៏ប្រកបដោយឆន្ទៈនិងសមាធិ, ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់រួមធម៌ទាំងអស់នោះចូលគ្នាផង ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិបាទដែលប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ។ ចំណែកក្នុងឥទ្ធិបាទវិភង្គ ត្រាស់ដល់ធម៌ដែលមិនមានរូបដ៏សេស ដែលប្រកបដោយធម៌ទាំងនេះ ដោយន័យ

ជាដើមថា វេទនាខន្ធរបស់អ្នកដូច្នោះណា ថាជាឥទ្ធិបាទ ។

មួយវិញទៀត ធម៌ទាំងបីយ៉ាង ទាំងជាឫទ្ធិ ទាំងជាទីតាំងឲ្យដល់នៃឫទ្ធិ ។ យ៉ាងណា ។ ពិតមែន កាលចម្រើនឆន្ទះ ឆន្ទះក៏រមែងឈ្មោះថា ជាឫទ្ធិ , សមាធិនិងបធានសង្ខារ ក៏រមែងឈ្មោះថា ជាទីតាំងឲ្យដល់នៃឫទ្ធិ ។

កាលចម្រើនសមាធិ សមាធិក៏រមែងឈ្មោះថាជាឫទ្ធិ ឆន្ទះនិងបធានសង្ខារ ក៏រមែងឈ្មោះថាជាផ្លូវឲ្យដល់ឫទ្ធិនៃសមាធិ, កាលចម្រើនបធានសង្ខារ បធានសង្ខារក៏ឈ្មោះថាជាឫទ្ធិ ។

ឆន្ទះនិងសមាធិ ក៏ឈ្មោះថាជាផ្លូវឲ្យដល់ឫទ្ធិ នៃបធានសង្ខារ ព្រោះកាលធម៌ដែលប្រកបព្រមសម្រេចក្នុងធម៌មួយ សូម្បីធម៌ដ៏សេស ក៏រមែងសម្រេចដូចគ្នា ។

មួយវិញទៀត គប្បីជ្រាបសេចក្តីដែលធម៌ទាំងនេះជាឥទ្ធិបាទ សូម្បីដោយអំណាចជាចំណែកខាងដើម របស់ធម៌នោះៗ ។

ពិតមែន ឈានទី ១ ឈ្មោះថា ជាឫទ្ធិ ឆន្ទះជាដើមដែលប្រកបព្រមដោយបរិកម្មដែលជាចំណែកខាងដើមរបស់ឈានទី ១ ក៏ឈ្មោះថា ជាផ្លូវឲ្យដល់ឫទ្ធិ ។

តាមន័យនេះទៅដរាបដល់នេវសញ្ញានាសញ្ញាយតនៈ ផ្តើមអំពីការសម្តែងឫទ្ធិទៅដរាបដល់អភិញ្ញាគឺ ភ្នែកទិព្វ ហើយនាំយកន័យនេះទៅប្រើបានតាំងពីសោតាបត្តិមគ្គ រហូតដល់អរហត្តមគ្គ ។ សូម្បីក្នុងឥទ្ធិបាទដ៏សេសក៏ទំនងនេះ ។

តែអាចារ្យពួកខ្លះលោកពោលថា ឆន្ទៈដែលនៅមិនទាន់សម្រេច (មិនទាន់កើត) ជាឥទ្ធិបាទ ។ ក្នុងករណីយនេះ ដើម្បីជាការញ៉ាំញីវាទៈរបស់លោកទាំងនោះ យើងមានពាក្យឈ្មោះថាឧត្តរចូឡវារ ដែលមកក្នុងអភិធម្មថា ៖

ឥទ្ធិបាទមាន ៤ យ៉ាង គឺ ឆន្ទិទ្ធិបាទ វីរិយិទ្ធិបាទ ចិត្តិទ្ធិបាទ វិមំសិទ្ធិបាទ ។ ក្នុងឥទ្ធិបាទ ៤ នោះ ឆន្ទិទ្ធិបាទ ដូចម្ដេច ។ ភិក្ខុក្នុងធម៌វិន័យនេះ សម័យណាចម្រើនលោកុត្តរឈាន ដែលនាំចេញចាកទុក្ខ ដែលឲ្យដល់ការអស់ទៅនៃទុក្ខ ស្ងាត់ចាកកាមទាំងឡាយបានហើយ ដើម្បីសម្រេចជាន់ទី ១ សម្រាប់លះសេចក្ដីយល់ឃើញខុស ។ល។ ហើយចូលដល់ឈានទី ១ ដែលបដិបត្តិលំបាក ត្រាស់ដឹងបានដោយយឺតយូរ ក្នុងសម័យនោះសេចក្ដីពេញចិត្ត សេចក្ដីជាអ្នកពេញចិត្ត សេចក្ដីប្រាថ្នានឹងធ្វើសេចក្ដីឆ្លាសវាងវៃ សេចក្ដីប្រាថ្នាធម៌យ៉ាងនេះ យើងហៅថា ឥទ្ធិបាទគឺសេចក្ដីពេញចិត្ត ។ ធម៌ដ៏សេសប្រកបចូលនឹង ឥទ្ធិបាទគឺ សេចក្ដីពេញចិត្ត តែឥទ្ធិបាទទាំងនេះ មកហើយដោយអំណាចលោកុត្តរៈប៉ុណ្ណោះ ។

ក្នុងឥទ្ធិបាទ ៤ នោះ ព្រះរដ្ឋបាលត្ថេរៈ ធ្វើសេចក្ដីពេញចិត្តឲ្យជាធុរៈ ហើយទើបញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើងបាន ។ ព្រះសោណត្ថេរៈ ធ្វើសេចក្ដីព្យាយាមឲ្យជាធុរៈ ព្រះសម្ភូតត្ថេរៈ ធ្វើសេចក្ដីដាក់ចិត្តឲ្យជាធុរៈ ព្រះមោឃរាជដ៏មានអាយុ ធ្វើការ

ពិចារណារកហេតុផលឲ្យជាធុរៈ ដោយប្រការដូច្នេះ ។ ក្នុងឥទ្ធិបាទ ៤ នោះ ដូចកាលកូនអមាត្យ ៤ នាក់ ប្រាថ្នាតំណែង ចូលទៅអាស្រ័យព្រះរាជា ម្នាក់កើតសេចក្តីពេញចិត្តក្នុងការ ទទួលបម្រើដឹងព្រះរាជអធ្យាស្រ័យ និងសេចក្តីពេញព្រះរាជហឫទ័យរបស់ព្រះរាជា ទើបទទួលបម្រើទាំងពេលថ្ងៃ និងពេលយប់ ធ្វើឲ្យព្រះរាជាប្រោសប្រាណហើយ ក៏បានទទួលតំណែងយ៉ាងណា គប្បីជ្រាបអ្នកឲ្យលោកុត្តរធម៌កើតបានដោយឆន្ទធុរៈ ដូច្នោះ ។

តែម្នាក់ទៀត មិនអាចទទួលបម្រើរាល់ៗ ថ្ងៃបាន ទើបគិតថា កាលសេចក្តីចាំបាច់កើតឡើង យើងអាចនឹងទទួលបម្រើដរាបដល់ទីបំផុត កាលជាយដែនកម្រើក ត្រូវព្រះរាជាបញ្ជូនទៅហើយ ក៏អាចបង្ក្រាបសត្រូវដរាបដល់ទីបំផុត បានទទួលតំណែង ។ អ្នកនោះយ៉ាងណា គប្បីជ្រាបអ្នកដែលឲ្យលោកុត្តរធម៌កើតបានដោយវីរិយធុរៈ ដូច្នោះ ។

ម្នាក់ទៀតគិតថា ការទទួលបម្រើរាល់ៗថ្ងៃក្តី ការយកទ្រូងទទួលលំពែងនិងកូនសរក្តី ជាភារៈដោយពិត, យើងនឹងទទួលបម្រើដោយកម្លាំងមន្ត ហើយក៏តាំងហ្វឹកហាត់ខត្តវិជ្ជា ធ្វើឲ្យព្រះរាជាប្រោសប្រាណដោយការចាត់ចែងមន្ត (សេចក្តីដឹង) ដរាបបានទទួលតំណែង ។ បុគ្គលនោះយ៉ាងណា គប្បីជ្រាបអ្នកដែលឲ្យលោកុត្តរធម៌កើតបានដោយចិត្តធុរៈ ដូច្នោះ ។

ម្នាក់ទៀតគិតថា ការទទួលបម្រើជាដើម មានប្រយោជន៍អ្វី ធម្មតាពួកព្រះរាជា រមែងប្រទានតំណែងដល់អ្នកបរិបូរណ៍ដោយជាតិ កាលប្រទានដល់បុគ្គលដូច្នោះ ក៏នឹងប្រទានដល់យើង អាស្រ័យការដល់ព្រមដោយជាតិប៉ុណ្ណោះ ក៏បានទទួលឋានន្តរ ។ គេយ៉ាងណា គប្បីជ្រាបអ្នកដែលអាស្រ័យសេចក្ដីពិចារណារក-ហេតុផលសុទ្ធៗ ហើយធ្វើឲ្យកើតលោកុត្តរធម៌ដោយវីមំសាដូច្នោះ ។

ក្នុងសូត្រនេះ ទ្រង់សម្ដែងឥទ្ធិដែលមានវិវដ្ដៈជាបាទ ដូចពោលមកនេះ ។

ចប់ អដ្ឋកថាឆន្ទសូត្រ ។

(បាកគម្ពីរសារត្ថបកាសិនី អដ្ឋកថា ៣១ / ១៤៥)

# ៧_អសុភសូត្រ

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរពិចារណាឃើញរឿយៗ នូវអាការមិនស្អាតក្នុងកាយ ឯអានាបាស្សតិកម្មដ្ឋាន ក៏អ្នកទាំងឡាយចូរតាំងឡើងប្រាកដ ឲ្យមានមុខឆ្ពោះទៅកាន់អារម្មណ៍ខាងក្នុង អ្នកទាំងឡាយចូរពិចារណាឃើញរឿយៗ ក្នុងសង្ខារទាំងពួងថា មិនទៀង ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ពិចារណាឃើញរឿយៗ នូវអាការមិនស្អាតក្នុងកាយហើយ រាគានុស្ស័យណា គួរដល់កិរិយាកើតឡើងក្នុងសុភធាតុ (កាន់យកនូវអារម្មណ៍ថាស្អាត) រាគានុស្ស័យនោះ អ្នកទាំងឡាយរមែងលះបង់បាន ។ កាលអានាបានុស្សតិកម្មដ្ឋានតាំងឡើងប្រាកដ មានមុខឆ្ពោះទៅកាន់អារម្មណ៍ខាងក្នុងហើយ អាសយវិតក្កៈទាំងឡាយណាជាខាងក្រៅដែលជាចំណែកនៃសេចក្តីចង្អៀតចង្អល់ អាសយវិតក្កៈនោះ មិនមានតទៅទៀតឡើយ ។ កាលបើអ្នកទាំងឡាយ ពិចារណាឃើញរឿយៗ ក្នុងសង្ខារទាំងពួងថាមិនទៀងហើយ អវិជ្ជាអ្នកទាំងឡាយក៏រមែងលះបង់បាន វិជ្ជាសោត ក៏រមែងកើតឡើង ។

អសុភានុបស្សី កាយស្មឹ អានាបានេ បដិស្សតោ
សព្វសង្ខារសមថំ បស្សំ អាតាបិ សព្វទា ។
ស វេ សម្មទ្ទសោ ភិក្ខុ យតោ តត្ថ វិមុច្ចតិ

អភិញ្ញាវោសិតោ សន្តោ ស វេ យោគាតិគោ មុនិ ។
ភិក្ខុជាអ្នកពិចារណាឃើញរឿយៗ ក្នុងកាយថាមិនស្អាត មានសតិតម្កល់ខ្ជាប់ក្នុងអានាបានស្សតិកម្មដ្ឋាន ពិចារណាឃើញព្រះនិព្វានជាទីរម្ងាប់សង្ខារទាំងពួងហើយ ជាអ្នកមានព្យាយាមជាគ្រឿងដុត-កំដៅកិលេសសព្វៗកាល ។ ភិក្ខុនោះឯង ឈ្មោះថា ឃើញដោយប្រពៃ ជាអ្នកសង្រួម រមែងចុះចិត្តស៊ប់ក្នុងព្រះនិព្វាន ជាទីរម្ងាប់សង្ខារទាំងពួងនោះ ភិក្ខុនោះឯង ជាអ្នកមានព្រហ្មចរិយធម៌ប្រព្រឹត្តរួចហើយ ជាអ្នកស្ងប់ ព្រោះដឹងច្បាស់ ឈ្មោះថា អ្នកប្រាជ្ញប្រព្រឹត្តកន្លងយោគៈ ។

## អដ្ឋកថាអសុភសូត្រ

បទថា អសុភានុបស្សី មានសេចក្ដីថា លោកទាំងឡាយ កាលពិចារណាឃើញថាមិនស្អាត ឈ្មោះថា ជាអ្នកពិចារណាឃើញការមិនស្អាត គឺអាការដែលមិនស្អាតក្នុងកាយ ដោយអំណាចនៃអាការៈ ៣២ យ៉ាង និងដោយអំណាចនៃការនាំចូលរកនិមិត្តដែលខ្លួនកាន់យកហើយ ក្នុងអសុភដែលហើមពោរពងឡើងជាដើម ។

បទថា អានាបានស្សតិ បានដល់ សតិក្នុងខ្យល់ គឺសតិដែលប្រារព្ធខ្យល់នោះប្រព្រឹត្តទៅ ។ អធិប្បាយថា សតិដែល

កំណត់ខ្យល់ចូល ខ្យល់ចេញជាអារម្មណ៍ សមពិតដូចលោកពោល ទុកមានជាដើមថា ខ្យល់ចូល ឈ្មោះថា **អានៈ** មិនមែនខ្យល់ចេញ ខ្យល់ចេញ ឈ្មោះថា **បានៈ** មិនមែនខ្យល់ចូល ។ បទថា វោ ប្រែថា ដើម្បីលោកទាំងឡាយ ។ ក្នុងបទថា អជ្ឈត្តំ នេះ លោកប្រាថ្នាយក អារម្មណ៍ខាងក្នុង ។ បទថា បរិមុខំ បានដល់ចំពោះមុខ ។ បទថា សុបតិដ្ឋិតា សេចក្ដីថា សតិដែលតាំងមាំហើយដោយល្អ ។ លោកអធិប្បាយទុកថា ក៏អានាបានស្សតិចូរជាការដែលអ្នកទាំងឡាយ ចូលទៅតាំងទុកហើយដោយល្អចំពោះមុខកម្មដ្ឋាន ដូច្នេះ ។ មួយវិញទៀត បទថា បរិមុខំ សេចក្ដីថា មានការនាំចេញទៅតាមដែលកំណត់ទុកហើយ មែនពិត ដូចព្រះសារីបុត្រ ពោលទុកក្នុងបដិសម្ភិទាមគ្គថា បទថា បរិ មានសេចក្ដីសំដៅថា កំណត់, បទថា មុខំ មានសេចក្ដីសំដៅថា នាំចេញ ។ បទថា សតិ មានសេចក្ដីសំដៅថា ចូលទៅតាំងទុក ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ចូរតាំងសតិទុកចំពោះមុខ ដូច្នេះ ។ ដោយបទថា បរិមុខំ សតី នេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់សម្ដែងដល់ការចម្រើនកម្មដ្ឋាន គឺអានាបានស្សតិ ១៦ ប្រភេទ ក្នុងសតិប្បដ្ឋាន ៤ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ដែលជាទីសប្បាយដល់អ្នកមានរាគចរិត និង

វិតក្កចរិត ដោយអំណាចការពិចារណាកាយរឿយៗ ដោយការធ្វើទុកក្នុងចិត្តថាបដិកូល ដោយសង្ខេបប៉ុណ្ណោះ យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងចំពោះវិបស្សនាកម្មដ្ឋានសុទ្ធៗ ទើបត្រាស់ពាក្យមានជាដើមថា សព្វសង្ខារេសុ អនិច្ចានុបស្សី វិហរតិ ដូច្នេះ ។

ក្នុងវិបស្សនាកម្មដ្ឋាន គប្បីជ្រាបពួកទាំង ៤ នេះ គឺ **អនិច្ចំ** ១ **អនិច្ចលក្ខណ** ១ **អនិច្ចានុបស្សនា** ១ **អនិច្ចានុបស្សី** ១ ។ ខន្ធបញ្ចកៈ ឈ្មោះថា **អនិច្ចំ** ព្រោះមានហើយត្រឡប់ជាមិនមាន ព្រោះប្រកបដោយការកើតឡើង និងការសាបសូន្យទៅ ព្រោះប្រព្រឹត្តទៅ គ្រាំគ្រានិងព្រោះជំទាស់ចំពោះនិច្ចៈ (សេចក្តីទៀង) ។ អាការដែលមានហើយ ត្រឡប់ជាមិនមានយ៉ាងណារបស់បញ្ចក្ខន្ធនោះយ៉ាងនោះ ឈ្មោះថា **អនិច្ចលក្ខណៈ** ។ វិបស្សនា ដែលប្រារព្ធអនិច្ចលក្ខណៈនោះប្រព្រឹត្តទៅ ឈ្មោះថា **អនិច្ចានុបស្សនា** ព្រះយោគាវចរអ្នកឃើញច្បាស់អនិច្ចលក្ខណៈនោះថា មិនទៀង ឈ្មោះថា **អនិច្ចានុបស្សី** ។ ក៏ក្នុងសតិប្បដ្ឋាននេះ គួរនឹងពោលអសុភកថា ១១ យ៉ាង ឲ្យដល់បឋមជ្ឈាន អានាបានកថាមានវត្ថុ ១៦ យ៉ាង ឲ្យដល់ចតុត្ថជ្ឈាន និងវិបស្សនាកថា ដោយពិស្តារ តែអសុភកថាជាដើមនោះ ខ្ញុំបានពោលទុកហើយក្នុងបករណ៍វិសេសឈ្មោះថាវិសុទ្ធិមគ្គ ដោយគ្រប់អាការ ព្រោះដូច្នោះ គប្បីជ្រាប

ដោយន័យដូចដែលខ្ញុំពោលទុកហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះចុះ (ក្នុងសៀវភៅនេះ បានពោលទុកហើយក្នុងខាងដើម) ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងផលវិសេស ដែលទីងគប្បីឲ្យសម្រេចដោយអសុភានុបស្សនាជាដើម ព្រះមានព្រះភាគ ទើបត្រាស់ពាក្យមានជាដើមថា **អសុភានុបស្សីនំ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា សុភាយ ធាតុយា សេចក្តីថា ក្នុងភាពជារបស់ស្អាត អធិប្បាយថា ក្នុងអសុភនិមិត្ត ។ បទថា រាគានុសយោ បានដល់ កាមរាគានុស្ស័យនោះ ដែលគួរដល់ការកើតឡើង ក្នុងព្រោះសុភារម្មណ៍ ។ កាមរាគានុស្ស័យនោះ ព្រះយោគាវចរលះបានដោយអនាគាមិមគ្គ ដែលខ្ទនកាន់យកអសុភនិមិត្ត របស់អ្នកពិចារណាឃើញអសុភៈក្នុងអាការ ៣២ មានសក់ជាដើម ឬក្នុងសាកសពដែលហើមពោរពងឡើង ហើយញុំាងបឋមជ្ឈានឲ្យកើតឡើង ក្នុងព្រោះអសុភនិមិត្តនោះ ធ្វើបឋមជ្ឈាននោះឲ្យជាបាទ ផ្តើមតាំងវិបស្សនាហើយសម្រេច អធិប្បាយថា កាត់ផ្តាច់ដោយប្រការទាំងពួង ។ សមដូចដែលខ្ញុំបានពោលទុកហើយថា គួរចម្រើនអសុភៈដើម្បីលះកាមរាគៈ ដូច្នេះ ។ បទថា **ពាហិរា** សេចក្តីថា អកុសលធម៌ដែលឈ្មោះថា ខាងក្រៅ គឺដែលឈ្មោះថា ជាខាងក្រៅ ព្រោះជាទីតាំងនៃអារម្មណ៍ក្នុងខាងក្រៅ និងនាំកម្មមិនប្រយោជន៍មកឲ្យ ។ បទថា វិតក្កាសា បានដល់ មិច្ឆា-

វិតក្កៈ មានសេចក្ដីត្រិះរិះក្នុងកាមជាដើម ។ ក៏មិច្ឆាវិតក្កៈទាំងនោះ ដែលនៅមិនទាន់លះបាន និងអាសយានុគតា (កិលេសដែលដេក នៅ) ព្រះមានព្រះភាគ ត្រាស់ថា វិតក្កាសយា ព្រោះកាលមាន សេចក្ដីព្រមព្រៀងនៃបច្ច័យ ក៏នឹងកើតឡើងបាន ។ ក៏ក្នុងវិតក្កៈ ទាំង ៣ នេះ កាមវិតក្កៈ ព្រះមានព្រះភាគ ទ្រង់កាន់យកហើយ ដោយស័ព្ទថា កាមរាគៈនោះឯង ។ ព្រោះហេតុនោះ វិតក្កៈ ដ៏សេសអំពីកាមវិតក្កៈនោះឯង គប្បីជ្រាបថា ព្រះមានព្រះភាគ ត្រាស់ទុកហើយ ។ បទថា វិឃាតបក្ខិកា សេចក្ដីថា ជាចំណែក នៃសេចក្ដីទុក្ខ គឺធ្វើការកើតឡើងនៃសេចក្ដីទុក្ខ ដោយអំណាចនៃ សេចក្ដីលំបាក ។ បទថា តេ ឆ ហោន្តិ សេចក្ដីថា លះកាម-វិតក្កៈទាំងនោះបាន ។

មហាវិតក្ក ៩ យ៉ាង គឺ វិតក្ក ៨ មាន ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ ញាតិវិតក្ក ១ ជនបទវិតក្ក ១ អមរាវិតក្ក (ត្រិះរិះ ប្រកបដោយទិដ្ឋិដែលបោះពាក្យសំដីមិនចេះស្លាប់) ១ វិតក្កដែល ប្រកបព្រមដោយសេចក្ដីប្រាថ្នាមិនឲ្យគេមើលងាយ (ខ្ញុំន) (អន-វញ្ញត្តិបដិសំយុត្តោ)[១] ១ វិតក្កដែលប្រកបព្រមដោយលាភសក្ការ

---

១- ក្នុងគម្ពីរអដ្ឋកថាវិភង្គ កែថា ធ្វើដូចម្ដេចហ្ន៎ អ្នកដទៃមិនគប្បីមើលងាយ អាត្មាអញ មិនគប្បីពោលបៀតបៀនអាត្មាអញ ។ ក្នុងដីកាមូលបណ្ណាសក កែថា

និង សេចក្ដីសរសើរ ១ វិតក្កដែលប្រកបព្រមដោយ (សេចក្ដីស្រឡាញ់ អាស្រ័យផ្ទះ ដូចនឹង) សេចក្ដីអាណិតក្នុងអ្នកដទៃ[២] ១ ព្រមទាំងកាមវិតក្កៈមួយទៀត, ដែលគ្របសង្កត់បានក្នុងខាងដើមដោយសមាធិដែលកើតព្រោះអានាបានស្សតិ និងវិបស្សនាដែលអាស្រ័យអានាបានស្សតិសមាធិនោះ ។ នឹងលះបានដោយមិនមានសល់ តាមសមគួរដោយអរិយមគ្គដែលធ្វើអានាបានស្សតិសមាធិ (បានដល់ឈាន) នោះឲ្យជាបាទហើយសម្រេច ។ សមពិតដូចព្រះមានព្រះភាគ ត្រាស់ទុកថា គប្បីចម្រើនអានាបានស្សតិ ដើម្បីចូលទៅកាត់នូវវិតក្ក ដូច្នេះ ។

បទថា យា អវិជ្ជា សា បហីយតិ សេចក្ដីថា អវិជ្ជាណាដែលបិទបាំងសភាពនៃសេចក្ដីពិត ធ្វើសេចក្ដីវិនាសឲ្យគ្រប់យ៉ាង (សព្វានត្ថការី) ជាមូលនៃវដ្ដទុក្ខទាំងអស់ អវិជ្ជានោះ លោកអ្នកពិចារណាឃើញសេចក្ដីមិនទៀង នឹងកាត់ផ្ដាច់បាន ។ បានឮថា បទថា យា អវិជ្ជា សា បហីយតិ នេះ ព្រះមានព្រះភាគ

---

ធ្វើដូចម្ដេចហ្ន៎ អ្នកដទៃមិនគប្បីមើលងាយអាត្មាអញ មិនគប្បីសម្គាល់អាត្មាអញធ្វើឱ្យនៅខាងក្រោម គប្បីធ្វើអាត្មាអញឱ្យជាទីគោរព ដូចឆត្រថ្ម ។

២- ក្នុងគម្ពីរអដ្ឋកថាអាសវសូត្រ កែថា វិតក្កដែលប្រកបដោយសេចក្ដីស្រឡាញ់អាស្រ័យផ្ទះ ដែលប្រហែលគ្នានឹងសេចក្ដីអាណិត ប្រព្រឹត្តទៅដោយអំណាចនៃការរីករាយជាមួយគ្នាជាដើម ក្នុងពួកជនដទៃមានឧបដ្ឋាកជាដើម ។

ត្រាស់ហើយដោយអំណាចនៃព្រះវីណាស្រេពជាសុក្ខវិបស្សក អ្នកនៅចប់ព្រហ្មចរិយ ដោយអាការនៃអនិច្ចលក្ខណៈ ពាក្យនោះមានសេចក្ដីសង្ខេបតទៅនេះ ។ កាលព្រះយោគាវចរទាំងឡាយ ផ្ដើមតាំងសម្មសនញាណ ឃើញច្បាស់សង្ខារទាំងពួងដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយសេចក្ដីមិនទៀងជាដើម វិបស្សនាដែលជាវុដ្ឋានគាមិនី ដែលប្រព្រឹត្តទៅនៅថាមិនទៀង ដូច្នេះ តចំពោះបានដោយមគ្គក្នុងវេលាណា ក្នុងវេលានោះ អរហត្តមគ្គ ក៏កើតឡើងតាមលំដាប់ កាលលោកទាំងនោះ ពិចារណាអនិច្ចលក្ខណៈរឿយៗ ក៏នឹងលះអវិជ្ជាបាន ដោយមិនមានសល់ អរហត្តមគ្គវិជ្ជានឹងកើតឡើង ។

បទថា អនិច្ចានុបស្សីនំ វិហារតំ នេះ ព្រះមានព្រះភាគត្រាស់ទុកដោយអនិច្ចលក្ខណៈ ជាធម៌ប្រាកដដល់យោគាវចរទាំងនោះ ។ ឬព្រោះជាឧបាយក្នុងការកាន់យកលក្ខណៈទាំងពីរក្រៅនេះ តែមិនបានត្រាស់ទុក ដោយព្រះយោគាវចរនឹងគប្បីពិចារណាលក្ខណៈតែម៉្យាងប៉ុណ្ណោះរឿយៗ ។ សមដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ទុកថា របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា ដូច្នេះ ទាំងត្រាស់ពាក្យដទៃទុកថា ម្នាលមេឃិយៈ ក៏អនត្តសញ្ញារបស់អ្នកមានអនិច្ចសញ្ញា នឹងតាំងមាំ អ្នកមានអនត្តសញ្ញានឹងដល់ការដកអស្មិមានៈឡើងបាន ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយ ដូចតទៅនេះ បទថា អានាបានេ បដិស្សតោ សេចក្ដីថា មានសតិចំពោះៗ ក្នុងអានាបាននិមិត្ត អធិប្បាយថា ចូលទៅតាំងសតិទុកនោះ ។ បទថា បស្សំ មានសេចក្ដីថា ឃើញនូវព្រះនិព្វានដែលជាទីរម្ងាប់សង្ខារ ដោយញាណចក្ខុដែលជាទីអស់ទៅនៃអាសវៈ ។ បទថា អាតាបី សព្វទា សេចក្ដីថា មានសេចក្ដីព្យាយាមរឿយៗ ក្នុងធម៌មានអសុភានុបស្សនា (ការពិចារណាឃើញថាមិនស្អាត) ជាដើម ដោយមិនឈប់ក្នុងចន្លោះ គឺប្រកបហើយប្រកបទៀត ។ បទថា យតោ បានដល់ ព្យាយាម, ម្យ៉ាងទៀត បានដល់ ជាអ្នកទៀង ក្នុងធម៌នោះ គឺក្នុងព្រះនិព្វានដែលជាទីរម្ងាប់នៃសង្ខារទាំងពួង ដោយសម្មត្តនិយាម ការរួចផុតដោយអំណាចអរហត្តផល ។ ពាក្យដ៏សេស មានន័យដូចពោលហើយទាំងអស់ ។

ចប់ អដ្ឋកថាអសុភសូត្រ ។